សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# របបសន្តិកម្មនៅកម្ពុជា

ស្រាវជ្រាវ ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ :

និស្សិតឈ្មោះ **សាត សុខវិសាល**

**ប៉ាវ ត័ងម៉េង**

សាស្ត្រាចារ្យណែនាំ

លោកស្រី **ម៉ូលី បញ្ញា**


ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ២៦ ( អាហារូបករណ៍ )

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Économiques**
**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# របបសន្តតិកម្មនៅកម្ពុជា

ស្រាវជ្រាវ ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ :
និស្សិតឈ្មោះ **សាត សុខវិសាល**
**ប៉ាវ គ័ងម៉េង**

សាស្ត្រាចារ្យណែនាំ
លោកស្រី **ម៉ូលី បញ្ញា**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ
ជំនាន់ទី ២៦ ( អាហារូបករណ៍ )

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **សាត សុខវិសាល** និង **ប៉ាវ ឥតម៉េង** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី ២៦ (អាហារូបករណ៍) នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។

**យើងខ្ញុំ សូមសម្តែងនូវការដឹងគុណចំពោះគុណតម្លៃយ៉ាងជ្រាលជ្រៅ ជូនចំពោះ ៖**

**លោកឪពុក-អ្នកម្តាយ** ដែលមានគុណធ្ងន់មហិមាក្នុងការផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាកូនៗ រហូតបានដឹងក្តីដូចសព្វថ្ងៃនេះ ក៏ដូចជាបាន អប់រំ ទូន្មាន ប្រៀនប្រដៅ ព្រមទាំងលើកទឹកចិត្តឱ្យកូន បានសិក្សារៀនសូត្រ ក្រេបយកចំណេះដឹងពីការអប់រំនៅសាលារៀនតាំងពីកម្រិតមតេយ្យសិក្សា រហូតដល់បានបញ្ចប់កម្រិតឧត្តមសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះ។

**រាជរដ្ឋាភិបាលកម្ពុជា តាមរយៈសេនាធិការ ផ្នែកអប់រំ ដ៏លេចធ្លោរបស់ខ្លួន ពោលគឺ ក្រសួងអប់រំ យុវជន និងកីឡា** ដែលបានផ្តល់អាហារូបករណ៍ ដែលធ្វើឱ្យពួកយើងខ្ញុំទទួលបានឱកាសក្នុងការសិក្សា និងទាញយកចំណេះដឹងពីគ្រឹះស្ថានឧត្តមសិក្សា ដែលមានប្រវត្តិអប់រំជំនាញនីតិសាស្ត្រដ៏យូរលង់មួយនេះ និង រហូតដល់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនៃពួកខ្ញុំបាទ។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង គណៈគ្រប់គ្រង លោក-លោកស្រីសាស្ត្រាចារ្យ និងបុគ្គលិកការិយាល័យស្រាវជ្រាវ ការិយាល័យសិក្សា នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់** ដែលបានរួមចំណែកក្នុងការពង្រឹងវិន័យ និងផ្តល់ការអប់រំ សីលធម៌ រួមទាំងផ្តល់ចំណេះជំនាញ និងចំណេះដឹងបច្ចេកទេសនានាដល់ពួកយើងខ្ញុំ។

**លោកស្រីសាស្ត្រាចារ្យ ម៉ូលី បញ្ញា អនុប្រធានការិយាល័យស្រាវជ្រាវ និង ជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលលោកស្រីបានផ្តល់កិត្តិយស យល់ព្រមនិងឯកភាពតាមសំណូមពរ ធ្វើជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំនេះ។ ការចំណាយពេលផ្ទាល់ខ្លួន ដើម្បីណែនាំ ផ្តល់យោបល់ ចែករំលែកនូវពុទ្ធិ ក៏ដូចជាកែសម្រួលនូវខ្លឹមសារនិងទម្រង់នៃកិច្ចការសារណានេះ រហូតលេចចេញជាលទ្ធផលដ៏រលូននេះ គឺសុទ្ធតែមានបង្កប់នូវការលះបង់ទាំងកម្លាំងកាយចិត្ត និង ស្មារតីរបស់លោកស្រីសាស្ត្រាចារ្យ។

ជាចុងក្រោយ យើងខ្ញុំសូមគោរពជូនពរដល់ លោកអ្នកមានគុណទាំងឡាយ ដូចបានរៀបរាប់និងមិនបានរៀបរាប់អស់ ឱ្យសមប្រកបដោយ ពុទ្ធពរទាំងឡាយ ៤ ប្រការ គឺ **អាយុ** សូមឱ្យមានអាយុវែង, **វណ្ណៈ** សូមឱ្យមានពណ៌សម្បុរកាយល្អ, **សុខៈ** សូមឱ្យបានសុខកាយ សប្បាយចិត្ត, និង **ពលៈ** សូមឱ្យបានប្រកបដោយកម្លាំងកាយ កម្លាំងប្រាជ្ញា វាងវៃ កុំបីឃ្លៀងឃ្លាតឡើយ ៕

# អារម្ភកថា

ការបន្តការសិក្សានៅឧត្តមសិក្សា ជាក្តីប្រាថ្នារបស់យើងខ្ញុំ និងអ្នកសិក្សាជាច្រើនទៀត។ អាហារូបករណ៍របស់ក្រសួងអប់រំ យុវជន និងកីឡា និងការអនុញ្ញាតឱ្យយើងខ្ញុំបានសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច លើជំនាញនីតិសាស្ត្រ បានឱ្យយើងខ្ញុំសម្រេចក្តីស្រមៃមួយនេះ។ ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ បានផ្តល់ឱ្យយើងខ្ញុំនូវចំណេះដឹងមូលដ្ឋានផ្នែកនីតិសាស្ត្រជាច្រើន រួមទាំងបានផ្តល់នូវពន្លកនៃចំណូលចិត្តលើនីតិគ្រួសារ ដែលជម្រុញឱ្យយើងខ្ញុំជ្រើសរើសប្រធានបទស្តីពី **របបសន្តតិកម្មនៅកម្ពុជា** មកធ្វើការសិក្សាស្រាវជ្រាវ ដើម្បីបន្សល់ទុកជាស្នាដៃសម្រាប់ការបញ្ចប់ការសិក្សា និងទុកជាប្រយោជន៍ដល់អ្នកស្រាវជ្រាវ និងនិស្សិតជំនាន់ក្រោយៗទៀតក្នុងការពិគ្រោះ និងស្វែងយល់បន្ថែមលើករណីពាក់ព័ន្ធ។

គ្រួសារជាកោសិកានៃសង្គម។ ទំនាស់ដែលកើតឡើងនៅក្នុងគ្រួសារ គឺប្រៀបដូចជាកោសិកានៃសង្គមមានជំងឺដូច្នេះដែរ ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ក្នុងការថែទាំ។ ក្នុងចំណោមប្រភពនៃជម្លោះជាច្រើន ជម្លោះលើការបែងចែកមត៌ក គឺជាចំណុចរសើបមួយនៅក្នុងសង្គមសេដ្ឋកិច្ចទីផ្សារដូចជាកម្ពុជា ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ តាមរយៈការសិក្សាឱ្យបានស៊ីជម្រៅ និងផ្តល់ជាដំណោះស្រាយ។ ទិដ្ឋភាពនេះហើយដែលជាកាតាលីករជម្រុញឱ្យយើងខ្ញុំ ជ្រើសរើសប្រធានបទខាងលើមកធ្វើការស្រាវជ្រាវ និងចងក្រងឡើង។

យើងខ្ញុំ ក៏សង្ឃឹម និងជឿជាក់ផងដែរថា ស្នាដៃមួយនេះនឹងអាចរួមចំណែកដល់ការគ្រប់គ្រងទំនាក់ទំនងនៅក្នុងគ្រួសារ ពិសេសទំនាក់ទំនងទ្រព្យសម្បត្តិដែលកើតចេញពីការផ្ទេរមត៌កនេះ។ មិនតែប៉ុណ្ណោះ ពួកយើងក៏រំពឹងដែរថា ការសិក្សានេះនឹងរួមចំណែកជម្រុញការស្រាវជ្រាវបែបវិទ្យាសាស្ត្រនៅកម្ពុជា ដើម្បីជាផ្នែកមួយនៃការដោះស្រាយបញ្ហារបស់មិត្តអ្នកអានផងដែរ។

ក្នុងអវសាននៃកថានេះ យើងខ្ញុំសូមអធ្យាស្រ័យផងដែរចំពោះកំហុសដោយអចេតនាណាមួយ និងសូមស្វាគមន៍ជានិច្ចនូវរាល់មតិរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យស្នាដៃនេះអាចទទួលយកបានក្នុងកម្រិតមួយ។ យើងខ្ញុំសូមថ្លែងអំណរគុណ និងជូនពរដល់ លោក-លោកស្រីជាសាស្ត្រាចារ្យ មិត្តនិស្សិត និងមិត្តអ្នកអានដទៃទៀតឱ្យជួបប្រទះតែនឹងពុទ្ធពរ និងពរទាំងប្រាំប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** និង **បដិភាណៈ** កុំបីឃ្លៀងឃ្លាតឡើយ។ សូមអរគុណ ៕

ថ្ងៃចន្ទ ១០ កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១

**ហត្ថលេខា**

**សាត សុខវិសាល** **ប៉ាវ ឥន្ទម៉េង**

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ 1

## ជំពូកទី ១
## សញ្ញាណទូទៅនៃរបបសន្តតិកម្ម

**ផ្នែកទី ១ ៖ ប្រវត្តិនៃរបបសន្តតិកម្មនៅកម្ពុជា** ........ 3

**កថាខណ្ឌទី ១ ៖ សញ្ញាណនៃសន្តតិកម្មក្នុងអក្សរសិល្ប៍ខ្មែរ** ........ 3

១. សន្តតិកម្មនៅក្នុងរឿងព្រេងខ្មែរ ........ 4

ក. រឿងមហាសេដ្ឋីមានកូនបីនាក់ឈ្លោះដណ្តើមមត៌កគ្នា ........ 4

ខ. រឿងកុដុម្ពិក៏មានកូនប្រុសបីនាក់ឈ្លោះដណ្តើមមត៌កគ្នា ........ 4

២. គោលការណ៍ច្បាប់នៅក្នុងរឿងព្រេងខ្មែរ ........ 5

ក. គោលការណ៍ទាក់ទងនឹងច្បាប់នីតិវិធី ........ 5

ខ. គោលការណ៍ទាក់ទងនឹងច្បាប់សារធាតុ ........ 6

**កថាខណ្ឌទី ២ ៖ សញ្ញាណនៃសន្តតិកម្មក្នុងច្បាប់សរសេរ** ........ 6

១. សន្តតិកម្មក្នុងសម័យអាណានិគមបារាំង ........ 6

ក. ក្រមមត៌ក ........ 7

ខ. ក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ ........ 7

២. សន្តតិកម្មក្រោយសម័យអាណានិគមបារាំង ........ 7

ក. សន្តតិកម្មក្រោមរដ្ឋធម្មនុញ្ញបែបសង្គមនិយម ........ 8

ខ. សន្តតិកម្មក្រោមរដ្ឋធម្មនុញ្ញបែបសេរីនិយម ........ 8

**ផ្នែកទី ២ ៖ ការចាប់ផ្តើមសន្តតិកម្ម** ........ 9

**កថាខណ្ឌទី ១ ៖ មូលហេតុនៃការចាប់ផ្តើមសន្តតិកម្ម** ........ 9

១. ការទទួលមរណភាព ........ 10

ក. លក្ខខណ្ឌគ្រឹះ ........ 10

ខ. លក្ខខណ្ឌទម្រង់ ........ 10

២. ការចាត់ទុកថាបានទទួលមរណភាព ........ 11
ក. លក្ខខណ្ឌគ្រឹះ ........ 11
ខ. លក្ខខណ្ឌទម្រង់ ........ 12
**កថាខណ្ឌទី ២ ៖ ទីកន្លែងចាប់ផ្ដើមសន្តតិកម្ម** ........ 13
១. ករណីមតកជនមានទីលំនៅនៅកម្ពុជា ........ 13
២. ករណីមតកជនមានទីលំនៅនៅបរទេស ........ 14
**ផ្នែកទី ៣ ៖ សញ្ញាណទូទៅនៃសន្តតិជន** ........ 15
**កថាខណ្ឌទី ១ ៖ លក្ខណសម្បត្តិនៃសន្តតិជន** ........ 15
១. ករណីបុគ្គលដែលមានជីវិតរស់នៅ ........ 15
២. ករណីទារកនៅក្នុងគភ៌ ........ 17
ក. បុព្វហេតុនៃការទទួលសិទ្ធិ ........ 17
ខ. អត្ថិភាពនៃកំណើត ........ 18
**កថាខណ្ឌទី ២ ៖ បុគ្គលដែលបាត់បង់សិទ្ធិជាសន្តតិជន** ........ 19
១. អភ័ព្វបុគ្គល ........ 19
ក. អំពើដែលប៉ះពាល់ដល់សុវត្ថិភាពមតកជន ........ 19
ខ. អំពើដែលប៉ះពាល់ដល់អត្តន័យមតកសាសន៍ ........ 20
២. ជនដែលផ្ដាច់ចេញពីមត៌ក ........ 21
ក. ការផ្ដាច់មត៌កពីសន្តតិជន ........ 21
ខ. ការលុបចោលការផ្ដាច់មត៌កពីសន្តតិជន ........ 23
**កថាខណ្ឌទី ៣ ៖ ករណីសន្តតិជនជាជនបរទេស** ........ 23
១. បុព្វហេតុនៃការមិនអាចទទួលបានសិទ្ធិលើដីធ្លី ........ 23
២. ដំណោះស្រាយក្នុងក្រមរដ្ឋប្បវេណី ........ 24
**ផ្នែកទី ៤ ៖ អានុភាពនៃសន្តតិកម្ម** ........ 25
**កថាខណ្ឌទី ១ ៖ គោលការណ៍នៃសន្តតិកម្ម** ........ 25
១. គោលការណ៍ជម្រះបញ្ជី ........ 25
២. គោលការណ៍សន្តតិកម្មដោយស្វ័យប្រវត្តិ ........ 26

**កថាខណ្ឌទី ២ ៖ អានុភាពនៃសន្តតិកម្មលើសន្តតិជន** ..... 26
១. ករណីសន្តតិជនតែម្នាក់ ..... 26
២. ករណីមានសន្តតិជនច្រើននាក់ ..... 27
៣. ករណីពិសេស ..... 28

## ជំពូកទី ២
## ប្រភេទនៃសន្តតិកម្ម

**ផ្នែកទី ១ ៖ សន្តតិកម្មតាមច្បាប់** ..... 29
**កថាខណ្ឌទី ១ ៖ បុគ្គលដែលអាចទទួលសន្តតិកម្ម** ..... 30
១. ការគណនាថ្នាក់ញាតិ ..... 30
ក. ការគណនាថ្នាក់នៃញាតិលោហិតខ្សែផ្ទាល់ ..... 30
ខ. ការគណនាថ្នាក់នៃសាខាញាតិលោហិត ..... 31
២. សន្តតិជន ..... 32
ក. សន្តតិជនលំដាប់ទី ១ សន្តតិជនជំនួស និង សន្តតិជនជានិច្ច ..... 32
ខ. សន្តតិជនលំដាប់ទី ២ សន្តតិជនជំនួស និង សន្តតិជនជានិច្ច ..... 36
គ. សន្តតិជនលំដាប់ទី ៣ សន្តតិជនជំនួស និង សន្តតិជនជានិច្ច ..... 37
**កថាខណ្ឌទី ២ ៖ នីតិវិធីក្នុងការបែងចែកមត៌ក** ..... 37
១. វិធានក្នុងការបែងចែកចំណែកមត៌ក ..... 38
ក. ចំណែកមត៌ក ..... 38
ខ. ការបែងចែកចំណែកមត៌ក ..... 42
២. វិធានក្នុងការផ្ទេរកម្មសិទ្ធិលើមត៌ក ..... 44
**ផ្នែកទី ២ ៖ សន្តតិកម្មតាមមតកសាសន៍** ..... 46
**កថាខណ្ឌទី ១ ៖ លក្ខខណ្ឌសុពលភាពនៃមតកសាសន៍** ..... 47
១. លក្ខខណ្ឌគ្រឹះ ..... 47
២. លក្ខខណ្ឌទម្រង់ ..... 47
ក. មតកសាសន៍សម្រាប់ស្ថានភាពធម្មតា ..... 48
ខ. មតកសាសន៍សម្រាប់ស្ថានភាពពិសេស ..... 51

គ. ខ្លឹមសារនៃមតកសាសន៍......53
**កថាខណ្ឌទី ២ ៖ នីតិវិធីក្នុងការបែងចែកមត៌ក**......54
១. វិធានក្នុងការបែងចែកចំណែក......54
ក. ការបញ្ជាក់ និង ការបើកលិខិតមតកសាសន៍......54
ខ. ការបញ្ជាក់អំពីសន្តតិជន......55
គ. ការបញ្ជាក់អំពីកម្មវត្ថុនៃសន្តតិកម្ម......55
ឃ. ការបញ្ជាក់អំពីកាតព្វកិច្ច......56
២. វិធានក្នុងការផ្ទេរកម្មសិទ្ធិ......56
ក. ការពិភាក្សាបែងចែកមត៌ក......57
ខ. មត៌កបែងចែកដោយតុលាការ......59

## ជំពូកទី ៣
## ករណីនត្ថិភាពនៃសន្តតិជន

**ផ្នែកទី ១ ៖ បុគ្គលដែលអាចទទួលបានមត៌ក**......61
**កថាខណ្ឌទី ១ ៖ ការកំណត់ដោយយកឆន្ទៈមតកជនជាមូលដ្ឋាន**......61
១. អច្ច័យលាភី......61
២. បុគ្គលដែលមាននិស្ស័យពិសេស......61
**កថាខណ្ឌទី ២ ៖ ការកំណត់ដោយយកស្មារតីច្បាប់ជាមូលដ្ឋាន**......62
១. ម្ចាស់បំណុល......63
២. រដ្ឋ៖ សន្តតិជនចុងក្រោយ......63
**ផ្នែកទី ២ ៖ ករណីសិក្សាពីនីតិបុគ្គលមត៌ក**......63
**កថាខណ្ឌទី ១ ៖ ការចាប់ផ្ដើមនៃនីតិបុគ្គលមត៌ក**......64
១. បុព្វហេតុនៃការបង្កើត......64
២. លក្ខខណ្ឌក្នុងការបង្កើត......65
៣. នីតិវិធីក្នុងការបង្កើតនីតិបុគ្គលមត៌ក......65
**កថាខណ្ឌទី ២ ៖ ការរៀបចំ និងការប្រព្រឹត្តទៅនៃនីតិបុគ្គលមត៌ក**......66
១. ការគ្រប់គ្រងមត៌ក......66

២. ការចាត់ចែងមត៌ក ..... 67
ក. ការជូនដំណឹងលើកទី ១ ..... 67
ខ. ការជូនដំណឹងលើកទី ២ ..... 67
គ. ការជូនដំណឹងលើកទី ៣ ..... 68
**កថាខណ្ឌទី ៣ ៖ ការបញ្ចប់នីតិបុគ្គលមត៌ក** ..... 70
១. វត្ថុមានសន្តតិជន និងការទទួលមត៌ក ..... 70
២. ករណីធនក្ស័យ ..... 70
៣. ការបញ្ចប់នីតិវិធីដោយស្ពាពរ ..... 71
**សេចក្តីសន្និដ្ឋាន** ..... 72
**អនុសាសន៍** ..... 76
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

ទស្សនៈពុទ្ធនិយមយល់ឃើញថា សត្វលោកទាំងឡាយរមែងវិលកើតវិលស្លាប់ មិនចេះអស់ មិនចេះហើយក្នុងសំសារៈ។ កាលបើកើតឡើងហើយរមែងតែងមានចាស់ ឈឺ ស្លាប់ ជារឿងធម្មតា។[1] ជាទូទៅ បើបានទទួលមរណភាពហើយ បុគ្គលនោះនឹងបាត់បង់សមត្ថភាពទទួលសិទ្ធិរបស់ខ្លួន ដែលមានន័យថា បុគ្គលនោះមិនអាចតាំងខ្លួនជាកម្មសិទ្ធិករ ឬជាម្ចាស់បំណុលបានទៀតទេ ដែលតម្រូវឱ្យមានការគិតគូរពីម្ចាស់សិទ្ធិថ្មីត្រូវទទួលបន្តនូវសិទ្ធិទាំងនោះ។[2] ក្រៅពីសិទ្ធិលើទ្រព្យសកម្ម បុគ្គលម្នាក់ៗក៏អាចមានកាតព្វកិច្ចមួយចំនួនដែរ មុនពេលដែលខ្លួនបានទទួលមរណភាពទៅ ដែលតម្រូវឱ្យមានអ្នកទទួលបន្តនូវកាតព្វកិច្ចនេះបន្ត ដើម្បីធានាឱ្យបាននូវសុវត្ថិភាពរបស់ម្ចាស់បំណុល។ លើសពីនេះទៅទៀត ការបែងចែកមត៌កនេះក៏ស្របតាមទស្សនៈមួយចំនួនផងដែរ។[3] ទស្សនៈទីមួយយល់ថា ទោះបីជាទ្រព្យសម្បត្តិនោះជារបស់មតកជនក៏ដោយ ក៏ការរកបាននូវសិទ្ធិ និងកាតព្វកិច្ចទាំងនោះ ត្រូវបានទទួលឥទ្ធិពលពីកិច្ចសហការរបស់ក្រុមគ្រួសារទាំងមូលផងដែរ។ ទស្សនៈមួយទៀតយល់ឃើញថា ការបែងចែកមត៌ក គឺមានសារសំខាន់ក្នុងការទ្រទ្រង់ជីវភាពគ្រួសាររបស់មតកជន ដែលធ្លាប់តែទទួលបាននូវការទំនុកបម្រុងនៅពេលដែលមតកជននៅរស់។ ហេតុនេះ ការផ្ទេរមត៌ក ពីបុគ្គលដែលទទួលមរណភាពមកបុគ្គលដែលមានជីវិតនេះ ជាការសមហេតុផលមួយ។ ហើយវិធានទាំងឡាយ ដែលគ្រប់គ្រងនូវទំនាក់ទំនងនៃការផ្ទេរសិទ្ធិ និងកាតព្វកិច្ចនេះ ត្រូវបានកំណត់នៅក្នុងរបបមួយដែលគេហៅថា **របបសន្តតិកម្ម**។

តាមពិតទៅ របបសន្តតិកម្មនេះ ត្រូវបានគេទទួលស្គាល់តាំងពីយូរលង់ណាស់មកហើយ ដោយផ្អែកលើមូលដ្ឋាននៃរបបទ្រព្យសម្បត្តិឯកជន។ ហើយរបបនេះ ក៏មិនមែនជាបញ្ហាថ្មីដែរសម្រាប់ប្រទេសកម្ពុជា ដោយហេតុថា គេឃើញមានសញ្ញាណមួយចំនួននៃសន្តតិកម្មស្ថិតក្នុងប្រវត្តិនៃនីតិខ្មែរ។ សញ្ញាណទាំងនោះ ត្រូវបានគេសង្កេតឃើញទាំងក្នុងប្រភពសរសេរ និងប្រភពមិនសរសេរ។ ប្រភពទាំងនោះរួមមានដូចជា រឿងព្រេងបុរាណខ្មែរ ក្រំមរដក់ (ក្រមមត៌ក) ក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ និងច្បាប់ភូមិបាលទាំងពីរជាដើម មុនពេលដែលរបបសន្តតិកម្មថ្មី ត្រូវបានបង្កើតឡើងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ហើយដែលត្រូវបានអនុវត្តតាមរយៈច្បាប់ស្តីពីការដាក់ឱ្យអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ ២០១១។

ការសិក្សា និងការបង្កើតរបបសន្តតិកម្មនេះ គឺមានការវិវឌ្ឍពីមួយជំនាន់ទៅមួយជំនាន់អាស្រ័យតាមស្ថានភាពសង្គម សេដ្ឋកិច្ច និងនយោបាយរបស់កម្ពុជា។ ក្នុងពេលបច្ចុប្បន្ន ការសិក្សាពីរបបនេះ គឺមានសារ

[1] ត្រឹង ងារ, *អរិយធម៌ខ្មែរ* ( ភ្នំពេញ៖ ការផ្សាយរបស់អ្នកនិពន្ធ, បោះពុម្ពលើកទី ៣, ១៩៧៤), ៤៩-៦៦។

[2] អ៊ីកិដា ម៉ាសាអូ, *ច្បាប់រដ្ឋប្បវេណី៖ ករណីប្រទេសជប៉ុន* (ភ្នំពេញ៖ សមាគមអ្នកច្បាប់ជប៉ុនដើម្បីកម្ពុជា, ២០០៨), ២៦០។

[3] ណូមូរ៉ា តូយ៉ូហ៊ីរ៉ូ, *សេចក្តីផ្តើមនីតិរដ្ឋប្បវេណី* (ភ្នំពេញ៖ បោះពុម្ពលើកទី ៥ ដោយ JICA, ២០១១), ១៧១។

សំខាន់ជាងសម័យណាៗទាំងអស់ ត្បិតប្រជាជនកម្ពុជាកាន់តែមានជីវភាពធូរធារទៅៗ ដែលធ្វើឱ្យទំហំនៃមត៌កក៏កាន់តែមានតម្លៃខ្លាំងឡើងៗ។ ជាក់ស្តែង ចាប់តាំងពីព្រះរាជាណាចក្រកម្ពុជាទី២ ត្រូវបានបង្កើតឡើងដោយកំណើតនៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ការរីកចម្រើនទាំងផ្នែកសេដ្ឋកិច្ច និងសង្គមក៏កាន់តែមានភាពល្អប្រសើរឡើងជាលំដាប់។ ចំណូលក្នុងស្រុកសរុបសម្រាប់ប្រជាជនម្នាក់បានកើនឡើងពី ២៩០ ដុល្លារអាម៉េរិក ក្នុងឆ្នាំ ១៩៩៨ ដល់ប្រមាណ ១៣៨០ ដុល្លារអាម៉េរិកក្នុងឆ្នាំ ២០១៨ ចំណែកឯភាគរយនៃប្រជាជនដែលស្ថិតក្រោមបន្ទាត់នៃភាពក្រីក្របានធ្លាក់ចុះពី ៤៧.៨ ភាគរយ ក្នុងឆ្នាំ ២០០៧ មកត្រឹម ១៣.៥ ភាគរយ ប៉ុណ្ណោះក្នុងឆ្នាំ ២០១៤។[4]

ឆ្លើយតបទៅនឹងតម្រូវការនៃការសិក្សាខាងលើ សារណានេះ នឹងធ្វើការសិក្សាក្នុងក្របខណ្ឌទូទៅស្តីពីរបបសន្តតិកម្មនៅកម្ពុជា។ ការសិក្សានេះ បែងចែកជា ៣ (បី)ជំពូក។ ជាបឋម យើងនឹងធ្វើការបង្ហាញឱ្យឃើញពីសញ្ញាណទូទៅនៃរបបសន្តតិកម្មនៅកម្ពុជា ដែលនឹងពិនិត្យអំពីដំណើរវិវឌ្ឍន៍នៃរបបនេះមុន និងក្រោយការចូលជាធរមាននៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ (ជំពូកទី១)។ ជំពូកបន្ទាប់ នឹងធ្វើការបង្ហាញពីប្រភេទផ្សេងៗនៃសន្តតិកម្ម ដែលរួមមានសន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍ (ជំពូកទី២)។ ចំណែកឯជំពូកចុងក្រោយនៃសារណានេះ យើងនឹងធ្វើការសិក្សាជាពិសេស ទៅលើករណីនត្តិភាពនៃសន្តតិជន (ជំពូកទី៣)។

[4] *Cambodia, 2019-2023: Inclusive Pathways to a Competitive Economy* (បោះពុម្ពដោយ ADB, តុលា ២០១៩)។

# ជំពូកទី ១
# សញ្ញាណទូទៅនៃរបបសន្តតិកម្ម

# ជំពូកទី ១
# សញ្ញាណទូទៅនៃរបបសន្តតិកម្ម

នៅពេលដែលបុគ្គលម្នាក់ទទួលមរណភាពទៅរមែងបន្សល់ទុកនូវសិទ្ធិ និងកាតព្វកិច្ចមួយចំនួន ដែលតម្រូវឱ្យមានអ្នកទទួលបន្ត។ ការផ្ទេរបន្តនូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជន[5]តាមឆន្ទៈក្តី ឬតាមច្បាប់ក្តី ទៅឱ្យជនម្នាក់ ឬច្រើននាក់នេះ ត្រូវបានគេហៅថា "សន្តតិកម្ម"។[6] តាមរយៈទិដ្ឋភាពនេះ គេអាចធ្វើការកត់សម្គាល់នូវបញ្ហាទូទៅចំនួនបី ទាក់ទងនឹងសន្តតិកម្មដែលរួមមាន ស្ថានភាពដែលនាំឱ្យសន្តតិកម្មចាប់ផ្តើម (ផ្នែកទី២) ជនដែលអាចទទួលបានសិទ្ធិ និងកាតព្វកិច្ចពីមតកជន (ផ្នែកទី៣) និងអានុភាពដែលអាចកើតឡើងនៅពេលដែលជននោះទទួលយកមត៌ក (ផ្នែកទី៤)។ ប៉ុន្តែ ដោយហេតុថាសេចក្តីស្លាប់ជារឿងធម្មតារបស់មនុស្សលោកគ្រប់សម័យកាលទាំងអស់ ជាបឋមយើងគួរតែចាប់ផ្តើមសិក្សាពីបទពិសោធន៍នៃការអនុវត្តសន្តតិកម្មក្នុងប្រវត្តិនៃនីតិកម្ពុជាជាមុនសិន (ផ្នែកទី១)។

## ផ្នែកទី ១ ៖ ប្រវត្តិនៃរបបសន្តតិកម្មនៅកម្ពុជា

នៅក្នុងបរិបទនៃប្រទេសកម្ពុជា ការសិក្សាពីបទពិសោធន៍នៃនីតិខ្មែរអាចធ្វើទៅបានដោយផ្អែកលើប្រភពពីរសំខាន់គឺ ប្រភពឥតសរសេរដែលរួមមានរឿងព្រេង (កថាខណ្ឌទី១) និងប្រភពសរសេរដែលរួមមានដូចជាច្បាប់ផ្សេងៗដែលត្រូវបានអនុវត្តពីអតីតកាល (កថាខណ្ឌទី២)។

### កថាខណ្ឌទី ១ ៖ សញ្ញាណនៃសន្តតិកម្មក្នុងអក្សរសិល្ប៍ខ្មែរ

អក្សរសិល្ប៍ ត្រូវបានគេចាត់ទុកថាជាកញ្ចក់មួយប្រភេទដ៏សំខាន់របស់សង្គមមនុស្ស ដោយហេតុថា វាឆ្លុះឱ្យឃើញពីការរស់នៅដ៏ជាក់ស្តែងរបស់មនុស្សក្នុងសម័យនីមួយៗ ហើយអក្សរសិល្ប៍តែងតែប្រែប្រួលទៅតាមដំណើរវិវឌ្ឍន៍របស់សង្គមមនុស្សជាដរាប។[7] លើសពីនេះទៅទៀត អក្សរសិល្ប៍ប្រជាប្រិយខ្មែរក៏បង្កប់នូវវប្បធម៌ អរិយធម៌ ប្រពៃណី ទំនៀមទម្លាប់ ផ្នត់គំនិត ស្រទាប់ទស្សនៈរបស់ខ្មែរក្នុងវិស័យនយោបាយ យុត្តិធម៌ ធម្មសាស្ត្រ និងនីតិសាស្ត្រផងដែរ។[8] ហេតុនេះ ការសិក្សាពីអក្សរសិល្ប៍ខ្មែរ ពិតជាអាចឱ្យយើងស្គាល់ពីទិដ្ឋភាពនៃការអនុវត្តសន្តតិកម្មកាលពីអតីតកាល។ អត្ថបទខាងក្រោម នឹងធ្វើការសិក្សាពីរឿងព្រេងខ្មែរមួយចំនួន ដែល

[5] គណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, *សទ្ទានុក្រមផ្នែករដ្ឋប្បវេណី* (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧), ១៧ ៖ "មតកជន សំដៅទៅលើជនដែលបានស្លាប់បាត់ទៅ"។

[6] ដដែល។

[7] ត្រឹង ងារ, *អរិយធម៌ខ្មែរ* (ភ្នំពេញ៖ ការផ្សាយរបស់អ្នកនិពន្ធ, បោះពុម្ពលើកទី ៣, ១៩៧៤), ១០០-១០១។

[8] ហៃល ចំរើន, *មរតកយុត្តិធម៌ខ្មែរ* (ភ្នំពេញ៖ រោងពុម្ពដាយអឹមិនព្រីនធីង, បោះពុម្ពឡើងវិញ, ២០១៩), ៨-១០។

ដកស្រង់ចេញពីសាស្ត្រាកឹងកន្ទ្រែ (១) មុននឹងធ្វើការវិភាគពីគោលការណ៍ផ្សេងៗដែលបានបង្កប់ក្នុងរឿងព្រេងទាំងនោះ (២)។

**១. សន្តតិកម្មនៅក្នុងរឿងព្រេងខ្មែរ**

បើយើងធ្វើការពិនិត្យនៅក្នុងអក្សរសិល្ប៍ខ្មែរ មានរឿងព្រេងមួយចំនួនបានបង្កប់នូវសញ្ញាណមួយចំនួនទាក់ទងនឹងសន្តតិកម្មដែលអាចត្រូវបានអនុវត្តនៅក្នុងសង្គមខ្មែរ។ ជាក់ស្តែងដូចជា រឿងមហាសេដ្ឋីមានកូនបីនាក់ឈ្លោះដណ្តើមមត៌កគ្នា (ក) និងរឿងកុដុម្ពិក៏មានកូនប្រុសបីនាក់ឈ្លោះដណ្តើមមត៌កគ្នាជាដើម (ខ) សុទ្ធតែបង្កប់នូវចំណោទបញ្ហា និងដំណោះស្រាយក្នុងបញ្ហាសន្តតិកម្មនេះ។

**ក. រឿងមហាសេដ្ឋីមានកូនបីនាក់ឈ្លោះដណ្តើមមត៌កគ្នា**[9]

រឿងនេះមានដំណើរដូចតទៅ “ មាននិទានមួយថា មានមហាសេដ្ឋីម្នាក់មានកូនប្រុស ៣ នាក់ កូនច្បងនិងកូនបន្ទាប់ទាំងពីរនាក់មានប្រពន្ធហើយ ចេញទៅធ្វើផ្ទះនៅដោយខ្លួនពីគ្នា ឆ្ងាយពីឪពុក ចំណែកកូនពៅនៅផ្ទះជាមួយឪពុកជាប់រហូត។ លុះឪពុកមានជំងឺធ្ងន់ កូនពៅដែលនៅផ្ទះជាមួយ តែងថែទាំបម្រើឪពុករាល់ថ្ងៃរហូតដល់ឪពុកក្ស័យជីវិត។ ឯកូនបងពីរនាក់មិនបាននៅថែរក្សាជំងឺឪពុកទេ ប៉ុន្តែលុះឪពុកក្ស័យផុតទៅហើយ ទើបបានមកជួយធ្វើបុណ្យខ្មោចឪពុក។

កូនទាំងបីនាក់ឈ្លោះប្រកែកគ្នាដណ្តើមមត៌កឪពុក ដោយបែងចែកមិនដាច់ស្រេចសោះ ក៏នាំគ្នាទៅប្តឹងចៅក្រម ចៅក្រមកាត់សេចក្តីពុំបាន ក៏នាំបុរសទាំងនោះឡើងក្រាបបង្គំព្រះមហាក្សត្រតាមដំណើរគ្រប់ប្រការ។ ព្រះមហាក្សត្រទ្រង់ពិចារណាជ្រាបហើយទ្រង់កាត់សេចក្តីថា ព្រះស្តែងជាចម្បងទាំងពីរដែលមានប្រពន្ធហើយចេញទៅសង់ផ្ទះឆ្ងាយពីឪពុកនោះ ត្រូវបានមួយភាគម្នាក់ស្មើគ្នា ឯប្អូនពៅដែលនៅផ្ទះជាមួយឪពុក ហើយបានថែរក្សាឪពុកនោះត្រូវបានពីរភាគ។ កូនមហាសេដ្ឋីទាំងបីនាក់សុខចិត្តព្រមព្រៀងទទួលតាមព្រះបន្ទូលនោះហើយ ថ្វាយបង្គំលាទៅយកទ្រព្យកេរមត៌កតាមចំណែកគ្នាហើយទៅទីលំនៅនៃខ្លួនទីទៃៗ។ ព្រះមហាក្សត្រទ្រង់សម្រេចសេចក្តីបែបនេះ ហៅសុគតិគមនំហោង។ ”

**ខ. រឿងកុដុម្ពិក៏មានកូនប្រុសបីនាក់ឈ្លោះដណ្តើមមត៌កគ្នា**[10]

រឿងនេះមានដំណើរដូចតទៅ “ មាននិទានមួយថា មានកុដុម្ពិក៏ម្នាក់មានកូនប្រុស ៣ នាក់ កូនច្បងទៅបម្រើស្តេច កូនបន្ទាប់ទៅជួញស្វែងរកទ្រព្យសម្បត្តិមកចិញ្ចឹមខ្លួនឯង ឯប្អូនពៅទៅបួសក្នុងសំណាក់សាស្តាព្រះតថាគត។ លុះចំណេរយូរមក ឪពុកនោះអស់អាយុទៅ កូនទាំងបីនាក់ឈ្លោះប្រកែកគ្នាដណ្តើមទ្រព្យសម្បត្តិរបស់

[9] ក្រុមប្រជុំទំនៀមទម្លាប់ខ្មែរ, *ប្រជុំរឿងព្រេងខ្មែរ ភាគ ៣* (ភ្នំពេញ៖ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត, ២០០១), ២៣-២៤។

[10] ក្រុមប្រជុំទំនៀមទម្លាប់ខ្មែរ, *ប្រជុំរឿងព្រេងខ្មែរ ភាគ ៣* (ភ្នំពេញ៖ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត, ២០០១), ២៥-២៦។

ឪពុកតែរាល់ខ្លួន ជជែកគ្នាមិនដាច់ស្រេចសោះ ហើយនាំគ្នាទៅប្តឹងចៅក្រម ចៅក្រមកាត់សេចក្តីចែកសម្បត្តិនោះឱ្យកូនទាំងបីនាក់។ កូនទាំងបីនាក់មិនសុខចិត្តក៏នាំរឿងនោះទៅក្រាបបង្គំទូលព្រះមហាក្សត្រតាមដំណើរ។ ព្រះមហាក្សត្រទ្រង់កាត់សេចក្តីថា ព្រះស្តេងកូនច្បងចេញទៅបម្រើស្តេច ប្រាថ្នាចង់ឱ្យបានកិត្តិយសជាប្រយោជន៍ផ្ទាល់ខ្លួន និងព្រះស្តេងប្អូនបន្ទាប់ដែលចេញទៅជួញស្វែងរកទ្រព្យសម្បត្តិមកចិញ្ចឹមខ្លួនឯងនោះ ត្រូវបានមួយភាគស្មើគ្នា ឯព្រះស្តេងប្អូនពៅដែលចេញទៅបួស យកផលានិសង្ស ចម្រើនជូនទៅម្តាយឪពុកនោះ ត្រូវបានពីរភាគម្នាក់ឯង។ កូនទាំងបីនាក់សុខចិត្តទទួលចំណែកតាមព្រះបន្ទូលគ្រប់គ្នា ហើយក្រាបបង្គំលាទៅលំនៅទីទៃៗ។ ព្រះមហាក្សត្រ ទ្រង់កាត់សេចក្តីចែកសម្បត្តិឱ្យកូនទាំង ៣ នាក់យ៉ាងនេះ ហៅថា សុគតិគមនំហោង។"

### ២. គោលការណ៍ច្បាប់នៅក្នុងរឿងព្រេងខ្មែរ

តាមរយៈដំណើររឿងខាងលើ យើងអាចពិនិត្យឃើញថាមានគោលការណ៍ពីរប្រភេទយ៉ាងតិចដែលបង្កប់នៅក្នុងអត្ថន័យនៃរឿងទាំងពីរនេះ ដែលរួមមានគោលការណ៍ទាក់ទងនឹងច្បាប់នីតិវិធី (ក) និងគោលការណ៍ទាក់ទងនឹងច្បាប់សារធាតុ (ខ)។

#### ក. គោលការណ៍ទាក់ទងនឹងច្បាប់នីតិវិធី

រឿងព្រេងទាំងពីរខាងលើបានបង្ហាញពីនីតិវិធីក្នុងការជម្រះក្តីមួយ ដែលស្រដៀងគ្នាទៅនឹងនីតិវិធីដែលត្រូវបានប្រើប្រាស់ក្នុងពេលបច្ចុប្បន្ន ពោលគឺការបែងចែកសាលាជម្រះក្តីជាថ្នាក់ៗ។ មាត្រា ៣ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ បានចែងថា សាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជារួមមាន សាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល ដែលសាលាដំបូងជាសាលាជម្រះក្តីជាន់ទាប ហើយសាលាឧទ្ធរណ៍ និងតុលាការកំពូលជាសាលាជម្រះក្តីជាន់ខ្ពស់។[11] នៅក្នុងរឿងខាងលើ នៅពេលដែលមានជម្លោះទាក់ទងនឹងការបែងចែកចំណែកមត៌ក ភាគីជម្លោះបានបញ្ជូនរឿងក្តីទៅកាន់ចៅក្រមឱ្យធ្វើការសម្រេចសេចក្តី ដែលប្រៀបដូចជាសាលាដំបូងដូច្នេះដែរ។ លើសពីនេះទៅទៀត នៅពេលដែលភាគីជម្លោះនោះមិនពេញចិត្តនឹងការសម្រេចសេចក្តីរបស់ចៅក្រម ឬចៅក្រមមិនអាចធ្វើការសម្រេចសេចក្តីបាន រឿងក្តីនោះត្រូវបញ្ជូនទៅកាន់ព្រះមហាក្សត្រដើម្បីជម្រះបន្តហើយសេចក្តីសម្រេចនោះហាក់បីដូចជាបិទផ្លូវតវ៉ា ពោលគឺប្រៀបដូចជាតុលាការកំពូលដូច្នេះដែរ។ ហេតុនេះរឿងនេះបានបង្កប់នូវនីតិវិធីនៃការបែងចែកការជម្រះក្តីជាពីរជាន់ ដើម្បីធានានូវការសម្រេចឱ្យកាន់តែសុក្រឹត។

[11] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤, ១៦ កក្កដា ២០១៤, មាត្រា ៣។

### ខ. គោលការណ៍ទាក់ទងនឹងច្បាប់សារធាតុ

ក្រៅពីគោលការណ៍ទាក់ទងនឹងនីតិវិធី រឿងទាំងពីរក៏បានឆ្លុះបញ្ចាំងនូវគោលការណ៍ទាក់ទងនឹងច្បាប់សារធាតុផងដែរ ពោលគឺគោលការណ៍បែងចែកភាគមត៌កតាមទំហំឧបការគុណ។[12] ត្បិតព្រះមហាក្សត្រយល់ថាកូនទាំងអស់គួរតែបានចំណែកមត៌ក ប៉ុន្តែការបែងចែកចំណែកធំ ឬតូចសម្រាប់កូននីមួយៗទើបជាបញ្ហា។ ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ ព្រះអង្គបានសម្រេចបែងចែកទ្រព្យសម្បត្តិឱ្យស្របទៅតាមទំហំនៃការលះបង់របស់កូននីមួយៗនៅពេលឪពុកនៅរស់។ ជាក់ស្តែង នៅក្នុងរឿងមហាសេដ្ឋីមានកូនបីនាក់ឈ្លោះដណ្តើមមត៌កគ្នា ព្រះអង្គយល់ថា កូនច្បង និងកូនទីពីរ ដែលបានរៀបការហើយទៅនៅផ្ទះដទៃនោះ គួរតែទទួលបានចំណែកមត៌កស្មើគ្នា ប៉ុន្តែត្រូវទទួលបានតិចជាងកូនពៅដែលបាននៅមើលថែឪពុករបស់ខ្លួនរហូតដល់ឪពុកបាត់បង់ជីវិត។ លើសពីនេះទៅទៀត ការបែងចែកមត៌កនេះក៏មិនយោងទៅតាមលំដាប់នៃកូនឡើយ។ ហេតុនេះ គោលការណ៍ទាក់ទងនឹងច្បាប់សារធាតុគឺ ការបែងចែកចំណែកទៅតាមទំហំឧបការគុណរបស់សន្តតិជន។

## កថាខណ្ឌទី ២ ៖ សញ្ញាណនៃសន្តតិកម្មក្នុងច្បាប់សរសេរ

ការសិក្សាពីប្រភពនៃសន្តតិកម្មនៅក្នុងច្បាប់សរសេរ គួរតែចាប់ផ្តើមសិក្សាពីសម័យអាណាព្យាបាលបារាំងមក។ ពួកអាណានិគមបារាំង បានធ្វើការរៀបចំចងក្រងប្រព័ន្ធច្បាប់នៅកម្ពុជា ហើយក៏ជាពេលដែលប្រព័ន្ធច្បាប់សរសេរចាប់ផ្តើមលេចចេញនៅកម្ពុជាផងដែរ ទោះបីជាបរណីនៅតែត្រូវបានប្រជាជនខ្មែរគាំទ្រ និងថែរក្សាក៏ដោយចុះ។ [13] ដើម្បីធ្វើឱ្យការសិក្សាពីប្រវត្តិនៃច្បាប់សរសេរនេះកាន់តែលម្អិត យើងសាកល្បងធ្វើការបែងចែកការសិក្សាច្បាប់ទាំងនេះជាពីរក្រុមគឺ សន្តតិកម្មក្នុងសម័យអាណានិគមបារាំង (១) និងសន្តតិកម្មក្រោយសម័យអាណានិគមបារាំង (២)។

### ១. សន្តតិកម្មក្នុងសម័យអាណានិគមបារាំង

បារាំងបានដាក់អាណានិគមនៅកម្ពុជាអស់ពេល ៩០ ឆ្នាំ ពោលគឺ ពីឆ្នាំ ១៨៦៣ ដល់ឆ្នាំ ១៩៥៣។[14] នៅក្នុងសម័យនេះ គេឃើញមានច្បាប់សរសេរមួយចំនួនត្រូវបានលេចចេញឡើង ដែលមានដូចជា ក្រមមត៌ក (ក) និងក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ (ខ) ជាដើម។

---

[12] ហ៊ែល ចំរើន, *មរតកយុត្តិធម៌ខ្មែរ* (ភ្នំពេញ៖ រោងពុម្ពដាយអឺមិនព្រីនធីង, បោះពុម្ពឡើងវិញ, ២០១៩), ៤០-៤៤។

[13] ព្រុំ រិទ្ធី, *នីតិបេតិកភណ្ឌ និងគ្រួសារ,* (ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, បោះពុម្ពលើកទី១, ២០១៩), ៤-៦។

[14] ដេវិឌ ឆាណ្ឌល័រ ប្រវត្តិសាស្ត្រខ្មែរ បោះពុម្ពលើកទី៣ ឆ្នាំ២០០៩ ទំព័រ ១៦១៖ "តាមពិតទៅកម្ពុជាមិនទាន់ស្ថិតក្រោមអាណានិគមបារាំងនៅឡើយទេនៅឆ្នាំ ១៨៦៣ ដោយកម្ពុជាគ្រាន់តែត្រូវបានដាក់ក្រោមអាណាព្យាបាលរបស់បារាំងប៉ុណ្ណោះ។ ក្រោយពីឆ្នាំ១៨៨៦ ពោលគឺក្រោយពេលដែលការបះបោរក្នុងឆ្នាំ១៨៨៤ ត្រូវរលាយបាត់ បារាំងចាប់ផ្តើមគ្រប់គ្រងកម្ពុជាកាន់តែខ្លាំងទៅៗ។ ចាប់ពីឆ្នាំ១៩៤១ ដល់ឆ្នាំ១៩៥៣ ទើបជាសម័យអាណានិគមយ៉ាងពេញទីព្រោះបារាំងបានក្តោបក្តាប់អំណាចយ៉ាងណែននៅកម្ពុជា"។

**ក. ក្រមមត៌ក**

ក្រមមត៌កមាន ៧០ មាត្រា ត្រូវបានតាក់តែងឡើងនៅឆ្នាំ ១៨៧៦ ក្រោមរជ្ជកាលព្រះបាទសម្តេចព្រះនរោត្តម ដែលត្រូវបានបោះពុម្ពដោយរោងពុម្ពអាណាព្យាបាលបារាំង។[15] ក្រមនេះមានចែងពីឋានៈរបស់សន្តតិជន និងរបៀបនៃការបែងចែកទ្រព្យសម្បត្តិរបស់មតកជន។ ក្រមនេះមានចែងពីចំណុចសំខាន់ៗដូចតទៅនេះ។ ទីមួយ ទ្រព្យរបស់ប្តី ឬប្រពន្ធដែលស្លាប់ឥតកូន ត្រូវទុកជាទ្រព្យដែលត្រូវបញ្ចូលជាទ្រព្យហ្លួង។ ទីពីរ បើអ្នកស្លាប់មានបំណោចបំណាន (គុណបំណាច់) ក្នុងរាជការ តែគ្មានមាតាបិតាបុត្រភរិយា មត៌កត្រូវប្រគល់ឱ្យញាតិសន្តាន។ ទីបី មត៌ករបស់អ្នកស្លាប់ដែលមានបណ្តាសក្តិ តែគ្មានបំណោចបំណាន ត្រូវបែងចែកតាមរបៀបដូចជាទ្រព្យជាព្រះរាជទានត្រូវយកចូលព្រះឃ្លាំងហ្លួង ទ្រព្យដែលនៅសល់ត្រូវទូទាត់សងបំណុល សល់ពីនេះត្រូវបែងចែងជាបួនភាគស្មើគ្នា ដែលមួយភាគៗត្រូវចែកឱ្យព្រះឃ្លាំងហ្លួង ឪពុកម្តាយ ភរិយា កូនចៅផៅសណ្តានដែលឱ្យថ្នាំជំងឺលើកខ្មោចស្រោចផ្សឹង។ ទីបួន បើអ្នកស្លាប់គ្មានប្រពន្ធកូនឪពុកម្តាយ ទ្រព្យត្រូវចែកជាបីភាគ ដែល ២ ភាគឱ្យយកចូលព្រះឃ្លាំងហ្លួង និងមួយភាគឱ្យបានទៅតែចៅផៅសន្តានដែលឱ្យថ្នាំជំងឺលើកខ្មោចស្រោចផ្សឹងប៉ុណ្ណោះ។ ចុងក្រោយ គឺការបែងចែកទៅកាន់ភរិយា និងកូន តាមជំពូកនៃកូន និងភរិយានីមួយៗ។

**ខ. ក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០**

ក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ មាន ១៣៦៥ មាត្រា ដែលបទប្បញ្ញត្តិទាក់ទងនឹងសន្តតិកម្មមានចែងពីមាត្រា ៤៨៦ ដល់ មាត្រា ៦២៦។[16] ច្បាប់នេះមានចែងលម្អិតច្រើន ពាក់ព័ន្ធនឹងបញ្ហាសន្តតិកម្ម។ ច្បាប់នេះមានចែងពីចំណុចសំខាន់ៗដូចតទៅ ៖ ទីមួយ គឺនិយាយពីសញ្ញាណទូទៅនៃសន្តតិកម្ម។ ទីពីរ គឺនិយាយអំពីប្រភេទនៃសន្តតិកម្ម ដែលរួមមានសន្តតិកម្មមានបណ្តាំ និងសន្តតិកម្មឥតបណ្តាំ រួមទាំងប្បញ្ញត្តិលម្អិត។ ទីបី គឺនិយាយអំពីលំដាប់នៃការផ្ទេរសន្តតិកម្ម។ ទីបួន និយាយអំពីការកាន់យកនូវមត៌ក។ ចុងក្រោយ គឺវិធានការដែលត្រូវចាត់ឱ្យរក្សាទុកនូវមត៌ក និងចំណុចមួយចំនួនទៀត។ ហេតុនេះ គេសង្កេតឃើញថា វិធានស្តីពីសន្តតិកម្មក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ ក៏មានភាពទំនើបផងដែរ។

**២. សន្តតិកម្មក្រោយសម័យអាណានិគមបារាំង**

ក្រោយទទួលបានឯករាជ្យក្នុងឆ្នាំ ១៩៥៣ គេឃើញមានទិដ្ឋភាពពិសេសមួយចំនួនទាក់ទងនឹងការវិវត្តនៃនីតិខ្មែរទាក់ទងនឹងបញ្ហាសន្តតិកម្ម។ ចាប់ពីពេលដែលទទួលឯករាជ្យ រហូតដល់ឆ្នាំ ១៩៧៥ កម្ពុជានៅអនុវត្តប្រព័ន្ធច្បាប់សរសេរដែលទទួលឥទ្ធិពលពីច្បាប់បារាំងនៅឡើយ ប៉ុន្តែក្រោយមកទៀត ទិដ្ឋភាពនីតិខ្មែរមានការ

---

[15] ហ៊ែល ចំរើន, *មរតកយុត្តិធម៌ខ្មែរ* (ភ្នំពេញ៖ រោងពុម្ពដាយអឺមិនព្រីនធីង, បោះពុម្ពឡើងវិញ, ២០១៩), ៤៤៦-៤៥៤។

[16] អេង សុត, *ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ បោះពុម្ពលើកទី ១, ១៩៦៧)។

ប្រែប្រួលគួរឱ្យចាប់អារម្មណ៍ដែលអាចធ្វើការបែងចែកជាពីរចំណុចដូចជា ការអនុវត្តសន្តតិកម្មក្រោមឥទ្ធិពលលទ្ធិសង្គមនិយម (ក) និងការអនុវត្តសន្តតិកម្មក្រោមឥទ្ធិពលលទ្ធិសេរីនិយម (ខ)។

**ក. សន្តតិកម្មក្រោមរដ្ឋធម្មនុញ្ញបែបសង្គមនិយម**

របបកុម្មុយនីស្ត ដែលមានឈ្មោះ " របបកម្ពុជាប្រជាធិបតេយ្យ " បានគ្រប់គ្រងប្រទេសកម្ពុជាពីខែមេសា ឆ្នាំ ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩។[17] នៅក្នុងរបបនេះ បាននាំមកទីបញ្ចប់នូវប្រាក់កាស ផ្សារផ្សោ ការអប់រំជាផ្លូវការ ព្រះពុទ្ធសាសនា សៀវភៅ ទ្រព្យសម្បត្តិឯកជន សម្លៀកបំពាក់ប្លែកគ្នា និងសេរីភាពក្នុងការដើរហើរជាដើម ដោយពួកកុម្មុយនីស្តយល់ថា ស្ថាប័នទាំងអស់នេះសុទ្ធតែជាការរារាំងដល់បដិវត្តន៍។ នៅក្នុងស្ថានភាពនេះ របបគតិយុត្តបែបទំនើបដែលបានទទួលឥទ្ធិពលពីបារាំងក៏ត្រូវបានបញ្ចប់ ហើយត្រូវបានគេជំនួសមកវិញដោយរបបមួយដែលមិនទទួលស្គាល់ទ្រព្យសម្បត្តិឯកជន[18] ហើយក៏មានន័យថា សន្តតិកម្មមិនត្រូវបានអនុវត្តនោះឡើយនៅក្នុងសម័យនេះ។[19] បើទោះបីជាកម្ពុជាបានរួចចេញពីរបបខ្មៅងងឹតនេះក្នុងឆ្នាំ ១៩៧៩ ក៏ដោយ ក៏ប្រទេសកម្ពុជានៅតែទទួលឥទ្ធិពលក្រោមរបបនយោបាយសង្គមនិយមនេះដដែល ដែលជាហេតុធ្វើឱ្យកម្មសិទ្ធិឯកជនត្រូវបានរឹតត្បិត ដែលជាមូលហេតុចំពោះអវត្តមាននៃរបបសន្តតិកម្មនៅកម្ពុជា រហូតមកដល់ឆ្នាំ ១៩៨៩។[20] និយាយជារួម អត្ថិភាពនៃសន្តតិកម្ម គឺមិនមានឡើយក្រោមឥទ្ធិពលនៃលទ្ធិសង្គមនិយម។

**ខ. សន្តតិកម្មក្រោមរដ្ឋធម្មនុញ្ញបែបសេរីនិយម**

រដ្ឋធម្មនុញ្ញរដ្ឋកម្ពុជាឆ្នាំ ១៩៨៩ និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្នឆ្នាំ ១៩៩៣ បានទទួលស្គាល់កម្មសិទ្ធិឯកជនឡើងវិញ ហើយក៏ជាការរស់ឡើងវិញនៃរបបសន្តតិកម្មដែរ។ គេអាចសិក្សាពីការរស់ឡើងវិញនៃសន្តតិកម្មនេះជាពីរដំណាក់កាល គឺពីចន្លោះឆ្នាំ ១៩៨៩ ដល់ឆ្នាំ ២០០៧ និងពីឆ្នាំ ២០០៧ ដល់ឆ្នាំ ២០១១។[21] នៅក្នុងដំណាក់កាលទី១ បើទោះបីជាកម្មសិទ្ធិឯកជនត្រូវបានទទួលស្គាល់ហើយក៏ដោយ ក៏បញ្ហាសន្តតិកម្មនៅមិនទាន់ត្រូវបានដោះស្រាយនៅឡើយ។ គេក៏សង្កេតឃើញមានច្បាប់មួយចំនួនដូចជាច្បាប់ស្តីពី

---

[17] ដេវិឌ ឆាណ្ឌលើរ, *ប្រវត្តិសាស្ត្រខ្មែរ* (កម្ពុជា៖ មជ្ឈមណ្ឌលខេមរសិក្សា, បោះពុម្ពលើកទី ៣, ២០០៩), ២៤៧។

[18] មាត្រា ២ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យឆ្នាំ ១៩៧៦៖ *"មធ្យោបាយផលិតកម្មសំខាន់ៗជាទូទៅជាកម្មសិទ្ធិរបស់ប្រជាជន និងកម្មសិទ្ធិរួមរបស់ប្រជាជនសមូហភាព។ រីឯរបស់របរប្រើប្រាស់ប្រចាំថ្ងៃ ស្ថិតនៅជាកម្មសិទ្ធិផ្ទាល់របស់ឯកជន។"* វ៉ាន់ឌី កាអុន, *ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា* ភាគទី ២, (បោះពុម្ពលើកទី ២, ២០០៨), ទាក់ទងនឹង *"ជីវភាពរបស់ប្រជាជនខ្មែរក្រោមរបបខ្មែរក្រហម", ១៥៥-១៥៩ ៖ "ទោះបីជាមានបញ្ជាក់ថា របស់របរប្រើប្រាស់ប្រចាំថ្ងៃស្ថិតក្រោមកម្មសិទ្ធិឯកជនក៏ដោយ ការអនុវត្តជាក់ស្តែង កម្មសិទ្ធិឯកជនត្រូវបានហាមឃាត់ជាដាច់ខាត ដែលការអនុវត្តសន្តតិកម្មគឺមិនអាចធ្វើទៅបានឡើយ"*។

[19] ព្រុំ រិទ្ធី, *នីតិបេតិកកណ្ឌ និងគ្រួសារ,* (ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, បោះពុម្ពលើកទី១, ២០១៩), ៨០។

[20] ដដែល។

[21] ព្រុំ រិទ្ធី, *នីតិបេតិកកណ្ឌ និងគ្រួសារ,* (ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, បោះពុម្ពលើកទី១, ២០១៩), ៨១-៨២។

អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ ១៩៨៩ និងច្បាប់ភូមិបាលចាស់ ឆ្នាំ ១៩៩២ ប៉ុន្តែមានតែច្បាប់ភូមិបាលចាស់នេះប៉ុណ្ណោះដែលមានបញ្ជាក់ពីពាក្យ សន្តតិកម្ម បើទោះបីជាវិធានដោះស្រាយបញ្ហាសន្តតិកម្មនៅមិនទាន់មាននៅឡើយក្តី។ មកដល់ឆ្នាំ ២០០១ គេឃើញមានច្បាប់ភូមិបាលថ្មីចូលជាធរមាន ប៉ុន្តែបញ្ហាសន្តតិកម្មនៅតែមិនមានចែងឱ្យដាច់ស្រេចនៅឡើយ ដោយគេទុកឱ្យបវេណីជាអ្នកដោះស្រាយរហូតដល់ក្រមរដ្ឋប្បវេណីថ្មីចូលបានចូលជាធរមាន។ នៅក្នុងដំណាក់កាលទី ២ ពោលគឺពីឆ្នាំ ២០០៧ ដល់ឆ្នាំ២០១១ បញ្ហាសន្តតិកម្មត្រូវបានដោះស្រាយភាគច្រើនដោយគោលការណ៍សមធម៌ បើទោះបីជាវិធានគតិយុត្តមិនមានចែង ហើយក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មិនទាន់ចូលជាធរមានជាផ្លូវការក៏ដោយ។

ឆ្លងតាមការសិក្សាខាងលើទាក់ទងទៅនឹងប្រវត្តិនៃរបបសន្តតិកម្មនៅកម្ពុជា ដែលបានផ្តោតទាំងទៅលើសញ្ញាណដែលបង្កប់ទាំងនៅក្នុងអក្សរសិល្ប៍ និងច្បាប់សរសេរ យើងបានទាញចេញជាគោលការណ៍ និងបទពិសោធន៍មួយចំនួនដែលមានតម្លៃសម្រាប់ធ្វើការពិចារណាពីបញ្ហាសន្តតិកម្ម។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់កម្ពុជាប្រកាន់យកគោលការណ៍នីត្យានុកូល ពោលគឺការជម្រះក្តីត្រូវធ្វើតាមច្បាប់ជាធរមាន ដោយស្របតាមស្មារតីនៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ត្រង់កថាខណ្ឌទី១ នៃមាត្រា ១២៩ ថ្មី ដែលបានចែងថា “ការជម្រះក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន”។[22] ហេតុនេះ ចំណុចបន្តបន្ទាប់ពីនេះ នឹងធ្វើការសិក្សាពីសន្តតិកម្មក្នុងធរមានបញ្ញត្តិវិញម្តង។

## ផ្នែកទី ២ ៖ ការចាប់ផ្តើមសន្តតិកម្ម

ដើម្បីធ្វើការសិក្សាឱ្យបានពេញលេញពីការចាប់ផ្តើមសន្តតិកម្ម យើងសាកល្បងធ្វើការបែងចែកការសិក្សានេះជាពីរចំណុច។ ជាបឋម យើងនឹងពិនិត្យមើលជាមុនសិន ថាតើអ្វីទៅជាមូលហេតុនៃការចាប់ផ្តើមសន្តតិកម្ម? (កថាខណ្ឌទី១) មុននឹងយើងសិក្សាអំពីថាតើសន្តតិកម្មនឹងត្រូវចាប់ផ្តើមនៅទីណានៅពេលដែលមូលហេតុនៃការចាប់ផ្តើមត្រូវបានបំពេញ? (កថាខណ្ឌទី២)

### កថាខណ្ឌទី ១ ៖ មូលហេតុនៃការចាប់ផ្តើមសន្តតិកម្ម

ដូចដែលបានបញ្ជាក់នៅចំណុចខាងលើ សន្តតិកម្ម គឺជាការផ្ទេរសិទ្ធិ និងកាតព្វកិច្ចពីជនដែលស្លាប់ទៅជនដែលនៅរស់។ ហេតុនេះ ការសិក្សាពីមូលហេតុនៃការចាប់ផ្តើមសន្តតិកម្ម គួរតែផ្តើមចេញពីមរណភាពនៃមតកជន (១)។ ប៉ុន្តែ ករណីដែលបុគ្គលមួយចំនួនបានបាត់ខ្លួនមិនដឹងថាស្លាប់ ឬរស់ ក៏ជាបញ្ហាសំខាន់ដែរ ហេតុនេះយើងនឹងពិនិត្យពីបញ្ហានេះនៅចំណុចបន្ទាប់ (២)។

[22] ហ៊ី សោភា, *នីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច), ៩។

**១. ការទទួលមរណភាព**

មាត្រា ១១៤៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានកំណត់ថា សន្តតិកម្មត្រូវចាប់ផ្តើមដោយមរណភាពរបស់មតកជន។ ក្រមរដ្ឋប្បវេណីមិនទទួលស្គាល់សន្តតិកម្ម នៅពេលដែលម្ចាស់សិទ្ធិ និងកាតព្វកិច្ចនៅរស់នោះទេ។[23] ដើម្បីកំណត់ថាបុគ្គលណាមួយបានទទួលមរណភាព គេត្រូវពិនិត្យមើលលក្ខខណ្ឌពីរ គឺលក្ខខណ្ឌគ្រឹះ (ក) និងលក្ខខណ្ឌទម្រង់ (ខ)។

**ក. លក្ខខណ្ឌគ្រឹះ**

ចំពោះលក្ខខណ្ឌគ្រឹះ បុគ្គលម្នាក់ត្រូវបានគេសន្មតថាទទួលមរណភាព នៅពេលដែលបេះដូងឈប់ដកដង្ហើម ហើយកាន់តែច្បាស់ជាងនេះទៅទៀតគឺភាពរឹងនៃសព។[24] ចំពោះការបកស្រាយនៃក្រមរដ្ឋប្បវេណីជប៉ុន មរណភាព តាមទំនៀមទម្លាប់គឺជាពេលដែលសួត បេះដូង ខួរក្បាល ឈប់មានដំណើរការ ហើយគេបញ្ជាក់មរណភាពដោយពិនិត្យមើល ការអស់ដង្ហើម បេះដូងឈប់លោត និងការរីកនៃប្រស្រីភ្នែក ព្រមទាំងគ្មានប្រតិកម្មនៃពន្លឺ។[25] ដោយទស្សនៈមរណភាពនៅក្នុងវិស័យវេជ្ជសាស្ត្រកាន់តែមានការអភិវឌ្ឍ មានបញ្ហាចោទមួយចំនួននៅតែត្រូវមានការបកស្រាយថាត្រូវចាត់ទុកថាទទួលមរណភាពឬទេ ដូចជាករណីការស្លាប់នៃខួរក្បាលជាដើម។

**ខ. លក្ខខណ្ឌទម្រង់**

ចំពោះលក្ខខណ្ឌទម្រង់វិញ ការបញ្ជាក់ពីអត្ថិភាពនៃមរណភាពគឺត្រូវបង្ហាញសំបុត្រមរណភាព។ ចំពោះនីតិវិធីនៃការទទួលស្គាល់មរណភាពជាផ្លូវការមានចែងនៅក្នុងអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០០០។ នីតិវិធីនេះអាចត្រូវបានបែងចែកជាពីរ គឺករណីជនជាតិខ្មែរទទួលមរណភាពនៅកម្ពុជា និងករណីជនជាតិខ្មែរទទួលមរណភាពនៅឯបរទេស។

ករណីជនជាតិខ្មែរទទួលមរណភាពនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា[26] នៅពេលមានអ្នកស្លាប់ ក្រុមគ្រួសារ ឬសាច់ញាតិសន្តាន ឬអ្នកជិតខាង ឬអ្នកមានភារកិច្ចនៅក្រសួង ស្ថាប័ន អង្គភាពរបស់អ្នកស្លាប់ ត្រូវរាយការណ៍ជូនមន្ត្រីអត្រានុកូលដ្ឋានសាលាឃុំ ឬសង្កាត់ នៃទីកន្លែងរស់នៅជាប់លាប់របស់អ្នកស្លាប់។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសព បើស្លាប់ដោយជំងឺធម្មតា ដោយចាស់ជរា ដោយគ្រោះថ្នាក់ធម្មជាតិ ឬដោយគ្រោះថ្នាក់ផ្សេងៗ ដែលមិនមានមន្ទិលសង្ស័យទាក់ទងដល់អំពើឃាតកម្មនៃ

---

[23] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), មាត្រា ១១៤៥។

[24] ប៊ួយ ធីតា និង កង ស៊ីផាន់ណារ៉ា, *នីតិរដ្ឋប្បវេណី* (ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច, បោះពុម្ពឆ្នាំ ២០១៨), ២៨។

[25] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), មាត្រា ៨។

[26] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, លេខ ១០៣ អនក្រ.បក, ២០០០, មាត្រា ៣៥។

បទល្មើសឧក្រិដ្ឋណាមួយ។ ការចុះសៀវភៅមរណភាព និងចេញសំបុត្រមរណភាព ត្រូវធ្វើក្នុងរយៈពេលយូរបំផុត ១៥ ថ្ងៃ ក្រោយពីថ្ងៃទទួលមរណភាព។ បើអ្នកស្លាប់ដោយជំងឺរាតត្បាត អាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់សង្គម គេត្រូវធ្វើការរាយការណ៍ទៅមន្ទីរពេទ្យ ឬផ្នែកអនាម័យភ្លាមៗ។ បើពេទ្យ ឬផ្នែកអនាម័យសម្រេចយ៉ាងណា មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើលិខិតអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសពតាមការសម្រេចនោះ។

ក្នុងករណីជនជាតិខ្មែរបានទទួលមរណភាពនៅលើដែនដីបរទេស[27] ក្រុមគ្រួសារ ឬក៏សាច់ញាតិសន្តាន ឬអ្នកជិតខាង ឬអ្នកដែលបានឃើញអ្នកស្លាប់នោះផ្ទាល់ អាចទៅចុះសំបុត្រមរណភាពនៅប្រទេសនោះ តាមច្បាប់របស់ប្រទេសនោះ។ ពេលត្រលប់មកព្រះរាជាណាចក្រកម្ពុជាវិញ ត្រូវយកសំបុត្រមរណភាព ដែលធ្វើនៅបរទេសនោះទៅចុះសៀវភៅនៅ ឃុំ ឬសង្កាត់ ដែលសាមីខ្លួនអ្នកស្លាប់ធ្លាប់ស្នាក់នៅជាប់លាប់មុនចេញទៅក្រៅប្រទេស។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវដកយកសំបុត្រមរណភាពថតចម្លងជាផ្លូវការទុកជាឯកសារ ហើយចម្លងចេញពីសៀវភៅមរណភាពនូវសំបុត្រមរណភាពថ្មី ប្រគល់ឱ្យសាមីខ្លួនអ្នកសុំយកទៅប្រើប្រាស់។ បើបានទៅរាយការណ៍ចុះសៀវភៅមរណភាពនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជានៅប្រទេសនោះ រួចហើយត្រលប់មកប្រទេសកម្ពុជាវិញ គេអាចយកសំបុត្រមរណភាពនោះមកធ្វើការប្រើប្រាស់ជាផ្លូវការបាន។

### ២. ការចាត់ទុកថាបានទទួលមរណភាព

ក្រៅពីករណីនៃការទទួលមរណភាពខាងលើ សន្តតិកម្មក៏អាចត្រូវបានចាប់ផ្តើមតាមរយៈការចាត់ទុកថាបានទទួលមរណភាពផងដែរ។[28] ការសន្មតថាបានទទួលមរណភាព អាចធ្វើទៅបានដោយផ្អែកលើលក្ខខណ្ឌចំនួនពីរ គឺលក្ខខណ្ឌគ្រឹះ (ក) និងលក្ខខណ្ឌទម្រង់ (ខ)។

#### ក. លក្ខខណ្ឌគ្រឹះ

ការចាត់ទុកថាបានទទួលមរណភាព អាចធ្វើបានតាមរយៈករណីណាមួយក្នុងចំណោមករណីចំនួនពីរ គឺការបាត់ខ្លួនធម្មតា និងការបាត់ខ្លួនក្នុងលក្ខណៈពិសេស។[29]

ករណីទីមួយ ការបាត់ខ្លួនធម្មតា គឺប្រសិនបើពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមានស្លាប់ ឬរស់ក្នុងរយៈពេលយ៉ាងតិច ៥ឆ្នាំ។ ការបាត់ខ្លួនក្នុងរយៈពេលយូរបែបនេះ នឹងធ្វើឱ្យទំនាក់ទំនងគតិយុត្តពាក់ព័ន្ធនឹងបុគ្គលនោះមិនច្បាស់លាស់ ដែលធ្វើឱ្យមានការលំបាកដល់ជនដែលពាក់ព័ន្ធ។[30] ជាក់ស្តែង សហព័ទ្ធរបស់

---

[27] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, លេខ ១០៣ អនក្រ.បក, ២០០០, មាត្រា ៤១។

[28] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), មាត្រា ១១៨៥។

[29] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៤១-៤៣។

[30] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), មាត្រា ៤១។

បុគ្គលនោះមិនអាចរៀបអាពាហ៍ពិពាហ៍បានដោយសារបញ្ហាទ្វេពន្ធភាព សន្តតិជនក៏មិនអាចស្នងទ្រព្យសម្បត្តិដោយសន្តតិកម្មបាន ដែលធ្វើឱ្យការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលនោះមិនដឹងទីបញ្ចប់។ ហេតុនេះ ការបង្កើតនូវរបបអំពីការបាត់ខ្លួននេះ គឺមានភាពចាំបាច់ ប៉ុន្តែក៏ត្រូវតែមានភាពច្បាស់លាស់ និងប្រុងប្រយ័ត្នផងដែរ ត្បិតការប្រកាសនេះមានអានុភាពខ្លាំងដល់បុគ្គលភាពគតិយុត្តរបស់បុគ្គលមួយរូប។

ករណីទីពីរ គឺការបាត់ខ្លួនក្នុងករណីពិសេស ដូចជាការបាត់ខ្លួនក្នុងករណីជួបប្រទះនូវគ្រោះថ្នាក់ផ្សេងៗ ដូចជា ការបាត់ខ្លួនក្នុងសង្គ្រាម ការលិចនាវា រញ្ជួយដី អគ្គិភ័យ ស៊ូណាមិ ការរអិលផ្ទាំងទឹកកកពីភ្នំ ជាអាទិ៍ ហើយមិនដឹងថារស់ ឬស្លាប់ក្នុងរយៈពេល ១ ឆ្នាំ។[31] ការបាត់ខ្លួនក្នុងករណីនេះ គឺមានភាពពិសេសជាងករណីទូទៅ ត្បិតភាគរយនៃការស្លាប់ដោយគ្រោះថ្នាក់ទាំងនេះ គឺមានភាគរយច្រើនជាងការស្លាប់ក្នុងករណីទូទៅ ហេតុនេះ ការទុកពេលវេលាដែលអាចប្រកាសពីការចាត់ទុកថាទទួលមរណភាពបាន គឺតិចជាងករណីទូទៅ។

ហេតុនេះ នៅពេលរយៈពេល ៥ ឆ្នាំបានផុតទៅចំពោះករណីបាត់ខ្លួនធម្មតា និងពេល ១ ឆ្នាំបានកន្លងផុតទៅបន្ទាប់ពីគ្រោះថ្នាក់បានបញ្ចប់ក្នុងករណីការបាត់ខ្លួនពិសេស អានុភាពនៃការបាត់ខ្លួនទាំងនេះនឹងនាំទៅរកការចាត់ទុកថាទទួលមរណភាពនៅពេលលក្ខខណ្ឌទម្រង់ត្រូវបានបំពេញ។

**ខ. លក្ខខណ្ឌទម្រង់**

នៅពេលលក្ខខណ្ឌគ្រឹះដូចមានបង្ហាញក្នុងចំណុចខាងលើត្រូវបានបំពេញ ការប្រកាសអំពីការបាត់ខ្លួនដែលអាចនាំទៅរកអានុភាពនៃការចាត់ទុកថាទទួលមរណភាពខាងលើ អាចធ្វើទៅបានដោយការប្រកាសរបស់តុលាការ។[32] ការស្នើសុំនេះអាចបកស្រាយបានតាមពីរចំណុចដូចខាងក្រោម។

ទីមួយ គឺបុគ្គលដែលមានសិទ្ធិធ្វើការដាក់ពាក្យសុំ។ បុគ្គលទាំងនេះមានដូចជា សហព័ទ្ធ អ្នកដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឪពុកម្តាយ ឬអ្នកផ្សេងទៀតដែលមានផលប្រយោជន៍សំខាន់តាមផ្លូវច្បាប់ក្នុងការប្រកាសអំពីការបាត់ខ្លួន ដូចដែលបានបញ្ជាក់ក្នុងមាត្រា ៤១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។ ដោយឡែក មេឃុំ ចៅសង្កាត់ ឬព្រះរាជអាជ្ញា មិនត្រូវបានផ្តល់សិទ្ធិធ្វើការដាក់ពាក្យសុំឡើយ ដោយហេតុថា គ្រួសារកំពុងទន្ទឹងរង់ចាំការត្រលប់មកវិញរបស់បុគ្គលដែលអវត្តមាននោះ ហើយប្រសិនបើអនុញ្ញាតឱ្យរដ្ឋអំណាចជាអាទិ៍ អាចដាក់ពាក្យសុំឱ្យតុលាការប្រកាសអំពីការបាត់ខ្លួនទៅ គឺមិនសមរម្យឡើយ។[33]

---

[31] ដដែល។

[32] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៤១-៤៣។

[33] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), មាត្រា ៤១។

ទីពីរ គឺតុលាការដែលមានសមត្ថកិច្ច។ នៅក្នុងរឿងក្ដីនេះ សមត្ថកិច្ចតុលាការគឺត្រូវបានកំណត់នៅក្នុងច្បាប់ស្ដីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងត្រង់មាត្រា ៤ និងបន្តបន្ទាប់។ តារាងឧបសម្ព័ន្ធ ផ្នែកទី១ បានបញ្ជាក់ថា តុលាការដែលមានសមត្ថកិច្ចក្នុងរឿងនេះ គឺតុលាការនៃលំនៅឋានចុងក្រោយរបស់បុគ្គលដែលអវត្តមាន។ ដោយហេតុថារឿងក្ដីនេះ មិនមានចុងចម្លើយនៃបណ្ដឹង នោះគឺមិនអាចធ្វើនៅលំនៅឋានចុងចម្លើយបានឡើយ។ នៅក្នុងករណីអត្ថិភាព ឬនត្ថិភាព ឬភាពមិនច្បាស់លាស់នៃលំនៅឋាន ឬទីសំណាក់ ត្រូវកំណត់ដោយយកពេលវេលានៃការដាក់ពាក្យសុំមកធ្វើជាមូលដ្ឋានដូចមានចែងក្នុងមាត្រា ១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ពោលគឺកំណត់តាមបទដ្ឋានជាធរមានក្នុងពេលដាក់ពាក្យបណ្ដឹងនោះតាមបទពិសោធន៍របស់ប្រទេសជប៉ុន។[34]

ជារួម ការចាប់ផ្ដើមសន្តតិកម្ម គឺតម្រូវឱ្យមានអត្ថិភាពនៃមរណភាព ដែលអាចស្ដែងឡើងក្នុងទម្រង់ជាការទទួលមរណភាព ឬការចាត់ទុកថាបានទទួលមរណភាព។ ប៉ុន្តែ ក្រៅពីការយល់ដឹងពីមូលហេតុនៃការចាប់ផ្ដើមសន្តតិកម្ម ការស្វែងយល់ពីទីកន្លែងចាប់ផ្ដើមសន្តតិកម្មក៏ជារឿងសំខាន់ដែរ។

### កថាខណ្ឌទី ២ ៖ ទីកន្លែងចាប់ផ្ដើមសន្តតិកម្ម

ការកំណត់ពីទីកន្លែងនៃការចាប់ផ្ដើមសន្តតិកម្ម គឺមានភាពចាំបាច់សម្រាប់កំណត់ពីតុលាការដែលមានសមត្ថកិច្ច ក្នុងករណីមានអន្តរាគមន៍ចាំបាច់របស់តុលាការចំពោះសន្តតិកម្ម ដូចជាការបោះបង់នូវសន្តតិកម្ម ការយល់ព្រមដោយមានកម្រិត ការបែងចែកមត៌ក ជាអាទិ៍។[35] ការសិក្សាពីសមត្ថកិច្ចតុលាការនេះ អាចចែកជាពីរចំណុចគឺ ករណីមតកជនមានទីលំនៅនៅកម្ពុជា (១) និងករណីមតកជនមានទីលំនៅនៅបរទេស (២)។

#### ១. ករណីមតកជនមានទីលំនៅនៅកម្ពុជា

ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានកំណត់យ៉ាងច្បាស់ត្រង់មាត្រា ១១៤៦ ថា សន្តតិកម្ម ត្រូវចាប់ផ្ដើមនៅលំនៅឋានរបស់មតកជននាពេលទទួលមរណភាព ដែលមានន័យថា តុលាការនៅលំនៅឋានរបស់មតកជននេះ ជាតុលាការដែលមានសមត្ថកិច្ច។[36] ការជ្រើសយកលំនៅឋានចុងក្រោយជាកន្លែងនៃការចាប់ផ្ដើមសន្តតិកម្មនេះ គឺដើម្បីរក្សាភាពងាយស្រួលក្នុងការអនុវត្តវិធានច្បាប់ ដោយហេតុថាវាជាកន្លែងដែលត្រូវចុះសំបុត្រមរណភាព[37] ម្យ៉ាងទៀតក៏ដោយសារតែវាមានទំនាក់ទំនងជិតស្និទ្ធខ្លាំងជាមួយនឹងមតកជន ដែលធ្វើឱ្យមាន

[34] *សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០១១), មាត្រា ៣។

[35] *សេចក្ដីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), មាត្រា ១១៤៦។

[36] ដដែល។

[37] ព្រុំ រិទ្ធី, *នីតិបេតិកភណ្ឌ និងគ្រួសារ* (ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, បោះពុម្ពលើកទី ១, ឆ្នាំ ២០១៩), ៨៥។

ភាពងាយស្រួលក្នុងការប្រមូលភស្តុតាងផ្សេងៗដែលត្រូវពិនិត្យ ដែលដើម្បីធានាឱ្យបានផងដែរនូវផលប្រយោជន៍សេដ្ឋកិច្ចទាក់ទងនឹងបណ្តឹង ការដោះស្រាយ និងការវិនិច្ឆ័យក្តី។[38]

**២. ករណីមតកជនមានទីលំនៅនៅបរទេស**

មាត្រា ១១៤៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ គ្រាន់តែបានបញ្ជាក់ថា សន្តតិកម្ម ត្រូវចាប់ផ្តើមនៅលំនៅឋានរបស់មតកជននៅពេលទទួលមរណភាព ដែលធ្វើឱ្យតុលាការនៅទីកន្លែងនោះជាតុលាការដែលមានសមត្ថកិច្ច។ ប៉ុន្តែ បញ្ហាអាចកើតមានឡើងនៅពេលដែលលំនៅឋានបច្ចុប្បន្នរបស់មតកជនមិនស្ថិតនៅលើដែនដីរបស់ប្រទេសកម្ពុជា។ បើទោះបីជាមិនមានប្បញ្ញត្តិណាមួយបានកំណត់ជាក់លាក់ពីករណីនេះក៏ដោយ គេក៏ឃើញមានសញ្ញាណខ្លះៗក្នុងក្រមនីតិវិធីរដ្ឋប្បវេណីដែលអាចយកមកពិចារណាបាន។ មាត្រា ៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ថា ចំពោះបណ្តឹងទាក់ទងនឹងមត៌ក គេអាចប្តឹងទៅតុលាការនៅលំនៅឋានរបស់មតកជននៅពេលសន្តតិកម្មត្រូវចាប់ផ្តើម ឬទីសំណាក់ បើមតកជនពុំមានលំនៅឋានក្នុងព្រះរាជាណាចក្រកម្ពុជា ឬមានលំនៅឋានមិនពិតប្រាកដ ឬលំនៅឋានចុងក្រោយ បើមតកជននោះពុំមានទីសំណាក់ ក្នុងព្រះរាជាណាចក្រកម្ពុជា ឬមានទីសំណាក់មិនពិតប្រាកដ។ ពិតណាស់ថា រឿងក្តីសន្តតិកម្ម ជារឿងក្តីដែលត្រូវគោរពតាមច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ត្បិតរឿងក្តីនេះមិនមានដើមចោទ និងចុងចម្លើយដូចរឿងក្តីរដ្ឋប្បវេណីធម្មតានោះឡើយ។ ហេតុនេះ មាត្រាខាងលើ គួរតែអនុវត្តចំពោះតែករណីដែលមានបណ្តឹងកើតឡើងក្នុងការធ្វើសន្តតិកម្មប៉ុណ្ណោះ។[39] ប៉ុន្តែ មាត្រាខាងលើហាក់បានបញ្ជាក់ដោយប្រយោលថា លំនៅឋានរបស់មតកជន ជាកន្លែងដែលសន្តតិកម្មត្រូវបានចាប់ផ្តើម ហើយក្នុងករណីដែលមិនមានលំនៅឋានក្នុងប្រទេសកម្ពុជា ទីកន្លែងចាប់ផ្តើមសន្តតិកម្មអាចប្តូរទៅជាទីសំណាក់ ឬលំនៅឋានចុងក្រោយរបស់សន្តតិជនវិញ។ ម្យ៉ាងទៀត ក្នុងមាត្រា ៤១ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានឆ្នាំ ២០០០ ក៏បានបញ្ជាក់ដែរថា ក្នុងករណីដែលពលរដ្ឋខ្មែរទទួលមរណភាពនៅបរទេស ពេលត្រលប់មកព្រះរាជាណាចក្រកម្ពុជាវិញ ត្រូវយកសំបុត្រមរណភាព ដែលធ្វើនៅបរទេសនោះទៅចុះសៀវភៅនៅ ឃុំ ឬសង្កាត់ ដែលសាមីខ្លួនអ្នកស្លាប់ធ្លាប់ស្នាក់នៅជាប់លាប់មុនចេញទៅបរទេស។[40] សាស្ត្រាចារ្យបណ្ឌិត ព្រុំ រិទ្ធី ក៏បានបញ្ជាក់នៅក្នុងសៀវភៅរបស់គាត់ដែរថា ការកំណត់យកលំនៅឋានចុងក្រោយរបស់មតកជនជាកន្លែងដែលសន្តតិកម្មចាប់ផ្តើម គឺដោយសារតែវាជាកន្លែងដែលសំបុត្រ

---

[38] ហ៊ី សោភា, *នីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច), ២៦។

[39] *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០១១), មាត្រា ៣។

[40] អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន, លេខ ១០៣ អនក្រ.បក, ២០០០, មាត្រា ៤១។

មរណភាពត្រូវបានចុះ។[41] ហេតុនេះ យើងអាចសន្និដ្ឋានបានថា ទីកន្លែងចុងក្រោយដែលមតកជនបានស្នាក់នៅជាប់លាប់នៅកម្ពុជា នឹងក្លាយជាកន្លែងដែលសន្តតិកម្មចាប់ផ្ដើម ក្នុងករណីដែលមតកជនទទួលមរណភាព ឬមានលំនៅនៅបរទេស។

ដូច្នេះ សន្តតិកម្មត្រូវបានចាប់ផ្ដើមនៅពេលដែលមានអត្ថិភាពនៃមរណភាព មិនថាវាជាការទទួលមរណភាពធម្មតា ឬជាការចាត់ទុកថាទទួលមរណភាពនោះទេ។ ចំណែកឯលំនៅឋានរបស់មតកជននៅពេលទទួលមរណភាព ក្នុងករណីមតកជនស្លាប់នៅប្រទេសកម្ពុជា ឬអាចជាលំនៅឋានចុងក្រោយដែលមតកជនធ្លាប់ស្នាក់នៅជាប់លាប់នៅកម្ពុជា ក្នុងករណីមតកជនទទួលមរណភាពនៅបរទេស។ ក្រោយពីការកំណត់ពីពេលវេលា និងទីកន្លែងដែលសន្តតិកម្មត្រូវចាប់ផ្ដើមហើយ ការយល់ដឹងថាតើជនណាខ្លះដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានសន្តតិកម្មក៏ជាការចាំបាច់ដែរ។

## ផ្នែកទី ៣ ៖ សញ្ញាណទូទៅនៃសន្តតិជន

សន្ទានុក្រមនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានឱ្យនិយមន័យ សន្តតិជន ថាជាជនដែលទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនតាមរយៈសន្តតិកម្ម។ ប៉ុន្តែ តើជនគ្រប់រូបសុទ្ធតែអាចទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចនេះ ឬយ៉ាងណា? ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ យើងមានភាពចាំបាច់ក្នុងការសិក្សាពីលក្ខណសម្បត្តិនៃសន្តតិជនដែលអាចទទួលមត៌ក (កថាខណ្ឌទី១)។ ប៉ុន្តែ ដោយហេតុថាបុគ្គលមួយចំនួនមិនសក្ដិសមនឹងទទួលមត៌ក យើងនឹងសិក្សាពីបញ្ហានេះនៅចំណុចបន្ទាប់ (កថាខណ្ឌទី២)។ ចំណែកករណីសន្តតិជនជាជនបរទេសវិញ យើងនឹងសិក្សាក្នុងចំណុចចុងក្រោយ (កថាខណ្ឌទី៣)។

### កថាខណ្ឌទី ១ ៖ លក្ខណសម្បត្តិនៃសន្តតិជន

ការសិក្សាពីលក្ខណសម្បត្តិនៃសន្តតិជន អាចធ្វើការបែងចែកជា ២ ករណី គឺករណីបុគ្គលដែលនៅមានជីវិត (១) និងករណីទារកនៅក្នុងគភ៌ (២)។

#### ១. ករណីបុគ្គលដែលមានជីវិតរស់នៅ

មាត្រា ១១៨៤ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីបានកំណត់ថា បុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ជាសន្តតិជន គឺមានតែបុគ្គលដែលមានជីវិតរស់នៅ លើកលែងតែបុគ្គលដែលបានថ្លោះសិទ្ធិជាសន្តតិជន[42] នាពេលចាប់ផ្ដើមសន្តតិកម្មប៉ុណ្ណោះទើបអាចទទួលមត៌កបាន។ ចំណុចនេះ បង្កប់លក្ខខណ្ឌមួយធំគឺ អត្ថិភាពនៃការរស់រានមានជីវិតនៅពេលសន្តតិកម្មចាប់ផ្ដើម។ គេអាចកំណត់ពីអត្ថិភាពនេះបានតាមលក្ខខណ្ឌចំនួនពីរ គឺ

[41] ព្រុំ រិទ្ធី, *នីតិបេតិកភណ្ឌ និងគ្រួសារ* (ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, បោះពុម្ពលើកទី ១, ឆ្នាំ ២០១៩), ៨៥។

[42] ជំពូកទី១ ផ្នែកទី៣ កថាខណ្ឌទី២ ស្ដីពី “បុគ្គលដែលថ្លោះសិទ្ធិជាសន្តតិជន” នៃសារណានេះ។

គ្មានអត្ថិភាពនៃការទទួលមរណភាព ឬចាត់ទុកថាទទួលមរណភាពពេលចាប់ផ្តើមសន្តតិកម្ម[43] និងមិនមានការចាត់ទុកថាជនដែលសន្មតថាជាសន្តតិជនបានទទួលមរណភាពព្រមគ្នាជាមួយមតកជន។[44]

ការសន្មតថាបានទទួលមរណភាពព្រមគ្នានេះ ត្រូវបានកំណត់ក្នុងមាត្រា ៤៥ នៃក្រមរដ្ឋប្បវេណី។ មាត្រានេះកំណត់ថា ក្នុងចំណោមបុគ្គលដែលបានទទួលមរណភាពច្រើននាក់ ប្រសិនបើមិនច្បាស់លាស់ថាមានបុគ្គលណាម្នាក់នៅរស់ ក្រោយពេលបុគ្គលផ្សេងទៀតបានទទួលមរណភាពទេ បុគ្គលទាំងអស់នោះ ត្រូវបានចាត់ទុកថាបានទទួលមរណភាពព្រមពេលជាមួយគ្នា។[45] ជាក់ស្តែង ក្នុងករណីដែលយន្តហោះធ្លាក់ ហើយឪពុក និងកូននោះបានទទួលមរណភាព ត្រូវចាត់ទុកថាទាំងឪពុក និងកូនបានទទួលមរណភាពព្រមគ្នា ក្នុងគោលបំណងសម្រួលការដោះស្រាយបញ្ហាសន្តតិកម្មឱ្យបានសមរម្យ ដោយហេតុថាការទទួលមរណភាពមុន ឬក្រោយគឺមានឥទ្ធិពលខ្លាំងដល់សន្តតិកម្ម។[46] បញ្ហាទី១ គឺទាក់ទងនឹងចំណែកមត៌ក។ តាមរយៈអត្ថន័យខាងលើ ប្រសិនបើឪពុកទទួលមរណភាពមុន នោះទ្រព្យសម្បត្តិនឹងត្រូវចែកឱ្យសហព័ទ្ធពាក់កណ្តាល និងកូនពាក់កណ្តាល។[47] ហើយនៅពេលដែលកូននោះស្លាប់បន្ទាប់ ម្តាយដែលជាសហព័ទ្ធខាងលើនេះ នឹងទទួលបានទ្រព្យសម្បត្តិទាំងអស់ពីកូនទៀត។[48] ហេតុនេះ ម្តាយរូបនេះនឹងទទួលបានទ្រព្យសម្បត្តិទាំងអស់របស់ប្តី។ ប៉ុន្តែ ក្នុងករណីដែលកូនទទួលមរណភាពមុនវិញ[49] ហើយឪពុកស្លាប់ក្រោយ នោះសហព័ទ្ធនឹងទទួលបានចំណែកមត៌កស្មើនឹងឪពុកម្តាយរបស់សហព័ទ្ធដែលជាប្តីដែរ[50]។ ហេតុនេះ ទាំងឪពុកម្តាយខាងប្តី និងសហព័ទ្ធជាប្រពន្ធនឹងទទួលបាន ១ ភាគ ៣ នៃទ្រព្យរបស់ប្តីដែលស្លាប់នោះ។ ដូច្នេះហើយ យើងអាចកំណត់បានថា ការស្លាប់មុន និងក្រោយនឹងមានឥទ្ធិពលលើចំណែកមត៌ក។ បញ្ហាទី២ គឺទាក់ទងជាមួយនឹងការកាន់កាប់ទ្រព្យសម្បត្តិមុន។ ជាក់ស្តែង ដោយដឹងថាការស្លាប់មុន ឬក្រោយមានឥទ្ធិពលដល់ចំណែកមត៌ក នោះភាគីតាមករណីខាងលើដែលមានទាំងសហព័ទ្ធ និងឪពុកម្តាយរបស់សហព័ទ្ធជាប្តី នឹងព្យាយាមដាក់ពាក្យស្នើសុំចែកមត៌កឱ្យបានមុន ដោយសហព័ទ្ធជាប្រពន្ធ អាចអះអាងថាសហព័ទ្ធជាប្តីទទួលមរណភាពមុន នោះសហព័ទ្ធជាប្រពន្ធនឹងទទួលបានទ្រព្យសម្បត្តិទាំងអស់ដូចបានបកស្រាយខាងលើ។ ចំណែកឯភាគីខាងឪពុកម្តាយរបស់សហព័ទ្ធជាប្តី នឹងព្យាយាមដាក់ពាក្យទៅតុលាការដោយអះអាងថាកូន(ចៅរបស់ខ្លួន)ជាអ្នកស្លាប់មុន ដើម្បីទទួលមត៌ក ១ ភាគ ៣

[43] កថាខណ្ឌទី១ ផ្នែកទី១ នៃជំពូកទី១ នៃសារណានេះ ចំពោះការកំណត់ពីអត្ថិភាពនៃមរណភាព និងការចាត់ទុកថាទទួលមរណភាព។

[44] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), មាត្រា ១១៨៩។

[45] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៤៥។

[46] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), មាត្រា ៤៥។

[47] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦២-១។

[48] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៥៩-១។

[49] សន្មតថាកូននោះមិនមានទ្រព្យនោះទេ ហេតុនេះក៏មិនមានសន្តតិកម្មកើតឡើងដែរ។

[50] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខនស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦២-២។

សម្រាប់ម្នាក់។ ហើយដោយហេតុថា ភាគីដែលបានដាក់ពាក្យមុន នឹងទទួលបានផលប្រយោជន៍ច្រើន ត្បិតភាគីដែលចង់បដិសេធ គឺត្រូវមានភស្តុតាងរឹងមាំដើម្បីបង្ហាញថាភាគីណាទទួលមរណភាពមុន ដែលជាបន្ទុកភស្តុតាងមួយដ៏ពិបាក។[51] ហេតុនេះ វានឹងបង្កជាបញ្ហា អ្នកធ្វើមុនជាអ្នកឈ្នះ។ ដើម្បីដោះស្រាយបញ្ហានេះ ក្រមរដ្ឋប្បវេណីបានធ្វើការកំណត់ជាមុនពីប្បញ្ញត្តិស្ដីពីការទទួលមរណភាពព្រមជាមួយគ្នា ដើម្បីដោះស្រាយបញ្ហានេះ។

ហេតុនេះ ជនដែលមិនទទួលមរណភាព មិនត្រូវបានចាត់ទុកថាទទួលមរណភាព និងជនដែលមិនត្រូវបានចាត់ទុកថាទទួលមរណភាពព្រមគ្នាជាមួយសន្តតិជន គឺសន្មតថាមានលក្ខណសម្បត្តិជាសន្តតិជនបាន លើកលែងតែមានប្បញ្ញត្តិផ្ទុយ។

**២. ករណីទារកនៅក្នុងគភ៌**

កថាខណ្ឌទី ២ នៃមាត្រា ១១៤៩ នៃក្រមរដ្ឋប្បវេណីបានកំណត់ថា ទារកដែលនៅក្នុងគភ៌ក៏មានលក្ខណសម្បត្តិជាសន្តតិជនដូចករណីបុគ្គលដែលនៅមានជីវិតខាងលើដែរ។ ប៉ុន្តែ បើយោងតាមមាត្រា ៨ ទារកក្នុងគភ៌ពុំមានសមត្ថភាពទទួលសិទ្ធិទេ ហេតុនេះយើងនឹងពិនិត្យពីបុព្វហេតុនៃការទទួលបានសិទ្ធិជាសន្តតិជន (ក) និងបញ្ហាផ្សេងៗដែលទាក់ទងនឹងអត្ថិភាពនៃកំណើត (ខ)។

**ក. បុព្វហេតុនៃការទទួលសិទ្ធិ**

ចំណុចទី១ គឺការទទួលបានលក្ខណសម្បត្តិជាសន្តតិជន។ មាត្រា ១១៤៩ បានចង្អុលទៅកាន់មាត្រា ៩ ត្រង់កថាខណ្ឌទី ២ និងទី ៣ នៃក្រមរដ្ឋប្បវេណី ទាក់ទងនឹងករណីទារកនៅក្នុងគភ៌។ កថាខណ្ឌទាំងពីរនេះបានបញ្ជាក់ថា ចំពោះទារកដែលនៅក្នុងគភ៌នាពេលដែលចាប់ផ្តើមសន្តតិកម្ម បើទារកនោះមានកំណើតនៅពេលក្រោយ អាចទទួលមត៌កដោយសន្តតិកម្មនោះបាន។ ម្យ៉ាងទៀត ទារកដែលនៅក្នុងគភ៌នៅពេលម្ចាស់បណ្ដាំទទួលមរណភាព បើទារកនោះមានកំណើតនៅពេលក្រោយ អាចទទួលអានុភាពនៃបណ្ដាំនោះបាន។ កថាខណ្ឌទាំងពីរនេះ ជាការឆ្លើយតបទៅនឹងភាពអយុត្តិធម៌នៅក្នុងមាត្រា ៨ នៃក្រមរដ្ឋប្បវេណី។ មាត្រា ៨ បានកំណត់ថា រូបវន្តបុគ្គលម្នាក់ៗ មានសមត្ថភាពទទួលសិទ្ធិនៅពេលចាប់កំណើត ហើយបាត់បង់អស់នូវសមត្ថភាពទទួលសិទ្ធិនេះ នៅពេលទទួលមរណភាព។ ដោយយោងទៅតាមការបកស្រាយនៃក្រមរដ្ឋប្បវេណីជប៉ុន អាចចាត់ទុកថាចាប់កំណើតបាន គឺនៅពេលដែលទារកទាំងមូលបានចេញផុតពីឧទរម្ដាយ ហើយមានជីវិត ឬ ដែលមានន័យថា ទារកក្នុងគភ៌ពុំមានសមត្ថភាពទទួលសិទ្ធិទេ។[52] ប៉ុន្តែ បើធ្វើការកំណត់ដាច់ខាតបែបនេះ វាហាក់បីដូចជាមានភាពអយុត្តិធម៌ពេកសម្រាប់ទារកនៅក្នុងគភ៌នោះ ដោយហេតុថាទារកនោះនៅក្នុងគភ៌ហើយ ហើយដឹងថាអាច

[51] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), មាត្រា ៤៥។

[52] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), មាត្រា ៨។

នឹងមានកំណើតនៅពេលក្រោយបន្តិច តែបែរជាមិនទទួលស្គាល់នូវសមត្ថភាពទទួលសិទ្ធិទៅវិញ។ ហេតុដូច្នេះហើយទើបមាត្រា ៩ ត្រង់កថាខណ្ឌទី ២ និងកថាខណ្ឌទី ៣ បានចែងពីករណីលើកលែងទាក់ទងនឹងសន្តតិកម្មនេះ ដើម្បីធ្វើឱ្យមានភាពយុត្តិធម៌។[53]

**ខ. អត្ថិភាពនៃកំណើត**

ចំណុចទី ២ គឺការកំណត់ពីការទទួលបានកំណើត។ ទោះបីជាកថាខណ្ឌទី ២ និងទី ៣ បានបញ្ជាក់ហើយក៏ដោយថា ទារកនៅក្នុងគភ៌ក៏មានលក្ខណសម្បត្តិជាសន្តតិជនក្តី ក៏កថាខណ្ឌទាំងពីរនេះ បានកំណត់ដែរថា សិទ្ធិនេះនឹងទទួលបាននៅពេលដែលទារកចាប់កំណើតប៉ុណ្ណោះ។ ហេតុនេះ ជាជាងហៅមាត្រា ៩ ថាជាប្បញ្ញត្តិដែលផ្តល់សមត្ថភាពទទួលសិទ្ធិដល់ទារកក្នុងគភ៌ គេគួរតែហៅវាថាជាការរក្សា ឬបម្រុងទុកនូវសិទ្ធិសម្រាប់ទារកដែលបានចាប់កំណើតប៉ុណ្ណោះ ដោយហេតុថា បើទារកនោះមិនចាប់កំណើតនៅពេលខាងមុខទេ ទារកក្នុងគភ៌នោះក៏មិនទទួលបានសិទ្ធិនេះដែរ។ នៅក្នុងស្ថានភាពនេះ វាបានលេចឡើងនូវបញ្ហាមួយទៀត គឺអត្ថិភាពនៃការចាប់កំណើត។ យើងអាចចោទជាសំនួរថា ប្រសិនបើទារកនោះ កើតបានមកបន្តិច ក៏ស្លាប់បាត់ទៅវិញ អាចចាត់ទុកថាជាការចាប់កំណើតឬទេ? ចំណុចនេះ មិនបានបញ្ជាក់នោះទេនៅក្នុងក្រមរដ្ឋប្បវេណី។ ប៉ុន្តែ យើងអាចពិចារណាតាមរយៈបទពិសោធន៍របស់នីតិខ្មែរ និងនីតិបារាំងបាន។ មាត្រា ៤៨៨ នៃក្រមរដ្ឋប្បវេណីចាស់កម្ពុជា ត្រង់កថាខណ្ឌទី ២ បានកំណត់ថា ទារកដែលនៅក្នុងគភ៌នៅឡើយ បើកើតក្នុងរវាង ៣០០ ថ្ងៃ គិតតាំងពីថ្ងៃដែលខ្មោចនោះស្លាប់មក ហើយរស់ អាចទទួលសន្តតិកម្មបាន។ ចំណែកឯក្រមរដ្ឋប្បវេណីបារាំងវិញ ត្រង់មាត្រា ៩០៦ បានកំណត់ថា ដើម្បីឱ្យមានសមត្ថភាពទទួលសន្តតិកម្មតាមមតកសាសន៍ ឱ្យតែបុគ្គលនៅក្នុងគភ៌ពេលដែលម្ចាស់បណ្តាំទទួលមរណភាព ជាការគ្រប់គ្រាន់ហើយ ប៉ុន្តែមតកសាសន៍នោះមានអានុភាព លុះត្រាតែកូននោះកើតឡើងដោយមានសមត្ថភាពរស់នៅ។ ទោះបីជាមានបទពិសោធន៍ទាំងពីរនេះក៏ដោយ ក៏ការបកស្រាយទៅលើចំណោទបញ្ហាខាងលើ ហាក់នៅតែមានភាពស្រពេចស្រពិល ដែលត្រូវពឹងលើយុត្តិសាស្ត្រតុលាការកម្ពុជានៅថ្ងៃអនាគតដើម្បីធ្វើការកំណត់។

ហេតុនេះ ទារកនៅក្នុងគភ៌ទទួលបានការរក្សាសិទ្ធិ ក្នុងការទទួលបានលក្ខណសម្បត្តិជាសន្តតិជន។ ទារកអាចទទួលបានសិទ្ធិនេះ នៅពេលដែលខ្លួនចាប់កំណើត ប៉ុន្តែរយៈពេលនៃការរស់រានមានជីវិតបន្ទាប់ពីការកើតចេញពីផ្ទៃម្តាយដែលត្រូវបានចាត់ទុកថាជាការចាប់កំណើតនៅតែមិនទាន់កំណត់បាននៅឡើយ។

[53] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), មាត្រា ៩។

### កថាខណ្ឌទី ២ ៖ បុគ្គលដែលថ្លោះសិទ្ធិជាសន្តតិជន

ទោះបីជាបុគ្គលមួយរូប បានបំពេញលក្ខខណ្ឌជាបុគ្គលដែលរស់រានមានជីវិតនៅពេលសន្តតិកម្មចាប់ផ្តើម ឬក៏ជាទារកនៅក្នុងគភ៌ដែលត្រូវបានច្បាប់រក្សាសិទ្ធិជូនក៏ដោយ ក្រមរដ្ឋប្បវេណីបានកំណត់បុគ្គលដែលថ្លោះសិទ្ធិជាសន្តតិជនជាពីរប្រភេទគឺ អភ័ព្វបុគ្គល (១) និងជនដែលផ្តាច់ចេញពីមត៌ក (២)។[54]

**១. អភ័ព្វបុគ្គល**

អភ័ព្វបុគ្គល ត្រូវបានសន្ទានុក្រមនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ឱ្យនិយមន័យថា ជាបុគ្គលដែលពុំអាចក្លាយជាសន្តតិជន ឬពុំអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បាន។ ការកំណត់ថាជនណាមួយថាជា អភ័ព្វបុគ្គល គឺជាការធ្វើអន្តរាគមមួយរបស់រដ្ឋទៅលើការអនុវត្តសន្តតិកម្ម ដោយមិនគិតពីឆន្ទៈរបស់មតកជននោះឡើយ ប៉ុន្តែគឺផ្អែកទាំងស្រុងទៅលើការរក្សាសណ្តាប់ធ្នាប់សង្គមទៅវិញ។[55] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានធ្វើការចែងទុកជាមុននូវអំពើដែលប្រព្រឹត្តឡើងដោយបុគ្គលមួយចំនួន ដែលមិនគួរទទួលបានសិទ្ធិជាសន្តតិជន ឬអច្ច័យលាភី។ យើងអាចធ្វើការបែងចែកអំពើនោះជាពីរក្រុម គឺអំពើដែលប៉ះពាល់សុវត្ថិភាពរបស់មតកជន (ក) និងអំពើដែលប៉ះពាល់ដល់អត្ថន័យនៃមតកសាសន៍ (ខ)។

**ក. អំពើដែលប៉ះពាល់ដល់សុវត្ថិភាពមតកជន**

ចំណុច *ក* និងចំណុច *ខ* នៃមាត្រា ១១៥០ បានកំណត់ពីជនដែលប្រព្រឹត្តអំពើដែលប៉ះពាល់ខ្លាំងដល់សុវត្ថិភាពរបស់មតកជនដែលមិនគួរទទួលបានសិទ្ធិជាសន្តតិជនដូចខាងក្រោម ៖

ទីមួយ គឺបុគ្គលដែលបានទទួលទោស ដោយមានចេតនាធ្វើឃាត ឬប៉ុនប៉ងធ្វើឃាតលើមតកជន ឬទៅលើជនដែលមានលំដាប់សន្តតិកម្មមុន ឬលំដាប់ស្មើគ្នា ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី។ អំពើមនុស្សឃាត និងប៉ុនប៉ងមនុស្សឃាតនេះ ជាអំពើមួយដ៏ធ្ងន់ធ្ងរដែលមិនត្រឹមតែប៉ះពាល់ខ្លាំងដល់សុវត្ថិភាពមតកជនប៉ុណ្ណោះទេ វាថែមទាំងអាចជះឥទ្ធិពលមិនល្អដល់សណ្តាប់ធ្នាប់សាធារណៈទៀតផង ដែលពិតជាសមហេតុផលក្នុងការដកហូតសិទ្ធិជាសន្តតិជនក្នុងករណីនេះ។[56] ក្រៅពីមតកជន ការប្រព្រឹត្តអំពើនេះលើសន្តតិជនដែលមានលំដាប់មុន ឬស្មើគ្នាក៏ដូចគ្នាដែរ ដោយហេតុថា ការធ្វើឃាតជនដែលមានលំដាប់សន្តតិកម្មខ្ពស់ជាងដោយជនដែលមិនត្រូវក្លាយជាសន្តតិជនសោះ ក្នុងគោលបំណងក្លាយជាមានលក្ខណសម្បត្តិជាសន្តតិជន ឬការធ្វើឃាតជនដែលបានសន្មតថាជាសន្តតិជនដែលមានលំដាប់សន្តតិកម្មដូចគ្នា ក្នុងគោលបំណងដល់ចំណែកមត៌ក ក៏ជា

[54] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៤៥។

[55] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), មាត្រា ១១៥០។

[56] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ១៩៩៖ *"អំពើសម្លាប់មនុស្សដោយចេតនា ដោយប្រើអាវុធ ឬមិនប្រើអាវុធ ដោយគ្មានស្ថានទម្ងន់ទោសណាមួយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ ឆ្នាំ ទៅ ១៥ ឆ្នាំ"*។

ទង្វើដែលផ្ទុយនឹងសណ្តាប់ធ្នាប់សង្គមយ៉ាងធ្ងន់ធ្ងរដែរ។[57] មួយវិញទៀត បើទោះបីជាអំពើខាងលើត្រូវបានធ្វើឡើងដោយផ្ទាល់ ឬដោយប្រយោលតាមរយៈការជួយ ឬសមគំនិតក្នុងការធ្វើឃាតក៏ដោយ ក៏មិនមានការលើកលែងដែរ។

ទីពីរ គឺបុគ្គលដែលដឹងពីការសម្លាប់មតកជន តែមិនបានរាយការណ៍ ឬមិនបានប្តឹង។ ប៉ុន្តែ ប្បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះមិនអាចវិនិច្ឆ័យអំពើល្អ ឬអាក្រក់បាន ឬករណីដែលអ្នកសម្លាប់ជាសហព័ទ្ធ ឬញាតិលោហិតខ្សែផ្ទាល់របស់បុគ្គលនោះ។ ថ្វីត្បិតតែបុគ្គលនោះមិនបានចូលរួមក្នុងការប្រព្រឹត្ត តែការមិនរាយការណ៍ពីបទឧក្រិដ្ឋ ដែលត្រូវបានប្រព្រឹត្តលើមកតជន ក៏ត្រូវបានចាត់ទុកថាជាអំពើធ្ងន់ធ្ងរមួយដែរ។ ចំណែកឯការការចែងកម្រិតត្រឹមមតកជននេះ ដោយមិនបានបញ្ចូលការសម្លាប់បុគ្គលផ្សេងទៀតដែលបានបញ្ជាក់ក្នុងចំណុចទី ១ គឺជាការទុកសិទ្ធិឱ្យមតកជនធ្វើការសម្រេចថាតើគួរតែផ្តាច់ជននោះចេញពីសន្តតិកម្មឬទេ។[58]

ហេតុនេះ ប្រសិនបើជនណាមួយប្រព្រឹត្តនូវអំពើខាងលើ ជននោះត្រូវចាត់ទុកជាអភ័ព្វបុគ្គល។

**ខ. អំពើដែលប៉ះពាល់ដល់អត្ថន័យមតកសាសន៍**

ចំណុច *គ ឃ* និង *ង* នៃមាត្រា ១១៥០ បានចាត់ទុកជនមួយចំនួនដែលប្រព្រឹត្តអំពើដែលប៉ះពាល់ធ្ងន់ធ្ងរដល់ខ្លឹមសារមតកសាសន៍ថាជាអភ័ព្វបុគ្គល។ ទីមួយ គឺបុគ្គលដែលបានរារាំងមតកជនក្នុងការធ្វើ លុបចោល ឬកែប្រែមតកសាសន៍ស្តីពីសន្តតិកម្ម ដោយឆបោក ឬគំរាមកំហែង។ ទីពីរ គឺបុគ្គលដែលបានឱ្យមតកជនធ្វើ លុបចោល ឬកែប្រែមតកសាសន៍ស្តីពីសន្តតិកម្មដោយការឆបោក ឬគំរាមកំហែង។ ចុងក្រោយ គឺបុគ្គលដែលបានក្លែង កែបន្លំ បំផ្លាញចោល ឬលាក់ទុកនូវលិខិតមតកសាសន៍ស្តីពីសន្តតិកម្មរបស់មតកជន។ អំពើខាងលើនេះអាចត្រូវបានចាត់ទុកថាជាអំពើមួយដែលផ្ទុយពីគោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់ដែលមានចែងនៅក្នុងមាត្រា ៥ នៃក្រមរដ្ឋប្បវេណីផងដែរ ត្បិតការធ្វើឱ្យប៉ះពាល់ដល់អត្ថន័យនៃមតកសាសន៍ គឺផ្ទុយនឹងឆន្ទៈរបស់មតកជនយ៉ាងខ្លាំង។ មាត្រានេះបានចែងថា ការប្រើសិទ្ធិ និងការអនុវត្តករណីយកិច្ច ត្រូវធ្វើឡើងដោយភាពស្មោះត្រង់។ ទោះបីជាគោលការណ៍នេះត្រូវបានប្រើជាទូទៅសម្រាប់ទំនាក់ទំនងរវាងសិទ្ធិលើបំណុល និងកាតព្វកិច្ចក៏ដោយ ក៏គោលការណ៍នេះអាចអនុវត្តបានចំពោះទំនាក់ទំនងផ្សេងទៀតបានដែរ ដែលសំដៅដល់ការប្រើប្រាស់សិទ្ធិដែលផ្ទុយនឹងសីលធម៌សង្គមជាដើម គឺមិនត្រូវបានទទួលស្គាល់ឡើយ។[59] ហេតុនេះ ជនដែលប្រព្រឹត្តអំពើខាងលើ គួរតែចាត់ទុកជាអភ័ព្វបុគ្គល។

---

[57] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), មាត្រា ១១៥០។

[58] ដដែល។

[59] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), មាត្រា ៥។

**២. ជនដែលផ្តាច់ចេញពីមត៌ក**

ផ្ទុយពីអភ័ព្វបុគ្គលដែលត្រូវបានច្បាប់ជាអ្នកកំណត់ទាំងស្រុង ជនដែលផ្តាច់ចេញពីមត៌ក គឺត្រូវតែមានការបង្ហាញឆន្ទៈរបស់មតកជន។ ហេតុនេះ មតកជនអាចធ្វើការដាក់ពាក្យសុំផ្តាច់មត៌កពីសន្តតិជន (ក) ហើយក៏អាចលុបចោលការផ្តាច់មត៌កនេះផងដែរ (ខ)។

**ក. ការផ្តាច់មត៌កពីសន្តតិជន**

ការផ្តាច់មត៌កពីសន្តតិជនអាចធ្វើបានដោយត្រូវគោរពលក្ខខណ្ឌមួយចំនួន (ចំណុចទី១) ហើយការផ្តាច់នេះក៏អាចធ្វើទៅបានតាមទម្រង់ផ្សេងគ្នាផងដែរ (ចំណុចទី២)។

**ចំណុចទី ១ ៖ លក្ខខណ្ឌនៃការផ្តាច់មត៌ក**

មាត្រា ១១៥១ នៃក្រមរដ្ឋប្បវេណីបានកំណត់ថា មតកជនកាលដែលនៅរស់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យផ្តាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ មិនឱ្យទទួលសន្តតិកម្មបាន បើជនដែលត្រូវបានសន្មតថាជាសន្តតិជនមានភាគបម្រុង បានប្រព្រឹត្តនូវសកម្មភាពដែលបានកំណត់មួយចំនួន។ ហេតុនេះ បើពិនិត្យទៅតាមអត្ថន័យនៃមាត្រានេះ ការផ្តាច់មត៌កពីសន្តតិជន ត្រូវឆ្លងកាត់លក្ខខណ្ឌចំនួនពីរគឺ ឆន្ទៈរបស់មតកជន និងការពិនិត្យរបស់តុលាការ។

លក្ខខណ្ឌទី ១ គឺឆន្ទៈរបស់មតកជន។ ច្បាប់បានកំណត់ទុកនូវអំពើមួយចំនួន ដែលអនុញ្ញាតឱ្យមតកជនផ្តាច់មត៌កចេញពីបុគ្គលដែលប្រព្រឹត្តអំពើនោះ។ អំពើទាំងនោះរួមមាន ការធ្វើបាបចំពោះមតកជន ការប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ ការដែលអាចមើលថែទាំមតកជននៅពេលដែលមានជំងឺ ប៉ុន្តែបែរជាមិនមើលថែទាំ ការដែលត្រូវទទួលសាលក្រម ឬសាលដីកាផ្តន្ទាទោសឱ្យជាប់ពន្ធនាគារមួយជីវិត[60] និងការប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរដែលគួរឱ្យកត់សម្គាល់ ជាអាទិ៍។[61]

លក្ខខណ្ឌទី ២ គឺការពិនិត្យរបស់តុលាការ។ ទោះបីជាមតកជនមានសិទ្ធិក្នុងការបង្ហាញឆន្ទៈផ្តាច់មត៌កក៏ដោយ ក៏ច្បាប់តម្រូវឱ្យមានការពិនិត្យពីតុលាការ ដើម្បីចៀសវាងភាពអយុត្តិធម៌ណាមួយដែលកើតចេញពីការសម្រេចរបស់មតកជន ដោយហេតុថាអំពើមួយចំនួនដែលកំណត់ក្នុងចំណុចខាងលើ តម្រូវឱ្យយកទស្សនៈនៃតម្លៃមកធ្វើជាមូលដ្ឋាន។[62] ជាក់ស្តែង ចំណុចស្តីពីការប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ និងការប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរគួរឱ្យកត់សម្គាល់ជាអាទិ៍ តម្រូវឱ្យតុលាការធ្វើការថ្លឹងថ្លែងអំពីទម្ងន់នៃអំពើទាំងនេះជាមុនសិន ដោយហេតុ

---

[60] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), មាត្រា ១១៥១ ៖ *"តាមពិតទៅក្រមរដ្ឋប្បវេណីចាស់បានចាត់ទុកថាជនដែលជាប់ពន្ធនាគារអស់មួយជីវិតជាអភ័ព្វបុគ្គល ប៉ុន្តែដោយពិចារណាថា ការដែលរក្សាសិទ្ធិជននេះត្រឹមជាបុគ្គលដែលអាចផ្តាច់ចេញពីមត៌កវិញ គឺមកពីអាចយកមកធ្វើជាសំណងការខាតជូនជនរងគ្រោះបាន"*។

[61] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៥១-១។

[62] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), មាត្រា ១១៥១។

ថាមានករណីច្រើនដែលមតកជនមានអាយុច្រើន ហើយសមត្ថភាពនៃការវិនិច្ឆ័យ ក៏ត្រូវចុះអន់ថយ ដែលធ្វើឱ្យមតកជនអាចខឹងខ្លាំងចំពោះកំហុសតូចតាចរបស់ជនដែលត្រូវបានសន្មតថាជាសន្តតិជនជាដើម។ ហេតុនេះ ការសម្រេចរបស់តុលាការជាការចាំបាច់មួយផងដែរ។

បើទោះបីជាតុលាការបានសម្រេចពីការផ្តាច់មត៌កនេះហើយក៏ដោយ ក៏ជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ អាចធ្វើវិវាទអំពីអត្ថិភាព ឬនត្ថិភាពនៃមូលហេតុនៃការផ្តាច់មត៌កនេះ នៅក្នុងការសម្រេចសេចក្តីនេះបានដោយយោងតាមមាត្រាដដែល។ តាមការជាក់ស្តែង ជននោះធ្វើជាវិវាទចំពោះអត្ថិភាព ឬនត្ថិភាពនៃមូលហេតុដែលមានចែងក្នុងចំណុច *ក ខ គ* និង *ឃ* និងវិវាទអំពីភាពសមស្រប ឬមិនសមស្របក្នុងការផ្តាច់មត៌កទោះជាសន្មតថាមានមូលហេតុនៃអំណះអំណាងរបស់មតកជនក៏ដោយ។

ហេតុនេះ បើទោះបីជាការយល់ព្រមរបស់មតកជនជាលក្ខខណ្ឌសំខាន់ ការពិនិត្យរបស់តុលាការក៏ជាលក្ខខណ្ឌមិនអាចខ្វះបានផងដែរ។

**ចំណុចទី ២ ៖ ទម្រង់នៃការផ្តាច់មត៌ក**

ការផ្តាច់មត៌កអាចធ្វើតាមទម្រង់ចំនួនពីរ គឺការធ្វើឡើងដោយបើកចំហ និងការធ្វើឡើងតាមរយៈមតកសាសន៍ ដូចបានកំណត់នៅក្នុងមាត្រា ១១៥១ នៃក្រមរដ្ឋប្បវេណី។ ការអនុញ្ញាតឱ្យ មតកជនបង្ហាញឆន្ទៈផ្តាច់មត៌កតាមមតកសាសន៍ គឺដោយហេតុថា ប្រសិនបើមតកជនពេលនៅរស់ធ្វើការផ្តាច់មត៌កដោយចំហនោះ ជនដែលត្រូវបានសន្មតថាជាសន្តតិជនបានដឹងពីការផ្តាច់មត៌កនោះ អាចបង្កគ្រោះថ្នាក់ដល់មតកជនតាមរយៈការធ្វើបាប ឬការបោះបង់ចោលមតកជនជាដើម។ ហេតុនេះ ការផ្តាច់តាមរយៈមតកសាសន៍ គឺធានាបាននូវសុវត្ថិភាពជាង។[63] ការផ្តាច់មត៌កតាមទម្រង់នេះ ត្រូវគោរពតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ១១៥២ នៃក្រមដដែល។ មាត្រានេះ ចែងថា បើមតកជនបានធ្វើមតកសាសន៍ដូចមានកំណត់នៅក្នុងមាត្រា ១១៥១ អ្នកប្រតិបត្តិមតកសាសន៍ ត្រូវដាក់ពាក្យសុំទៅតុលាការឱ្យផ្តាច់មត៌កពីសន្តតិជន ដោយគ្មានការយឺតយ៉ាវ នៅក្រោយពេលដែលមតកសាសន៍នោះបានបង្កើតអានុភាព។ ក្នុងករណីនេះ ការផ្តាច់មត៌កពីសន្តតិជននោះមានអានុភាពប្រតិសកម្ម ចាប់ពីពេលដែលមតកជននោះទទួលមរណភាព។ ប៉ុន្តែ បើករណីដែលការផ្តាច់មត៌កនេះមិនផ្លាស់ប្តូរលំដាប់សន្តតិជន ហើយបើសហសន្តតិជនបានដឹងពីការផ្តាច់មត៌ក ព្រមទាំងព្រមព្រៀងបែងចែកមត៌កនេះ នោះមិនចាំបាច់ប្តឹងទៅតុលាការទេ ហើយប្រសិនបើតុលាការធ្វើការទទួលស្គាល់ការផ្តាច់មត៌កក៏ដោយ ក៏គេនៅតែអាចចាត់ទុកថាជនដែលត្រូវផ្តាច់ចេញពីមត៌កនោះទទួលបានចំណែកមត៌កតាមប្រទានកម្មដែរ។[64]

---

[63] ដដែល។

[64] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), មាត្រា ១១៥២។

**ខ. ការលុបចោលការផ្តាច់មត៌កពីសន្តតិជន**

មាត្រា ១១៥៤ នៃក្រមដដែលបានកំណត់ថា មតកជន កាលនៅរស់ អាចដាក់ពាក្យសុំទៅតុលាការឱ្យលុបចោលនូវការផ្តាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជន នៅពេលណាក៏បាន ទោះការលុបចោលនេះ ស្ថិតក្នុងទម្រង់ណាក៏ដោយ។ ដូចបានបញ្ជាក់ខាងនៅចំណុចខាងលើ ការផ្តាច់មត៌កពីសន្តតិជន គឺយោងទៅតាមឆន្ទៈរបស់មតកជនជាសំខាន់ ហេតុនេះការសម្រេចចិត្តផ្តាច់មត៌ក ឬការលុបចោលមត៌ក គឺជាសិទ្ធិរបស់មតកជន។ បើទោះជាការលុបចោលនេះ តម្រូវឱ្យមានការដាក់ពាក្យទៅតុលាការក្តី ក៏តុលាការគ្រាន់តែធ្វើការពិនិត្យពីឆន្ទៈពិតប្រាកដរបស់មតកជនប៉ុណ្ណោះ ចំណែកឯអត្ថិភាព ឬនត្ថិភាពនៃមូលហេតុនៃការផ្តាច់មត៌ក គឺមិនតម្រូវឱ្យធ្វើការពិនិត្យឡើយ។[65] ចំពោះការលុបចោលការផ្តាច់មត៌កតាមទម្រង់មតកសាសន៍វិញ គឺមិនចាំបាច់ដាក់ពាក្យសុំទៅតុលាការទេ គឺគ្រាន់តែធ្វើតាមនីតិវិធីលុបចោលមតកសាសន៍ ដូចមានចែងក្នុងមាត្រា ១១៨៨ នៃក្រមនេះជាការគ្រប់គ្រាន់។

ជារួម បើទោះបីជាបុគ្គលមួយរូបជាជនដែលរស់រានមានជីវិតនៅពេលសន្តតិកម្មចាប់ផ្តើម ឬជាទារកនៅក្នុងគភ៌ដែលត្រូវបានរក្សាសិទ្ធិក្នុងការទទួលបានមត៌កក៏ដោយ ក៏បុគ្គលនេះមិនអាចទទួលបានសន្តតិកម្មដែរ ក្នុងករណីដែលបុគ្គលនោះបានថ្លោះសិទ្ធិក្នុងការទទួលសន្តតិកម្ម ដែលរួមមានអភ័ព្វបុគ្គល និងជនដែលផ្តាច់ចេញពីមត៌កជាដើម។ ប៉ុន្តែ ក្នុងករណីដែលបុគ្គលទាំងពីរប្រភេទនេះ បានកាន់កាប់មត៌ក តាមមាត្រា ១១៥៣ បុគ្គលនោះត្រូវបានចាត់ទុកថាជាអ្នកកាន់កាប់ដោយទុច្ចរិត ហើយត្រូវអនុវត្តតាមប្បញ្ញត្តិនៃមាត្រា ១៥៧ និង មាត្រា ១៥៨ នៃក្រមនេះ។[66]

**កថាខណ្ឌទី ៣ ៖ ករណីសន្តតិជនជាជនបរទេស**

ក្រមរដ្ឋប្បវេណីត្រង់មាត្រា ១១៥៥ បានបញ្ជាក់ថាសន្តតិជន ឬបុគ្គលដែលទទួលទ្រព្យសម្បត្តិតាមមតកសាសន៍ជាជនបរទេស មិនអាចធ្វើលទ្ធកម្មលើដីធ្លីតាមរយៈសន្តតិកម្មបានឡើយ។ ដើម្បីធ្វើការសិក្សាឱ្យបានលម្អិត យើងនឹងពិភាក្សាទៅលើបុព្វហេតុនៃការមិនអាចទទួលសិទ្ធិ (១) និងដំណោះស្រាយចំពោះបញ្ហានេះដែលផ្តល់ឱ្យដោយក្រមរដ្ឋប្បវេណី (២)។

**១. បុព្វហេតុនៃការមិនអាចទទួលបានសិទ្ធិលើដីធ្លី**

ដូចដែលបានបញ្ជាក់ខាងលើ សន្តតិជន ឬបុគ្គលដែលទទួលទ្រព្យសម្បត្តិតាមរយៈមតកសាសន៍ មិនមានសញ្ជាតិខ្មែរទេ ជននោះពុំអាចទទួលដីធ្លី តាមសន្តតិកម្ម ឬតាមអច្ច័យទានបានឡើយ។ ប្បញ្ញត្តិនេះ គឺជាការអន្តរាគមមួយ ដើម្បីសម្របរបបសន្តតិកម្មក្នុងក្រមរដ្ឋប្បវេណី ឱ្យស្របតាមគោលការណ៍ដែលបានកំណត់នៅ

[65] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), មាត្រា ១១៥៤។

[66] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), មាត្រា ១១៥៣។

ក្នុងរដ្ឋធម្មនុញ្ញរបស់កម្ពុជា។ មាត្រា ៤៤ កថាខណ្ឌទី ១ នៃរដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ថា មានតែរូបវន្តបុគ្គល និងនីតិបុគ្គលដែលមានសញ្ជាតិខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។ មាត្រា ៧ នៃក្រមរដ្ឋប្បវេណីផ្ទាល់ ក៏បានបញ្ជាក់ដែរថា ជនជាតិបរទេស មិនអាចទទួលបាន ឬកាន់កាប់នូវសិទ្ធិមួយចំនួនដែលត្រូវបានកំណត់ឡើយ ក្នុងករណីដែលមានប្បញ្ញត្តិផ្សេងនៅក្នុងច្បាប់ជាតិ ឬសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ដែលនៅចំណុចនេះ គឺទាក់ទងនឹងសិទ្ធិលើដីធ្លីនេះតែម្តង។ ហេតុនេះ ទោះក្នុងករណីណាក៏ដោយ បុគ្គលដែលមិនមានសញ្ជាតិខ្មែរ គឺមិនអាចធ្វើលទ្ធកម្មនៃកម្មសិទ្ធិលើដីធ្លីបាននោះទេ។

**២. ដំណោះស្រាយក្នុងក្រមរដ្ឋប្បវេណី**

នៅក្នុងជីវភាពរស់នៅ សន្តតិជន ឬមតកជនអាចមានសញ្ជាតិខុសគ្នា។ ជាក់ស្តែង អាចជាករណីសហព័ទ្ធជាជនបរទេស ឬកូនរបស់មតកជនជាជនបានចូលសញ្ជាតិបរទេសជាដើម។ ម្យ៉ាងទៀត ក៏អាចមានករណីដែលអច្ច័យលាភីបានចូលសញ្ជាតិបរទេស ក្រោយពីបានធ្វើមតកសាសន៍រួច ប៉ុន្តែមតកជនបានភ្លេចប្តូរមតកសាសន៍នោះ ដែលធ្វើឱ្យភាគីទាំងពីរមានសញ្ជាតិផ្សេងគ្នា។ ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ ក្រមរដ្ឋប្បវេណីត្រង់មាត្រា ១១៥៥ បានកំណត់នូវដំណោះស្រាយមួយចំនួន ដោយអាចចែកជា ២ ករណី។ ករណីទី ១ គឺប្រសិនបើមិនមែនសន្តតិជនទាំងអស់មានសញ្ជាតិបរទេសទេ នោះការបែងចែកគួរតែពិចារណាទៅចំណុចខាងលើ ដោយឱ្យសន្តតិជនដែលជាជនជាតិខ្មែរ អាចធ្វើលទ្ធកម្ម ឬចាត់ចែងលើដីធ្លីនោះបាន ចំណែកឯសន្តតិជនដែលជាជនបរទេសអាចធ្វើលទ្ធកម្ម លើទ្រព្យសម្បត្តិផ្សេងដែលមិនមែនជាដីធ្លីជាដើម។[67] ករណីទី ២ គឺប្រសិនបើសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ ពុំមានសញ្ជាតិជាខ្មែរទេ ដីធ្លីនៅក្នុងចំណោមមត៌កត្រូវក្លាយជានីតិបុគ្គល ហើយការគ្រប់គ្រង និងការចាត់ចែងដីធ្លីនោះ ត្រូវធ្វើឡើងដោយសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ។ តាមពិតទៅ សន្តតិជនទាំងនេះ ត្រូវប្តូរដីនេះជាប្រាក់ ប៉ុន្តែដោយពួកគេមិនមានសិទ្ធិលើដីនេះ ហេតុនេះតម្រូវឱ្យមានបុគ្គលណាមួយដើម្បីដើរតួនាទីជាម្ចាស់សិទ្ធិលើដីដើម្បីធ្វើការចាត់ចែង។ ហេតុនេះ ក្រមរដ្ឋប្បវេណីបាន ប្រែក្លាយដីនេះជានីតិបុគ្គលដែលមានកម្មសិទ្ធិលើដីធ្លី ហើយសន្តតិជនមានសិទ្ធិក្នុងការចាត់ចែង។ ប៉ុន្តែ ការដាក់ដីឱ្យស្ថិតក្រោមនីតិបុគ្គលដោយមិនមានពេលកំណត់ គឺមិនត្រឹមត្រូវទេ ហេតុនេះក្រមរដ្ឋប្បវេណីបានកំណត់រយៈពេល ៣ ខែ សម្រាប់ធ្វើការចាត់ចែង ដោយរាប់ពីពេលដែលសន្តតិជនទាំងអស់ដែលមានលំដាប់ខ្ពស់ជាងគេបានយល់ព្រមទាំងស្រុង ឬយល់ព្រមដោយកម្រិត។ ប្រសិនបើមិនធ្វើការចាត់ចែងតាមពេលកំណត់នេះទេ នោះសន្តតិជនដែលមានលំដាប់បន្ទាប់ត្រូវក្លាយជាសន្តតិជនវិញ ហើយត្រូវអនុវត្តតាមករណីខាងលើដដែលក្នុងករណីដែលគ្មានសន្តតិជនដែលមានសញ្ជាតិខ្មែរ។

[67] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), មាត្រា ១១៥៥។

ហេតុនេះ បើទោះបីជាសន្តតិជនជាអាទិ៍ មិនមានសញ្ជាតិខ្មែរមិនអាចទទួលបានសិទ្ធិលើដីធ្លីក៏ដោយ ក៏ក្រមនេះបានផ្តល់នូវដំណោះស្រាយដើម្បីការពារប្រយោជន៍របស់សន្តតិជននោះដែរ។

សរុបសេចក្តីមក បុគ្គលដែលរស់រានមានជីវិត រួមទាំងទារកដែលនៅក្នុងគភ៌ សុទ្ធតែអាចមានលក្ខណសម្បត្តិជាសន្តតិជនបាន លើកលែងតែបុគ្គលនោះជាអភ័ព្វបុគ្គល ឬជនដែលផ្តាច់ចេញពីមត៌ក។ ចំពោះករណីសន្តតិជនជាអាទិ៍ ជាជនបរទេសវិញ ការធ្វើលទ្ធកម្មលើសិទ្ធិលើដីធ្លីត្រូវបានហាមឃាត់ ប៉ុន្តែក្រមរដ្ឋប្បវេណីក៏បានផ្តល់នូវដំណោះស្រាយក្នុងការការពារសិទ្ធិនេះផងដែរ។

## ផ្នែកទី ៤៖ អានុភាពនៃសន្តតិកម្ម

ការសិក្សាទៅលើអានុភាពនៃសន្តតិកម្ម គឺអាស្រ័យទៅលើគោលការណ៍នៃសន្តតិកម្ម ដែលច្បាប់កម្ពុជាទទួលយក។ ហេតុនេះ ជាបឋម យើងគួរតែសិក្សាពីគោលការណ៍នៃសន្តតិកម្ម (កថាខណ្ឌទី ១) មុននឹងធ្វើការសិក្សាពីអានុភាពនៃសន្តតិកម្មទៅលើសន្តតិជន (កថាខណ្ឌទី ២)។

### កថាខណ្ឌទី ១៖ គោលការណ៍នៃសន្តតិកម្ម

ជាទូទៅ គោលការណ៍សន្តតិកម្ម ត្រូវបានបែងចែកជាពីរប្រភេទ គឺគោលការណ៍ជម្រះបញ្ជី (១) និងគោលការណ៍សន្តតិកម្មដោយស្វ័យប្រវត្តិ (២)។[68]

#### ១. គោលការណ៍ជម្រះបញ្ជី

ចំពោះគោលការណ៍ជម្រះបញ្ជី នៅពេលដែលសន្តតិកម្មបានចាប់ផ្តើមតាមរយៈការទទួលមរណភាពក្តី ឬការចាត់ទុកថាទទួលមរណភាពក្តី តុលាការត្រូវធ្វើការជ្រើសតាំងអ្នកគ្រប់គ្រងមត៌កដើម្បីធ្វើការជម្រះបញ្ជី។[69] គេត្រូវធ្វើការជម្រះបញ្ជីលើសិទ្ធិលើបំណុល និងកាតព្វកិច្ចទាំងអស់របស់មតកជន ហើយសន្តតិជននឹងស្នងទ្រព្យនោះក្នុងករណីដែលមានទ្រព្យសកម្មប៉ុណ្ណោះ ហើយក្នុងករណីដែលមានកាតព្វកិច្ចធ្ងន់ធ្ងរហួសហេតុ គេត្រូវប្រកាសធនក្ស័យនូវមត៌ក ដើម្បីកុំឱ្យសន្តតិជនទទួលបន្ទុកកាតព្វកិច្ចនោះ។[70] គុណសម្បត្តិនៃគោលការណ៍នេះគឺផ្តល់នូវសមភាពរវាងម្ចាស់បំណុលរបស់មតកជន និងសន្តតិជន។ ប៉ុន្តែ វាក៏ផ្តល់នូវគុណវិបត្តិដែរ ដូចជានីតិវិធីស្មុគស្មាញ អស់សោហ៊ុយ និងចំណាយពេលវេលាច្រើន។ ចំពោះស្ថានភាពប្រទេសកម្ពុជា ប្រជាជនធម្មតាគ្មានទ្រព្យសម្បត្តិច្រើនល្មមដើម្បីធ្វើការជម្រះទេ ហើយចំពោះប្រជាជនដែលមានទ្រព្យសម្បត្តិច្រើន ក៏អាចប្រើមតកសាសន៍ដើម្បីធ្វើជានីតិវិធីទូទាត់ដែរដើម្បីសងបំណុលជាក់លាក់ណាមួយ។ ហេតុនេះ គោលការណ៍ជម្រះបញ្ជី ហាក់មិនសក្តិសមសម្រាប់ស្ថានភាពរបស់កម្ពុជានោះទេ។

[68] អនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រម, *ក្រមរដ្ឋប្បវេណី ភាគ ៦* (ភ្នំពេញ៖ បោះពុម្ពដោយ JICA និង ICD, ២០១២), ២៦។
[69] ដដែល។
[70] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៦* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), ១។

**២. គោលការណ៍សន្តតិកម្មដោយស្វ័យប្រវត្តិ**

គោលកាណ៍សន្តតិកម្មដោយស្វ័យប្រវត្តិ គឺជាគោលការណ៍ដែលសន្តតិជនត្រូវទទួលទាំងស្រុងនូវសិទ្ធិ និងករណីយកិច្ចទាំងអស់របស់មតកជន ដែលមានន័យថា សន្តតិជនត្រូវទទួលបន្តនូវឋានៈរបស់មតកជនតែម្តង លើកលែងតែក្នុងករណីសហសន្តតិជន ដែលត្រូវធ្វើការបែងចែក។[71] ប៉ុន្តែ ដោយសារតែសន្តតិជន ត្រូវទទួលបន្តនូវឋានៈរបស់មតកជនបែបនេះ ក្នុងករណីដែលមតកជនបានបន្សល់ទុកនូវកាតព្វកិច្ចច្រើនពេក ហើយសន្តតិជនទទួលបន្តនូវកាតព្វកិច្ចនោះទាំងអស់ សន្តតិកម្មនេះនឹងធ្វើឱ្យសន្តតិជនទទួលការខូចខាតយ៉ាងធ្ងន់ធ្ងរ។ ហេតុនេះហើយ ទើបគេបង្កើតឱ្យមានរបបបោះបង់នូវសន្តតិកម្ម ឬការយល់ព្រមដោយមានកម្រិតដើម្បីចៀសវាងបញ្ហានេះ។ ទោះជាយ៉ាងណាក៏ដោយ គោលការណ៍សន្តតិកម្មដោយស្វ័យប្រវត្តិនេះ គឺមានភាពងាយស្រួល ទាំងទៅលើប្បញ្ញត្តិច្បាប់ និងនីតិវិធី។ ហើយក្រមរដ្ឋប្បវេណីនៃប្រព័ន្ធស៊ីវិលឡ និងក្រមរដ្ឋប្បវេណីជប៉ុនជាដើម ក៏បានយកគោលការណ៍នេះមកធ្វើជាមូលដ្ឋាន។ ហេតុនេះ គោលការណ៍នេះ គឺមានភាពសក្តិសមសម្រាប់កម្ពុជា ជាងគោលការណ៍ជម្រះបញ្ជី។

**កថាខណ្ឌទី ២ ៖ អានុភាពនៃសន្តតិកម្មលើសន្តតិជន**

ផលគតិយុត្តនៃសន្តតិកម្ម គឺមានសភាពខុសគ្នារវាងករណីសន្តតិកម្មមានសន្តតិជនតែម្នាក់ (១) និងសន្តតិកម្មមានសន្តតិជនច្រើននាក់ (២)។ ប៉ុន្តែ ក្រមរដ្ឋប្បវេណីក៏បានបន្ថែមនូវករណីពិសេសមួយផងដែរ (៣)។

**១. ករណីសន្តតិជនតែម្នាក់**

មាត្រា ១១៤៧ នៃក្រមរដ្ឋប្បវេណី ត្រង់កថាខណ្ឌទី ១ បានកំណត់ថា សន្តតិជនត្រូវទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចទាំងអស់ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន ចាប់តាំងពីពេលដែលចាប់ផ្តើមសន្តតិកម្ម លើកលែងតែចំពោះសិទ្ធិ និងកាតព្វកិច្ចផ្តាច់មុខទាំងស្រុងរបស់មតកជន។ មាត្រានេះ បង្កប់នូវចំណុចសំខាន់ៗយ៉ាងតិចចំនួន ៣។

ចំណុចទី១ គឺការប្រកាន់យកគោលការណ៍សន្តតិកម្មដោយស្វ័យប្រវត្តិនៃក្រមរដ្ឋប្បវេណីនេះដោយផ្អែកទៅតាមនិយមន័យដែលបានបញ្ជាក់ក្នុងចំណុចខាងលើ។[72] ចំណុចទី២ គឺ ការធ្វើលទ្ធកម្មនូវកម្មសិទ្ធិដោយស្វ័យប្រវត្តិ ដោយមិនតម្រូវឱ្យមានការចុះបញ្ជីជាលក្ខខណ្ឌ។ មាត្រាខាងលើ បានបញ្ជាក់ថា សន្តតិជនត្រូវទទួលទាំងសិទ្ធិ និងកាតព្វកិច្ចចាប់តាំងពីសន្តតិកម្មបានចាប់ផ្តើម ដែលមានន័យថាសន្តតិជនបានធ្វើលទ្ធកម្មនៃកម្មសិទ្ធិលើមត៌កនោះបានតែម្តង ដែលរាប់ទាំងទៅលើអចលនវត្ថុផងដែរ ដោយមិនចាំបាច់ធ្វើការចុះបញ្ជីអំពីការដែលបានធ្វើសន្តតិកម្មឡើយ។ ការដែលមិនតម្រូវឱ្យមានការចុះបញ្ជីជាលក្ខខណ្ឌទទួលបន្តសន្តតិកម្មបែបនេះ

[71] ដដែល។

[72] ចំណុចលេខ ២ "គោលការណ៍សន្តតិកម្មដោយស្វ័យប្រវត្តិ" នៃកថាខណ្ឌទី១ ផ្នែកទី៤ នៃជំពូកទី១ នៃសារណានេះ។

គឺដើម្បីការពារមិនឱ្យមានអំឡុងពេលមុនសន្តតិជនធ្វើការចុះបញ្ជី ដែលធ្វើឱ្យម្ចាស់កម្មសិទ្ធិលើអចលនវត្ថុមិនមានអត្ថិភាព ហើយដែលធ្វើឱ្យទ្រព្យនោះក្លាយទៅជារបស់រដ្ឋ។[73] ចំណុចទី៣ គឺការលើកលែងចំពោះសិទ្ធិ និងកាតព្វកិច្ចផ្តាច់មុខរបស់មតកជន។ សិទ្ធិប្រភេទនេះ អាចសំដៅទៅលើសិទ្ធិក្រៅបេតិកភណ្ឌ ដែលជាសិទ្ធិដែលមិនទាក់ទងនឹងទ្រព្យសម្បត្តិហើយមិនអាចលក់ដូរបាន។ សិទ្ធិប្រភេទនេះអាចមានពីរយ៉ាងគឺ សិទ្ធិឯកជនក្រៅបេតិកភណ្ឌដែលរួមមានសិទ្ធិគ្រួសារ និងសិទ្ធិបុគ្គលភាព និងសិទ្ធិក្រៅបេតិកភណ្ឌសាធារណៈដែលរួមមានសិទ្ធិនយោបាយជាដើម។[74]

ហេតុនេះ ក្នុងករណីមានសន្តតិជនតែម្នាក់ សន្តតិជននោះត្រូវទទួលបន្តនូវឋានៈរបស់មតកជនទាំងស្រុង លើកលែងតែសិទ្ធិក្រៅបេតិកភណ្ឌរបស់មតកជនប៉ុណ្ណោះ។

**២. ករណីមានសន្តតិជនច្រើននាក់**

មាត្រា ១១៤៨ បានកំណត់ពីការទទួលសិទ្ធិលើទ្រព្យសម្បត្តិ ក្នុងករណីដែលមានសន្តតិជនច្រើននាក់។ មាត្រានេះចែងថា ប្រសិនបើមានសន្តតិជនច្រើននាក់ សហសន្តតិជនម្នាក់ៗ ត្រូវទទួលបន្តនូវសិទ្ធិ និងករណីយកិច្ច តាមសមាមាត្រនៃចំណែកមត៌កនោះ។ ប៉ុន្តែ ចំពោះសិទ្ធិ ឬករណីយកិច្ចដែលមិនអាចចែកបានតាមលក្ខណៈនៃសិទ្ធិ ឬករណីយកិច្ចនោះ ត្រូវទទួលបន្តដោយអវិភាគីយ៍[75]។ មត៌កនេះ នឹងត្រូវស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សហសន្តតិជន។ មាត្រានេះ បានបង្កប់នូវករណីចំនួនពីរ។

ចំណុចទី ១ ក្នុងករណីដែលមានសន្តតិជនច្រើននាក់ ហើយមត៌កអាចបែងចែកបាន សហសន្តតិជនត្រូវបែងចែកមត៌កទៅតាមចំណែកដែលខ្លួនត្រូវស្នង។ ហេតុនេះ ប្រសិនបើមតកជនមានសិទ្ធិលើបំណុល ហើយបំណុលនោះជាប្រាក់ហើយដែលអាចបែងចែកបាន នោះសិទ្ធិលើបំណុលនោះត្រូវបែងចែកទៅឱ្យសហសន្តតិជនតាមសមាមាត្រដែលច្បាប់កំណត់។ ករណីនេះ ក៏អនុវត្តដូចគ្នាចំពោះការបែងចែកកាតព្វកិច្ចរបស់មតកជនក្នុងករណីមិនមានការបោះបង់សន្តតិកម្ម។[76]

ចំណុចទី ២ គឺករណីដែលមត៌កមិនអាចធ្វើការបែងចែកបាន។ ក្នុងករណីនេះ មត៌កត្រូវចាត់ទុកថាជាកម្មសិទ្ធិអវិភាគរបស់សហសន្តតិជន។ ហេតុនេះ ប្រសិនបើចំណែកមត៌កទាំងស្រុង ឬមួយផ្នែកមិនអាចបែងចែកបានទេ តតិយជនអាចធ្វើកិច្ចការជំនួញ ឬធ្វើការរឹបអូស ដោយផ្អែកទៅលើការដែលសន្តតិជននីមួយៗមានចំណែកកម្មសិទ្ធិតាមចំណែកមត៌កដែលច្បាប់បានកំណត់។ ហេតុនេះ សន្តតិជននៅតែអាចប្រើសិទ្ធិ ជាម្ចាស់

---

[73] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), មាត្រា ១១៤៧។

[74] ហាប់ ផល្លី, *នីតិរដ្ឋប្បវេណី* (ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច), ១៩-២២។

[75] គណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, *សន្ទានុក្រមផ្នែករដ្ឋប្បវេណី* (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧), ២៨៖ *"អវិភាគីយ៍ មានន័យថា ដែលមិនអាចបំបែកបាន"*។

[76] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), មាត្រា ១១៤៨។

កម្មសិទ្ធិអវិភាគដែលទទួលបានតាមរយៈសន្តតិកម្ម ដោយមិនចាំបាច់រង់ចាំរហូតដល់មានការយល់ព្រមក្នុងការបែងចែកកម្មសិទ្ធិអវិភាគនោះរួចរាល់នោះទេ។[77]

ហេតុនេះ ប្រសិនបើអាចបែងចែកបាន សហសន្តតិជនអាចបែងចែកតាមចំណែកដែលច្បាប់បានកំណត់ ចំណែកឯផ្នែកដែលមិនអាចបែងចែកបាន គឺត្រូវដាក់ឱ្យស្ថិតក្រោមកម្មសិទ្ធិអវិភាគ។

**៣. ករណីពិសេស**

មាត្រា ១១៤៧ ត្រង់កថាខណ្ឌទី ២ បានចែងនូវករណីពិសេសមួយទាក់ទងនឹងអានុភាពនៃសន្តតិកម្មចំពោះសិទ្ធិលើវត្ថុសម្រាប់ជំនឿសាសនា និងចេតិយ ឬចលនវត្ថុដែលជារតនសម្បត្តិគ្រួសារនៃសន្តតិជន។ មាត្រានេះ បានផ្តល់នូវលំដាប់នៃការចាត់ចែងជាបីថ្នាក់។

លំដាប់ទី១ គឺសម្រេចដោយផ្អែកលើឆន្ទៈរបស់សន្តតិជន។ ជាក់ស្តែង មាត្រានេះបានកំណត់ថា បើមានជនដែលត្រូវទទួលបន្តកម្មសិទ្ធិទាំងនោះ ដូចជាជនដែលត្រូវដឹកនាំពិធីបុណ្យនៃបុព្វជន ដោយយោងតាមការកំណត់របស់មតកជន ជននោះត្រូវទទួលបន្ត។ នៅក្នុងករណីខ្លះ វត្ថុទាំងនេះមិនត្រូវបានធ្វើសន្តតិកម្មដោយសន្តតិជនតាមច្បាប់ឡើយ ពោលគឺត្រូវបានទទួលដោយជនដទៃទៀត ឬសហសន្តតិជនណាមួយដោយមិនស្ថិតក្រោមកម្មសិទ្ធិអវិភាគឡើយ។[78] លំដាប់ទី២ គឺត្រូវសម្រេចដោយផ្អែកលើទំនៀមទម្លាប់។ មាត្រាខាងលើបានបញ្ជាក់ថា បើមតកជនពុំបានកំណត់ទេ ជនដែលត្រូវដឹកនាំពិធីបុណ្យនៃបុព្វជន ត្រូវទទួលបន្តនូវសិទ្ធិទាំងនោះដោយយោងតាមទំនៀមទម្លាប់។ លំដាប់ទី៣ គឺ ការសម្រេចដោយផ្អែកលើតុលាការ។ មាត្រាដដែលកំណត់ថា ប្រសិនបើទំនៀមទម្លាប់មិនច្បាស់លាស់ទេ តុលាការត្រូវកំណត់ជនដែលត្រូវទទួលបន្តនោះ។ ហេតុនេះ តុលាការត្រូវបានផ្តល់សិទ្ធិឱ្យសម្រេចតែក្នុងជម្រើសចុងក្រោយប៉ុណ្ណោះ។

ដូច្នេះ ការចាត់ចែងនូវកម្មវត្ថុនៃសន្តតិកម្មក្នុងករណីពិសេសនេះ គឺត្រូវផ្តល់អាទិភាពទៅតាមលំដាប់ដោយរាប់ពីឆន្ទៈរបស់មតកជន ទំនៀមទម្លាប់ និងចុងក្រោយគឺតុលាការ។

[77] ដដែល។

[78] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), មាត្រា ១១៤៧។

# ជំពូកទី ២

# ប្រភេទនៃសន្ធិកម្ម

# ជំពូកទី ២
# ប្រភេទនៃសន្តតិកម្ម

ដូចដែលបានបកស្រាយរួចមកហើយ នៅក្នុងផ្នែកខាងលើ យើងដឹងហើយថាក្រមរដ្ឋប្បវេណីកម្ពុជា ជាធរមាននេះ បានប្រកាន់យកនូវគោលការណ៍នៃការទទួលបន្តសន្តតិកម្មដោយស្វ័យប្រវត្តិ ពោលគឺ សន្តតិជននឹងត្រូវទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ចទាំងអស់របស់មតកជននៅពេលដែលចាប់ផ្តើមសន្តតិកម្ម[79]។ ហើយមួយវិញទៀត នៅបន្ទាប់ពីបានដឹងហើយថា តើបុគ្គលដែលមានលក្ខណសម្បត្តិបែបណា អាចក្លាយទៅជាសន្តតិជននោះ ហើយជាបន្តទៅទៀតនេះ យើងនឹងធ្វើការសិក្សាអំពីប្រភេទផ្សេងៗនៃសន្តតិកម្ម ថាតើការផ្ទេរនូវសិទ្ធិ និង ករណីយកិច្ចរបស់មតកជនទៅឱ្យសន្តតិជនរបស់ខ្លួនអាចស្ថិតក្រោមរូបភាពបែបណាខ្លះ។ យោងទៅតាមប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា សន្តតិកម្មអាចត្រូវបានបែងចែកជាពីរប្រភេទធំៗ ពោលគឺ សន្តតិកម្មតាមច្បាប់ និង សន្តតិកម្មមានបណ្តាំ[80]។ នៅទីនេះ យើងអាចនិយាយបានថា ប្រសិនបើអ្នកស្លាប់ទៅមិនបានបន្សល់ទុកនូវបណ្តាំនោះទេ ពេលនោះប្បញ្ញត្តិដែលទាក់ទងទៅនឹងសន្តតិកម្ម(សន្តតិកម្មតាមច្បាប់) នឹងត្រូវបានអនុវត្ត។ ក៏ប៉ុន្តែ ផ្ទុយមកវិញ ប្រសិនបើមតកជនបានបន្សល់ទុកនូវលិខិតបណ្តាំ ដូច្នេះ សន្តតិកម្មរបស់គាត់នឹងប្រព្រឹត្តទៅតាមខ្លឹមសារនៃបណ្តាំ ហើយនៅក្នុងករណីនេះ ក៏មិនមែនមានន័យថា សន្តតិកម្មតាមច្បាប់លែងយកអនុវត្តទេ វាក៏នឹងអនុវត្តទន្ទឹមគ្នាផងដែរ ដែលថា នៅពេលណាមានការខ្វះចន្លោះចំពោះខ្លឹមសារនៃមតកសាសន៍ ពេលនោះទិដ្ឋភាពច្បាប់នឹងចូលទៅបំពេញបន្ថែម និងមួយវិញទៀត លិខិតបណ្តាំរបស់មតកជននោះទៀតសោត ក៏ត្រូវតែគោរពតាមបទប្បញ្ញត្តិមួយចំនួននៃច្បាប់។ ការដែលមានចែងផ្ទុយពីការណែនាំរបស់ច្បាប់ នឹងធ្វើឱ្យបណ្តាំរបស់គាត់មិនអាចអនុវត្តបានទេ។ ជារួមមកវិញ តាមរយៈប្រព័ន្ធ ឬ របបនៃសន្តតិកម្មនៅក្នុងច្បាប់របស់កម្ពុជាយើង គឺគេធ្វើការគោរពទៅនឹងឆន្ទៈរបស់ខ្មោច(មតកជន) ជាមុន មុនពេលដែលយកច្បាប់ទៅអនុវត្ត។ ហើយនៅក្នុងជំពូកទី ២ ស្តីអំពីប្រភេទនៃសន្តតិកម្មនេះ យើងនឹងធ្វើការបកស្រាយដោយចាប់ផ្តើមពីសន្តតិកម្មតាមច្បាប់ (ផ្នែកទី ១) និង សន្តតិកម្មតាមមតកសាសន៍ (ផ្នែកទី ២)។

## ផ្នែកទី ១ ៖ សន្តតិកម្មតាមច្បាប់

នៅក្នុងខណៈពេលដែលមិនមានការបង្ហាញឆន្ទៈចុងក្រោយ នៅពេលដែលម្ចាស់ទ្រព្យនៅមានជីវិតតាមរយៈមតកសាសន៍ទេ ការចាត់ចែងទ្រព្យរបស់គាត់ ទៅឱ្យទាយាទបន្តនឹងត្រូវប្រព្រឹត្តទៅតាមច្បាប់។ ហើយដើម្បីយល់កាន់តែច្បាស់អំពី ថាតើរបបនៃសន្តតិកម្មតាមច្បាប់ គេធ្វើការផ្ទេរនូវសិទ្ធិ និង ករណីយកិច្ចរបស់មតក

[79] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៤៧។
[80] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៤៥-២។

ជនទៅបុគ្គលណាខ្លះ និងមាននីតិវិធីនៃការបែងចែក ក៏ដូចជា ការធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើមត៌កដែលបន្សល់ទុកនោះយ៉ាងដូចម្តេច យើងនឹងធ្វើការសិក្សាជាបន្តបន្ទាប់។

**កថាខណ្ឌទី ១ ៖ បុគ្គលដែលអាចទទួលសន្តតិកម្ម**

ជាទូទៅ នៅក្នុងការពិភាក្សាទាក់ទងទៅនឹងបញ្ហានៃសន្តតិកម្ម ទោះបីជា ប្រភេទនៃសន្តតិកម្មតាមច្បាប់ក្តី សន្តតិកម្មតាមមតកសាសន៍ក្តី ទំនាក់ទំនងរវាងញាតិ ទៅនឹងទ្រព្យសម្បត្តិរបស់មតកជន គឺជាបញ្ហាសំខាន់មួយដែលគេតែងតែលើកយកមកពិភាក្សាមុនគេ។ ពាក្យថា « ញាតិ » ដោយយោងតាមវចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ ជួន ណាត បានឱ្យនិយមន័យថា ជាអ្នកដែលរួមខ្សែលោហិតនឹងគ្នា ទាំងខាងម្តាយ ឬ ខាងឪពុក។ ហើយមិនតែប៉ុណ្ណោះ បើយើងពិនិត្យមើលទៅលើប្បញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីចាស់ គេធ្វើការបែងចែកញាតិជាពីរ គឺញាតិជួរខ្សែផ្ទាល់ និង សាខាញាតិ[81]។ ទោះបីជាយ៉ាងណាក៏ដោយ ការពិភាក្សាពាក់ព័ន្ធទៅលើអត្ថន័យនៃពាក្យថា « ញាតិ » ដោយយោងទៅលើក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានឱ្យនិយមន័យដោយកំណត់ទៅលើទំហំញាតិ ថាបុគ្គលដែលកំណត់ថាជាញាតិ មានដូចជាញាតិលោហិតក្នុង ៦(ប្រាំមួយ) ថ្នាក់ ញាតិពន្ធក្នុង ៣(បី) ថ្នាក់ និង សហព័ទ្ធ[82]។ លើសពីនេះទៅទៀត ចំណុចដែលយើងអាចដឹងបានតាមរយៈការពិភាក្សានៅក្នុងចំណុចខាងលើៗ ពាក់ព័ន្ធទៅនឹងប្រវត្តិនៃរបបសន្តតិកម្មនៅកម្ពុជា ជាពិសេសពាក់ព័ន្ធទៅនឹងរឿងព្រេងនានា យើងឃើញថា ជាទូទៅ ទ្រព្យសម្បត្តិរបស់មតកជន គឺត្រូវបានផ្ទេរទៅឱ្យទាយាទរបស់គាត់ដែលអ្នកស្នងនោះហើយភាគច្រើន គឺជាញាតិរបស់អ្នកស្លាប់នោះតែម្តង។ ជារួមមកវិញ យើងឃើញថា ញាតិគឺមានសារសំខាន់ណាស់នៅក្នុងទំនាក់ទំនងនៃសន្តតិកម្ម។

**១. ការគណនាថ្នាក់ញាតិ**

មុននឹងឈានចូលដល់ការគណនាថ្នាក់ញាតិ យើងគួរតែយល់ពីអ្វីទៅគឺជា ថ្នាក់ញាតិ ជាមុនសិន។ ថ្នាក់ញាតិ អាចត្រូវបានគេឱ្យនិយមន័យ ថាជាឯកតាឬរង្វាស់រង្វាល់នៅក្នុងការបង្ហាញអំពីរូបភាពនៃទំនាក់ទំនងញាតិ។ ហើយមួយវិញទៀត ប្រសិនបើចង់ដឹងថា អ្នកណាមួយមានទំនាក់ទំនងកាន់តែជិត នោះគេអាចពិចារណាបានតាមរយៈលេខលំដាប់នៃថ្នាក់ញាតិ ពោលគឺប្រសិនបើលេខលំដាប់ថ្នាក់ញាតិ កាន់តែតូច នោះគេអាចនិយាយបានថា ទំនាក់ទំនងញាតិ កាន់តែមានភាពជិតផងដែរ។ ហើយនៅទីនេះផងដែរ ការគណនាថ្នាក់នៃសាខាញាតិ និង ថ្នាក់នៃញាតិលោហិតខ្សែផ្ទាល់ គឺមានការគណនាខុសគ្នា។

**ក. ការគណនាថ្នាក់នៃញាតិលោហិតខ្សែផ្ទាល់**

[81] ប៉ួយ ធីតា និង កង ស៊ីផាន់ណារ៉ា, « នីតិរដ្ឋប្បវេណី », ២០១៨, ១១៥។

[82] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៣៩។

នៅក្នុងការរកឱ្យឃើញលេខលំដាប់ថ្នាក់ញាតិខ្សែផ្ទាល់ គឺមានលក្ខណៈងាយស្រួល ដោយគេធ្វើការពិនិត្យមើលទៅលើចំនួនតំណពូជរវាងញាតិដែលរាប់តាមរយៈអក្សបញ្ឈរ ឬ អាចនិយាយបានថា ជាការរាប់ទំនាក់ទំនងពីលើចុះក្រោម ឬ ពីក្រោមឡើងទៅលើវិញ។ នៅទីនេះ យើងអាចឱ្យឧទាហរណ៍បានថា ឪពុក និង កូន គឺជាញាតិថ្នាក់ទី ១ ហើយ ជីដូនជីតា និង ចៅ គឺជាញាតិថ្នាក់ទី ២។

### ខ. ការគណនាថ្នាក់នៃសាខាញាតិលោហិត

ចំពោះនិយមន័យនៃពាក្យថា « សាខា » អាចត្រូវបានគេយល់ថា ជាការបែកខ្នែងចេញពីប្រភពដើមតែមួយ។ នៅទីនេះ ពាក់ព័ន្ធទៅនឹងសាខាញាតិ គេអាចយល់បានថា ជាទំនាក់ទំនងដែលបែកចេញជាពីបុព្វញាតិ ឬ ពីបុព្វជនរួមតែមួយ ហើយចំពោះការគណនាថ្នាក់ញាតិនៃសាខាញាតិនេះ គឺគេគិតចាប់ពីជននោះ ឬ សហព័ទ្ធរបស់ជននោះឡើងទៅដល់បុព្វជនដូចគ្នា និង ចំនួននៃតំណពូជគិតចាប់ពីបុព្វជននោះ ចុះរហូតដល់ជនម្នាក់ទៀត ដើម្បីធ្វើការរកអំពីទំនាក់ទំនងនោះ។ ជាឧទាហរណ៍ យើងឃើញថារវាងពូមីងនិងក្មួយ គឺស្ថិតនៅក្នុងញាតិថ្នាក់ទី ៣ នៃសាខាញាតិលោហិត។ រីឯកូនរបស់ពូមីងទៅនឹង ក្មួយរបស់ពូមីងនោះ ឬ អាចនិយាយបានម្យ៉ាងទៀតថា ជាបងប្អូនជីដូនមួយ គឺស្ថិតនៅក្នុងថ្នាក់ទី ៤ នៃសាខាញាតិលោហិត[83]។

ហើយមួយវិញទៀត ក្រៅតែអំពីញាតិដែលកើតឡើងពីកំណើត ពោលគឺជាអ្នកដែលមានឈាមជ័ររួមតែមួយ ញាតិលោហិតក្នុង ៦(ប្រាំមួយ) ថ្នាក់ ក៏ដូចជាញាតិដែលអាចកើតឡើងតាមរយៈអាពាហ៍ពិពាហ៍ ដែលក្នុងនោះរួមមាន ញាតិជាសហព័ទ្ធ និង ញាតិពន្ធក្នុង ៣(បី) ថ្នាក់ តាមប្បញ្ញត្តិនៃច្បាប់ជាធរមាន យើងឃើញថា ញាតិក៏អាចកើតឡើងតាមរយៈរូបភាពមួយផ្សេងទៀតផងដែរ គឺតាមរយៈការសុំកូន ឬ ទំនាក់ទំនងញាតិភាពដែលកើតឡើងតាមរយៈការកំណត់នៃច្បាប់។ កូនសុំ ដោយមិនគិតពីប្រភេទ ថាតើវាជាការសុំកូនពេញលេញ ឬសុំកូនធម្មតា កូននោះនឹងមានឋានៈ ឬ ទំនាក់ទំនងញាតិភាព ដូចជាកូនបង្កើតផងដែរជាមួយនឹងឪពុកម្តាយចិញ្ចឹម[84]។ ហើយចំណុចដែលគួរឱ្យកត់សម្គាល់មួយទៀតផងដែរនោះ គឺថាទំនាក់ទំនងញាតិភាពដែលកើតឡើងរវាងកូនសុំ និងឪពុកម្តាយចិញ្ចឹម គឺមានលក្ខណៈដាច់ខាត គឺ តែត្រឹមជាទំនាក់ទំនងរវាងភាគីទាំងពីរនេះប៉ុណ្ណោះ ពោលគឺ ទំនាក់ទំនងញាតិភាពរវាងញាតិលោហិតរបស់កូនសុំ ជាមួយនឹងឪពុកម្តាយចិញ្ចឹម ឬក៏រវាងញាតិលោហិតរបស់កូនសុំទៅនឹងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹម គឺមិនត្រូវបានបង្កើតឡើងទេ។ ហើយមួយវិញទៀត នៅក្នុងករណីសុំកូនពេញលេញ ទំនាក់ទំនងរវាងកូនសុំ ទៅនឹងញាតិរបស់កូនសុំដែលមានមុនសុំកូន ត្រូវ

---

[83] ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី (ភាគ ៥ : គន្ថីទី ៧)* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០), មាត្រា ៩៣៩។

[84] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៤០។

រលត់។ ហើយចំណែកឯនៅក្នុងករណីសុំកូនធម្មតាវិញ ទំនាក់ទំនងញាតិភាពរវាងកូនសុំ និងឪពុកម្ដាយបង្កើត ក៏ដូចជាញាតិរបស់កូនសុំនោះ មិនត្រូវបានរលត់ទេ[85]។

ជារួមមកវិញ យើងឃើញថាបុគ្គលដែលអាចត្រូវបានសន្មតទៅតាមច្បាប់ថាជាញាតិ រួមមានញាតិលោហិតក្នុង ៦(ប្រាំមួយ) ថ្នាក់ សហព័ទ្ធ ក៏ដូចជាញាតិពន្ធ(សាច់ថ្លៃ)ក្នុង ៣(បី) ថ្នាក់ ហើយវិធីនៃការគណនាថ្នាក់ញាតិ ដើម្បីស្វែងរកទំនាក់ទំនង គឺត្រូវបានកំណត់តាមរយៈការគណនានៃចំនួនតំណពូជ។ ជាបន្តទៅទៀតនេះ យើងនឹងធ្វើការសិក្សាទៅលើសញ្ញាណនៃញាតិ ដែលជាពិសេសពាក់ព័ន្ធទៅនឹងបុគ្គលដែលនឹងក្លាយជាសន្តតិជន ហើយនឹងមកទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ចរបស់មតកជនតាមរយៈសន្តតិកម្មតាមច្បាប់។

## ២. សន្តតិជន

ដូចដែលបានបកស្រាយរួចមកហើយ នៅក្នុងផ្នែកទី ៤ នៃជំពូកទី ១ ពាក់ព័ន្ធទៅនឹងភាពគ្រប់លក្ខណៈជាសន្តតិជន ហើយមួយវិញទៀត ក៏បានពិភាក្សារួចហើយផងដែរ ពាក់ព័ន្ធទៅនឹងសញ្ញាណនៃអ្នកអាចមានទំនាក់ទំនងទៅនឹងមតកជន សន្តតិជនដែលមានភាពគ្រប់លក្ខណៈដូចបានបកស្រាយខាងលើ គឺត្រូវតែតម្រូវឱ្យចូលទៅក្នុងចំណុចណាមួយដែលមានចែងដូចតទៅ ជាពិសេសពាក់ព័ន្ធទៅនឹងប្បញ្ញត្តិស្ដីអំពីសន្តតិកម្មតាមច្បាប់នេះតែម្ដង ទើបបុគ្គលនោះអាចនឹងត្រូវក្លាយជាទាយាទ ឬ សន្តតិជន មកទទួលស្នងបន្តមត៌ករបស់មតកជននោះបាន។ នៅក្នុងច្បាប់ យើងឃើញថាមានការបែងចែកសន្តតិជនទៅជា ៣ លំដាប់ គឺសន្តតិជនលំដាប់ទី ១ សន្តតិជនលំដាប់ទី២ និង សន្តតិជនលំដាប់ទី ៣ ហើយក៏មានផងដែរសញ្ញាណនៃសន្តតិជនជានិច្ច (សន្តតិកម្មរបស់សហព័ទ្ធ) ហើយនៅក្នុងលំដាប់នីមួយៗ ក៏អាចមានផងដែរអ្វីដែលហៅថា សន្តតិជនជំនួស លើកលែងតែនៅក្នុងលំដាប់ទី២ ដែលមិនមានសន្តតិជនជំនួសទេ។

### ក. សន្តតិជនលំដាប់ទី ១ សន្តតិជនជំនួស និង សន្តតិជនជានិច្ច

នៅក្នុងករណីដែលម្ចាស់ទ្រព្យបានទទួលមរណភាព សន្តតិកម្ម គឺត្រូវបានចាប់ផ្ដើម ហើយអ្នកដែលត្រូវបានគេពិចារណាមុនគេ ជុំវិញបញ្ហានៃសន្តតិកម្មតាមច្បាប់ គឺសន្តតិជនលំដាប់ទី ១ នេះឯង។ សន្តតិជនលំដាប់ទី ១ គឺគេសំដៅទៅលើកូនរបស់មតកជន ហើយពាក្យថា « កូន » នៅទីនេះ មិនមែនសំដៅទៅតែកូនបង្កើតប៉ុណ្ណោះទេ វាក៏សំដៅផងដែរ កូនសុំ របស់មតកជន។ នៅទីនេះ គេមិនបានធ្វើការបែងចែករវាងកូននោះជាកូនសុំពេញលេញឬជាសុំធម្មតាអ្វីទេ ឱ្យតែជាកូនសុំគាត់នឹងទទួលបានឋានៈស្មើនឹងកូនបង្កើតរបស់មតកជន ហើយផងដែរ គាត់ក៏ទទួលបានចំណែកនៃសន្តតិកម្មស្មើទៅនឹងសន្តតិជនលំដាប់ទី ១ ដែលជាកូនបង្កើតផងដែរនោះ។

---

[85] ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី, *សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី (ភាគ ៥ : គន្ថីទី ៧)* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០), មាត្រា ៩៥០។

ដោយឡែក បើនិយាយចំពោះទំនាក់ទំនងរវាងកូនសុំនោះទៅនឹងឪពុកម្តាយបង្កើតរបស់គាត់វិញ យើងឃើញថា បើសិនជាកូនសុំនោះស្ថិតក្នុងរបបនៃសុំកូនពេញលេញ អ្វីដែលគាត់អាចទទួលបាន គឺតែអំពីឪពុកម្តាយចិញ្ចឹមតែប៉ុណ្ណោះ ដោយហេតុថាញាតិភាពតាមផ្លូវច្បាប់ជាមួយនឹងឪពុកម្តាយបង្កើតនៃកូននោះ គឺត្រូវបានរលត់ទៅហើយ។ ក៏ប៉ុន្តែ ប្រសិនបើនៅទីនេះគឺជា របបនៃសុំកូនធម្មតាវិញ កូនសុំនោះអាចទទួលបានញាតិភាពទាំងជាមួយឪពុកម្តាយបង្កើតរបស់គាត់ ក៏ដូចជាជាមួយនឹងពីឪពុកម្តាយចិញ្ចឹមរបស់កូនសុំនោះផងដែរ។ ហើយមួយវិញទៀត ចំពោះកូនរបស់មតកជន ដែលជាកូនក្រៅអាពាហ៍ពិពាហ៍ ឬ ដែលហៅថាអនីតិសង្វាស ក៏ត្រូវមានចំណែកស្មើគ្នាផងដែរ ដោយធៀបទៅនឹងកូនក្នុងចំណងអាពាហ៍ពិពាហ៍ស្របច្បាប់[86]។

<u>សន្តតិកម្មជំនួស</u>

នៅក្នុងវាលវដ្តសង្សារនេះ មនុស្សម្នាក់ៗមិនមែនសុទ្ធតែអាចបំពេញបាននូវភាពដែលថា កើត ចាស់ ឈឺ ស្លាប់ បានទាំងអស់នោះទេ។ ហើយក៏មិនមែនបានន័យថា មនុស្សដែលមានអាយុច្រើន គឺត្រូវតែស្លាប់មុនមនុស្សដែលមានអាយុតិចនោះដែរ។ ហើយមួយវិញទៀត ក៏យើងនិយាយផងដែរពាក់ព័ន្ធទៅនឹងទង្វើដែលជាសកម្មភាពរបស់មនុស្ស ជាពិសេសនោះ គឺសន្តតិជនតែម្តង ដែលអាចនាំឱ្យមានផលប៉ះពាល់ទៅដល់ជីវភាពរស់នៅរបស់មតកជន នៅពេលដែលគាត់នៅរស់ ជាដើម ដែលវាអាចនាំឱ្យគាត់ក្លាយជាបុគ្គលថ្លោះសិទ្ធិដូចបានបកស្រាយនៅក្នុងជំពូកទី ១ ហើយដែលនៅទីនេះ ច្បាប់បានប្បញ្ញត្តិថា បុគ្គលនោះមិនអាចត្រូវបានក្លាយជាសន្តតិជន មកទទួលស្នងមត៌កបានទេ។ ហើយមួយវិញទៀត វាអាចនឹងហាក់ដូចជាមិនសមហេតុផលនោះទេ ប្រសិនបើឱ្យចំណែក ដែលអាចនឹងត្រូវប្រគល់ទៅឱ្យសន្តតិជនដែលទទួលមរណភាព មុន ឬ ស្របពេលជាមួយគ្នានឹងមតកជន ឬ សន្តតិជនដែលបានក្លាយជាបុគ្គលដែលថ្លោះសិទ្ធិជាសន្តតិជន តាមរយៈប្បញ្ញត្តិស្តីអំពីអភ័ព្វបុគ្គល និង ជនដែលត្រូវបានផ្តាច់ពីមត៌ក បាត់បង់ទទេៗនោះ។ ដូច្នេះហើយ នៅទីនេះប្បញ្ញត្តិស្តីអំពីសន្តតិកម្មជំនួស គឺត្រូវបានបង្កើតឡើងក្នុងគោលបំណង និង វត្ថុបំណងនេះ។

ជារួមមកវិញ នៅក្នុងករណីដែលកូនរបស់មតកជនបានទទួលមរណភាព នៅមុន ឬ ព្រមពេលនឹងពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិដែលត្រូវទៅនឹងលក្ខខណ្ឌដែលមានចែងពាក់ព័ន្ធទៅនឹងអភ័ព្វបុគ្គល ឬ បុគ្គលដែលត្រូវបានកាត់ផ្តាច់ពីមត៌ក កូនរបស់បុគ្គលនោះនឹងត្រូវក្លាយជាសន្តតិជនជំនួស។ ឬនិយាយឱ្យសាមញ្ញជាងនេះទៀត យើងអាចនិយាយបានថាចៅរបស់មតកជន នឹងមកទទួលស្នងនូវចំណែកមត៌ករបស់បុព្វជនរបស់ខ្លួននោះ ហើយដែលបុព្វជនរបស់ខ្លួននោះដំបូងឡើយ ត្រូវបានសន្មតថាជាសន្តតិជននៃមតកជន។

[86] ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី (ភាគ ៦ : គន្ថីទី ៨)* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០), មាត្រា ១១៥៦។

ហើយពាក់ព័ន្ធទៅនឹងទំនាក់ទំនងសន្តតិជនជំនួសនេះផងដែរ ក៏មានបន្តិចឱ្យឃើញផងដែរ នូវសញ្ញាណដែលស្តីអំពីសន្តតិជនជំនួស ដែលជាកូនស្មុំ។ នៅក្នុងប្បញ្ញត្តិនៃមាត្រា ១១៥៧ ថ្មី កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី បានប្បញ្ញត្តិពាក់ព័ន្ធទៅនឹងបញ្ហានេះថា *ប្បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះបុគ្គលដែលមិនមែនជាបច្ចាញាតិផ្ទាល់របស់មតកជន*។ នៅទីនេះ យើងអាចទាញបានជាពីរករណី គឺករណីដែលមតកជនសុំជនដែលមានកូន តាមរយៈស្មុំកូនធម្មតា និងក្នុងករណីដែលមតកជនបានសុំជនដែលមិនមានកូន តាមរយៈស្មុំកូនធម្មតាដូចគ្នា។ ក្នុងករណីទី១ កូនរបស់កូនស្មុំមិនអាចក្លាយទៅជាសន្តតិជនជំនួសបានទេ។ ដោយយោងតាមប្បញ្ញត្តិនៃមាត្រា ១០២៦ និង ១០២៧ យើងឃើញថា ក្រោយពេលប្រតិបត្តិការស្មុំកូន ញាតិភាពនឹងកើតឡើងរវាងកូនស្មុំនោះ និង ឪពុកម្តាយចិញ្ចឹម ហើយកូនស្មុំនោះនឹងជាញាតិរបស់ឪពុកម្តាយចិញ្ចឹមផងដែរ។ ហើយនៅក្នុងករណីនេះបើកូនស្មុំនោះមានកូន ដូច្នេះហើយកូនរបស់កូនស្មុំដែលមានមុនទំនាក់ទំនងញាតិភាពនោះ មិនអាចទទួលស្គាល់បានទេថា ជាញាតិជាមួយនឹងឪពុកម្តាយចិញ្ចឹមរបស់បុព្វជនរបស់ខ្លួន ហើយដែលនឹងអាចក្លាយទៅជាសន្តតិជនជនោះបានឡើយ។ ក៏ប៉ុន្តែ ប្រសិនបើតាមរយៈការស្មុំកូនធម្មតានោះ យើងឃើញថាកូនរបស់កូនស្មុំនោះ បានកើតនៅក្រោយពេលការស្មុំទៅវិញឬអាចនិយាយបានថាទំនាក់ទំនងញាតិភាពរវាងកូនចិញ្ចឹមនោះនិងឪពុកម្តាយចិញ្ចឹមបានកើតមានរួចហើយ ដូច្នេះសន្តតិកម្មជំនួសអាចប្រព្រឹត្តទៅបានបើយោងទៅតាមប្បញ្ញត្តិនេះ[87]។ គួររំឭកផងដែរថា ពាក់ព័ន្ធទៅនឹងប្បញ្ញត្តិដែលស្តីអំពីការស្មុំកូនដូចដែលមានចែងនៅក្នុងមាត្រា ១០០៧ និង បន្តបន្ទាប់ ដែលនិយាយអំពីស្មុំកូនពេញលេញ និងពីមាត្រា ១០២០ និងបន្តបន្ទាប់ ដែលនិយាយអំពីស្មុំកូនធម្មតា គេអាចកំណត់លក្ខខណ្ឌបានថា ស្មុំកូនពេញលេញ គឺគេធ្វើឡើងចំពោះក្មេងដែលមានអាយុមិនលើសពី ៨(ប្រាំបី) ឆ្នាំ ហើយដើម្បីបង្កើតជាញាតិលោហិតនឹងឪពុកម្តាយចិញ្ចឹម ហើយបានកាត់ផ្តាច់ញាតិភាពជាមួយនឹងឪពុកម្តាយបង្កើតរបស់ក្មេងនោះ។ ដោយឡែក ចំពោះស្មុំកូនធម្មតា គឺគេធ្វើឡើងចំពោះក្មេងដែលមិនកំណត់អាយុ ប៉ុន្តែឪពុក ឬ ម្តាយចិញ្ចឹមត្រូវមានអាយុមិនតិចជាង ២៥ ឆ្នាំ និងឪពុកឬម្តាយចិញ្ចឹមនោះ ក៏មិនត្រូវជាបច្ចាញាតិ ឬមានអាយុតិចជាងកូនចិញ្ចឹមឡើយ[88]។ ហើយអត្ថិភាពនៃទំនាក់ទំនងញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើតនៅតែបន្ត ព្រមគ្នាជាមួយនឹងអត្ថិភាពនៃទំនាក់ទំនងញាតិរវាងកូនសុំនោះ និង ឪពុកម្តាយចិញ្ចឹម។ ភ្ជាប់ជាមួយទៅនឹងប្បញ្ញត្តិស្តីអំពីសន្តតិកម្មជំនួសខាងលើ យើងឃើញថា ផ្អែកទៅលើលក្ខណៈជីវសាស្ត្រ និងបញ្ហាផ្សេងៗទៀត គឺមិនសមហេតុផលឡើយចំពោះកូនសុំតាមរយៈប្បញ្ញត្តិស្តីពីស្មុំកូនពេញលេញដែលអាចមានកូន មុនការបង្កើតទំនាក់ទំនងញាតិភាពនោះ ទទួល

[87] ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី (ភាគ ៦ : គន្ថីទី ៨)* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០), មាត្រា ១១៥៧ ថ្មី។

[88] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១០២០។

សន្តតិកម្មជំនួសបាននោះ។ ហើយជាទូទៅ ការអនុវត្តសុំកូនពេញលេញ គេតែងតែធ្វើយ៉ាងណាឱ្យក្មេងនោះមានអាយុកាន់តែតិចតាមដែលអាចធ្វើទៅបាន បើទោះបីជាគេកំណត់មិនឱ្យលើសពី ៨ ឆ្នាំ ជាគោលការណ៍ក៏ដោយ ការធ្វើបែបនេះ អាចនឹងមានគោលដៅឱ្យឪពុកម្តាយចិញ្ចឹមនោះ គឺអាចធ្វើខ្លួនឱ្យដូចជាឪពុកម្តាយបង្កើតរបស់កូនសុំអញ្ចឹង។ ជារួមមកវិញ ពាក់ព័ន្ធទៅនឹងករណីនៃសន្តតិកម្មជំនួស គឺគេអាចធ្វើទៅបាន តែក្នុងករណីមួយប៉ុណ្ណោះ គឺកូនរបស់កូនសុំធម្មតានោះ បានកើតក្រោយការសុំកូន ហើយដែលគេត្រូវសន្មតថាជាបច្ឆាញាតិផ្ទាល់របស់មតកជន ទៅតាមច្បាប់ និងដែលអាចទទួលសន្តតិកម្មជំនួសបាន។

នៅក្នុងប្បញ្ញត្តិនៃមាត្រា ១១៥៧ ថ្មី ដដែលនោះ នៅក្នុងកថាខណ្ឌទី ២ ក៏បានគិតគូរផងដែរ ទៅលើស្ថានភាពមួយចំនួនទៀត ដែលអាចកើតមានឡើងទៅលើបុគ្គលដែលជាសន្តតិជនជំនួស ពោលគឺ មូលហេតុដែលនាំឱ្យកើតមាននូវរបបសន្តតិកម្មជំនួស ដែលនៅទីនេះច្បាប់បានអនុញ្ញាតឱ្យមាននូវ របបសន្តតិកម្មជំនួសដែលត្រូវអនុវត្តជាបន្តបន្ទាប់ ដែលមានន័យថា កូនរបស់សន្តតិជនជំនួស ឬ ចៅរបស់សន្តតិជនជំនួស អាចនឹងក្លាយជាសន្តតិជនជំនួសជាបន្តបន្ទាប់គ្នា ក្នុងមូលហេតុណាមួយដែលធ្វើឱ្យសន្តតិជនជំនួសមិនអាចទទួលជំនួសដូចបានរៀបរាប់ខាងលើ។ គួរបញ្ជាក់ផងដែរថា សន្តតិកម្មជំនួសដែលអនុវត្តជាបន្តបន្ទាប់នេះ គឺអនុវត្តតែចំពោះសន្តតិជនដែលជាកូនរបស់មតកជនប៉ុណ្ណោះ។ ដោយឡែក ចំពោះបងប្អូនបង្កើតរបស់មតកជន គេទទួលស្គាល់របបសន្តតិកម្មជំនួសនេះ តែមួយតំណប៉ុណ្ណោះ[៨៩]។

<u>សន្តតិជនជានិច្ច</u>

ដូចមានប្បញ្ញត្តិនៅក្នុងមាត្រា ១១៦១ នៃក្រមរដ្ឋប្បវេណី ដែលស្តីអំពីសន្តតិកម្មរបស់សហព័ទ្ធ ច្បាប់បានទទួលស្គាល់ សហព័ទ្ធរបស់មតកជន គឺជាសន្តតិជនជានិច្ច ហើយពាក្យថា « សន្តតិជនជានិច្ច » នេះមានន័យថា សហព័ទ្ធរបស់មតកជននឹងត្រូវប្រជែងនូវគ្រប់លំដាប់នៃសន្តតិជន ប្រសិនបើមាន ហើយបើទោះបីជាគ្មានសន្តតិជនផ្សេងទៀតទេ ក៏ដោយ ក៏សហព័ទ្ធនៅតែជាសន្តតិជនជាដរាប។ នៅក្នុងករណីនេះ ប្រសិនបើគេរកឃើញថា មានសន្តតិជនលំដាប់ទី ១ (ដែលជាកូនរបស់មតកជន) និងមានផងដែរសហព័ទ្ធរបស់មតកជន សហព័ទ្ធនោះ នឹងត្រូវមានលំដាប់ស្មើគ្នានឹងសន្តតិជនលំដាប់ទី ១ នោះ។ បើទោះបីជាគេកំណត់ថា សហព័ទ្ធត្រូវបានក្លាយជាសន្តតិជនជានិច្ចរបស់មតកជន ដែលនឹងត្រូវទទួលស្នងបន្ត ប្រជែងទៅនឹងលំដាប់នៃសន្តតិជនផ្សេងៗទៀតក៏ដោយ ក៏ប៉ុន្តែ ប្រសិនបើសហព័ទ្ធនោះត្រូវបានគេរកឃើញថា បានបំពេញលក្ខខណ្ឌដែលត្រូវបានកំណត់

[៨៩] ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី (ភាគ ៦ : គន្ថីទី ៨)* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០), មាត្រា ១១៥៧ ថ្មី។

ថាជាអភ័ព្វបុគ្គល ឬ ជាបុគ្គលដែលត្រូវបានផ្ដាច់ពីមត៌ក សហព័ទ្ធរបស់មតកជននោះ ក៏មិនអាចទទួលសន្តតិកម្មបានដែរ[90]។

**ខ. សន្តតិជនលំដាប់ទី ២ សន្តតិជនជំនួស និង សន្តតិជនជានិច្ច**

នៅក្នុងករណីដែលពុំមានសន្តតិជនលំដាប់ទី ១ ទេ ឬ អាចនិយាយបានម្យ៉ាងទៀតថា មតកជនពុំមានបច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ សន្តតិជនលំដាប់ទី ២ ឬ បុព្វញាតិផ្ទាល់ របស់មតកជននឹងត្រូវក្លាយជាសន្តតិជន។ ហើយមួយវិញទៀត រវាងបុគ្គលដែលមានថ្នាក់ញាតិខុសគ្នា គេត្រូវកំណត់យកបុព្វញាតិដែលនៅជិតជាងគេជាមុន (ឧទាហរណ៍ថា មតកជន មានទាំងឪពុកម្ដាយនិងជីដូនជីតា គេយកតែឪពុកម្ដាយប៉ុណ្ណោះមកកំណត់ជាទាយាទស្នងមត៌ករបស់មតកជន)។ ហើយចំពោះពាក្យថា សន្តតិជនលំដាប់ទី ២ ឬ បុព្វញាតិផ្ទាល់របស់មតកជន គឺគេសំដៅទៅលើឪពុកម្ដាយ ឬក៏ជីដូជីតារបស់មតកជននោះ។ ហើយពាក្យថា យកតែថ្នាក់ញាតិដែលនៅជិតជាង នៅទីនេះ គឺគេចង់សំដៅទៅលើ ប្រសិនបើឪពុកឬម្ដាយរបស់មតកជននៅរស់តែម្នាក់ ដូច្នេះហើយបុព្វញាតិដែលនៅជិតជាងគេ គឺមានតែឪពុកឬម្ដាយដែលនៅរស់ម្នាក់នោះប៉ុណ្ណោះ ហើយអ្នកដែលនៅជិតនោះនឹងក្លាយជាសន្តតិជនលំដាប់ទី ២ តែម្នាក់ឯង។ ហើយចំពោះជីដូនជីតាខាងឪពុកឬម្ដាយដែលឪពុកឬម្ដាយនោះបានទទួលមរណភាពនោះ គឺ ជីដូនឬជីតានោះ មិនទទួលបានសន្តតិកម្មជំនួសឡើយ។ ជារួមមកវិញ យើងអាចនិយាយបានថា ចំពោះសន្តតិជនដែលមានលំដាប់ទី ២ គឺមិនមានប្បញ្ញត្តិស្ដីអំពីសន្តតិកម្មជំនួសឡើយ។ ហើយនៅក្នុងករណីមួយចំនួនទៀតគឺថា ទាំងឪពុកនិងម្ដាយរបស់មតកជនក៏បានចែកឋានផងដែរដូច្នេះហើយសន្តតិជនលំដាប់ទី ២ នឹងអាចរុញទៅដល់ជីដូនជីតាខាងម្ដាយ ឬ/និង ជីដូនជីតាខាងឪពុក ដែលនៅមានជីវិតនោះ ឱ្យត្រូវក្លាយជាសហសន្តតិជនលំដាប់ទី ២[91]។

<u>សន្តតិជនជានិច្ច និង សន្តតិជនលំដាប់ទី ២</u>

ដូចគ្នាដែរ នៅក្នុងករណីនេះ នៅពេលដែលបុព្វញាតិផ្ទាល់របស់មតកជន ត្រូវបានក្លាយជាសន្តតិជនលំដាប់ទី ២ មកទទួលស្នងមត៌ក ហើយគេក៏រកឃើញផងដែរថាមតកជននៅមានសហព័ទ្ធនៅរស់ សហព័ទ្ធនោះក៏ត្រូវមកទទួលសន្តតិកម្មជាមួយនឹងសន្តតិជនលំដាប់ទី ២ នោះដែរ[92]។

---

[90] ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី (ភាគ ៦ : គន្ថីទី ៨)* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០), មាត្រា ១១៦១។

[91] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៥៩-១។

[92] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦១-២។

### គ. សន្តតិជនលំដាប់ទី ៣ សន្តតិជនជំនួស និង សន្តតិជនជានិច្ច

មកដល់ទីនេះ យើងឃើញថា ប្រសិនបើមតកជនពុំមាន ទាំងសន្តតិជនលំដាប់ទី ១ ហើយដូចគ្នាដែរ ពុំមាននូវសន្តតិជនលំដាប់ទី ២ នៅពេលនេះ សន្តតិជនលំដាប់ទី ៣ គឺត្រូវបានទទួលស្គាល់ ហើយដែលសន្តតិជនលំដាប់នេះ គឺជាបងប្អូនបង្កើតរបស់មតកជន ហើយដែលនឹងត្រូវក្លាយជាសន្តតិជនមកទទួលស្នងមត៌ក[93]។

<u>សន្តតិជនជំនួស</u>

នៅទីនេះ ប្រសិនបើសន្តតិជនលំដាប់ទី ៣ ដែលជាបងប្អូនបង្កើតរបស់មតកជនបានទទួលមរណភាព យើងក៏មានផងដែរប្បញ្ញត្តិស្តីអំពីសន្តតិកម្មជំនួស តែគេទទួលស្គាល់ត្រឹមតែមួយតំណប៉ុណ្ណោះ ឬ គេអាចនិយាយបានម្យ៉ាងទៀតថា មានត្រឹមតែក្មួយរបស់មតកជនប៉ុណ្ណោះ ដែលអាចក្លាយជាសន្តតិជនជំនួសនៅក្នុងករណីនេះ[94]។

<u>សន្តតិជនជានិច្ច</u>

នៅក្នុងករណីនេះ យើងឃើញថា ប្រសិនបើមតកជនគ្មានឡើយ សន្តតិជនលំដាប់ទី ១ ក៏គ្មានផងដែរ បុព្វញាតិផ្ទាល់ ដែលជាសន្តតិជនលំដាប់ទី ២ ចំណែកនៃសន្តតិកម្មនោះនឹងត្រូវបានទៅលើសន្តតិជនដែលមានលំដាប់ទី៣ គឺបងប្អូនបង្កើតរបស់មតកជន។ ហើយនៅទីនេះ យើងឃើញថា សហព័ទ្ធរបស់មតក នឹងត្រូវមកប្រជែងជាមួយនឹងសន្តតិជនលំដាប់ទី ៣ ផងដែរ។

នៅក្នុងករណីពិសេសមួយផ្សេងទៀត គឺថា ប្រសិនបើគ្មានឡើយសន្តតិជនពីលំដាប់ទី ១ រហូតដល់លំដាប់ទី ៣ សហព័ទ្ធដែលជាសន្តតិជនជានិច្ច នឹងត្រូវទទួលស្នងមត៌កនោះតែម្នាក់ឯង[95]។

ហើយមួយវិញទៀត ពាក់ព័ន្ធទៅនឹង ផ្នែកដែលនិយាយអំពីលំដាប់នៃសន្តតិជននេះ ក្រៅពីជនដូចដែលបានបកស្រាយខាងលើ ឧទាហរណ៍ដូចជាពូមីង ឬបងប្អូនជីដូនមួយរបស់មតកជនមិនមានសិទ្ធិអ្វីឡើយ ក្នុងការទទួលស្នងមត៌ករបស់មតកជន។ ការបិទបញ្ចប់នូវសន្តតិកម្ម នៅត្រឹមតែបីលំដាប់នេះ អាចនឹងសម្រួលឱ្យគេពិចារណានូវចំណែកមត៌កនោះទៅដល់ជនដែលមាននិស្ស័យពិសេសផ្សេងៗទៀត ទៅតាមទំនាក់ទំនងជាក់ស្តែងរវាងមតកជន និង ជននោះ ហើយឱ្យសមស្របទៅតាមការអនុវត្ត។

### កថាខណ្ឌទី ២ ៖ នីតិវិធីក្នុងការបែងចែកមត៌ក

---

[93] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦០-១។

[94] ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី (ភាគ ៦ : គន្ថីទី ៨)* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០), មាត្រា ១១៥៧ ថ្មី។

[95] ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី (ភាគ ៦ : គន្ថីទី ៨)* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០), មាត្រា ១១៦១-១។

**១. វិធានក្នុងការបែងចែកចំណែកមត៌ក**

មុននឹងយើងសិក្សាអំពីនីតិវិធីនៃការបែងចែកចំណែកមត៌ក យើងគួរយល់ជាមុនសិនអំពី អ្វីទៅជាចំណែកមតក។ ចំណែកមត៌ក គឺជាភាគ ឬ ចំនួន ឬ ទំហំនៃមត៌កដែលសន្តតិជនអាចនឹងទទួលបាន។

**ក. ចំណែកមត៌ក**

<u>ករណីសន្តតិជនលំដាប់ទី ១ សន្តតិជនជានិច្ច និង សន្តតិជនជំនួស</u>

ជាទូទៅនៅក្នុងករណីដែលមានកូនរបស់មតកជន ឬសន្តតិជនលំដាប់ទី ១ យើងឃើញថា ចំណែកមត៌ករបស់សន្តតិជនទាំងនោះនឹងត្រូវបែងចែកតាមចំណែកស្មើៗគ្នា។ ហើយនៅទីនេះ ពាក្យថា ចំណែកស្មើគ្នា ក៏គេមិនបំភ្លេចសញ្ញាណទាក់ទងទៅនឹងកូនសុំ ក៏ដូចជាកូនក្រៅអាពាហ៍ពិពាហ៍នោះដែរ ឬអាចនិយាយបានម្យ៉ាងទៀតថាបុគ្គលទាំងនោះ សុទ្ធតែជាកូនរបស់មតកជន ហើយដែលនឹងត្រូវទទួលចំណែកមត៌កស្មើគ្នា[96]។

នៅក្នុងករណីនេះ បើយើងនិយាយអំពីចំណែកមត៌ករបស់សន្តតិជនជំនួស យើងឃើញថា ចំណែកដែលគាត់ទទួលបាន គឺជាចំណែករបស់បុគ្គលដែលជាសន្តតិជនដើមដូចបានបកស្រាយខាងលើ។ ហើយប្រសិនបើសន្តតិជននោះ មានគ្នាច្រើននាក់ ការបែងចែក គឺត្រូវបែងចែកស្មើៗគ្នា រវាងសន្តតិជនជំនួសទាំងនោះ។ ហើយមួយវិញទៀត ចំពោះសន្តតិជនផ្សេងទៀតរបស់មតកជន មិនត្រូវបានយកមករាប់បញ្ចូលជាមួយនឹងចំណែករបស់សន្តតិជនជានិច្ច ដោយបែងចែកស្មើៗគ្នាទេ[97]។

មួយវិញទៀត ប្រសិនបើក្រោយពេលមរណភាពរបស់មតកជន គេរកឃើញថា មានទាំងសន្តតិជនលំដាប់ទី១ និងមានផងដែរសហព័ទ្ធរបស់មតកជននោះ នៅទីនេះ សន្តតិកម្មគេនឹងធ្វើការបែងចែកចំណែកស្មើៗគ្នារវាងសហព័ទ្ធនេះ និងសន្តតិជនលំដាប់ទី ១[98]។

<u>ករណីសន្តតិជនលំដាប់ទី ២ សន្តតិជនជានិច្ច និង សន្តតិជនជំនួស</u>

ដូចបានបកស្រាយខាងលើ នៅពេលដែល ពុំមានឡើយសន្តតិជនលំដាប់ទី ១ សន្តតិជនលំដាប់ទី ២ នឹងត្រូវបានលើកយកមកសិក្សា ហើយដែលគាត់នឹងក្លាយជាសន្តតិជនទទួលស្នងបន្តមត៌ករបស់មតកជន។ ដោយពុំពិចារណាថា មតកជនមានសហព័ទ្ធ យើងឃើញថា បុព្វញាតិផ្ទាល់ដែលអាចរួមមាន ឪពុកម្តាយ និងជីដូនជីតា របស់មតកជន នឹងក្លាយជាសន្តតិជន ហើយដែលនឹងធ្វើការបែងចែកចំណែកមត៌កនោះ។ នៅទីនេះផងដែរ ចំណែកមត៌ក គឺអាចត្រូវបានបែងចែក ដោយគេគិតទៅលើថ្នាក់ញាតិដែលជិតជាងគេជាមុនសិន។

96 ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៥៦។
97 ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៥៨។
98 ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦២-ក។

ឧទាហរណ៍ថា មតកជននៅមានឪពុកម្តាយមានជីវិតរស់នៅ ឪពុកឬ/និងម្តាយនោះនឹងក្លាយជាសន្តតិជនតែម្តង។ នៅទីនេះ យើងឃើញថាបើឪពុកឬម្តាយ មានតែម្នាក់ទេ ឪពុកឬម្តាយម្ខាងទៀតដែលនៅរស់ នឹងទទួលសន្តតិកម្មមូលតែម្តង ដោយមិនពិចារណាទៅលើករណីនៃសន្តតិកម្មជំនួសទេ។ ដោយឡែក ប្រសិនបើមិនមានទាំងពីរ ទាំងឪពុក ទាំងម្តាយ សន្តតិកម្មនៅក្នុងករណីនេះ នឹងបានទៅដល់ ជីដូន ជីតា របស់មតកជន។ ហើយដែលគេប្រើពាក្យថា ជីដូនជីតាខាងម្តាយ ឬ ខាងឪពុក នឹងក្លាយជាសហសន្តតិជន មកទទួលចំណែកស្មើៗគ្នា។ ហើយមួយវិញទៀត ប្រសិនបើជីដូន ឬ ជីតា ខាងឪពុក ឬ ម្តាយណាម្នាក់បានទទួលមរណភាព អ្នកដែលនៅសល់ប៉ុន្មានទៀត នឹងត្រូវទទួលបានសន្តតិកម្មស្មើៗគ្នា[99]។

ចំពោះចំណែកមត៌ករបស់សន្តតិជនលំដាប់ទី ២ នៅក្នុងខណៈពេលដែលអាចប្រជែងជាមួយនឹងសហព័ទ្ធរបស់មតកជន យើងឃើញថា ចំណែកមត៌ករបស់សហព័ទ្ធ ត្រូវបាន ១/៣ (មួយភាគបី) ឯចំណែកមត៌ករបស់ឪពុកម្តាយត្រូវបាន ២/៣ (ពីរភាគបី)។ ក៏ប៉ុន្តែ នៅក្នុងចំណុចនេះផងដែរ ប្រសិនបើឪពុកឬម្តាយរបស់មតកជនមានតែម្នាក់នៅរស់ ឪពុកឬម្តាយនោះ និង សហព័ទ្ធត្រូវបានចំណែកមត៌កស្មើគ្នា[100]។ ត្រង់ចំណុចនេះ យើងឃើញថា វានឹងមិនមែនជាបញ្ហាអ្វីឡើយ ប្រសិនបើឱ្យចំណែកមត៌ករបស់បុគ្គលទាំងបីនោះ ពោលគឺ ឪពុកម្តាយរបស់មតកជន និងសហព័ទ្ធមានចំណែកស្មើៗគ្នា ដែលវានឹងអាចត្រូវជា ១/៣ ម្នាក់ ប៉ុន្តែវានឹងអាចមានបញ្ហានៅពេលដែលមតកជននោះ គឺជាកូនសុំ តាមរយៈរបបសុំកូនធម្មតា ដែលនៅពេលនោះ គាត់អាចមានអត្ថិភាពនៃញាតិទាំងឪពុកម្តាយបង្កើត ហើយនិងឪពុកម្តាយចិញ្ចឹម ដូច្នេះហើយ នៅទីនេះ ច្បាប់បានពិចារណាជាពិសេសថា សហព័ទ្ធគួរតែ យ៉ាងហោចណាស់ ទទួលបានចំណែក ១/៣ (មួយភាគបី) ទើបជាការសមរម្យ[101]។ ពាក់ព័ន្ធទៅនឹងការបែងចែកចំណែកមត៌ក រវាងសហព័ទ្ធ និង បុព្វជនផ្ទាល់ក្រៅពីឪពុកម្តាយ ច្បាប់បានបញ្ញត្តិឱ្យសហព័ទ្ធ ត្រូវទទួលបាន ១/២ (មួយភាគពីរ) ហើយចំណែកមួយភាគពីរទៀត ត្រូវបែងចែកឱ្យទៅសន្តតិជននោះ[102]។

[99] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៥៩-២។

[100] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦២-ខ។

[101] ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី (ភាគ ៦ : គន្ថីទី ៨)* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០), មាត្រា ១១៦២-ខ។

[102] ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី (ភាគ ៦ : គន្ថីទី ៨)* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០), មាត្រា ១១៦២-គ។

ករណីសន្តតិជនលំដាប់ទី ៣ សន្តតិជនជានិច្ច និង សន្តតិជនជំនួស

នៅពេលដែលសន្តតិជនលំដាប់ទី ១ និងលំដាប់ទី ២ ពុំត្រូវបានរកឃើញ សន្តតិជនលំដាប់ទី ៣ (បងប្អូនបង្កើតរបស់មតកជន) នឹងត្រូវបានក្លាយជាសន្តតិជនមកទទួលស្នងចំណែកមត៌ក [103] ។ យោងទៅតាមប្បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១១៦០ ករណីដែលមានបងប្អូនបង្កើតមានច្រើននាក់ បងប្អូនបង្កើតនីមួយៗត្រូវទទួលបានចំណែកមត៌កភាគស្មើៗគ្នា ប៉ុន្តែ ប្រសិនបើមានបងប្អូនបង្កើតដែលមានម្តាយ ឬ ឪពុកផ្សេងគ្នា ចំណែកមត៌ក ត្រូវបែងចែកទៅតាមរបៀបផ្សេង គឺត្រូវបានទទួលតែពាក់កណ្តាលនៃចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុកម្តាយទាំងសងខាងដូចគ្នា។ ហើយពាក់ព័ន្ធទៅនឹងចំណែករបស់សន្តតិជនជំនួសនៃសន្តតិជនលំដាប់ទី ៣ ច្បាប់អនុញ្ញាតឱ្យមានតែមួយតំណប៉ុណ្ណោះ ហើយដែលមកជំនួសនូវចំណែករបស់សន្តតិជនដោយសារតែមូលហេតុនៃសន្តតិកម្មជំនួសនោះ។

មួយវិញទៀត ពាក់ព័ន្ធទៅនឹងចំណែកមត៌ក ក្នុងករណីមានសហព័ទ្ធរបស់មតកជន ប្រជែងជាមួយនឹងសន្តតិជនលំដាប់ទី ៣ ដែលជាបងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសរបស់បងប្អូនបង្កើតនៃមតកជននោះ ជាសន្តតិជន សហព័ទ្ធដែលជាសន្តតិជនជានិច្ច ត្រូវបានចំណែក ១/២ (មួយភាគពីរ) ហើយចំណែក ១/២ (មួយភាគពីរ) ទៀត នឹងត្រូវធ្វើការបែងចែករវាងបុគ្គលទាំងនោះ[104]។

ហើយគួរបញ្ជាក់ផងដែរថា ប្បញ្ញត្តិស្តីអំពីការសម្រួលចំណែកមត៌ក គឺត្រូវបានបង្កើតឡើងនៅក្នុងករណីបន្ទាប់ពីចាប់ផ្តើមសន្តតិកម្ម គេរកឃើញថាមាន សន្តតិជនដែលទទួលនូវផលប្រយោជន៍ពិសេសពីមតកជន ឬ ក្នុងករណីដែលរកឃើញមានសន្តតិជនដែលបានផ្តល់ភាគនៃវិភាគទានពិសេសទៅក្នុងទ្រព្យរបស់មតកជន។ ដូច្នេះ ដើម្បីឱ្យមានសមភាពត្រឹមត្រូវជាក់ស្តែង រវាងសហសន្តតិជនទាំងអស់ ជាមួយនឹងបុគ្គលដែលទទួលផលប្រយោជន៍ពិសេស ឬ បុគ្គលដែលចូលរួមភាគនៃវិភាគទានក្នុងទ្រព្យសម្បត្តិរបស់មតកជន គេត្រូវគោរពតាមប្បញ្ញត្តិស្តីអំពីការសម្រួលចំណែកមតកនេះ។ ហើយនៅក្នុងករណីនេះផងដែរ ក៏តម្រូវឱ្យមានការសម្រួលចំណែកមត៌កផងដែរ ដើម្បីបន្សុីទៅនឹងប្បញ្ញត្តិ ដែលចែងថា ជាគោលការណ៍ សន្តតិជនត្រូវទទួលបានចំណែកស្មើៗគ្នា ប្រសិនបើ មិនបានធ្វើការសម្រួលឱ្យជាច់ស្រេចទេក្នុងករណីពិសេសនេះទេ វានឹងអាចបំពានខ្លឹមសារនៃការទទួលបានចំណែកមត៌កជាក់ស្តែង[105]។

ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស

---

[103] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦០-១។

[104] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦២-គ។

[105] ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី (ភាគ ៦ : គន្ថីទី ៨)* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០), មាត្រា ១១៦៣។

ផលប្រយោជន៍ពិសេស ត្រូវបានច្បាប់ទទួលស្គាល់ និងឱ្យនិយមន័យថា ជាផលប្រយោជន៍ដែលបុគ្គលម្នាក់ ឬច្រើននាក់ទទួលក្នុងរូបភាពជាប្រទានកម្ម ពីម្ចាស់ទ្រព្យពេលទៅរស់ ក្នុងឱកាសអាពាហ៍ពិពាហ៍ ឬ ហេតុការណ៍ផ្សេងទៀត ឬ ដើម្បីមូលធននៃជីវភាពរស់នៅ ឬ ដែលទទួលបានអច្ច័យទានពីមតកជន[106]។ នៅទីនេះ យើងសង្កេតឃើញថា ថ្វីបើអច្ច័យទាន ដែលជាប្រទានកម្មមួយប្រភេទដែលនឹងមានអានុភាពនាពេលចាប់ផ្តើមសន្តតិកម្ម ត្រូវបានរាប់ជាផលប្រយោជន៍ពិសេសក៏ដោយ ក៏ប៉ុន្តែ ផលប្រយោជន៍ពិសេសនេះ មិនត្រូវបានគេរាប់បញ្ចូលនៅក្នុងការគណនាការសម្រួលចំណែកមត៌កឡើយ ដោយអាចយោងទៅលើមូលហេតុថា ទ្រព្យសម្បត្តិដែលជាអច្ច័យទាននោះ គឺមិនទាន់ត្រូវបានគ្រប់គ្រងនិងកាន់កាប់នៅឡើយទេ[107]។

នៅក្នុងករណីមានអ្នកទទួលផលប្រយោជន៍ពិសេសបែបនេះ ក្នុងការគណនាដើម្បីបែងចែកមត៌កបានដំបូងគេត្រូវរកឱ្យឃើញនូវតម្លៃសរុបនៃមត៌កជាមុនសិន។ ហើយដែលតម្លៃសរុបនៃមត៌កនោះ គឺត្រូវយកទ្រព្យរបស់មតកជនដែលមាននាពេលចាប់ផ្តើមសន្តតិកម្ម បូកជាមួយនឹង តម្លៃនៃប្រទានកម្ម ជាអាទិ៍ ដែលជាផលប្រយោជន៍ពិសេសនោះ។ ហើយនៅពេលដែលរកឃើញទំហំមត៌កសរុបហើយ គេក៏នឹងអាចរកឃើញនូវចំណែកមត៌ករបស់សន្តតិជនម្នាហើយយកវាទៅដកនឹងតម្លៃនៃប្រទានកម្មនោះចេញ គេនឹងរកឃើញនូវចំណែកមត៌ករបស់អ្នកដែលមានផលប្រយោជន៍ពិសេស ហើយដែលអាចនឹងទទួលបាននោះ។

រូបមន្តៈ

**មត៌កសរុប** = មត៌កពេលចាប់ផ្តើមសន្តតិកម្ម + ផលប្រយោជន៍ពិសេស

**ចំណែកមត៌កនៃអ្នកមានផលប្រយោជន៍ពិសេស** = មត៌កសរុប - ផលប្រយោជន៍ពិសេស

ហើយគួរបញ្ជាក់ផងដែរថា ប្រសិនបើផលប្រយោជន៍ពិសេសលើពីតម្លៃនៃមត៌កត្រូវទទួលបាន សហសន្តតិជនដែលទទួលបានប្រទានកម្មរូបនោះ មិនចាំបាច់បង្វិលទ្រព្យសម្បត្តិនោះសងមត៌កសរុបទេ តែក៏មានករណីលើកលែងដែរ ពោលគឺនៅពេលដែលត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង[108]។

<u>ភាគនៃវិភាគទាន</u>

ភាគនៃវិភាគទាន ត្រូវបានគេស្គាល់ថា ជាស្ថានភាពនៃការចំណាយទ្រព្យសម្បត្តិ របស់សហសន្តតិជនណាម្នាក់ ដើម្បីបង្កើតទ្រព្យរបស់មតកជន ឬ ជាការចំណាយសម្រាប់ជីវភាពរបស់មតកជន ឬ ជាការចំណាយសម្រាប់ការមើលថែទាំមតកជន។ ស្ថិតនៅក្នុងស្ថានភាពបែបនេះ ការចំណាយរបស់បុគ្គលនេះគួរតែទទួលបាន

[106] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦៣-១។
[107] អ៊ុំ ប៉ូលី, *សន្តតិកម្ម (មេរៀនសង្ខេប)* (គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី, ២០១១), ៦។
[108] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦៥។

ការប៉ះប៉ូវមកវិញ នាពេលចាប់ផ្តើមសន្តតិកម្ម។ ម្លោះហើយ ច្បាប់បានបញ្ញត្តិពាក់ព័ន្ធនឹងវិធាននៃការសម្រួលចំណែកមត៌កក្នុងករណីភាគនៃវិភាគទាននេះឡើងផងដែរ សម្រាប់ឱ្យមានភាពស្មើភាពជាក់ស្តែងសម្រាប់ជនដែលបានចំណាយទ្រព្យរបស់ខ្លួនក្នុងជីវភាព ឬសកម្មភាពរបស់មតកជន កាលនៅរស់។

រូបមន្តៈ

**មត៌កជាក់ស្តែង** = មត៌កពេលចាប់ផ្តើមសន្តតិកម្ម - ភាគនៃវិភាគទាន

**ចំណែកមត៌កនៃអ្នកធ្វើភាគនៃវិភាគទាន** = មត៌កជាក់ស្តែង + ភាគនៃវិភាគទាន

នៅក្នុងករណីមានស្ថានភាពភាគនៃវិភាគទាននេះកើតឡើង មត៌កជាក់ស្តែងគឺត្រូវស្មើនឹង មត៌កនាពេលចាប់ផ្តើមសន្តតិកម្ម ដោយកាត់ចេញភាគនៃវិភាគទានចេញ។ ហើយចំណែកមត៌ករបស់អ្នកធ្វើភាគនៃវិភាគទានស្មើនឹងចំណែកមត៌ករបស់សន្តតិជនម្នាក់ៗត្រូវទទួល បូក នឹងភាគនៃវិភាគទាន។

### ខ. ការបែងចែកចំណែកមត៌ក

ជាទូទៅ ដូចដែលបានពិភាក្សាគ្នា ពីខាងលើមករួចហើយ ពាក់ព័ន្ធទៅនឹងគោលការណ៍នូវការទទួលបន្តជាស្វ័យប្រវត្តិ នៃទ្រព្យសម្បត្តិរបស់មតកជន ដោយឃើញថា ជាគោលគំនិត គឺដើម្បីកុំឱ្យមានចន្លោះពេលណាមួយ ដែលទ្រព្យស្ថិតនៅដោយគ្មានម្ចាស់ ដែលអាចនឹងបង្កជាហានិភ័យណាមួយកើតមានឡើងបាន។ ហើយពាក់ព័ន្ធជាមួយនឹងការបែងចែកចំណែកមត៌កនេះ យើងឃើញថា នៅបន្ទាប់ពីពេលចាប់ផ្តើមសន្តតិកម្ម គេត្រូវពិនិត្យឱ្យច្បាស់ថា តើសន្តតិជនមាននរណាខ្លះ ហើយទ្រព្យសម្បត្តិ ទាំងសិទ្ធិ និង ករណីយកិច្ច របស់មតកជននៅបន្សល់ទុកនោះមានអ្វីខ្លះ ដើម្បីងាយស្រួលនៅពេលដែលចូលទៅដល់នីតិវិធីនៃការបែងចែកចំណែក។ ស្របទៅនឹងគោលគំនិតខាងលើនេះ មត៌កដែលត្រូវបានគ្រប់គ្រងដោយនរណាម្នាក់នៅក្នុងអំឡុងពេលមុននីតិវិធីធ្វើការចែកចំណែក ដើម្បីធានាសុវត្ថិភាពនិងអត្ថិភាពនៃទ្រព្យនោះ[109]។ ដូច្នេះហើយ មុននឹងឈានចូលដល់ចំណុចដែលសិក្សាអំពីការបែងចែកចំណែកមត៌ក ជាទូទៅ យើងគួរតែសិក្សាជាមុនសិនអំពីការគ្រប់គ្រងមត៌កការស្វែងរក និង វាយតម្លៃមត៌កជាមុនសិន។ ពាក់ព័ន្ធទៅនឹងការរក្សាទុក ក៏ដូចជាគ្រប់គ្រងនូវទ្រព្យសម្បត្តិរបស់មតកជនចំពោះជនដែលបានគ្រប់គ្រងនៅពេលដែលចាប់ផ្តើមសន្តតិកម្ម ត្រូវធ្វើការគ្រប់គ្រង ឬ មើលថែរក្សាទ្រព្យសម្បត្តិនោះរហូតដល់ពេលដែលមានការបែងចែកនូវចំណែកមត៌ក។ ហើយនៅទីនេះ ជននោះក៏ត្រូវធ្វើការថែរក្សា និងគ្រប់គ្រងដោយប្រុងប្រយ័ត្នជាទីបំផុតតាមតែអាចធ្វើបាន ឬ និយាយបានម្យ៉ាងទៀតថា ធ្វើយ៉ាងណាកុំឱ្យមានការខូចខាត ឬ ប៉ះពាល់ដល់ផលប្រយោជន៍នៃទ្រព្យនោះ។ ហើយមួយវិញទៀត ប្រសិនបើនៅក្នុងមតកសាសន៍

[109] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៧២។

បានចែងកំណត់រួចហើយ ពាក់ព័ន្ធទៅនឹងបុគ្គលដែលត្រូវបានតែងតាំង ជាអ្នកប្រតិបត្តិមតកសាសន៍ នៅពេលនេះ បុគ្គលនោះនឹងមានអាទិភាពជាង នៅក្នុងការគ្រប់គ្រង និង ថែរក្សាទ្រព្យសម្បត្តិនោះ[110]។ ហើយមួយវិញទៀត ចំពោះសិទ្ធិ និង ករណីយកិច្ចមួយចំនួនរបស់អ្នកប្រតិបត្តិមតកសាសន៍ ក៏នឹងត្រូវចាប់ផ្តើមនៅពេលដែលចូលកាន់កាប់មុខងារនោះដែរ ហើយនៅទីនេះ ក៏មានការកម្រិតខ្លះដែរ នៅត្រង់ដែលថា ប្រសិនបើនៅក្នុងមតកសាសន៍ បានកំណត់អំពីទ្រព្យសម្បត្តិជាក់ច្បាស់ ដូច្នេះការគ្រប់គ្រងទ្រព្យសម្បត្តិណាមួយនោះ ក៏ទៅតាមតែការកំណត់នោះប៉ុណ្ណោះ[111]។ ហើយមួយវិញទៀត នៅក្នុងករណីដែលមតកសាសន៍ ពុំបានបញ្ញត្តិអំពីអ្នកប្រតិបត្តិមតកសាសន៍ទេ ជនដែលមានផលប្រយោជន៍ពាក់ព័ន្ធ ដែលអាចរួមមានដូចជា សន្តតិជន អច្ច័យលាភី ឬ ម្ចាស់បំណុលអាចធ្វើការដាក់ពាក្យសុំទៅតុលាការ ឱ្យធ្វើការជ្រើសតាំងអ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្នបាន។ អ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន ក៏ដូចគ្នាទៅនឹងអ្នកប្រតិបត្តិមតកសាសន៍ដែរ ដែលមានតួនាទីចាប់ពីពេលដែលត្រូវបានជ្រើសតាំងនៅក្នុងការគ្រប់គ្រង ក៏ដូចជាការពារ និង អនុវត្តនូវសកម្មភាពមួយចំនួនទៀតដែលច្បាប់អនុញ្ញាត ដើម្បីរក្សាការពារទ្រព្យសម្បត្តិនោះ រហូតដល់ពេលធ្វើការបែងចែកមត៌កចប់សព្វគ្រប់[112]។ ហើយមួយវិញទៀត បើយើងនិយាយអំពីអ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន ក្នុងការបំពេញការងារនេះ គាត់ក៏នឹងទទួលបាននូវប្រាក់កម្រៃ ជាសោហ៊ុយផងដែរ ហើយដែលសោហ៊ុយដែលត្រូវផ្តល់ជូនអ្នកគ្រប់គ្រងបណ្តោះអាសន្ននោះ គឺនឹងអាចត្រូវបានចំណាយចេញពីទ្រព្យសម្បត្តិដែលជាមត៌កនោះ[113]។

បន្ទាប់មកនៅពេលចូលមកដល់ដំណាក់កាលនៃការបែងចែកមត៌ក ជាទូទៅពាក់ព័ន្ធទៅនឹងការបែងចែកមត៌ក គេអាចមានជម្រើសដែលដំបូងឡើយ សន្តតិជនអាចធ្វើបាន តាមរយៈការពិភាក្សាគ្នា រវាងសហសន្តតិជនផ្សេងទៀត ហើយប្រសិនបើការពិភាក្សាមិនអាចធ្វើទៅបានទេ គេអាចធ្វើការបែងចែកតាមរយៈតុលាការ[114]។ បើនិយាយអំពីពាក្យថា ការពិភាក្សា ពាក់ព័ន្ធទៅនឹងបញ្ហានៃសន្តតិកម្ម វាអាចកើតឡើងក្រោមរូបភាពជាច្រើន ក្នុងនោះអាចមានរូបភាព ជាការពិភាក្សាលើចំណុចដែលចែងមិនច្បាស់លាស់ ឬដែលពិបាកនៅក្នុងការអនុវត្ត ការពិភាក្សាគឺដើម្បីឈានទៅរកឱ្យមានភាពច្បាស់លាស់ចំពោះមតកសាសន៍នោះ ឬក៏មួយវិញទៀតការពិភាក្សាដើម្បីធ្វើការបែងចែកមត៌កតែម្តង។

---

110 ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦២។

111 ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦៣។

112 ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦៤។

113 ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៦៥។

114 អ៊ីវ ប៉ូលី, *សន្តតិកម្ម (មេរៀនសង្ខេប)* (គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី, ២០១១), ៤៥។

បើទោះបីច្បាប់បានចែងថា ត្រូវគោរពតាមខ្លឹមសារនៃមតកសាសន៍ដែលជាឆន្ទៈចុងក្រោយរបស់មតក ជនក៏ដោយ ប៉ុន្តែ ប្រសិនបើការពិភាក្សាគ្នារវាងសហសន្តតិជនទាំងអស់ ឈានទៅរកមតិរួមមួយបាន ពាក់ព័ន្ធទៅនឹងការបែងចែកមត៌កនេះ មត៌ក គឺនឹងអាចត្រូវបានបែងចែកតាមរយៈការពិភាក្សាគ្នានោះ។ ក៏ប៉ុន្តែ នៅក្នុងករណីដែលការពិភាក្សាគ្នាមិនអាចឈានទៅសម្លេងរួមបានទេ សហសន្តតិជន អាចធ្វើការដាក់ពាក្យប្តឹងទៅតុលាការដើម្បីធ្វើការបែងចែកមត៌កនោះបាន។ នេះ ក៏ដោយហេតុថា នៅក្នុងការអនុវត្តជាក់ស្តែង យើងឃើញថាអាចមានលេចចេញជា ករណីដែលសហសន្តតិជនមួយចំនួនចង់ឱ្យមានការពិភាក្សាគ្នា សហសន្តតិជនមួយចំនួនទៀតចង់ឱ្យអនុវត្តតាមមតកសាសន៍តែម្តង ដែលនៅក្នុងចំណុចនេះហើយ នាំឱ្យមានការខ្វែងគំនិតគ្នានិងមិនអាចឈានទៅដល់ការសម្រេចជាយោបល់រួមបាននោះ។

ហើយនៅត្រង់ចំណុចនេះ ក៏លេចចេញនូវសញ្ញាណនៃអ្នកប្រតិបត្តិមតកសាសន៍ផងដែរ ដែលនៅទីនេះ ប្រសិនបើមាន គាត់នឹងដើរតួតំណាងឱ្យមតកជន ដូច្នេះ ប្រសិនបើមានមតិជំទាស់ពីអ្នកប្រតិបត្តិមតកសាសន៍ ការពិភាក្សាគ្នាក្នុងការបែងចែកមត៌ក ដោយមិនយកទៅតាមខ្លឹមសារ នៃមតកសាសន៍ ក៏មិនអាចធ្វើទៅបានដែរ។ ប៉ុន្តែវានឹងអាចធ្វើទៅបានវិញ នៅពេលដែលអ្នកប្រតិបត្តិមតកសាសន៍យល់ព្រមមានការព្រមព្រៀងគ្នារវាងសហសន្តតិជនទាំងអស់នោះ[115]។

### ២. វិធានក្នុងការផ្ទេរកម្មសិទ្ធិលើមត៌ក

ថ្វីបើយើងឃើញថា សន្តតិកម្មត្រូវចាប់ផ្តើមដោយមូលហេតុមរណភាពរបស់មតកជនក៏ពិតមែន ដែលតាមរយៈការណ៍នេះ សិទ្ធិ និង ករណីយកិច្ចទាំងអស់របស់មតកជន ត្រូវផ្ទេរទៅឱ្យសន្តតិជនរបស់ខ្លួន ដូចបានពិភាក្សាអំពីគោលការណ៍នៃការទទួលបន្តដោយស្វ័យប្រវត្តិខាងលើ ក៏ប៉ុន្តែ ដើម្បីឱ្យទ្រព្យសម្បត្តិដែលខ្លួនទទួលបាន អាចចាត់ចែង និង តតាំងជាមួយតតិយជនបាន ជាទូទៅ សន្តតិជននោះ ត្រូវគោរពនូវលក្ខខណ្ឌមួយចំនួនដែលពាក់ព័ន្ធនឹងលទ្ធកម្មនៃកម្មសិទ្ធិ។ ប្រសិនបើទ្រព្យដែលនឹងត្រូវទទួលតាមរយៈសន្តតិកម្មនោះ ជាចលនទ្រព្យ អ្នកទទួល ឬ សន្តតិជន គឺត្រូវគោរពប្បញ្ញត្តិស្តីពីលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុដូចមានចែងពីមាត្រា ១៨៧ ដល់ មាត្រា ២០១ នៃក្រមរដ្ឋប្បវេណី (២០០៧)។

ដោយឡែក ចំពោះការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ ដោយមូលហេតុសន្តតិកម្ម គឺនឹងមានអានុភាពនៅពេលមតកជនទទួលមរណភាព ម្លោះហើយ វាមិនមែនជាការព្រមព្រៀងនោះទេ ដែលតាមរយៈនេះ គេអាចទាញ

[115] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២២១។

បានថា គោលការណ៍នៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការចុះបញ្ជី គឺមិនយកមកអនុវត្តឡើយ ក៏ប៉ុន្តែ ប្រសិនបើមានការចុះបញ្ជី វានឹងក្លាយជាលក្ខខណ្ឌតតាំងជាមួយនឹងតតិយជនបាន[116]។

ក្នុងករណី មតកជន ពុំបានកំណត់អំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនក្រោយពេលមរណភាពតាមរយៈមតកសាសន៍ទេ បញ្ញត្តិស្ដីពីសន្តតិកម្មនឹងត្រូវបានយកមកអនុវត្ត ដែលមានន័យថា ចំណែកមត៌កដែលសន្តតិជនត្រូវទទួលបាន គឺជាចំណែកមត៌កដែលកំណត់ដោយច្បាប់។

<u>ករណីរកឃើញថាមានសន្តតិជនតែម្នាក់</u>

នៅពេលចាប់ផ្ដើមសន្តតិកម្ម សន្តតិជនតែម្នាក់នោះ ត្រូវធ្វើសន្តតិកម្មចំពោះអចលនវត្ថុ ដីនោះ។ ហើយប្រសិនបើសន្តតិជនរូបនោះ ចង់ធ្វើការចុះបញ្ជីផ្ទេរកម្មសិទ្ធិពីឈ្មោះ មតកជន ទៅឈ្មោះខ្លួន សន្តតិជនរូបនោះក្នុងនាមជាបុគ្គលដែលមានសិទ្ធិចុះបញ្ជី អាចដាក់ពាក្យសុំម្នាក់ឯង ដោយមូលហេតុសន្តតិកម្ម សុំចុះបញ្ជីទៅរដ្ឋបាលសុរិយោដីបាន[117]។

ក៏ប៉ុន្តែ ប្រសិនបើដីនោះ ដែលទទួលបានតាមរយៈសន្តតិកម្មមិនបានចុះបញ្ជីទេ ហើយក្រោយមកមានកិច្ចសន្យាទិញ-លក់ថ្មីមួយកើតឡើង ការចុះបញ្ជីផ្ទេរកម្មសិទ្ធិនៅទីនេះ គឺគេតម្រូវឱ្យទាំងភាគីអ្នកលក់ (បុគ្គលមានកាតព្វកិច្ចចុះបញ្ជី) នឹងទាំងភាគីអ្នកទិញ (បុគ្គលដែលមានសិទ្ធិចុះបញ្ជី) ដាក់ពាក្យសុំចុះបញ្ជីរួមគ្នាទៅរដ្ឋបាលសុរិយោដី។ ហើយមួយវិញទៀត ដើម្បីអាចទទួលបានការចុះបញ្ជីមកឈ្មោះអ្នកទិញនោះបាន គឺត្រូវបញ្ជីពីរលើក ដោយមានមូលហេតុផ្សេងទៀត ពោលគឺទី ១ ដោយមូលហេតុសន្តតិកម្ម ពីមតកជនមកសន្តតិជនដែលជាអ្នកលក់ និងទី ២ គឺមូលហេតលក់-ទិញ ពីអ្នកលក់ទៅអ្នកទិញ។ គេមិនអាចធ្វើការចុះបញ្ជីដោយរំលងបានទេ ដែលវាអាចធ្វើឱ្យបាត់ព័ត៌មាន ឬ ប្រវត្តិនៃដី[118]។

ក៏ប៉ុន្តែ ប្រសិនបើការចុះបញ្ជីផ្ទេរកម្មសិទ្ធិនោះ ដោយមូលហេតុសន្តតិកម្មមិនបានធ្វើទេ (លើកទី១) ប្រសិនបើមាន មូលហេតុសន្តតិកម្មបន្តទៀត (លើកទី២) គេអាចបកស្រាយថា អាចចុះបញ្ជីបានដោយរំលង តែត្រូវបញ្ជាក់ឱ្យបានច្បាស់ថា ដោយមូលហេតុសន្តតិកម្ម[119]។

---

[116] ទេព បូផល និង អ៊ីវ ប៉ូលី, *ការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយមូលហេតុសន្តតិកម្ម* (ភ្នំពេញ៖ វិភាគទានច្បាប់, ២០១៨), https://www.facebook.com/media/set/?vanity=contributionoflaws&set=a.779599389048127 (ចម្លងថ្ងៃទី ១0 កក្កដា ២០២១), ទំព័រ ២១។

[117] ដដែល, ទំព័រ ២៣។

[118] ដដែល, ទំព័រ ២៩។

[119] ដដែល, ទំព័រ ៣២។

<u>ករណីសហសន្តតិជន</u>

ក្នុងករណី មានសន្តតិជនច្រើននាក់ សហសន្តតិជនម្នាក់ៗ ត្រូវទទួលបន្តនូវ សិទ្ធិ និង ករណីយកិច្ចតាមសមាមាត្រនៃចំណែកមត៌ក។ ប៉ុន្តែ សិទ្ធិ និង ករណីយកិច្ច ដែលមិនអាចបែងចែកតាមលក្ខណៈនៃសិទ្ធិ ឬ ករណីយកិច្ចបាននោះ គឺត្រូវបន្តដោយអវិភាគយ៍។ ចំពោះកម្មវត្ថុនៃមត៌កជាដីធ្លី សហសន្តតិជន ត្រូវទទួលមត៌កស្ថិតក្នុងស្ថានភាពកម្មសិទ្ធិអវិភាគីយ៍[120]។

ការចុះបញ្ជីអាចត្រូវបានធ្វើឡើងរវាងកម្មសិទ្ធិករអវិភាគ ធ្វើការដាក់ពាក្យសុំ ទៅរដ្ឋបាលសុរិយោដី។ ករណីសហសន្តតិជនទាំងអស់ព្រមគ្នាជាឯកច្ឆ័ន្ទ ដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិ ទៅរដ្ឋបាលសុរិយោដី នោះមិនជាបញ្ហាទេ។ អ្វីដែលបញ្ហា គឺត្រង់ថា មានសហសន្តតិជនខ្លះចង់ចុះបញ្ជី ហើយខ្លះទៀតមិនសហការ។ នៅក្នុងករណីនេះ ដោយសារតែពុំមានបទប្បញ្ញត្តិដែលទាក់ទងនឹងបញ្ហានេះ គឺអាចបកស្រាយបានថា សន្តតិជនដែលចង់ចុះបញ្ជី អាចដាក់ពាក្យសុំចុះបញ្ជីតែម្នាក់ឯង ដោយគ្មានភាគីសន្តតិជនផ្សេងទៀត ហើយចុះតែចំណែករបស់ខ្លួន(ដាក់ពាក្យសុំ) ឬ អាចចុះបញ្ជីសម្រាប់ចំណែករបស់សន្តតិជនផ្សេងទៀតបាន[121]។

## ផ្នែកទី ២ ៖ សន្តតិកម្មតាមមតកសាសន៍

ពាក្យថា « មតកសាសន៍ » ដោយយោងទៅតាមសន្ទានុក្រមផ្នែករដ្ឋប្បវេណី បានឱ្យនិយមន័យថា ជាលិខិតបណ្ដាំ ដែលបុគ្គលម្នាក់បានធ្វើឡើង តាមទម្រង់ដែលកំណត់ដោយច្បាប់ ដើម្បីសំដែងឆន្ទៈចុងក្រោយរបស់ខ្លួនទាក់ទងទៅនឹងការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍ នៅបន្ទាប់ពីខ្លួនទទួលមរណភាព[122]។ ជារួមមកវិញ យើងឃើញថា មតកសាសន៍ដែលអាចយកទៅអនុវត្តបាន នៅពេលចាប់ផ្ដើមសន្តតិកម្ម លុះត្រាតែលិខិតនោះ គោរពទៅតាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់។ បើទោះបីវាជាការសម្ដែងឆន្ទៈចុងក្រោយរបស់មតកជនក៏ពិតមែន ប៉ុន្តែដើម្បីចៀសវាងនូវបញ្ហាណាមួយកើតឡើង ពាក់ព័ន្ធទៅនឹងការបែងចែកមត៌ក ច្បាប់បានប្បញ្ញត្តិនូវវិធានមួយចំនួន ដើម្បីឱ្យម្ចាស់ទ្រព្យត្រូវគោរពតាម និង អនុវត្តឱ្យ បានពាក់ព័ន្ធទៅនឹងខ្លឹមសារ និង ការអនុវត្តមតកសាសន៍របស់ខ្លួន។ ហើយនៅក្នុងផ្នែកទី ២ នេះយើងនឹងធ្វើការសិក្សាទៅលើ ២ ចំណុច ពោលគឺ

[120] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៤៨។

[121] ទេព បូផល និង អ៊ីវ ប៉ូលី, *ការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយមូលហេតុសន្តតិកម្ម* (ភ្នំពេញ៖ វិភាគទានច្បាប់, ២០១៨), https://www.facebook.com/media/set/?vanity=contributionoflaws&set=a.779599389048127 (ចម្លងថ្ងៃទី ១០ កក្កដា ២០២១) ទំព័រ ៣៣-៣៦។

[122] *សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី* (ភ្នំពេញ៖ ទីស្ដីការគណៈរដ្ឋមន្ត្រី, ២០០៧), ទំព័រ ១៧ (លេខរៀងទី ១១៨)។

លក្ខខណ្ឌសុពលភាពនៃមតកសាសន៍ (កថាខណ្ឌទី ១) និងពិភាក្សាផងដែរពាក់ព័ន្ធទៅនឹង នីតិវិធីនៃការបែងចែកមត៌ក (កថាខណ្ឌទី ២)។

### កថាខណ្ឌទី ១ ៖ លក្ខខណ្ឌសុពលភាពនៃមតកសាសន៍

#### ១. លក្ខខណ្ឌគ្រឹះ

ជាទូទៅ បើយើងនិយាយអំពីខ្លឹមសារនៃកិច្ចសន្យា មានអានុភាពបាន ទាល់តែ វាកើតឡើងតាមរយៈការព្រមព្រៀង ហើយនៅពេលដែលសំណើ និង ស្វីការត្រូវគ្នា[123]។ ប៉ុន្តែចំពោះលក្ខខណ្ឌគ្រឹះ នៅទីនេះ ដោយសារតែមតកសាសន៍ ជាការបង្ហាញឆន្ទៈដោយឯកតោភាគី របស់ម្ចាស់ទ្រព្យ ដូច្នេះហើយ ពាក់ព័ន្ធជាមួយទៅនឹងលក្ខខណ្ឌនៃការព្រមព្រៀង គឺអាចនឹងពិចារណាថា មិនមានដូចគ្នាទៅនឹងលក្ខខណ្ឌនៃកិច្ចសន្យាទេ។ ក៏ប៉ុន្តែ គេក៏អាចនិយាយបានថា ការព្រមព្រៀងអាចនឹងកើតមានឡើងនៅពេលដែលសន្តតិកម្មត្រូវបានចាប់ផ្តើម ពោលគឺនៅក្រោយពេលដែលម្ចាស់ទ្រព្យបានទទួលមរណភាព ដែលធ្វើឡើងដោយសន្តតិជនរបស់មតកជននោះ។ ក្រៅពីនេះ ឆន្ទៈរបស់ភាគី ក៏ជាកត្តាសំខាន់ដែលត្រូវពិចារណាពាក់ព័ន្ធទៅនឹងលក្ខខ័ណ្ឌគ្រឹះនៃមតកសាសន៍ ដែលត្រូវធ្វើយ៉ាងណាធានាថា ការបង្ហាញឆន្ទៈរបស់មតកជនត្រូវតែជាការបង្ហាញឆន្ទៈដែលពុំមានវិការៈ។ បន្ថែមពីនោះទៀត យោងតាមបញ្ញត្តិនៃមាត្រា ១១៦៨ នៃក្រមរដ្ឋប្បវេណី ពាក់ព័ន្ធលក្ខខណ្ឌសមត្ថភាពរបស់ម្ចាស់ទ្រព្យដែលអាចធ្វើបណ្តាំបាន យើងឃើញថា បុគ្គលដែលអាចធ្វើមតកសាសន៍បាន ត្រូវតែជាបុគ្គលដែលមានកំណត់ដូចតទៅ៖ ត្រូវតែជានីតិជន ដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ឬជននោះអាចជាអនីតិជនដែលមានអត្តាធិនភាពពោលគឺជាជនដែលមានអាយុមិនតិចជាង ១៦ ឆ្នាំ ហើយមិនស្ថិតនៅក្រោមអំណាចមេបា ឬ របបអាណាព្យាបាលសម្រាប់អនីតិជនឡើយ[124]។ នៅទីនេះ ក៏យើងអាចធ្វើការគួរបញ្ជាក់ផងដែរថា បុគ្គលដែលស្ថិតនៅក្រោមរបបអាណាព្យាបាលទូទៅ ក៏អាចធ្វើបណ្តាំបានដែរ។ ហើយទាញចេញពីការបកស្រាយនេះ នៅពេលដែលជនស្ថិតនៅក្រោមរបបអាណាព្យាបាលទូទៅ អាចធ្វើបណ្តាំបាន ដែលអាចឱ្យយើងយល់បានថាជនដែលស្ថិតនៅក្រោមរបបហិតូបត្ថម្ភ ក៏អាចធ្វើនូវលិខិតបណ្តាំនេះបានផងដែរ[125]។

#### ២. លក្ខខណ្ឌទម្រង់

ដោយយោងតាមបញ្ញត្តិនៃមាត្រា ១១៧០ នៃក្រមរដ្ឋប្បវេណី (២០០៧) មតកសាសន៍ដែលពុំធ្វើដោយអនុលោមទៅតាមលក្ខខណ្ឌទម្រង់ ដែលមានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីនេះទេ នឹងត្រូវបានចាត់ទុកជា

---

123 ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៣៦-១។

124 ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី (ភាគ ៦ : គន្ថីទី ៨)* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០), មាត្រា ១១៦៨-១។

125 ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៦។

មោឃៈ[126]។ ផ្ទុយមកវិញ គេអាចនិយាយបានថា ចំពោះមតកសាសន៍ ឬ លិខិតបណ្តាំ ដែលគោរពត្រឹមត្រូវតាមទម្រង់ណាមួយដែលមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីនេះ ត្រូវចាត់ទុកថាមានសុពលភាពចំពោះទម្រង់[127]។

**ក. មតកសាសន៍សម្រាប់ស្ថានភាពធម្មតា**

ជាទូទៅ នៅក្នុងស្ថានភាពធម្មតា មតកសាសន៍ អាចត្រូវបានធ្វើឡើងទៅតាមទម្រង់ ៣(បី)យ៉ាង ពោលគឺមតកសាសន៍ដែលធ្វើឡើងដោយលិខិតយថាភូត មតកសាសន៍ដោយលិខិតឯកជន និង មតកសាសន៍ដោយលិខិតសម្ងាត់។

<u>មតកសាសន៍ដោយលិខិតយថាភូត</u>

មតកជននៅពេលនៅរស់អាចសម្តែងឆន្ទៈ ពាក់ព័ន្ធទៅនឹងការចាត់ចែងបេតិកភណ្ឌរបស់ខ្លួន តាមរយៈមតកសាសន៍ដោយលិខិតយថាភូត នៅចំពោះមុខសារការីបាន។ ហើយចំពោះទម្រង់នៃមតកសាសន៍ដោយលិខិតយថាភូតនោះ ត្រូវតែធ្វើឡើងដោយគោរពទៅលើលក្ខខណ្ឌមួយចំនួនដូចជា (១) ត្រូវមានអន្តរាគមន៍ពីសារការី, (២) មានវត្តមាននៃសាក្សីយ៉ាងតិចពីរនាក់ ហើយសាក្សីនោះទៀតសោតត្រូវតែជាសាក្សីដែលគោរពទៅតាមបទប្បញ្ញត្តិនៃមាត្រា ១១៧២ នៃក្រមរដ្ឋប្បវេណី, (៣) ម្ចាស់បណ្តាំត្រូវប្រាប់ដោយផ្ទាល់មាត់នូវខ្លឹមសារនៃមតកសាសន៍នៅចំពោះមុខសារការី, (៤) សារការីត្រូវសរសេរនូវអត្ថន័យមតកសាសន៍របស់ម្ចាស់បណ្តាំនោះ ជាលាយលក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្តាំ និង សាក្សីនោះបានស្តាប់, (៥) ចំពោះលក្ខខណ្ឌចុងក្រោយ យើងឃើញថា បន្ទាប់ពីម្ចាស់បណ្តាំ និង សាក្សី បានទទួលស្គាល់ថា កំណត់ត្រាដែលធ្វើឡើងដោយសារការីជាលាយលក្ខណ៍អក្សរនោះត្រឹមត្រូវហើយ ទាំងម្ចាស់បណ្តាំ និង សាក្សី ត្រូវធ្វើឱ្យមានភាពច្បាស់លាស់នៅក្នុងលិខិតនោះ ពាក់ព័ន្ធទៅនឹងឈ្មោះ អាយុ ក៏ដូចជាលំនៅឋាន ហើយត្រូវចុះហត្ថលេខារៀងខ្លួន[128]។ ហើយពាក់ព័ន្ធទៅនឹងការចុះហត្ថលេខានេះ ម្ចាស់បណ្តាំត្រូវចុះហត្ថលេខា មិនអាចធ្វើការផ្តិតម្រាមដៃជំនួសឡើយ តែសាក្សីអាចធ្វើការផ្តិតម្រាមដៃជំនួសហត្ថលេខាបាន[129]។

ចំពោះការធ្វើមតកសាសន៍ដោយលិខិតយថាភូតនេះ យើងឃើញថា វាក៏នាំមកនូវគុណសម្បត្តិ និង គុណវិបត្តិមួយចំនួនផងដែរ ដែលគុណសម្បត្តិយើងឃើញថា វាធ្វើឱ្យមានភាពត្រឹមត្រូវច្បាស់លាស់ ដោយហេតុថា ការធ្វើនៅចំពោះមុខសាការី ជាអ្នកច្បាប់ ហេតុនេះហើយ ចំពោះបញ្ហាអសុពលភាពដោយសារតែកង្វះនូវ

---

[126] ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី (ភាគ ៦ : គន្ថីទី ៨)* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០), មាត្រា ១១៧០-១។

[127] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧១។

[128] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៣។

[129] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៨០។

លក្ខណៈគតិយុត្ត គឺនឹងត្រូវបានកាត់បន្ថយមួយចំនួនធំ។ លក្ខណៈសម្បត្តិទី ២ គឺវានឹងជាការប្រសើរចំពោះជនដែលមិនចេះអក្សរ ពីព្រោះថាគាត់ក៏អាចធ្វើមតកសាសន៍បានដែរ ដោយគ្រាន់តែធ្វើការពន្យល់អំពីខ្លឹមសាររបស់បណ្តាំដែលខ្លួនចង់បាន ដោយផ្ទាល់មាត់ ចំពោះសារការី សារការីនឹងជួយសម្រួលនៅក្នុងការចាត់ចែងជាលាយលក្ខណ៍អក្សរទៅក្នុងលិខិតយថាភូតនោះបាន។ ហើយ គុណសម្បត្តិទី ៣ គឺអាចជាការការពារកុំឱ្យមានការបាត់បង់ ឬ ការក្លែងបន្លំ ឬ ការធ្វើក្លែងក្លាយនូវលិខិតបណ្តាំ ពាក់ព័ន្ធទៅនឹងការអនុវត្ត។ សារការី ឬ មន្ទីរសារការី និយាយជារួម គឺជាកន្លែងដែលតម្កល់នូវលិខិតមតកសាសន៍ដោយលិខិតយថាភូតនេះ។ គុណសម្បត្តិទី ៤ គេអាចនិយាយបានថា នៅពេលអនុវត្តមតកសាសន៍ គឺមិនចាំបាច់មាននីតិវិធីពិនិត្យនិងបញ្ជាក់នៅតុលាការទេ។ ឬ អាចនិយាយបានម៉្យាងទៀតថា មតកសាសន៍ប្រភេទនេះ អាចបើកនៅក្រៅតុលាការបាន[130]។ ផ្ទុយពីនេះ បើយើងនិយាយអំពីគុណវិបត្តិ នៃមតកសាសន៍ដោយលិខិតយថាភូតនេះ យើងឃើញថា វាទាមទារជាចាំបាច់ត្រូវតែមានការចូលរួមអន្តរាគមន៍ពីសារការី ហើយត្រូវចាំបាច់ផងដែរ ឱ្យមានសាក្សីដឹងឮ ពីខ្លឹមសារនៃឯកសារនេះ[131]។

<u>មតកសាសន៍ដោយលិខិតឯកជន</u>

ចំពោះការបង្ហាញឆន្ទៈពាក់ព័ន្ធទៅនឹងការចាត់ចែកបេតិកភណ្ឌរបស់ខ្លួន នៅពេលដែលខ្លួននៅរស់មានជីវិត ម្ចាស់ទ្រព្យអាចធ្វើលិខិតបណ្តាំរបស់ខ្លួន ជាមតកសាសន៍ដោយលិខិតឯកជនបាន ហើយមតកសាសន៍ជាលិខិតឯកជនរបស់ខ្លួន ត្រូវគោរពទៅតាមខ្លឹមសារនៃច្បាប់ ពិសេសគឺនៅត្រង់ប្បញ្ញត្តិនៃមាត្រា ១១៧៤ នៃក្រមរដ្ឋប្បវេណី។ ចំពោះទម្រង់នៃមតកសាសន៍ដោយលិខិតឯកជននៅទីនេះ ម្ចាស់ទ្រព្យ ឬ ម្ចាស់បណ្តាំ ត្រូវសរសេរដោយខ្លួនឯង និង ផ្ទាល់ដៃ (លក្ខខណ្ឌទី ១) ហើយត្រូវចុះនូវ ថ្ងៃខែឆ្នាំ និង ហត្ថលេខាឱ្យបានច្បាស់លាស់នៅលើនោះ ហើយពាក់ព័ន្ធទៅនឹងក្នុងករណីដែល លិខិតនោះត្រូវបានសរសេរជំនួសដោយអ្នកដទៃ ឬ សរសេរដោយការប្រើប្រាស់ម៉ាស៊ីនអង្គុលីលេខ ជាអាទិ៍ ត្រូវចាត់ទុកជាមោឃៈ។ ហើយមួយវិញទៀតពាក់ព័ន្ធទៅនឹងការបន្ថែម ឬ ការកោសលុប កែប្រែផ្សេងៗ នៅក្នុងមតកសាសន៍ដោយលិខិតឯកជន គឺនឹងពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំ ពុំបានបង្ហាញភស្តុតាងនៅកន្លែង ហើយសរសេរបន្ថែមនូវហេតុនៃការកែប្រែនោះ និងជាពិសេស គឺមិនបានចុះហត្ថលេខាតែម្តងនោះ[132]។

---

[130] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៣-២។

[131] សមាជិកក្រុមការងារ អនាគតគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រម និង នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃវិទ្យាស្ថានស្រាវជ្រាវ និង បណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន (ICD), *ក្រមរដ្ឋប្បវេណី ភាគទី ៦* (ភ្នំពេញ, ២០១២), ទំព័រ ៣៨។

[132] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៤។

មតកសាសន៍ដោយលិខិតឯកជនបែបនេះ ក៏មាននូវគុណសម្បត្តិ និង គុណវិបត្តិមួយចំនួនផងដែរ។ ពាក់ព័ន្ធនឹងគុណសម្បត្តិ យើងឃើញថា ម្ចាស់បណ្តាំអាចធ្វើតែឯងបាន ដោយមិនចាំបាច់មានអន្តរាគមន៍ពីសារការី ឬ មានវត្តមានរបស់សាក្សីឡើយ។ ម៉្យាងទៀត គេអាចនិយាយបានថា វាមានភាពងាយស្រួលបត់បែននៅក្នុងការបង្កើត ក៏ដូចជាជាការកែប្រែ។ ហើយមួយវិញទៀត បើយើងនិយាយអំពីការទៅពឹងពាក់សារការីក្នុងការធ្វើលិខិតបណ្តាំ វាអាចនឹងចំណាយសោហ៊ុយមួយចំនួន ប៉ុន្តែនៅទីនេះគឺមិនចាំបាច់អស់សោហ៊ុយឡើយពាក់ព័ន្ធទៅនឹងការធ្វើមតកសាសន៍ក្នុងទម្រង់នេះ។ ហើយចំពោះគុណសម្បត្តិទី ៣ គឺអាចពាក់ព័ន្ធទៅនឹងការរក្សាការសម្ងាត់នៃខ្លឹមសាររបស់មតកសាសន៍នោះ ដោយហេតុថាបណ្តាំនោះ ដឹងតែអ្នកដែលបានធ្វើវានោះតែប៉ុណ្ណោះ។ ដោយឡែក ពាក់ព័ន្ធជាមួយនឹងគុណវិបត្តិ ឬ បញ្ហាប្រឈមវិញ យើងឃើញថា ប្រសិនបើម្ចាស់បណ្តាំគាត់មិនចេះអក្សរ នោះវានឹងពិបាកសម្រាប់គាត់ ដែលគាត់មិនអាចធ្វើបណ្តាំបែបនេះបានឡើយ។ ហើយមួយវិញទៀត ប្រសិនបើម្ចាស់បណ្តាំភ្លេចចុះហត្ថលេខា ឬ គ្រាន់តែផ្តិតមេដៃ ឬ ក៏ភ្លេចចុះនៃកាលបរិច្ឆេទ នៅពេលនោះវានឹងធ្វើឱ្យមតកសាសន៍ដោយលិខិតឯកជន នោះបាត់សុពលភាព។ មួយវិញទៀត លិខិតប្រភេទនេះអាចនឹងត្រូវបានបាត់ ឬ អាចនឹងត្រូវមានការធ្វើក្លែងក្លាយ ឬ ក្លែងបន្លំបាន។ ហើយជាចុងក្រោយ គុណវិបត្តិ ឬក៏បញ្ហាប្រឈម នៃមតកសាសន៍ដោយលិខិតឯកជននេះ គឺពាក់ព័ន្ធទៅនឹងការអនុវត្តតែម្តង។ ដើម្បីអនុវត្តមតកសាសន៍ដោយលិខិតឯកជននេះបាន គឺគេត្រូវតែដាក់ពាក្យសុំពិនិត្យ និង បញ្ជាក់ ក៏ដូចជាបើកវា នៅតុលាការ[133]។

មតកសាសន៍ដោយលិខិតសម្ងាត់

នៅក្នុងវិធីធ្វើមតកសាសន៍ធម្មតា ម្ចាស់ទ្រព្យក៏អាចធ្វើមតកសាសន៍ដោយលិខិតសម្ងាត់បានផងដែរ។ ពាក់ព័ន្ធទៅនឹងមតកសាសន៍ដោយលិខិតសម្ងាត់នេះ យើងឃើញថា ចំពោះខ្លឹមសារនៃបណ្តាំ គឺត្រូវបានធានាការសម្ងាត់។ ហើយមួយវិញទៀត ចំពោះទម្រង់ទៅតាមផ្លូវច្បាប់ដែលត្រូវគោរពមានដូចជា ម្ចាស់បណ្តាំត្រូវចុះហត្ថលេខាលើលិខិតនោះ (លក្ខខណ្ឌទី ១)។ ត្រង់ចំណុចនេះ វាអាចរំលេចជាការបកស្រាយបានថា គេអាចធ្វើលិខិតបណ្តាំនោះដោយប្រើប្រាស់ម៉ាស៊ីនក៏បាន ឬ អាចឱ្យអ្នកដទៃសរសេរជំនួសក៏បាន។ ហើយចំពោះលក្ខខណ្ឌទី ២ លិខិតបណ្តាំនោះ ត្រូវតែដាក់នៅក្នុងស្រោមបិទជិត ហើយចុះហត្ថលេខា ឬ សរសេរសញ្ញាសម្គាល់ផ្សេងទៀត ដែលអាចដឹងបានពីការដែលបានបើក ឬមិន បានបើកលិខិតនោះ។ ដោយឡែក ចំពោះលក្ខខណ្ឌទី ៣ គឺម្ចាស់បណ្តាំត្រូវដាក់លិខិតបិទជិតនោះ នៅចំពោះមុខសារការីម្នាក់ និងសាក្សីពីរនាក់ ហើយធ្វើសេចក្តីថ្លែងការណ៍ថា មតកសាសន៍នោះ ជារបស់ខ្លួនពិតប្រាកដមែន។ និង លក្ខខណ្ឌទី ៤ សារការីត្រូវចុះថ្ងៃខែ

[133] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៣។

ឆ្នាំ ដែលដាក់លិខិតមកមន្ទីរសារការីរបស់ខ្លួន នឹងសរសេរសេចក្ដីថ្លែងការណ៍របស់ម្ចាស់បណ្ដាំ នៅលើលិខិតនោះ រួចចុះហត្ថលេខារួមគ្នា ជាមួយនឹងសាក្សី ក៏ដូចជាម្ចាស់បណ្ដាំ[134]។

ចំពោះគុណសម្បត្តិនៃមតកសាសន៍ដោយលិខិតសម្ងាត់ យើងឃើញថា បើទោះបីជាម្ចាស់បណ្ដាំមិនចេះអក្សរ ក៏អាចធ្វើបានដែរ ហើយក៏អាចជួយសម្រួលដល់ម្ចាស់បណ្ដាំតាមរយៈការប្រើប្រាស់ម៉ាស៊ីន ឬ ក៏ឱ្យអ្នកដទៃសរសេរជំនួសឱ្យក៏បានដែរ។ គុណសម្បត្តិទី ២ គឺមានការចូលរួមអន្តរាគមន៍ពីសារការី និង បានដឹងឮដោយសាក្សីពីរនាក់ទៀតផង។ គុណសម្បត្តិទី ៣ យើងឃើញថា ពាក់ព័ន្ធទៅនឹងសុវត្ថិភាពនៃលិខិតបណ្ដាំនោះ ដោយវាបានដាក់តម្កល់ និង ថែរក្សាទុកនៅក្នុងមន្ទីរសារការី។ ហើយចំពោះគុណសម្បត្តិមួយទៀត គេអាចនិយាយបានថា ការសម្ងាត់ត្រូវបានធានាយ៉ាងមុតមាំ ចំពោះខ្លឹមសារនៃលិខិតបណ្ដាំប្រភេទនេះ។ ហើយចំពោះគុណវិបត្តិនៃមតកសាសន៍ប្រភេទនេះ គឺដោយហេតុថាខ្លឹមសាររបស់មតកសាសន៍នោះមានលក្ខណៈសម្ងាត់ដូច្នេះហើយវាអាចនឹងងាយខុស នឹងលក្ខខណ្ឌសុពលភាពមួយចំនួន។ ហើយមិនតែប៉ុណ្ណោះ ពាក់ព័ន្ធទៅនឹងការអនុវត្តនៃលិខិតបណ្ដាំនេះ គឺត្រូវតែដាក់ពាក្យសុំពិនិត្យនិងបញ្ជាក់ ហើយបើកនៅតុលាការទើបបាន[135]។

### ខ. មតកសាសន៍សម្រាប់ស្ថានភាពពិសេស

<u>មតកសាសន៍នៃជនដែលស្ថិតនៅក្រោមរបបអាណាព្យាបាលទូទៅ</u>

នៅទីនេះ យើងឃើញថា ជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ក៏អាចធ្វើមានលិខិតបណ្ដាំបានដែរ នៅពេលដែលខ្លួនជាសះស្បើយមួយរយៈឡើងវិញ មាននូវសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ហើយត្រូវមានការចូលរួមនៃវត្តមានរបស់វេជ្ជបណ្ឌិតយ៉ាងតិច ២ នាក់ ជាសាក្សី។ ហើយមិនតែប៉ុណ្ណោះ វេជ្ជបណ្ឌិត ដែលមានវត្តមាននៅពេលធ្វើមតកសាសន៍ត្រូវបញ្ជាក់បន្ថែមលើលិខិតនោះថា នៅពេលដែលម្ចាស់បណ្ដាំធ្វើមតកសាសន៍ គាត់ពុំបានស្ថិតនៅក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃអំពើរបស់ខ្លួនដោយសារវិបត្តិស្មារតីនោះទេ ហើយវេជ្ជបណ្ឌិតត្រូវចុះហត្ថលេខាដោយបញ្ជាក់ថា ខ្លួនជាវេជ្ជបណ្ឌិតផងដែរ[136]។

<u>មតកសាសន៍នៃជនដែលកំពុងជួបគ្រោះថ្នាក់ដល់អាយុជីវិត</u>

ចំពោះម្ចាស់បណ្ដាំដែលកំពុងជួបគ្រោះថ្នាក់ដល់អាយុជីវិតដោយសារតែជំងឺ ឬ ហេតុផលផ្សេងៗ ហើយដែលមានបំណងចង់ធ្វើមតកសាសន៍ នោះគាត់អាចធ្វើទៅបាន ដោយមានវត្តមានសាក្សីយ៉ាងតិច ៣(បី) នាក់

[134] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៥។
[135] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៣។
[136] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៦។

ហើយបានប្រកាសខ្លឹមសារនេះ ដោយផ្ទាល់មាត់នៅចំពោះជនម្នាក់នៅក្នុងចំណោមសាក្សីទាំងនោះ។ ក្នុងករណីនេះ ជនដែលទទួលបានការប្រកាស ត្រូវសរសេរជាលាយលក្ខណ៍អក្សរនៅក្នុងមតកសាសន៍នោះ ហើយអានឱ្យអ្នកដទៃស្តាប់ ឬ មើល ហើយក្រោយពេលបានស្តាប់ ឬ មើលហើយ សាក្សីត្រូវចុះហត្ថលេខាលើលិខិតនោះ។ សាក្សីណាម្នាក់ ឬ បុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធត្រូវដាក់ពាក្យសុំទៅតុលាការក្នុងកំឡុងពេល ១ ខែ គិតចាប់ពីពេលដែលបានធ្វើមតកសាសន៍នោះ ដើម្បីអាចទទួលបានការបញ្ជាក់អំពីភាពត្រឹមត្រូវ។ ហើយនៅទីនេះយើងឃើញថា តុលាការត្រូវធ្វើការបញ្ជាក់ឯកសារនោះ ប្រសិនបើយល់ឃើញថាមតកសាសន៍នោះ ចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំពិតប្រាកដមែន[137]។

មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង

ចំពោះខ្លឹមសារនៃក្រមរដ្ឋប្បវេណី យើងមិនត្រឹមតែគោរពពាក់ព័ន្ធទៅនឹងឆន្ទៈរបស់បុគ្គលដែលមានសិទ្ធិសេរីភាពដើរហើរប៉ុណ្ណោះទេ ដោយឡែកចំពោះជនដែលត្រូវជាប់ឃុំឃាំងដោយសារសេចក្តីសម្រេចរបស់តុលាការ ក៏អាចធ្វើលិខិតមតកសាសន៍ តាមឆន្ទៈរបស់ខ្លួនបានដែរ ដោយមានវត្តមាននគរបាល ឬ មន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ និង សាក្សីយ៉ាងតិច ២(ពីរ)នាក់។ ហើយបើនៅក្នុងករណីម្ចាស់បណ្តាំស្ថិតនៅក្នុងនាវា ឬ យន្តហោះអាចធ្វើក៏អាចធ្វើមតកសាសន៍បាន តែដោយត្រូវមានវត្តមានមេបញ្ជាការ ឬ បរិបាលនាវា ឬ បុគ្គលិកនាវា និង សាក្សីយ៉ាងតិចពីរនាក់។ ហើយជនដែលត្រូវជាប់ឃុំឃាំងនោះ អាចធ្វើមតកសាសន៍បានដោយផ្ទាល់មាត់ ហើយមន្ត្រីនគរបាល ឬ មន្ត្រីនៃមន្ទីរឃុំឃាំង ជាអាទិ៍ ត្រូវបានបកស្រាយថាមានតួនាទីដូចជាសារការី។ ហើយចំពោះមតកសាសន៍នេះ ពុំមានអានុភាពឡើយប្រសិនបើម្ចាស់បណ្តាំបន្តនៅរស់ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលខ្លួនត្រូវបានដោះលែង[138]។

មតកសាសន៍នៃជនដែលមិនអាចនិយាយបាន

ជនដែលមិនអាចនិយាយបាន អាចធ្វើមតកសាសន៍បាន ដោយម្ចាស់បណ្តាំធ្វើសេចក្តីថ្លែងការណ៍អំពីខ្លឹមសារមតកសាសន៍ តាមការបកប្រែរបស់អ្នកបកប្រែ ឬ សរសេរដោយដៃ ផ្ទាល់ខ្លួន នៅចំពោះមុខសារការី ឬ សាក្សី។ សារការី ឬ បុគ្គលផ្សេងទៀតត្រូវអានឱ្យម្ចាស់បណ្តាំស្តាប់ ឬ សាក្សីស្តាប់នូវខ្លឹមសារនៃមតកសាសន៍ក្រោយពេលសរសេរជាលាយលក្ខណ៍អក្សរ អំពីខ្លឹមសារនោះ។ ហើយបើម្ចាស់បណ្តាំថ្លង់ ត្រូវអានឱ្យស្តាប់ដោយ

[137] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៧។

[138] សមាជិកក្រុមការងារ អនាគតគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រម និង នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃវិទ្យាស្ថានស្រាវជ្រាវ និង បណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន (ICD), *ក្រមរដ្ឋប្បវេណី ភាគទី ៦* (ភ្នំពេញ, ២០១២), ទំព័រ ៤១។

មានការបកប្រែពីអ្នកបកប្រែទៅដល់ម្ចាស់បណ្តាំ ឬ សាក្សី។ សារការី ឬ បុគ្គលផ្សេងទៀតត្រូវសរសេរអំពីហេតុនោះនៅក្នុងលិខិតនោះ[139]។

មតកសាសន៍របស់អ្នកមានសញ្ជាតិខ្មែរ រស់នៅបរទេស

ចំពោះអ្នកដែលមានសញ្ជាតិខ្មែរ ហើយរស់នៅបរទេស អាចធ្វើមតកសាសន៍ដោយលិខិតយថាភូត ឬ លិខិតសម្ងាត់ នៅទីកន្លែងដែលមានកុងស៊ុល ឬ ស្ថានកុងស៊ុល នៃប្រទេសកម្ពុជាប្រចាំនៅ ដោយកុងស៊ុល ឬ ទូត ត្រូវអនុវត្តតួនាទីជាសារការី[140]។

**គ. ខ្លឹមសារនៃមតកសាសន៍**

ចំពោះខ្លឹមសារនៃមតកសាសន៍ ក៏ជាចំណុចសំខាន់ផងដែរ ដែលត្រូវដាក់បញ្ចូលទៅក្នុងលិខិតបណ្តាំ ហើយវាមានលក្ខណៈឆ្លុះបញ្ចាំងពីឆន្ទៈផ្ទាល់របស់មតកជន ហើយច្បាប់បានកំណត់នូវចំណុចសំខាន់ៗមួយចំនួនពាក់ព័ន្ធទៅនឹងខ្លឹមសារនៃមតកសាសន៍ ដូចជាការកំណត់ចំណែកមត៌ក ការកំណត់វិធីបែងចែក អនុប្បទាន ការកំណត់អ្នកប្រតិបត្តិមតកសាសន៍ និង ចំណុចផ្សេងៗទៀតផងដែរ។

ការកំណត់ចំណែកមត៌ក

ពាក់ព័ន្ធទៅនឹងការកំណត់ចំណែកមត៌ក មតកជនអាចធ្វើការសរសេរនៅក្នុងលិខិតបណ្តាំរបស់ខ្លួនទាក់ទង ទៅនឹងចំណែកមត៌ករបស់សហសន្តតិជន បើទោះបីជា វាផ្ទុយទៅនឹងប្បញ្ញត្តិស្តីពីផលប្រយោជន៍ពិសេសក៏ដោយ ប៉ុន្តែធ្វើយ៉ាងណាកុំឱ្យវាប៉ះពាល់ចំណែកមត៌កដែលបំពានទៅនឹងប្បញ្ញត្តិស្តីអំពីភាគបម្រុង[141]។

ការកំណត់វិធីបែងចែក

មតកជនអាចកំណត់នូវវិធីបែងចែក តាមរយៈមតកសាសន៍ ឬ ប្រគល់អាណត្តិឱ្យសន្តតិជនកំណត់ ឬ អាចហាមឃាត់មិនឱ្យបែងចែកនៅក្នុងកំឡុងពេលមិនលើសពី ៥ ឆ្នាំ គិតពីពេលដែលចាប់ផ្តើមសន្តតិកម្ម។

អនុប្បទាន

មតកជនអាចធ្វើអនុប្បទាននូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែក ឬ ធ្វើប្រទានកម្ម ឬ អច្ច័យទានតាមមតកសាសន៍ ទៅឱ្យជនដែលត្រូវបានសន្មតថា ជាសន្តតិជន ឬតតិយជនបានផងដែរ។ មួយវិញទៀត បើមតកជនបានធ្វើមតកសាសន៍ ដែលមានអត្ថន័យ ជាការធ្វើអនុប្បទាននូវទ្រព្យសម្បត្តិជាលក្ខខណ្ឌមួយ ឬ ច្រើនទៅឱ្យសហសន្តតិជនតែម្នាក់ ឬ ច្រើននាក់ មតកសាសន៍នោះ ត្រូវបានសន្មតថា ជាការកំណត់នូវវិធីនៃការបែងចែក

[139] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៧៩។

[140] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៨១។

[141] អ៊ីវ ប៉ូលី, *សន្តតិកម្ម (មេរៀនសង្ខេប)* (គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី, ២០១១), ១៧។

មត៌ក លើកលែងតែ មតកសាសន៍នោះមានអត្ថន័យជាអច្ច័យទានច្បាស់លាស់ ដូចជាអច្ច័យទានជាប់បន្ទុក ជាអាទិ៍ ហើយបើតម្លៃនៃទ្រព្យ ដែលបានកំណត់នោះមានចំនួនលើសចំណែកមត៌ករបស់សហសន្តតិជន បានកំណត់នូវចំណែកមត៌កផងដែរ។ លើសពីនេះទៀត បើមតកជនបានធ្វើមតកសាសន៍ចំពោះទ្រព្យតែមួយភាគនៅក្នុងចំណោមមត៌ក បើតម្លៃនៃទ្រព្យនោះ មានចំនួនតិចជាងចំណែកមត៌កដែលសន្តតិជននោះត្រូវទទួលខុសត្រូវលុះត្រាតែពុំមានការកំណត់ផ្សេង នៅក្នុងមតកសាសន៍នោះ ត្រូវសន្មតថា កំណត់វិធីបែងចែកមត៌ក ដែលត្រូវធ្លាក់ទៅលើសន្តតិជននោះតែប៉ុណ្ណោះ។

ការកំណត់អ្នកប្រតិបត្តិមតកសាសន៍

ម្ចាស់បណ្តាំ អាចកំណត់អ្នកប្រតិបត្តិមតកសាសន៍ម្នាក់ ឬ ច្រើននាក់ ឬ អាចប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិមតកសាសន៍បានផងដែរ។

ចំណុចផ្សេងៗ

ក្រៅពីចំណុចខាងលើ ដែលជាចំណុចនៃចរិតមតកសាសន៍ ម្ចាស់បណ្តាំក៏អាចផងដែរ កំណត់នូវប្បញ្ញត្តិដែលជាលក្ខខណ្ឌផ្សេងទៀត ដែលអាចនាំឱ្យមានសុខដុមរមនាដល់ក្រុមគ្រួសារបាន[142]។

## កថាខណ្ឌទី ២ ៖ នីតិវិធីក្នុងការបែងចែកមត៌ក

### ១. វិធានក្នុងការបែងចែកចំណែក

#### ក. ការបញ្ជាក់ និង ការបើកលិខិតមតកសាសន៍

មតកសាសន៍ដែលធ្វើឡើងក្រៅពីទម្រង់លិខិតយថាភូត ចាំបាច់ត្រូវធ្វើការពិនិត្យ និង បញ្ជាក់។ ការពិនិត្យ និង បញ្ជាក់លិខិតមតកសាសន៍ ត្រូវធ្វើឡើងដើម្បីឱ្យជនដែលមានផលប្រយោជន៍ពាក់ព័ន្ធបានដឹងឮ និងដើម្បីកំណត់នូវខ្លឹមសារនៃមតកសាសន៍នោះ។ ហេតុនេះអ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ ត្រូវដាក់ពាក្យសុំធ្វើការពិនិត្យនិងបញ្ជាក់នៅតុលាការ នៅពេលចាប់ផ្តើមសន្តតិកម្ម និង ប្រសិនបើរកឃើញមតកសាសន៍ក្រោយមក ត្រូវដាក់ពាក្យសុំទៅតុលាការ ដោយគ្មានការយឺតយ៉ាវ។ មួយវិញទៀត ចំពោះលិខិតមតកសាសន៍បិទដោយប្រថាប់ត្រា ត្រូវបើកនៅក្នុងនីតិវិធីតុលាការ ដើម្បីកុំឱ្យមានការកែប្រែ។ ក្នុងករណីប្រសិនបើមានជនណាមួយ បើកមតកសាសន៍ប្រភេទនេះនៅក្រៅតុលាការនោះ នឹងទទួលរងពិន័យស៊ីវិលមិនលើសពី ១ លានរៀល ក៏ប៉ុន្តែ ចំពោះលិខិតមតកសាសន៍នោះ មិនត្រូវបានចាត់ទុកថា បាត់អានុភាពដោយមូលហេតុនេះឡើយ។ ជារួមមកវិញ យើងឃើញថា ការពិនិត្យបញ្ជាក់លិខិតមតកសាសន៍ គឺមានគោលបំណងបញ្ជាក់អំពីអត្ថិភាព ឬ

---

[142] អ៊ុំ ប៉ូលី, *សន្តតិកម្ម (មេរៀនសង្ខេប)* (គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី, ២០១១), ១៧-១៩។

នត្ថិភាពនៃមតកសាសន៍ ដើម្បីមានភាពច្បាស់លាស់ ចំពោះឆន្ទៈពិតប្រាកដរបស់មតកជន និង ទម្រង់នៃការរៀបចំមតកសាសន៍តាមកំណត់នៃច្បាប់។ ហើយបើនៅក្នុងករណីរកឃើញថា មតកសាសន៍មានចំនួនច្រើនច្បាប់ គេត្រូវពិនិត្យអំពីទម្រង់ និង ខ្លឹមសារ ហើយប្រសិនបើត្រូវនឹងលក្ខខណ្ឌនៃការលុបចោលមតកសាសន៍ គេនឹងពិចារណាអនុវត្តទៅតាមទម្រង់នៃការលុបចោលនោះ[143]។

### ខ. ការបញ្ជាក់អំពីសន្តតិជន

នៅពេលដែលសន្តតិកម្មចាប់ផ្តើម បើទោះបី នោះជាសន្តតិកម្មតាមច្បាប់ ឬ សន្តតិកម្មតាមមតកសាសន៍ក៏ដោយ គេត្រូវធ្វើការផ្ទៀងផ្ទាត់អំពីអត្តសញ្ញាណសន្តតិជនឱ្យបានច្បាស់លាស់ ដោយភ្ជាប់ជាមួយនូវឯកសារបញ្ជាក់អត្តសញ្ញាណរបស់ជននោះ ដែលមានទំនាក់ទំនងញាតិជាមួយនឹងមតកជន ដូចជាសំបុត្រកំណើត សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ សំបុត្រមរណភាព និង ឯកសារអត្រានុកូលដ្ឋានផ្សេងៗទៀតដែលអាចបញ្ជាក់អំពីទំនាក់ទំនងញាតិនោះបាន។ ប្រសិនបើសន្តតិជនដែលបានកំណត់ហើយ ក៏ប៉ុន្តែក៏មិនអាចក្លាយជាសន្តតិជនបានដែរ ប្រសិនបើជននោះបានស្លាប់ ឬជាអភ័ព្វបុគ្គល ឬ ក៏ជាជនដែលត្រូវបានកាត់ផ្តាច់ពីមតកជាដើម។ ហើយនៅក្នុងករណីនេះ ប្រសិនបើរកឃើញថាមានសន្តតិជនជាជនបរទេស ឬ គ្មានសញ្ជាតិខ្មែរក៏មិនអាចទទួលមត៌កជាដីធ្លីបានដែរ ប៉ុន្តែនោះអាចធ្វើការចាត់ចែកដីធ្លីក្នុងអំឡុងពេល ៣ (បី) ខែដើម្បីប្តូរជាប្រាក់ បើផុតអំឡុងពេលនោះ គេនឹងធ្វើសន្តតិកម្មបន្ទាប់ទៅសន្តតិជនដែលមានសញ្ជាតិខ្មែរ តែបើគ្មានទៀតទេទ្រព្យសម្បត្តិនោះនឹងធ្លាក់ទៅជាទ្រព្យសម្បត្តិរដ្ឋ[144]។

### គ. ការបញ្ជាក់អំពីកម្មវត្ថុនៃសន្តតិកម្ម

កម្មវត្ថុនៃសន្តតិកម្ម គឺជាទ្រព្យផ្ទាល់របស់មតកជន ដែលនៅក្នុងនោះវាអាចជាទ្រព្យដោយឡែក និង ពាក់កណ្តាលនៃទ្រព្យសម្បត្តិរបស់មតកជន ប្រសិនបើមតកជនមានសហព័ទ្ធជាអាទិ៍។ ហើយចំពោះប្រភេទផ្សេងៗនៃទ្រព្យរបស់មតកជន អាចមានដូចជា ចលនទ្រព្យ អចលនទ្រព្យ ឬ សិទ្ធិលើបំណុលផ្សេងៗទៀត ដែលមតកជនមានកូនបំណុល។ល។ ហើយមួយវិញទៀត ពាក់ព័ន្ធទៅនឹងតម្លៃនៃកម្មវត្ថុដែលជាមត៌ក ជាទូទៅ ត្រូវបានបម្លែងជាប្រាក់ទៅតាមការសន្មត ដើម្បីងាយស្រួលក្នុងការបែងចែកមត៌កនោះ។ ហើយជាទូទៅ ការកំណត់តម្លៃកម្មវត្ថុមត៌ក ត្រូវសន្មតនៅពេលចាប់ផ្តើមសន្តតិកម្ម។ ហើយមួយវិញទៀត ពាក់ព័ន្ធទៅនឹងតម្លៃនេះផងដែរ ប្រសិនបើមិនមានការព្រមព្រៀងគ្នារវាងសន្តតិជនទាំងអស់ទេ ការវាយតម្លៃនោះ ភាគីអាចដាក់ពាក្យសុំទៅ

143 ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២១៣។

144 ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៤៩ - ១១៥៥, ១៣០០។

តុលាការ ដើម្បីជ្រើសរើសជ្រើសតាំងអ្នកជំនាញក្នុងការវាយតម្លៃ ដោយសួរយោបល់របស់ភាគីអំពីបុគ្គលដែលតុលាការមានបំណងជ្រើសរើស ប្រសិនបើមាន តែបើផ្សេងពីនេះ តុលាការនឹងសម្រេចដោយឆន្ទានុសិទ្ធិ។

**ឃ. ការបញ្ជាក់អំពីកាតព្វកិច្ច**

ដូចដែលយើងបានដឹងហើយថា របបសន្តតិកម្មនៅកម្ពុជា គឺទទួលយកតាមគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិ ហើយសន្តតិជននឹងទទួលស្នងនូវមត៌កទាំងសិទ្ធិ និង កាតព្វកិច្ចរបស់មតកជន ប្រសិនបើមិនមានការបោះបង់ណាមួយ។ ដូច្នេះហើយ នៅពេលចាប់ផ្តើមសន្តតិកម្ម គួរគប្បីស្រាវជ្រាវ និង ស្វែងយល់ពីបំណុលរបស់មតកជនផងដែរ ដើម្បីឱ្យមានភាពច្បាស់លាស់ថាតើទ្រព្យសកម្មច្រើនជាង ឬ តិចជាងបំណុលដែលនេះជាការចូលរួមយ៉ាងសំខាន់នៅក្នុងការបង្ហាញឆន្ទៈទទួលមត៌កដោយកម្រិត ទទួលទាំងស្រុង ឬក៏បោះបង់សន្តតិកម្មជាដើម។ ពាក់ព័ន្ធទៅនឹងកាតព្វកិច្ចនៅទីនេះផងដែរ ចំពោះបំណុលរបស់មតកជន គប្បីមានឯកសារបញ្ជាក់បំណុល ដែលអាចជាកិច្ចសន្យាខ្ចីប្រាក់ ជាអាទិ៍ តាមរយៈការសាកសួរពីសន្តតិជន ឯកសារនានាដែលបន្សល់ទុក ឬ តាមរយៈការប្រកាសជាសាធារណៈ។ ដូចនេះ ប្រសិនបើទ្រព្យអកម្មច្រើនជាង ការបោះបង់ឬក៏យល់ព្រមដោយកម្រិត គប្បីយកទៅអនុវត្ត។ ពាក់ព័ន្ធទៅនឹងសិទ្ធិយល់ព្រមដោយកម្រិត ឬក៏បោះបង់សន្តតិកម្ម សន្តតិជនរូបនោះមានអំឡុងពេល ៣ ខែ នៅពេលដែលដឹងថាសន្តតិកម្មបានចាប់ផ្តើមចំពោះខ្លួន រយៈពេល ៣ ខែនេះអាចនឹងមិនគ្រប់គ្រាន់ឡើយនៅក្នុងករណីមួយចំនួន ដែលនៅទីនេះច្បាប់អនុញ្ញាតឱ្យមានការសុំពន្យារពេលជាដើម។ ហើយតាមរយៈស្ថានភាពនោះ ភាគីដែលស្នើសុំពន្យារពេលអាចផ្អែកទៅលើករណីមួយចំនួនដូចជា ការពន្យារពេលដោយពាក្យសុំទៅតុលាការ (មាត្រា ១២៤៨) ករណីពិសេសដែលបណ្តាលឱ្យសន្តតិជនទទួលមរណៈភាព (មាត្រា ១២៤៩) ករណីពិសេសក្នុងករណីអនីតិជន (មាត្រា ១២៥០) និងករណីពិសេសដែលមិនដឹងពីអត្ថិភាពនៃកាតព្វកិច្ច (មាត្រា ១២៥១)។

**២. វិធានក្នុងការផ្ទេរកម្មសិទ្ធិ**

ដូចដែលបានដឹងហើយថា សន្តតិកម្មតាមមតកសាសន៍ គឺជាការផ្ទេរនូវសិទ្ធិ និង ករណីយកិច្ចពីទ្រព្យសម្បត្តិរបស់មតកជនទៅសន្តតិជន ហើយដែលម្ចាស់ទ្រព្យបង្ហាញឆន្ទៈតាមរយៈមតកសាសន៍ ដែលធ្វើឡើងតាមទម្រង់ដែលច្បាប់បានកំណត់។ ជាទូទៅ មតកសាសន៍ នឹងមានអានុភាពចាប់ពីពេលដែលម្ចាស់បណ្តាំទទួលមរណភាព លើកលែងតែ លិខិតបណ្តាំនោះមានភ្ជាប់មកជាមួយនូវលក្ខខណ្ឌបង្អង់ ដែលទាល់តែលក្ខខណ្ឌនេះត្រូវបានបំពេញ ទើបមតកសាសន៍នោះមានអានុភាព[145]។

[145] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៩៤។

ការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ តាមរយៈមតកសាសន៍ ត្រូវធ្វើឡើងដោយការដាក់ពាក្យសុំតែម្នាក់ឯង ដោយបុគ្គលដែលមានសិទ្ធិចុះបញ្ជី[146]។ ក៏ប៉ុន្តែ ប្រសិនបើក្នុងករណី អច្ច័យទាន ការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ គឺទាន់តែមានការចុះបញ្ជីរួមគ្នារវាងអ្នកមានសិទ្ធិ និងមានកាតព្វកិច្ចចុះបញ្ជី។ នៅទីនេះ យើងឃើញថា ប្រសិនបើអ្នកមានកាតព្វកិច្ចចុះបញ្ជីណាម្នាក់មិនព្រមសហការ ដាក់ពាក្យសុំចុះបញ្ជី (ករណីអច្ច័យទានទេ) ករណីនេះ ការចុះបញ្ជីមិនអាចធ្វើបានទេ។ ដូចនេះ សហសន្តតិជនផ្សេងទៀត ដើម្បីអាចចុះបញ្ជីបានត្រូវតែប្ដឹងទៅតុលាការទាមទារឱ្យអ្នកដែលមិនព្រមដាក់ពាក្យសុំចុះបញ្ជី ធ្វើនីតិវិធីចុះបញ្ជី។ ប្រសិនតុលាការសម្រេចបង្គាប់ឱ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដីនោះ ដោយមូលហេតុសន្តតិកម្ម ដើមបណ្ដឹងដែលទទួលបានសាលក្រមស្ថាពរ អាចដាក់ពាក្យសុំចុះបញ្ជីតែម្នាក់ឯង ដោយភ្ជាប់ជាមួយសាលក្រមនោះ ដោយចាត់ទុកថា ជាការបង្ហាញឆន្ទៈរបស់ចុងចម្លើយ[147]។

**ក. ការពិភាក្សាបែងចែកមត៌ក**

ជាគោលការណ៍ ការបែងចែកមត៌ក អាចត្រូវបានធ្វើឡើងតាមរយៈការពិភាក្សាគ្នានៃសហសន្តតិជនទាំងអស់ ដែលការពិភាក្សាគ្នា ពាក់ព័ន្ធទៅនឹងវិធីនៃការបែងចែកមត៌ក តើត្រូវបែងចែងដូចម្ដេច ដែលគេអាចធ្វើពេលណាក៏បានដែរ ក៏ប៉ុន្តែត្រូវរង់ចាំឱ្យកន្លងហួសរយៈពេល១(មួយ)ខែសិនក្រោយពីការចាប់ផ្ដើមសន្តតិកម្ម។ នៅក្នុងករណីនេះគេអាចធ្វើការបកស្រាយបាន ពាក់ព័ន្ធទៅនឹងរយៈពេលដែលសហសន្តតិជនត្រូវគោរពអំពីវិញ្ញាណក្ខន្ធរបស់មតកជន ក៏ដូចជា ការសិក្សាស្រាវជ្រាវអំពីបេតិកភណ្ឌរបស់មតកជននៅក្នុងពេលនោះ។ ការពិភាក្សាបែងចែកនេះ គឺផ្សេងពីចំណែកមត៌កតាមច្បាប់ ឬ តាមមតកសាសន៍ ហើយមិនមែនសុទ្ធតែអាចធ្វើបាននៅគ្រប់ករណីនោះទេ វាអាចធ្វើបានតែក្នុងករណីដែលការកំណត់ចំណែកមត៌ក ឬ វិធីបែងចែកមិនច្បាស់លាស់នៅក្នុងមតកសាសន៍ និងច្បាប់ផងដែរ។ ហើយបើការពិភាក្សាមិនអាចធ្វើបានទេ សហសន្តតិជនអាចដាក់ពាក្យសុំទៅតុលាការឱ្យបែងចែកមត៌កបាន[148]។

នៅទីនេះ យើងក៏ពិនិត្យឃើញដែរថា បើទោះបីជា នៅក្នុងមតកសាសន៍ បានកំណត់ច្បាស់លាស់ហើយក៏ដោយ ក្នុងករណីដែលសហសន្តតិជន ព្រមព្រៀងគ្នាជាឯកច្ឆ័ន្ទពិភាក្សាបែងចែកមត៌ក នោះគេអាចបែងចែកមត៌កតាមការពិភាក្សាបាន។ តែបើនៅទីនេះ មានវត្តមាននៃអ្នកប្រតិបត្តិមតកសាសន៍ ហើយបើទោះបីជា

[146] ប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី, លេខ ៥៩ ប្រក.ជនស/១១, ០៣ ឧសភា ២០១១, ប្រការ ១០ កថាខណ្ឌទី ២។

[147] ប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី, លេខ ៥៩ ប្រក.ជនស/១១, ០៣ ឧសភា ២០១១, ប្រការ ១០ កថាខណ្ឌទី ១។

[148] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦៦ និង មាត្រា ១២៧០។

សហសន្តតិជនព្រមព្រៀងហើយក៏ដោយ បើអ្នកប្រតិបត្តិមតកសាសន៍មិនយល់ព្រម គឺមិនអាចបែងចែកបានទេ។ តែបើអ្នកប្រតិបត្តិមតកសាសន៍យល់ព្រម នោះមិនជាបញ្ហាអ្វីទេ[149]។

ចំណុចមួយទៀត ដែលគួរកត់សម្គាល់គឺថា ការពិភាក្សាបែងចែកមត៌កនេះ មានអានុភាពប្រតិសកម្ម ចាប់តាំងពីពេលដែលមរណភាពរបស់មតកជន ហើយដោយសារតែសារធាតុនៃការពិភាក្សាបែងចែកមត៌ក គឺសម្រេចព្រមព្រៀងថាតើត្រូវបែងចែកទ្រព្យរបស់មតកជនដោយដូចម្តេច ហើយវាមិនមែនជាកិច្ចសន្យាឡើយ ដូច្នេះ លក្ខណៈសារធាតុនៃលទ្ធផលពីការពិភាក្សា ក៏នៅតែជាការទទួលបាន តាមរយៈសន្តតិកម្មដដែល ជាការផ្ទេរពីមតកជនទៅបុគ្គលណាមួយនោះ[150]។

ចំពោះការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអចលលវត្ថុ ក្រោយពីការការពិភាក្សាបែងចែកមត៌ក គឺអ្នកមានសិទ្ធិសុំចុះបញ្ជី អាចដាក់ពាក្យសុំចុះបញ្ជីតែម្នាក់ឯង ហើយដោយមូលហេតុសន្តតិកម្ម ពីមតកជន មកខ្លួនតែម្តងបាន នេះប្រសិនបើមិនទាន់បានចុះបញ្ជីពីមតកជន មកសហសន្តតិជនក្នុងរូបភាពជាកម្មសិទ្ធិអវិភាគយ៍។ ប៉ុន្តែបើបានចុះហើយក៏ដោយ ក៏ការចុះបញ្ជីផ្ទេរពីសហកម្មសិទ្ធិករអវិភាគ មកបុគ្គលដែលត្រូវទទួលតាមការពិភាក្សាបែងចែកមត៌ក ក៏នៅមានលក្ខណៈសារធាតុ ជាការផ្ទេរពីកម្មសិទ្ធិនៃមតកជន មកបុគ្គលនោះដែរ។ ជារួមមកវិញ ពាក្យថា អានុភាពប្រតិសកម្ម គឺសំដៅមានន័យថា បុគ្គលដែលទទួលបានតាមការពិភាក្សា ចាត់ទុកថា បានទទួលដោយផ្ទាល់ពី មតកជន។

ហើយមួយវិញទៀត គេការពារផងដែរពាក់ព័ន្ធទៅនឹងម្ចាស់សិទ្ធិលើបំណុលរបស់មតកជន នៅត្រង់ចំណុចនេះ ត្រង់ចំណុចដែលថាការផ្លាស់ប្តូរម្ចាស់សិទ្ធិលើមត៌ក ដោយសារលទ្ធផលនៃការបែងចែក មិនអាចធ្វើទៅបានឡើយ បើអំឡុងពេលច្បាប់កំណត់មិនទាន់កន្លងហួស ពោលគឺរយៈពេល ៣(បី)ខែនៃការបង្ហាញឆន្ទៈបោះបង់ ឬ យល់ព្រមមិនទាន់បានកន្លងហួស សន្តតិជនមិនទាន់អាចត្រូវបានក្លាយទៅជាម្ចាស់សិទ្ធិលើមត៌កបានឡើយ។ ក៏ប៉ុន្តែ នៅត្រង់ចំណុចនេះគេបានលើកឡើងថា កាលណាពាក់ព័ន្ធទៅនឹងភាពចាំបាច់ដើម្បីសងកាតព្វកិច្ចមតកជន ឬ មតកជនបានបង្ហាញឆន្ទៈនៅក្នុងមតកសាសន៍រួចមកហើយ អំពីអំឡុងពេលនៃការបែងចែកផ្សេងទៀត។ គួរបញ្ជាក់ផងដែរថា ការពិភាក្សាអាចប្រព្រឹត្តទៅដោយមិនចាំបាច់ធ្វើជាលាយលក្ខណ៍អក្សរក៏បានដែរ ដោយគ្រាន់តែពិភាក្សាគ្នាដោយផ្ទាល់មាត់ ក៏ប៉ុន្តែវានឹងក្លាយជាភាពចាំបាច់នៅពេលដែលការពិភាក្សាឈានទៅដល់លទ្ធផលមួយ គឺការបែងចែកមត៌កនោះ។ ប្រសិនបើការបែងចែក ឬ ផ្ទេរកម្មសិទ្ធិនីមួយៗ គឺចាំបាច់

[149] ទេព បូផល និង អ៊ីវ ប៉ូលី, *ការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយមូលហេតុសន្តតិកម្ម* (ភ្នំពេញ៖ វិភាគទានច្បាប់, ២០១៨), https://www.facebook.com/media/set/?vanity=contributionoflaws&set=a.779599389048127 (ចម្លងថ្ងៃទី ១០ កក្កដា ២០២១), ៥៩។

[150] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៧៣។

ត្រូវតែគោរពទៅតាមទំរង់ជាចាំបាច់ ហើយនៅទីនេះ ប្រសិនបើការធ្វើលទ្ធកម្មនោះទៅលើដីធ្លី គេត្រូវគោរពទៅលក្ខខណ្ឌចំពោះចំណែកកម្មសិទ្ធិនោះដោយអាចមានដូចជា ការធ្វើតាមលិខិតលាយជាលក្ខណ៍អក្សរ និងមានការចុះបញ្ជីនៃការផ្ទេរសិទ្ធិនោះដែលធ្វើដោយលិខិតយថាភូត។ ក្រៅពីនេះ គេក៏ពិចារណាផងដែរទៅលើវិធីនៃការបែងចែកមត៌ក ដែលជាទូទៅវាអាចត្រូវបានបែងចែកជា ៣ ប្រភេទ ដែលប្រភេទ ទី១ គឺពាក់ព័ន្ធទៅនឹងការបែងចែកវត្ថុជាក់ស្តែង គឺជាវិធីនៃការបែងចែកវត្ថុដោយផ្ទាល់តែម្តង។ វិធីទី ២ គេអាចធ្វើការបែងចែកជាតម្លៃថ្នូរ ពោលគឺជាការបែងចែកមត៌កទៅឱ្យសន្តតិជនណាម្នាក់ទទួលទ្រព្យទាំងមូលតែម្តង ហើយបង់ជាថ្លៃថ្នូរសមរម្យទៅតាមចំណែកមត៌កនៃសន្តតិជនម្នាក់ៗទៅឱ្យអ្នកទាំងនោះ។ និងវិធីទី ៣ គឺការបែងចែកមត៌កដោយការប្តូរប្រាក់ វាគឺជាវិធីធ្វើការបែងចែកមត៌កតាមរយៈការបែងចែក ថ្លៃលក់ ដែលបានមកពីការលក់ដោយបង្ខំ នៃនីតិវិធីតុលាការ[151]។

ហើយមួយវិញទៀតនៅក្នុងប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី ក៏បានចែងផងដែរ អំពីករណីដែលត្រូវពិចារណាពាក់ព័ន្ធទៅនៅសិទ្ធិអាទិភាពរបស់សហព័ទ្ធនៃមតកជនដែលក្លាយជាសន្តតិជន ដែលថា បើទ្រព្យដែលទទួលបាននោះជាកម្មសិទ្ធិអវិភាគជាមួយនឹងមតកជន នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ការបែងចែកមត៌កសម្រាប់ការនេះ គេពិចារណាថា សហព័ទ្ធមានអាទិភាពក្នុងការទទួលយកចំណែកកម្មសិទ្ធិនោះរហូតដល់គ្រប់ចំនួននៃចំណែកមត៌ក។ ហើយចំពោះគោលបំណងវិញ គឺអាចដើម្បីជាអនុស្សាវរីយ៍រវាងសហព័ទ្ធដែលនៅរស់ និងមតកជនដែលជាសហព័ទ្ធរបស់ខ្លួន។ លើសពីនេះទៅទៀត បើមតកជនមានកាតព្វកិច្ច សហសន្តតិជនត្រូវបែងចែកមត៌ក និង ទទួលករណីយកិច្ចតាមចំណែករបស់ខ្លួនផងដែរ នេះបើយោងទៅតាមគោលការណ៍ទទួលបន្តដោយស្វ័យប្រវត្តិនៃសន្តតិកម្ម ហើយសហសន្តតិជនមិនអាចប្តូរភាគនៃបន្ទុកនៃកាតព្វកិច្ចដោយគ្មានការយល់ព្រមពីម្ចាស់បំណុលឡើយ មានន័យថាកាតព្វកិច្ចទទួលបន្ទុកនៃសន្តតិកម្មត្រូវបែងចែកដោយស្វ័យប្រវត្តិក្នុងភាគសមាមាត្រនៃចំណែកខ្លួនរបស់ខ្លួន នៅពេលចាប់ផ្តើមសន្តតិកម្ម បើទោះបីជាមានការព្រមព្រៀងគ្នារវាងសហសន្តតិជនគ្នាឯងក៏ដោយ ក៏មិនអាចធ្វើបានដែរ លុះត្រាតែមានការយល់ព្រមពីម្ចាស់សិទ្ធិបំណុល។

### ខ. មត៌កបែងចែកដោយតុលាការ

ជាគោលការណ៍ ការបែងចែកដោយតុលាការ នឹងប្រព្រឹត្តទៅបានលុះត្រាតែការពិភាក្សាគ្នារវាងសហសន្តតិជន មិនអាចធ្វើទៅបាន ឬ ដែលមានមតិខ្វែងគំនិតគ្នារវាងសហសន្តតិជន ដែលតាមរយៈនេះ សហសន្តតិជនណាម្នាក់អាចដាក់ពាក្យសុំទៅតុលាកាឱ្យធ្វើការបែងចែកមត៌ក។ ការបែងចែកដោយតុលាការ តុលាការនឹងធ្វើការពិចារណាទៅលើមូលដ្ឋានមួយចំនួន ដូចជា ប្រភេទ និង លក្ខណៈនៃវត្ថុ ដែលមាននៅក្នុង

[151] សមាជិកក្រុមការងារ អនាគតគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រម និង នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃវិទ្យាស្ថានស្រាវជ្រាវ និង បណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន (ICD), *ក្រមរដ្ឋប្បវេណី ភាគទី ៦* (ភ្នំពេញ, ២០១២), ៣៥។

មត៌ក ជាអាទិ៍[152] ហើយតុលាការក៏ពិចារណាផងដែរ ពាក់ព័ន្ធទៅនឹងសំណាងនៃកាតព្វកិច្ចរបស់មតកជន ដែលគេអនុវត្តតាមទំនៀមទម្លាប់នៅក្នុងតំបន់ ក៏ដូចជាមតិលើសពីពាក់កណ្ដាលរបស់សហសន្តតិជន។ ក៏ប៉ុន្តែការពិចារណាលើមតិលើសពីពាក់កណ្ដាលរបស់សហសន្តតិជនមិនមែនមានន័យថាអាចនឹងឈ្នះក្ដី គ្រប់ពេលនោះទេ ប្រសិនបើមតិភាគច្រើននោះមិនសមរម្យ ហើយមួយវិញទៀត មតិភាគតិចក៏អាចនឹងជាអ្នកឈ្នះដែរ ប្រសិនបើមតិភាគតិចនោះត្រូវបានតុលាការពិចារណាថាសមរម្យ[153]។

នៅពេលដែលនីតិវិធីដើរបានរួចមកដល់តុលាការហើយ យើងឃើញថា ក្រោយពីមានមូលដ្ឋាននៅក្នុងការបែងចែកច្បាស់លាស់ ទ្រព្យដែលមិនអាចទទួលបានការព្រមព្រៀងអំពីការចែក អាចត្រូវបានតុលាការចាត់ចែងនៅក្នុងនីតិវិធីលក់ ហើយធ្វើការបែងចែកប្រាក់ដែលទទួលបានពីការលក់នោះទៅឱ្យសន្តតិជនបាន។ ហើយក្រៅពីនេះចំពោះទ្រព្យដែរត្រូវបានធ្វើលទ្ធកម្មរួចមកហើយ ដោយសន្តតិជនណាម្នាក់ ក៏ត្រូវបានរាប់បញ្ចូលជាសិទ្ធិនៅក្នុងមត៌កនោះដែរ ហើយក្លាយជាកម្មវត្ថុនៃការបែងចែកផងដែរ[154]។

[152] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៦៧។

[153] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៧០។

[154] អ៊ុំ ប៉ូលី, សន្តតិកម្ម (មេរៀនសង្ខេប) (គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈមេធាវី, ២០១១), ទំព័រ ៤៦។

# ជំពូកទី ៣

# ការណើនគ្តិភាពនៃសន្តតិជន

# ជំពូកទី ៣
# ករណីនត្ថិភាពនៃសន្តតិជន

ការអវត្តមានរបស់សន្តតិជន ធ្វើឱ្យបាត់បង់ប្រធាននៃកម្មសិទ្ធិមត៌កដែលមានចែងក្នុងករណីសន្តតិកម្មតាមច្បាប់ដែលមានសន្តតិជនជាអ្នកទទួលបន្តនូវឋានៈរបស់មតកជន។ ប៉ុន្តែ ចំណុចនេះក៏មិនមានន័យថាមត៌កនោះ មិនមានអ្នកទទួលបន្តនោះទេ។ ក្រមរដ្ឋប្បវេណី បានបង្កប់នូវសញ្ញាណមួយចំនួនចំពោះអ្នកដែលអាចទទួលមត៌កបន្តក្នុងករណីសន្តតិជនអវត្តមាន (ផ្នែកទី១) រួមទាំងបានបង្កើតប្បញ្ញត្តិស្តីពីនីតិបុគ្គលមត៌កដែលដើរតួនាទីជាអ្នកចាត់ចែងមត៌កនេះផងដែរ (ផ្នែកទី២)។

## ផ្នែកទី ១ ៖ បុគ្គលដែលអាចទទួលបានមត៌ក

ខុសពីសន្តតិកម្មតាមច្បាប់ដែលមានសន្តតិជនជាអ្នកទទួលបន្តនូវឋានៈរបស់មតកជន សន្តតិកម្មក្នុងករណីនត្ថិភាពនៃសន្តតិជនគេបានធ្វើការកំណត់អ្នកទទួលមត៌កតាមវិធីពីរយ៉ាងគឺ ការកំណត់ដោយយកឆន្ទៈរបស់មតកជនជាមូលដ្ឋាន(កថាខណ្ឌទី១) និងការកំណត់ដោយយកច្បាប់ជាមូលដ្ឋាន(កថាខណ្ឌទី២)។

### កថាខណ្ឌទី ១ ៖ ការកំណត់ដោយយកឆន្ទៈមតកជនជាមូលដ្ឋាន

ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានកំណត់ពីបុគ្គលមួយចំនួនដែលអាចទទួលបានមត៌កពីមតកជន ដោយផ្អែកតាមមូលដ្ឋានរបស់មតកជន ដែលរួមមាន អច្ច័យលាភី (១) និងបុគ្គលដែលមាននិស្ស័យពិសេស (២)។

**១. អច្ច័យលាភី**

អច្ច័យលាភី ត្រូវបានសន្ទានុក្រមនៃក្រមរដ្ឋប្បវេណីឱ្យនិយមន័យថាជា បុគ្គលដែលទទួលបានប្រទានកម្ម ឬអំណោយដែលម្ចាស់បណ្តាំ ឬមតកជនធ្វើទៅឱ្យមនុស្សម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈមតកសាសន៍[155]។[156] មាត្រា ១២៩៦ នៃក្រមរដ្ឋប្បវេណីបានកំណត់ថា ក្នុងករណីមិនដឹងច្បាស់ពីអត្ថិភាពនៃសន្តតិជន អ្នកគ្រប់គ្រងត្រូវជូនដំណឹងដោយគ្មានការយឺតយ៉ាវ ចំពោះម្ចាស់បំណុលរបស់មតកជន និងអច្ច័យលាភីទាំងអស់ អំពីការណ៍ដែលម្ចាស់បំណុល និងអច្ច័យលាភីនោះ ត្រូវស្នើសុំអំពីការទាមទារក្នុងអំឡុងពេលដែលបានកំណត់។ ដោយហេតុថាអច្ច័យលាភី មានសិទ្ធិទទួលបានមត៌កតាមរយៈមតកសាសន៍ដែលកើតចេញផ្ទាល់ពីឆន្ទៈរបស់មតកជន ដូច្នេះយើងអាចធ្វើការសន្និដ្ឋានបានថាវាជាការកំណត់ដោយផ្អែកលើមូលដ្ឋានរបស់មតកជន។

**២. បុគ្គលដែលមាននិស្ស័យពិសេស**

[155] ផ្នែកទី ២ ជំពូកទី ២ នៃសារណានេះ ចំពោះសន្តតិកម្មតាមមតកសាសន៍។

[156] គណកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, *សន្ទានុក្រមផ្នែករដ្ឋប្បវេណី* (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧), ២៦។

ជនដែលមាននិស្ស័យពិសេស ត្រូវបានគេឱ្យនិយមន័យថាជា បុគ្គលដែលមិនមែនជាសន្តតិជនតែមានជីវភាពរស់នៅជាមួយគ្នានឹងមតកជន ឬជាបុគ្គលដែលបានខិតខំមើលព្យាបាលមតកជនជាអាទិ៍។ [157] មាត្រា ១២៩៩ នៃក្រមរដ្ឋប្បវេណីបានចែងពីករណីនេះ។ មាត្រានេះ កំណត់ថា បើយល់ឃើញថាសមរម្យ តុលាការអាចចែកមួយផ្នែកនៃមត៌កដែលនៅសេសសល់ក្រោយការជម្រះ ទៅឱ្យជនដែលមានជីវភាពជាមួយគ្នានឹងមតកជន ជនដែលខិតខំមើលថែព្យាបាលមតកជន និងជនដែលមាននិស្ស័យពិសេសផ្សេងទៀត តាមពាក្យសុំរបស់ជននោះ។ ទោះជាយ៉ាងណាក៏ដោយ សញ្ញាណនៃជនដែលមាននិស្ស័យពិសេស ហាក់នៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ។ ប៉ុន្តែ សេចក្តីកំណត់នៃមាត្រា ១២៩៩ ក៏បានបង្ហាញពីករណីមួយចំនួនទុកជាមូលដ្ឋានក្នុងការពិចារណាផងដែរ ដូចជាការចាត់ទុកញាតិដែលមិនស្ថិតនៅក្នុងទំហំនៃសន្តតិជនដែលច្បាប់បានកំណត់ ដូចជាករណីបងប្អូនជីដូនមួយដែលបានរស់នៅសុខដុមរមនាជាមួយនឹងមតកជន និងអ្នកជិតខាងដែលមានភាពជិតស្និទ្ធជាមួយមតកជនដែលបានជួយថែរក្សា និងព្យាបាលមតកជនជាដើម អាចទទួលបានលក្ខណៈសម្បត្តិជាជនដែលមាននិស្ស័យពិសេស។ [158] ក្រមរដ្ឋប្បវេណី ក៏បានចែងថាអាចមានជនដែលមាននិស្ស័យពិសេសផ្សេងទៀតផងដែរ ដែលហាក់ទុកចន្លោះឱ្យតុលាការសម្រាប់ការបកស្រាយនៅថ្ងៃអនាគត។ ចំពោះករណីប្រទេសជប៉ុនវិញ ជនដែលធ្វើសកម្មភាពមួយចំនួនដូចជា ការជួយផ្នែកជីវភាពទាក់ទងនឹងនីតិវិធី ដូចជាការបំពេញឯកសារពិនិត្យសុខភាព ឬទាមទារសោហ៊ុយធានារ៉ាប់រងជាអាទិ៍ និងការជួយផ្នែកជីវភាពទាក់ទងនឹងថវិកា ដូចជាប្រទានកម្មសម្រាប់ការទ្រទ្រង់ជីវភាពជាដើម និងសកម្មភាពថែរក្សាទ្រព្យសម្បត្តិរបស់មតកជន ជួយរៀបចំពិធីបុណ្យសព និងថែផ្នូរជាអាទិ៍ ត្រូវបានគេចាត់ទុកថាជាជនដែលមាននិស្ស័យពិសេសខ្លាំងជាងជនដទៃទៀត។[159]ដោយការកំណត់នេះ ផ្អែកទៅលើភាពជិតស្និទ្ធរវាងអ្នកដែលអាចទទួលមត៌ក និងមតកជន ហេតុនេះ យើងអាចសន្និដ្ឋានបានថា វាជាការកំណត់ដោយយកឆន្ទៈមតកជនជាមូលដ្ឋាន ដោយការសន្មតថា មតកជនក៏អាចមានឆន្ទៈផ្តល់ទ្រព្យរបស់ខ្លួនដល់ជនទាំងនោះដែរ។

**កថាខណ្ឌទី ២ ៖ ការកំណត់ដោយយកស្មារតីច្បាប់ជាមូលដ្ឋាន**

ទោះបីជាការបែងចែងមត៌ក ត្រូវធ្វើការគោរពតាមឆន្ទៈរបស់មតកជនក៏ដោយ ក៏ច្បាប់មានតួនាទីចូលអន្តរាគមដើម្បីធានាឱ្យបាននូវស្ថេរភាពធុរកិច្ច និងផលប្រយោជន៍សង្គមផងដែរ។ ហេតុនេះ ច្បាប់បានកំណត់ពីបុគ្គលពីរប្រភេទទៀត ដែលអាចទទួលបានមត៌កនេះ គឺម្ចាស់បំណុល (១) និងរដ្ឋខ្លួនឯងផ្ទាល់ដែលគេចាត់ទុកថាជាសន្តតិជនចុងក្រោយ (២)។

---

[157] គណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, *សន្ទានុក្រមផ្នែករដ្ឋប្បវេណី* (ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី, ២០០៧)

[158] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), មាត្រា ១២៩៩។

[159] ក្រុមការងារគណៈមេធាវី *នីតិបុគ្គលមត៌ក*, ២៥-៣០ ឧសភា ២០១៤។

**១. ម្ចាស់បំណុល**

មាត្រា ១២៩៦ នៃក្រមរដ្ឋប្បវេណី បានបង្ហាញថាម្ចាស់បំណុលមានសិទ្ធិដាក់ពាក្យទាមទារមត៌កបាន ក្នុងករណីដែលសន្តតិជននៅតែអវត្តមានទោះបីមានការជូនដំណឹងក៏ដោយ។ តាមពិតទៅ ការសងបំណុល របស់មតកជន ជាគោលដៅធំបំផុតមួយនៃបញ្ញត្តិស្តីពីនត្ថិភាពនៃសន្តតិជនក្នុងក្រមរដ្ឋប្បវេណីនេះ។ ដោយ ហេតុថា ទ្រព្យសម្បត្តិដែលគ្មានម្ចាស់នឹងធ្លាក់ទៅជាទ្រព្យសម្បត្តិរដ្ឋចំពោះអចលនវត្ថុ និងជាកម្មសិទ្ធិរបស់អ្នក កាន់កាប់មុនចំពោះចលនវត្ថុ ដែលធ្វើឱ្យម្ចាស់បំណុលរបស់មតកជនពិបាកក្នុងការប្រជែងក្នុងការទទួលការសង ដែលអាចនាំឱ្យមានការជ្រួលច្របល់ក្នុងសង្គម និងប៉ះពាល់ដល់ស្ថេរភាពធុរកិច្ចផងនោះ ទើបបទប្បញ្ញត្តិនេះ បានចាត់ទុកម្ចាស់បំណុលជាអាទិភាពក្នុងការទទួលបានមត៌កក្នុងករណីនត្ថិភាពនៃសន្តតិជននេះ។[160]

**២. រដ្ឋ៖ សន្តតិជនចុងក្រោយ**

រដ្ឋត្រូវបានគេចាត់ទុកថាជាសន្តតិជនចុងក្រោយ ក្នុងករណីដែលចំណែកណាមួយ ឬទាំងស្រុងនៃមត៌ក មិនមានអ្នកទទួលបន្ត។ មាត្រា ១៣០០ នៃក្រមរដ្ឋប្បវេណីកំណត់ថា មត៌កដែលគ្មានសន្តតិជន ហើយមិនត្រូវ បានចែកទៅឱ្យជនដែលមាននិស្ស័យពិសេស ត្រូវក្លាយជារបស់រដ្ឋ។ ការអនុវត្តបែបនេះ គឺហាក់មានលក្ខណៈជា ប្រពៃណីទៅហើយទោះជាបីជាការអនុវត្តនៅកម្ពុជា ឬបរទេសក្តី។ ក្រមមត៌កកម្ពុជា ដែលត្រូវបានអនុវត្តនៅដើម សម័យអាណានិគមនិយមបារាំង ក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ ច្បាប់ភូមិបាលឆ្នាំ ១៩៩២ និងឆ្នាំ ២០០១ សុទ្ធតែ កំណត់ដូចគ្នា។ ចំពោះការអនុវត្តនៅបរទេស ដូចជាក្នុងបណ្តាប្រទេសកម្មិនឡូជាដើម ទ្រព្យសម្បត្តិដែលមិន មានម្ចាស់តាមករណីមួយចំនួនដែលរួមមានសន្តតិកម្មជាអាទិ៍ គឺត្រូវធ្លាក់ទៅជាទ្រព្យសម្បត្តិរបស់រដ្ឋ។[161] ហេតុ នេះ រដ្ឋគឺប្រៀបដូចជាសន្តតិជនចុងក្រោយអ៊ីចឹងដែរ។

ជារួម ក្នុងករណីនត្ថិភាពនៃសន្តតិជន ក្រមរដ្ឋប្បវេណីបានធ្វើការកំណត់ពីបុគ្គលមួយចំនួនដែលមាន សិទ្ធិទទួលបានមានមត៌ករបស់មតកជនដែលរួមមានអច្ច័យលាភី ជនដែលមាននិស្ស័យពិសេស ម្ចាស់បំណុល និងរដ្ឋផងដែរ។

## ផ្នែកទី ២ ៖ ករណីសិក្សាពីនីតិបុគ្គលមត៌ក

នីតិបុគ្គលមត៌ក ក៏ជានីតិបុគ្គលមួយប្រភេទផងដែរ។ ជាទូទៅ ការសិក្សាពីនីតិបុគ្គលអាចបែងចែកជាបី ចំណុចធំៗ គឺការបង្កើតនីតិបុគ្គល(កថាខណ្ឌទី១) ដំណើរការនៃនីតិបុគ្គល(កថាខណ្ឌទី២) និងការបញ្ចប់ទៅវិញ នៃនីតិបុគ្គលនោះ (កថាខណ្ឌទី៣)។

---

[160] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, បោះពុម្ពឆ្នាំ ២០០៩), មាត្រា ១២៩០។

[161] Revised Uniform Unclaimed Property Act 2016 បោះពុម្ពដោយ National Conference of Commissioner on Uniform State Laws។

**កថាខណ្ឌទី ១ ៖ ការចាប់ផ្តើមនៃនីតិបុគ្គលមត៌ក**

ការបង្កើតនីតិបុគ្គលណាមួយតម្រូវឱ្យមានលក្ខខណ្ឌ (២) និងនីតិវិធី (៣) ទៅតាមការកំណត់នៃច្បាប់ជាធរមាន។ ប៉ុន្តែ មុននឹងធ្វើការសិក្សាពីលក្ខខណ្ឌ និងនីតិវិធីនៃការបង្កើតនីតិបុគ្គលមត៌ក ជាបឋម យើងគួរសិក្សាពីបុព្វហេតុនៃការបង្កើតនីតិបុគ្គលប្រភេទនេះឡើង (១)។

**១. បុព្វហេតុនៃការបង្កើត**

នីតិបុគ្គលមត៌កត្រូវបានបង្កើតឡើង ក្នុងគោលបំណងធំមួយ គឺការធានាឱ្យបាននូវផលប្រយោជន៍របស់ម្ចាស់បំណុល។[162] ជាគោលការណ៍ ទ្រព្យសម្បត្តិដែលគ្មានម្ចាស់ ដែលរួមទាំងទ្រព្យសម្បត្តិរបស់មតកជនដែលមិនមានសន្តតិជនដែរ នឹងត្រូវក្លាយជាទ្រព្យសម្បត្តិរដ្ឋចំពោះអចលនវត្ថុ និងបានជាកម្មសិទ្ធិរបស់អ្នកកាន់កាប់ក្នុងករណីចលនវត្ថុ ដែលការអនុវត្តបែបនេះនឹងធ្វើឱ្យម្ចាស់បំណុលរបស់មតកជនពិបាកក្នុងការទទួលការសង ហើយដែលអាចនាំឱ្យមានការជ្រួលច្របល់នៅក្នុងសង្គម។ គោលការណ៍នេះ មានកំណត់នៅក្នុងមាត្រា ១៦១ និងមាត្រា ១៨៨ នៃក្រមរដ្ឋប្បវេណី។ មាត្រា ១៦១ កំណត់ថា អចលនវត្ថុដែលគ្មានម្ចាស់ ត្រូវក្លាយជាកម្មសិទ្ធិរដ្ឋ ដែលពាក្យថាគ្មានម្ចាស់នៅទីនេះ ក៏សំដៅទៅលើអចលនវត្ថុដែលមិនមែនជាកម្មវត្ថុនៃកម្មសិទ្ធិនៅឡើយ ឬអចលនវត្ថុដែលម្ចាស់មិនច្បាស់លាស់ផងដែរ។[163] ចំណែកឯមាត្រា ១៨៨ កំណត់ថា ចលនវត្ថុដែលគ្មានម្ចាស់ត្រូវជាកម្មសិទ្ធិរបស់អ្នកកាន់កាប់វត្ថុនោះមុនគេ ដោយមានឆន្ទៈយកជាកម្មសិទ្ធិ លើកលែងតែករណីការកាន់កាប់សត្វព្រៃដែលត្រូវអនុវត្តតាមប្បញ្ញតិពិសេសនោះ។ ការធ្វើលទ្ធកម្មនៃកម្មសិទ្ធិលើចលនវត្ថុដោយការកាន់កាប់មុននេះ បានក្លាយជាគោលការណ៍ទូទៅមួយទៅហើយ ត្បិតវាត្រូវបានអនុវត្តចាប់តាំងពីមានច្បាប់រ៉ូមមកម្លេះ ហើយក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជាក៏មានប្បញ្ញត្តិដូចគ្នានេះដែរ លើកលែងតែករណីសត្វព្រៃដែលតម្រូវឱ្យមានការការពារជាពិសេស ឱ្យស្របទៅតាមបរិបទនៃប្រទេសកម្ពុជា។[164] ហេតុនេះ ដើម្បីការពារការជ្រួលច្របល់នៅក្នុងសង្គម ក្រមរដ្ឋប្បវេណី បានសម្រេចចែងពីបទប្បញ្ញត្តិទាក់ទងនឹងនីតិបុគ្គលមត៌កនេះ ដើម្បីធ្វើជាប្រធាននៃសិទ្ធិនៃមត៌កនោះសិន។ ទោះជាយ៉ាងណាក៏ដោយ ការបង្កើតនីតិបុគ្គលមត៌ក មិនមែនជាជម្រើសតែមួយដើម្បីធ្វើអន្តរាគមលើបញ្ហានេះទេ។ គេឃើញមានបទពិសោធន៍បរទេសមួយចំនួន ដែលរួមមានបទប្បញ្ញត្តិក្នុងផ្នែកទី ២៩ នៃច្បាប់សន្តតិកម្មហិណ្ឌូឆ្នាំ ១៩៥៦ ជាដើម បានបង្ហាញពីដំណោះស្រាយផ្សេងពីនេះ។ ប្បញ្ញត្តិនេះ កំណត់ថាក្នុងករណីនត្ថិភាពនៃសន្តតិជន ទ្រព្យសម្បត្តិរបស់មតកជននឹងធ្លាក់ទៅកាន់រដ្ឋាភិបាល ហើយរដ្ឋាភិបាលត្រូវទទួលយកទាំងសិទ្ធិ និងកាតព្វកិច្ចរបស់មតកជននោះ។[165] ចំណុចនេះបង្ហាញថា គេមិនចាំបាច់បង្កើតនីតិ

---

[162] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* ភ្នំពេញ ក្រសួងយុត្តិធម៌ បោះពុម្ពឆ្នាំ២០០៩ មាត្រា ១១៩០។
[163] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* ភ្នំពេញ ក្រសួងយុត្តិធម៌ បោះពុម្ពឆ្នាំ២០០៩ មាត្រា ១៦១។
[164] *សេចក្តីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* ភ្នំពេញ ក្រសួងយុត្តិធម៌ បោះពុម្ពឆ្នាំ២០០៩ មាត្រា ១៨៨។
[165] ផ្នែកទី ២៩ នៃច្បាប់ស្តីពីសន្តតិកម្មហិណ្ឌូឆ្នាំ ១៩៥៦។

បុគ្គលមត៌កដើម្បីធ្វើការចាត់ចែងសិទ្ធិ និងកាតព្វកិច្ចនោះទេ ដោយហេតុថារដ្ឋបានក្លាយទៅជាសន្តតិជនម្នាក់ដែលទទួលបន្តនូវឋានៈរបស់មតកជននោះដូចករណីសន្តតិជនទូទៅដែរ។ ចំណែកឯផលប្រយោជន៍របស់ម្ចាស់បំណុលក៏បានធានាផងដែរ។ ហេតុនេះ វាជាជម្រើសរបស់នីតិករក្នុងការជ្រើសរើសវិធីសាស្ត្រណាមួយសម្រាប់ធ្វើអន្តរាគម។

**២. លក្ខខណ្ឌក្នុងការបង្កើត**

នីតិបុគ្គលមត៌កត្រូវបានបង្កើតឡើង ដោយបំពេញលក្ខខណ្ឌចំនួនពីរ គឺការមានមូលហេតុក្នុងការចាប់ផ្តើមសន្តតិកម្ម និងការពុំច្បាស់ថាមានសន្តតិជន។ មាត្រា ១២៩០ នៃក្រមរដ្ឋប្បវេណីបានបញ្ជាក់ថា ប្រសិនបើពុំច្បាស់ថាមានសន្តតិជនទេ មត៌កនោះត្រូវក្លាយជានីតិបុគ្គល។ ពាក្យថា "មត៌កនោះត្រូវក្លាយជានីតិបុគ្គល" បញ្ជាក់ពីអត្ថិភាពនៃការចាប់ផ្តើមសន្តតិកម្ម ដែលជាពេលដែលទ្រព្យសម្បត្តិ ឬឋានៈរបស់មតកជនត្រូវបានផ្ទេរ ឬទទួលបន្តដោយនីតិបុគ្គលនេះ។ ហើយការចាប់ផ្តើមនៃសន្តតិកម្មនេះ គឺអាចធ្វើទៅបានក្នុងករណីមានអត្ថិភាពនៃការទទួលមរណភាព ឬការចាត់ទុកថាបានទទួលមរណភាព។[166] ចំណែកឯ ពាក្យថា "ពុំច្បាស់ថាមានសន្តតិជននៅត្រង់នេះ" អាចសំដៅទៅលើករណីចំនួនបី គឺករណីច្បាស់ថាមិនមានសន្តតិជន ករណីមានសន្តតិជនដែរ ប៉ុន្តែពួកគេទាំងអស់បានបោះបង់ចោលសន្តតិកម្មដូចមានចែងក្នុងមាត្រា ១២៦១ និងករណីមានសន្តតិជនដែរ [167] ប៉ុន្តែពួកគេគឺជាអភ័ព្វបុគ្គលដែលមានកំណត់ក្នុងមាត្រា ១១៥៩ ឬជាជនដែលត្រូវបានផ្តាច់មត៌កដូចដែលបានកំណត់ក្នុងមាត្រា ១១៥១ នៃក្រមរដ្ឋប្បវេណី។[168] ហេតុនេះ យើងអាចកំណត់បានថា នីតិបុគ្គលមត៌កត្រូវបានបង្កើតនៅពេលដែលមានមូលហេតុនៃការចាប់ផ្តើមសន្តតិកម្ម និងនៅពេលដែលពុំច្បាស់ថាមានសន្តតិជន។

**៣. នីតិវិធីក្នុងការបង្កើតនីតិបុគ្គលមត៌ក**

ការបង្កើតនីតិបុគ្គលមត៌ក មិនតម្រូវឱ្យមាននីតិវិធីអ្វីឡើយ។ ដោយយោងតាមមាត្រា ១២៩០ នៃក្រមនេះ ប្រសិនបើពុំច្បាស់ថាមានសន្តតិជនទេ មត៌កនោះត្រូវក្លាយជានីតិបុគ្គល ដែលមានន័យថា នីតិបុគ្គលមត៌កនឹងត្រូវបានបង្កើតឡើងដោយស្វ័យប្រវត្តិបើទោះបីជាគ្មានការដាក់ពាក្យសុំក៏ដោយ។ ទោះជាយ៉ាងណាក៏ដោយ ដំណើរការនីតិវិធីក្នុងការគ្រប់គ្រងចាត់ចែងមត៌ករបស់នីតិបុគ្គលមត៌កក៏មិនអាចធ្វើទៅបានដែរ ប្រសិនបើមិន

[166] ផ្នែកទី២ នៃជំពូកទី១ នៃសារណានេះ។

[167] កថាខណ្ឌទី២ នៃផ្នែកទី៣ នៃជំពូកទី១ នៃសារណានេះ។

[168] សមាជិកក្រុមការងារ អនាគតគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រម និង នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃវិទ្យាស្ថានស្រាវជ្រាវ និង បណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន *ក្រមរដ្ឋប្បវេណី ភាគ ៦* ភ្នំពេញ បោះពុម្ពដោយ JICA និង ICD ឆ្នាំ ២០១២។

មានអ្នកគ្រប់គ្រងទេនោះ ហេតុនេះ គេត្រូវមានអ្នកគ្រប់គ្រងដើម្បីឱ្យនីតិបុគ្គលមត៌កនេះដំណើការទៅបាន។[169] មាត្រា ១២៩១ នៃក្រមរដ្ឋប្បវេណីបានកំណត់ថា ក្នុងករណីដែលលក្ខខណ្ឌនៃការបង្កើតនីតិបុគ្គលមត៌កខាងលើត្រូវបានបំពេញ តុលាការត្រូវជ្រើសតាំងអ្នកគ្រប់គ្រងមត៌កតាមពាក្យសុំរបស់បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ មេឃុំ ឬចៅសង្កាត់នៃលំនៅឋានចុងក្រោយរបស់មតកជន ឬតំណាងអយ្យការ។ ហេតុនេះ បើទោះបីជានីតិបុគ្គលមត៌កត្រូវបានបង្កើតឡើងដោយស្វ័យប្រវត្តិក៏ដោយ ក៏តម្រូវឱ្យមាននីតិវិធីក្នុងការជ្រើសរើសអ្នកគ្រប់គ្រងដែរ ដើម្បីឱ្យនីតិបុគ្គលនេះដំណើការទៅបាន។

### កថាខណ្ឌទី ២ ៖ ការរៀបចំ និងការប្រព្រឹត្តទៅនៃនីតិបុគ្គលមត៌ក

#### ១. ការគ្រប់គ្រងមត៌ក

ជាទូទៅ មិនត្រឹមតែនីតិបុគ្គលមត៌កទេ នីតិបុគ្គលណាក៏ដោយ គឺសុទ្ធតែមិនអាចអនុវត្តសកម្មភាពរបស់ខ្លួនបានដូចជារូបវន្តបុគ្គលឡើយ។ ថ្វីបើ នីតិបុគ្គល ត្រូវបានគេស្គាល់ថាជា ក្រុមមនុស្ស ឬក្រុមទ្រព្យសម្បត្តិដែលមានបុគ្គលភាពគតិយុត្តក៏ដោយ[170] ក៏ប៉ុន្តែដើម្បីឱ្យបានក្លាយជាប្រធាននៃសិទ្ធិ និងករណីយកិច្ចពេញលេញ ជាធម្មតា គឺតម្រូវឱ្យមានរូបវន្តបុគ្គលធ្វើសកម្មភាពតំណាងឱ្យនីតិបុគ្គលនោះ ក្នុងនាមជាអ្នកគ្រប់គ្រងជាដើម។ ដូចបានបកស្រាយខាងលើ នៅពេលគេពិនិត្យឃើញថា សន្តតិកម្មបានចាប់ផ្តើម ហើយពុំច្បាស់ថាមានសន្តតិជនទេ មត៌ករបស់មតកជននោះត្រូវក្លាយជានីតិបុគ្គលដោយស្វ័យប្រវត្តិ តែដោយហេតុថា វាមិនអាចដំណើរ សកម្មភាពបានដោយខ្លួនឯង នៅទីនេះ ច្បាប់តម្រូវឱ្យមានការជ្រើសតាំងអ្នកគ្រប់គ្រងនីតិបុគ្គលមត៌កនោះតាមពាក្យសុំទៅតុលាការ[171]។ សរុបមកវិញ យើងឃើញថា ការជ្រើសតាំងឱ្យមានបុគ្គលដែលជាអ្នកគ្រប់គ្រងមត៌ក គឺជាចំណុចសំខាន់ចម្បង ដើម្បីឱ្យនីតិបុគ្គលមត៌កមានដំណើរការបាន។

នៅពេលដែលអ្នកគ្រប់គ្រងមត៌កត្រូវបានជ្រើសតាំងរួចរាល់ នោះមានន័យថា នីតិបុគ្គលមត៌កដែលកើតឡើងដោយស្វ័យប្រវត្តិនោះ នឹងចាប់ផ្តើមមានដំណើរការទៅតាមនីតិវិធីដូចមានកំណត់នៅក្នុងច្បាប់។ ហើយមួយវិញទៀត នៅបន្ទាប់ពីបានជ្រើសតាំងអ្នកគ្រប់គ្រងមត៌កបានហើយ តុលាការត្រូវធ្វើការជូនដំណឹងអំពីការជ្រើសតាំងនេះជាសាធារណៈ ដោយគ្មានការយឺតយ៉ាវឡើយ[172]។ អ្នកគ្រប់គ្រង ជាទូទៅ នៅក្នុងពេលអនុវត្តមុខងាររបស់ខ្លួន ហើយដែលមុខងារចម្បងត្រូវបានស្គាល់ថា ជាអ្នកគ្រប់គ្រង ជម្រះបញ្ជី ក៏ដូចជាចែកមត៌កដែលសេសសល់តាមប្បញ្ញត្តិនៃច្បាប់ គឺនឹងទទួលបានកម្រៃឬសោហ៊ុយសមរម្យតាមការកំណត់របស់តុលាការ[173]។

---

[169] ដដែល។

[170] ប៊ួយ ធីតា និង កង ស៊ីផាន់ណារ៉ា, *នីតិរដ្ឋប្បវេណី*, (ភ្នំពេញ, ២០១៨) ទំព័រ ៣៨។

[171] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៩០ និង ១២៩១-១។

[172] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៩១-២។

[173] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៩៣។

ដោយឡែក ចំពោះសិទ្ធិ និងករណីយកិច្ចរបស់អ្នកគ្រប់គ្រងអាចទទួលបានក្នុងពេលអនុវត្តមុខងាររបស់ខ្លួនអាចមានដូចជា (១) ផ្ញើបញ្ជីសារពើភណ្ឌដែលទាក់ទងនឹងមត៌ក (កត់ត្រាទាំងទ្រព្យសកម្ម និងទ្រព្យអកម្មរបស់មតកជន) (២) ថែរក្សា និងគ្រប់គ្រងមត៌ក (៣) រាយការណ៍ពីស្ថានភាពនៃមត៌កទៅម្ចាស់បំណុលឬអច្ច័យលាភីរបស់មតកជន (៤) ត្រូវអនុវត្តចំណុចនីមួយៗ ដែលមានកំណត់ពីមាត្រា ១២៨២ (សិទ្ធិបដិសេធការសងនៅក្នុងអំឡុងពេលដាស់តឿន) រហូតដល់មាត្រា ១២៨៨ (ករណីដែលពុំបានស្នើសុំ) នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ ហើយដោយយើងតាមប្បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៩៦ (ការជូនដំណឹងជាសាធារណៈ និងការដាស់តឿនចំពោះម្ចាស់បំណុល ជាអាទិ៍) និង (៥) ត្រូវស្រាវជ្រាវអង្គហេតុ និងរាយការណ៍ពីលទ្ធផល តាមការបង្គាប់របស់តុលាការ[174]។ គួរបញ្ជាក់ផងដែរថា ប្រសិនបើក្នុងករណីអ្នកគ្រប់គ្រងអនុវត្តដោយបំពាន ឬធ្វេសប្រហែសចំពោះករណីយកិច្ចខាងលើ អ្នកគ្រប់គ្រងនោះក៏នឹងត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាតពីការបំពាននោះ[175]។

## ២. ការចាត់ចែងមត៌ក

នៅក្នុងការចាត់ចែង ឬជម្រះមត៌ក ជាទូទៅត្រូវឆ្លងកាត់ដំណាក់កាលនៃការជូនដំណឹងយ៉ាងហោចណាស់ ៣ លើក ដែលមានដូចជា ការជូនដំណឹងលើកទី ១ ដោយតុលាការ, ការជូនដំណឹងលើកទី ២ ដោយអ្នកគ្រប់គ្រង, និងការជូនដំណឹងលើកទី ៣ ដោយតុលាការ[176]។

### ក. ការជូនដំណឹងលើកទី ១

ដោយយោងតាមប្បញ្ញត្តិនៃមាត្រា ១២៩១ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ នៅបន្ទាប់ពីបានជ្រើសតាំងអ្នកគ្រប់គ្រងហើយ តុលាការត្រូវធ្វើការជូនដំណឹងជាសាធារណៈអំពីការណ៍នោះ ដោយគ្មានការយឺតយ៉ាវ។ ការជូនដំណឹងជាសាធាណៈដោយតុលាការនេះ គឺធ្វើឡើងតាមរយៈការបិទប្រកាសរបស់តុលាការ និងការចុះក្នុងព្រឹត្តិបត្ររបស់ក្រសួងយុត្តិធម៌[177]។

### ខ. ការជូនដំណឹងលើកទី ២

តាមលំហូរនៃនីតិវិធីជាបន្ទាប់ អ្នកគ្រប់គ្រងនឹងធ្វើការជូនដំណឹងអំពីការបង្ហាញការទាមទារ ហើយដែលនៅទីនេះ នៅក្នុងច្បាប់គេប្រើពាក្យថា ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុលជាអាទិ៍។ ការជូនដំណឹងនេះ គឺត្រូវធ្វើឡើងជាសាធារណៈ ហើយធ្វើឡើងដោយការបិទប្រកាសរបស់តុលាការ និងចុះក្នុងព្រឹត្តិបត្ររបស់ក្រសួងយុត្តិធម៌ផងដែរ។ ចំពោះគោលបំណងនៃការជូនដំណឹងនេះ គឺដើម្បីឱ្យម្ចាស់បំណុល

---

174 ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៩២។

175 ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៨៧-១។

176 ឯកសារភូមិន្ទចៅក្រម ស្តីពីនត្តិភាពនៃសន្តតិជន, ទំព័រ ២។

177 ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, មាត្រា ១២-២។

ជាអាទិ៍បានដឹង និងអនុវត្តសិទ្ធិរបស់ខ្លួន ក្នុងអំឡុងពេលកំណត់ណាមួយនោះ[178]។ លើសពីនេះទៅទៀត នៅក្នុងការជូនដំណឹងជាសាធារណៈនេះ អ្នកគ្រប់គ្រង (១) ត្រូវបញ្ជាក់នូវអំឡុងពេលជាក់លាក់ ហើយដែលមិនត្រូវតិចជាង ២ (ពីរ)ខែ, (២) បញ្ជាក់ក្នុងការជូនដំណឹងនោះថា គ្រប់សន្តតិជន និងអច្ច័យលាភីទាំងអស់ត្រូវបង្ហាញពីការទាមទាររបស់ខ្លួនក្នុងអំឡុងពេលកំណត់ខាងលើ, និង (៣) ត្រូវសរសេរបញ្ជាក់ផងដែរថា ម្ចាស់បំណុលរបស់មតកជន ដែលមិនបង្ហាញការទារទារក្នុងអំឡុងពេលកំណត់ខាងលើនោះទេ នឹងត្រូវដកចេញពីការជម្រះ[179]។

ជុំវិញការដកចេញពីការជម្រះទៅលើម្ចាស់បំណុល ឬអច្ច័យលាភីដែលមិនបានទាមទារក្នុងអំឡុងពេលកំណត់នោះ ម្ចាស់បំណុល ឬអច្ច័យលាភីទាំងអស់អាចអនុវត្តសិទ្ធិរបស់ពួកគេ លុះណាតែមានសល់ទ្រព្យសម្បត្តិក្រោយពីការជម្រះ។ ក៏ប៉ុន្តែ ប្រសិនបើអ្នកគ្រប់គ្រងបានដឹង ឬស្គាល់ពីបុគ្គលដែលជាម្ចាស់បំណុល ឬអច្ច័យលាភី ហើយដែលមិនបានបង្ហាញការទាមទាររបស់ខ្លួនក្នុងអំឡុងពេលកំណត់នោះ ពួកគេនឹងមានសិទ្ធិទទួលបានការសងតាមរយៈការជម្រះ។ ដោយឡែក ក៏មានលក្ខខណ្ឌពិសេសមួយទៀតផងដែរនៅទីនេះ ចំពោះម្ចាស់បំណុលលើសិទ្ធិប្រាតិភោគ ដោយហេតុថា បើទោះបីជា ខ្លួនពុំបានបង្ហាញការទាមទាររបស់ខ្លួនក្នុងអំឡុងពេលកំណត់ក៏ដោយ ក៏សិទ្ធិរបស់ខ្លួនជាម្ចាស់បំណុលមិនត្រូវបានរលត់ឡើយ[180]។

មួយវិញទៀត នៅពេលដែលអំឡុងពេលជាក់លាក់ (យ៉ាងហោចណាស់ ២ (ពីរ)ខែ) បានកន្លងផុតបន្ទាប់ពីការជូនដំណឹងលើកទី ២ ការជម្រះមត៌ក ឬការគ្រប់គ្រងសងបំណុល និងធ្វើអច្ច័យទាននឹងចាប់ផ្តើម[181]។ ម៉្យាងវិញទៀត នៅមុនអំឡុងពេលជាក់លាក់នេះ អ្នកគ្រប់គ្រងក៏អាចធ្វើការបដិសេធសង ឬធ្វើអច្ច័យទានចំពោះម្ចាស់បំណុល ឬអច្ច័យលាភីបានដែរ[182]។ ហើយនៅទីនេះ ប្រសិនបើអ្នកគ្រប់គ្រងបានធ្វើការទូទាត់សងម្ចាស់បំណុល និងអច្ច័យលាភីនានា (មិនមានការបដិសេធណាមួយ) ហើយស្រាប់តែមិនអាចសងទៅម្ចាស់បំណុល ឬអច្ច័យលាភីដទៃទៀតបាន ពេលនោះ អ្នកគ្រប់គ្រងនឹងមានកាតព្វកិច្ចក្នុងការសងសំណងការខូចខាត[183]។

**គ. ការជូនដំណឹងលើកទី ៣**

178 ក្រុមការងារគណៈមេធាវី *នីតិបុគ្គលមត៌ក,* ២៥-៣០ ឧសភា ២០១៤, ទំព័រ ៤។

179 ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៩៦។

180 ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៩៨។

181 ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៩៦-១។

182 ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៩២។

183 ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៩៦ និង ១៩៨៧។

ការជូនដំណឹងលើកទី ៣ ឬគេអាចហៅម៉្យាងទៀតបានថា ជាការជូនដំណឹងជាសាធារណៈសម្រាប់ការស្វែងរកសន្តតិជន គឺនឹងធ្វើឡើងនៅបន្ទាប់ពីអំឡុងពេលកំណត់សម្រាប់ការជូនដំណឹងលើកទី ២ បានកន្លងហួស ហើយនៅតែមិនទានមានអត្ថិភាពនៃសន្តតិជនទេនោះ។ ការជូនដំណឹងលើកទី ៣ នេះ ត្រូវធ្វើឡើងដោយតុលាការ តាមពាក្យសុំរបស់អ្នកគ្រប់គ្រង ឬតំណាងអយ្យការ។ ដូចបានបង្ហាញពីខាងលើ ម្ចាស់បំណុល ឬអច្ច័យលាភីរបស់មតកជនត្រូវបានគេការពារជាពិសេស និងមុនគេ ក៏ប៉ុន្តែ ចំពោះសន្តតិជនរបស់មតកជនក៏គេមិនបានបំភ្លេចដែរ ពោលគឺ នៅទីនេះ គេបានទុកលទ្ធភាពឱ្យសន្តតិជននោះទទួលស្នងនូវទ្រព្យសម្បត្តិដែលនៅសល់នោះ។ អ្វីដែលគួរឱ្យកត់សម្គាល់នៅទីនេះ គឺថា ប្រសិនបើតាមការប៉ាន់ប្រមាណរកឃើញថា មិនមានសេសសល់ទ្រព្យសម្បត្តិទេ អ្នកគ្រប់គ្រង ឬព្រះរាជអាជ្ញា គឺមិនចាំបាច់ធ្វើពាក្យសុំទៅតុលាការសម្រាប់គោលបំណងនៃការជូនដំណឹងលើកទី ៣ នេះឡើយ[184]។ ដូចគ្នានឹងការជូនដំណឹងមុនៗដែរ ការជូនដំណឹងលើកទី ៣ នេះ ក៏ត្រូវធ្វើឡើងដោយការបិទប្រកាសរបស់តុលាការ និងចុះក្នុងព្រឹត្តិបត្ររបស់ក្រសួងយុត្តិធម៌។ ដោយឡែក ចំពោះអំឡុងពេលកំណត់នៅក្នុងការជូនដំណឹងនេះ ក៏ត្រូវបញ្ជាក់ឱ្យច្បាស់លាស់ផងដែរ ដែលធ្វើយ៉ាងណាមិនឱ្យតិចជាង ៦ (ប្រាំមួយ)ខែ ហើយក្នុងពេលកំណត់នេះ ប្រសិនបើមានសន្តតិជនបង្ហាញខ្លួន ពួកគេត្រូវធ្វើការប្រកាសដោយខ្លួនឯងថាជាសន្តតិជន[185]។ គួររំលឹកផងដែរថា ប្រសិនបើក្នុងអំឡុងពេលកំណត់នេះ គ្មានសន្តតិជនណាមកបង្ហាញខ្លួនទេ ពួកគេនឹងបាត់បង់សិទ្ធិរបស់ខ្លួន ហើយម្ចាស់បំណុលរបស់មតកជន និងអច្ច័យលាភីដែលអ្នកគ្រប់គ្រងមិនអាចដឹងបាន ក៏ពុំអាចអនុវត្តសិទ្ធិនោះបានដូចគ្នា[186]។ យើងឃើញថា បើទោះបីជាមានមត៌កនៅសល់ក្រោយពីការជម្រះក៏ដោយ ក៏ពួកគេមិនអាចអនុវត្តសិទ្ធិរបស់ខ្លួនបានឡើយ។ មួយវិញទៀត ចំពោះការបង្ហាញខ្លួននៃសន្តតិជន ក្រោយពេលបញ្ចប់អំឡុងពេលនៅក្នុងនីតិវិធីនៃការជូនដំណឹងលើកទី ៣ នេះ មិននាំឱ្យរាំងស្ទះដល់នីតិវិធីនៃនីតិបុគ្គលមត៌កឡើយ ឬអាចនិយាយម៉្យាងទៀតថា នីតិបុគ្គលមត៌កនៅតែបន្តនីតិវិធី។

ហើយចំពោះនីតិវិធីនៃនីតិបុគ្គលមត៌ក ដែលនឹងបន្តនោះ គឺការចែកមត៌ក ដែលនៅសល់ក្រោយការរលត់សិទ្ធិ (ក្នុងករណីខ្លះ) ទៅឱ្យជនដែលមាននិស្ស័យពិសេស ហើយដែលជននោះ ត្រូវដាក់ពាក្យសុំទៅតុលាការ នៅក្នុងអំឡុងពេល ៣(បី)ខែ ក្រោយអំឡុងពេលស្វែងរកសន្តតិជនបានកន្លងហួស។ នៅទីនេះ ប្រសិនបើតុលាការពិចារណាឃើញថា សមហេតុផល តុលាការអាចនឹងចេញដីកាសម្រេចប្រគល់ផ្នែកនៃមត៌កនោះទៅឱ្យជនដែលមាននិស្ស័យពិសេស។ ហើយចំពោះចំនួននៃចំណែកដែលត្រូវប្រគល់ឱ្យទៅជនមាននិស្ស័យពិសេសនេះ គឺមិន

[184] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៩៧-១។
[185] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៩៧។
[186] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៩៧។

អាចលើសពីពាក់កណ្ដាលនៃមត៌កដែលនៅសេសសល់នោះឡើយ [187] ។ គួររំលឹកផងដែរថា ជនដែលមាននិស្ស័យពិសេស គឺជាបុគ្គលដែលអាចជាញាតិ ឬមិនមានជាញាតិរបស់មតកជន ហើយដែលខ្លួនបានខិតខំមើលថែ ព្យាបាលមតកជនពេលនៅរស់ ជាអាទិ៍។

## កថាខណ្ឌទី ៣ ៖ ការបញ្ចប់នីតិបុគ្គលមត៌ក

នៅពេលដែលដំណើរការទៅដល់ចំណុលណាមួយ ទោះបីជាបានសម្រេចដល់គោលបំណង ឬមិនបាន នីតិបុគ្គលមត៌កក៏នឹងត្រូវរលត់ទៅវិញផងដែរ ហើយដោយយោងតាមប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី ការបញ្ចប់ទៅវិញនៃនីតិបុគ្គលមត៌ក អាចស្តែងឡើងក្រោយរូបភាពយ៉ាងហោចណាស់ ៣(បី) ដូចជា (១) នៅពេលដែលមានការបង្ហាញខ្លួននៃសន្តតិជន ហើយយល់ព្រមទទួលសន្តតិកម្ម, (២) នៅពេលដែលគ្មានទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃនីតិបុគ្គលមត៌កនៅមាន, និង (៣) នៅពេលដែលនីតិវិធីបានដើរដល់ដំណាក់កាលចុងក្រោយដោយរលូន។

### ១. វត្តមានសន្តតិជន និងការទទួលមត៌ក

ជាធម្មតា ការបង្ហាញខ្លួននៃសន្តតិជន គឺអាចនឹងជះឥទ្ធិពលដល់ដំណើរការនីតិបុគ្គលមត៌ក ហើយការជះឥទ្ធិពលនោះ ក៏អាចជាការបញ្ចប់នូវនីតិបុគ្គលមត៌កនោះផងដែរ។ តាមរយៈនេះ យើងឃើញថា ប្រសិនបើសន្តតិជនមានវត្តមាននៅក្នុងអំឡុងពេលកំណត់នៃការជូនដំណឹងលើកទី ១ (ការជូនដំណឹងជាសាធារណៈចំពោះការជ្រើសតាំងអ្នកគ្រប់គ្រង), ឬ នៅក្នុងអំឡុងពេលកំណត់នៃការជូនដំណឹងលើកទី ៣[188]។ នៅក្នុងករណីនេះ ការបង្ហាញខ្លួននៃសន្តតិជន ភ្ជាប់នឹងការយល់ព្រមទទួលសន្តតិកម្ម នឹងធ្វើឱ្យនីតិបុគ្គលមត៌ករលាយ ឬបញ្ជប់ដំណើរការដោយស្វ័យប្រវត្តិ[189]។ ហើយដូចគ្នាដែរ ដោយសារតែកម្មវត្ថុនៃការងារជាអ្នកគ្រប់គ្រងត្រូវបានផ្ទេរទៅឱ្យសន្តតិជនហើយ ដូច្នេះ សិទ្ធិ និងករណីយកិច្ចរបស់អ្នកគ្រប់គ្រងមត៌កក៏ត្រូវរលត់ទៅតាមនោះដែរ[190]។

### ២. ករណីធនក្ស័យ

ពាក្យថា ធនក្ស័យ អាចនឹងត្រូវបានប្រើប្រាស់សម្រាប់នីតិបុគ្គលទូទៅ ក៏ប៉ុន្តែក៏អាចយកមកប្រើប្រាស់ក្នុងករណីនេះផងដែរ ដែលថា នីតិបុគ្គលមត៌កនឹងត្រូវរលត់នៅក្នុងករណីដែលបានធ្វើសកម្មភាពមួយចំនួន

---

[187] អ៊ឹរ ប៉ូលី, *សន្តតិកម្ម (មេរៀនសង្ខេប)* (គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី, ២០១១), ទំព័រ ៥០។

[188] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៩១ និង ១២៩៧។

[189] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៩៤។

[190] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១២៩៥។

ចាំបាច់សម្រាប់ការជម្រះមត៌ក សម្រាប់តែទូទាត់ទៅឃើញថា មិនមានមត៌កនៅសល់ឡើយ ដូច្នេះ ការរក្សាអត្ថិភាពនៃនីតិបុគ្គលមត៌ក ក៏គ្មានប្រយោជន៍អ្វីដែរ[191]។

**៣. ការបញ្ចប់នីតិវិធីដោយស្វ័យភាព**

នៅករណីដែលនីតិវិធីនៃនីតិបុគ្គលមត៌ក បានប្រព្រឹត្តទៅជាធម្មតា ដោយបានឆ្លងកាត់ដំណាក់កាលនានា ដូចជានីតិវិធីនៃការជូនដំណឹងជាសាធារណៈទាំង ៣ លើក ហើយនៅបន្ទាប់ពីបានឃើញថា មានមត៌កដែលទាន់បានចាត់ចែងក្រោយ បានសម្រេចឱ្យជនមាននិស្សិយពិសេស មត៌កសេសសល់នោះ នឹងធ្លាក់ទៅជាទ្រព្យសម្បត្តិរដ្ឋ។ ការធ្លាក់មកជាទ្រព្យសម្បត្តិរដ្ឋ នៃផ្នែកដែលនៅសល់ពីការបែងចែក ឬជម្រះនានានោះ គឺជាដំណាក់កាលចុងក្រោយនៃនីតិបុគ្គលមត៌ក បន្ទាប់ពីនេះ នីតិបុគ្គលមត៌កនឹងត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ[192]។

[191] ក្រុមការងារគណៈមេធាវី *នីតិបុគ្គលមត៌ក,* ២៥-៣០ ឧសភា ២០១៤, ៩។

[192] ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១៣០០។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

តាមរយៈការសិក្សាទៅលើទិដ្ឋភាពទូទៅនៃរបបសន្តតិកម្មក្នុងនីតិកម្ពុជា យើងសង្កេតឃើញថារបបនេះពិតជាមានសារៈសំខាន់ និងដែលត្រូវបានគេចាត់ទុកជាដំណោះស្រាយមួយដ៏ល្អចំពោះបញ្ហាគ្រួសារដែលកើតចេញពីការចែងចែកមត៌ករបស់បុគ្គលដែលស្លាប់ទៅ។ ចាប់តាំងពីសម័យបុរាណ មកដល់សម័យទំនើបនេះ របបសន្តតិកម្មត្រូវបានគេអនុវត្តក្នុងទម្រង់ផ្សេងៗគ្នា ដោយស្របតាមទិដ្ឋភាព និងការវិវឌ្ឍនៃសង្គមពីមួយសម័យកាលទៅមួយសម័យកាល។ នៅមុនច្បាប់សរសេរចូលមកដល់ យើងសង្កេតឃើញមានរឿងព្រេងខ្មែរមួយចំនួនបានបង្ហាញពីសញ្ញាណនៃការដោះស្រាយជម្លោះដែលកើតចេញពីសន្តតិកម្មនេះ។ រឿងព្រេងទាំងនោះ ត្រូវបានគេនិយាយតៗគ្នា ហើយនឹងត្រូវបានគេកត់ត្រាទុកនៅពេលក្រោយមកទៀត ដែលបន្សល់ជាទ្រព្យមួយយ៉ាងមានតម្លៃសម្រាប់ឆ្លុះបញ្ចាំងពីទិដ្ឋភាពសង្គមកាលពីសម័យបុរាណ ពិសេសទាក់ទងនឹងការដោះស្រាយទំនាស់ក្នុងការបែងចែកមត៌កទាំងផ្នែកសារធាតុ និងផ្នែកនីតិវិធី ដូចជាគោលការណ៍នៃការបែងចែកទ្រព្យតាមទំហំនៃឧបការគុណ និងការរៀបចំជាថ្នាក់នៃការជម្រះក្តីជាដើម។ គោលការណ៍ទាំងនេះ គឺបានបន្សល់ជាមត៌កនៃយុត្តិធម៌តាមបែបខ្មែរយ៉ាងមានតម្លៃ។ ក្រៅពីប្រភពនៅក្នុងរឿងព្រេង យើងក៏ឃើញមានប្រភពមួយចំនួនទៀតដែលមានរូបភាពជាច្បាប់សរសេរដូចជា ក្រមមត៌ក និងក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ ជាដើម។ ច្បាប់ទាំងនេះ បានបង្កើតជាមូលដ្ឋានរឹងមាំជាងមុនសម្រាប់ការដោះស្រាយវិវាទសន្តតិកម្ម ត្បិតវាមានភាពលម្អិត និងច្បាស់លាស់ជាងមុន ប៉ុន្តែគេជឿថាបវេណីនៅតែត្រូវបានគេអនុវត្តដដែល។ ច្បាប់ទាំងពីរនេះ ត្បិតតែបាននិរាករណ៍ហើយក្តី ប៉ុន្តែស្មារតីរបស់វានៅតែអាចរកឃើញក្នុងប្បញ្ញត្តិជាធរមានមួយចំនួនក្នុងពេលបច្ចុប្បន្ន។ តមកទៀត របត់សង្គមកម្ពុជាមានការប្រែប្រួលយ៉ាងខ្លាំង ពិសេសរយៈពេលពីរទសវត្សក្រោយការទទួលបានឯករាជ្យពីបារាំង។ របបសន្តតិកម្មនៅកម្ពុជា ទទួលឥទ្ធិពលយ៉ាងខ្លាំងពីរបត់សង្គមនេះ ដែលអាចចែកចេញជាពីរចំណុច គឺសង្គមកម្ពុជាក្រោមឥទ្ធិពលនៃរដ្ឋធម្មនុញ្ញបែបសង្គមនិយម ដែលរបបសន្តតិកម្មត្រូវបានរលត់ដោយហេតុថាទ្រព្យសម្បត្តិឯកជនត្រូវបានរឹតត្បិត និងរដ្ឋធម្មនុញ្ញបែបសេរីនិយមក្នុងពេលក្រោយមកទៀត ដែលជាការរស់ឡើងវិញនៃរបបសន្តតិកម្មតាមរយៈការចូលមកដល់នៃការទទួលស្គាល់ទ្រព្យសម្បត្តិឯកជន។ ក្នុងពេលបច្ចុប្បន្ន របបសន្តតិកម្មកម្ពុជាមានភាពធំធាត់ជាបន្តបន្ទាប់ក្រោយការចូលជាធរមាននៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ដែលជាការរួមបញ្ចូលនៃបទពិសោធន៍នីតិកម្ពុជា និងបទពិសោធន៍នៃនីតិជប៉ុន។ នៅក្នុងក្រមរដ្ឋប្បវេណីថ្មីនេះ ប្បញ្ញត្តិសំខាន់ៗផ្សេងៗដូចជា បទប្បញ្ញត្តិទូទៅនៃសន្តតិកម្ម ប្រភេទនៃសន្តតិកម្ម រួមទាំងចំណុចជាច្រើនទៀតដូចជា ករណីនត្ថិភាពនៃសន្តតិជនជាដើម ដែលបានផ្តល់ជាដំណោះស្រាយយ៉ាងសំបូរបែបសម្រាប់បញ្ហាដែលកើតចេញពីការបែងចែកមត៌ក។

ចំពោះបទប្បញ្ញត្តិទូទៅនៃសន្តតិកម្ម ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានកំណត់ពីចំណុចមួយចំនួនដូចជាការចាប់ផ្តើមសន្តតិកម្ម សញ្ញាណនៃសន្តតិជន និងអានុភាពនៃសន្តតិកម្មជាដើម។ សន្តតិកម្មត្រូវបានចាប់ផ្តើមនៅពេលដែលមានការទទួលមរណភាព ឬការចាត់ទុកថាបានទទួលមរណភាព។ ទីកន្លែងនៃសន្តតិកម្ម ត្រូវចាប់ផ្តើមនៅលំនៅឋានចុងក្រោយដែលមតកជនរស់នៅក្នុងករណីមតកជនរស់នៅប្រទេសកម្ពុជា និងលំនៅឋានចុងក្រោយរបស់មតកជននៅប្រទេសកម្ពុជាចំពោះមតកជនដែលរស់នៅបរទេស។ ក្រោយពេលទទួលមរណភាព សន្តតិជននឹងទទួលបានចំណែកមត៌ក។ នៅក្នុងករណីទូទៅ បុគ្គលម្នាក់អាចមានលក្ខណសម្បត្តិជាសន្តតិជនបានក្នុងករណីបុគ្គលនោះនៅរស់រានមានជីវិត។ ចំពោះទារកដែលនៅក្នុងគភ៌ ការទទួលបានសន្តតិកម្មនេះ ត្រូវបានរក្សាសិទ្ធិជូនក្រោយការចាប់កំណើត។ ទោះបីជាយ៉ាងនេះក្តី ប្រសិនបើបុគ្គលទាំងនេះបានប្រព្រឹត្តនូវកំហុសមួយចំនួនដែលប៉ះពាល់ដល់សន្តិសុខសង្គម សន្តិសុខរបស់មតកជន សន្តតិជនមួយចំនួនទៀត ឬអត្តន័យនៃមតកសាសន៍ជាដើម ជនទាំងនោះអាចថ្លោះសិទ្ធិជាសន្តតិជនបានដែលអាចមានទម្រង់ជាអភ័ព្វបុគ្គល ឬជនដែលត្រូវបានផ្តាច់ចេញពីមត៌ក។ ក្រៅពីនេះ ក្រមរដ្ឋប្បវេណីក៏បានបញ្ជាក់ពីករណីពិសេសមួយទាក់ទងនឹងសន្តតិជនជាជនបរទេសផងដែរ ដោយហេតុថាជនបរទេសមិនអាចទទួលបានសិទ្ធិលើដីធ្លីនៅកម្ពុជាបាននោះទេ ដែលតម្រូវឱ្យមានបញ្ញត្តិចូលអន្តរាគម ដែលនីតិបុគ្គលមត៌កជាឧទាហរណ៍មួយដ៏ល្អនៃការអន្តរាគមនេះ។ ក្រៅពីការបញ្ជាក់ពីប្រភេទនៃសន្តតិជន ក្រមរដ្ឋប្បវេណីក៏បានបង្ហាញពីអានុភាពនៃសន្តតិកម្មផងដែរ។ ក្រមថ្មីនេះ ជ្រើសរើសយកគោលការណ៍សន្តតិកម្មដោយស្វ័យប្រវត្តិជាគោលសម្រាប់កំណត់ពីអានុភាពនៃសន្តតិកម្មជាជាងការជ្រើសយកគោលការណ៍ជម្រះបញ្ជី ដោយពិចារណាទៅលើបទពិសោធន៍នៃនីតិខ្មែរផង និងទិដ្ឋភាពសង្គមជាក់ស្តែងផង។ ក្នុងគោលការណ៍នៃសន្តតិជនត្រូវទទួលបន្តនូវឋានៈរបស់មតកជនក្នុងករណីមានសន្តតិជនតែម្នាក់ ឬត្រូវបែងចែកសិទ្ធិ និងកាតព្វកិច្ចរបស់មតកជនចំពោះករណីមានសហសន្តតិជន។ ប៉ុន្តែដោយហេតុថា ការទទួលបន្តដោយស្វ័យប្រវត្តិនេះអាចនឹងជាបន្ទុកដល់សន្តតិជនក្នុងករណីដែលមតកជនមានទ្រព្យអកម្មច្រើន នោះគេបានបង្កើតរបបនៃការបោះបង់ចោលមត៌ក។ តាមរយៈបញ្ញត្តិទាំងនេះ យើងឃើញថាក្រមរដ្ឋប្បវេណីថ្មីបានកំណត់ពីដំណោះស្រាយទៅលើបញ្ហាយ៉ាងច្រើន។ ប៉ុន្តែនៅតែមានចំណុចមួយចំនួនដែលតម្រូវឱ្យមានការបកស្រាយ។ ទីមួយ គឺទាក់ទងនឹងការកំណត់ពីអត្ថិភាពនៃមរណភាព។ ទោះបីជាមានបទពិសោធន៍មួយចំនួនក៏ដោយ បញ្ហាមួយចំនួនដូចជាការស្លាប់នៃខួរក្បាលជាដើមនៅតែមិនទាន់ត្រូវបានកំណត់ថាជាការទទួលមរណភាពនៅឡើយ ត្បិតជីវិតរបស់បុគ្គលនេះនៅតែមាន ប៉ុន្តែទិដ្ឋភាពជារួមហាក់បីដូចជាមនុស្សស្លាប់ដូចគ្នាដែរ ដែលតម្រូវឱ្យមានការបកស្រាយ។ ទីពីរ គឺទាក់ទងនឹងការកំណត់ពីតុលាការមានសមត្ថកិច្ចចំពោះករណីមតកជនរស់នៅបរទេស ហើយដែលមិនធ្លាប់មានទីលំនៅពិតប្រាកដនៅកម្ពុជា ដែលនាំឱ្យបង្កើតជាផលពិបាកផ្នែកសមត្ថកិច្ច។ ទីបី គឺករណីទារកនៅក្នុងគភ៌ ពិសេសគឺទាក់ទងនឹងការចាប់កំណើត

ដោយហេតុថាទារកមួយអាចកើតហើយ និងស្លាប់ទៅវិញភ្លាម ឬអាចស្លាប់ទៅវិញនៅក្នុងពេលយ៉ាងខ្លី ដែលតម្រូវឱ្យមានការកំណត់ពីពេលវេលាជាក់លាក់នៃការចាត់ទុកថា តើការកើតមកក្នុងរយៈពេលយូរប៉ុណ្ណាទើបអាចចាត់ទុកថាជាការចាប់កំណើត។ បញ្ហាទាំងនេះ សុទ្ធតែតម្រូវឱ្យមានដំណោះស្រាយ។

មួយវិញទៀត ចំពោះការអនុវត្តរបបសន្តតិកម្មនៅកម្ពុជា ជាពិសេសតាមរយៈខ្លឹមសារនៃធរមានប្បញ្ញត្តិពិសេសក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ យើងឃើញថា សន្តតិកម្មអាចនឹងត្រូវបានបែងចែងទៅជា ២ ប្រភេទធំៗ រួមមាន សន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍។ ការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចពីមតកជន ទៅសន្តតិជនរបស់ខ្លួននោះ តាមរយៈប្រភេទផ្សេងៗនៃសន្តតិកម្មនេះ នឹងនាំឱ្យមានការអនុវត្តស្ដែងចេញតាមរូបភាពដោយឡែកពីគ្នាដែរ។ មិនតែប៉ុណ្ណោះ ក្រមរដ្ឋប្បវេណី ដោយគោរពទៅលើគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន យើងឃើញថា ឆន្ទៈរបស់ម្ចាស់ទ្រព្យនៅពេលដែលគាត់នៅរស់ក៏ត្រូវបានច្បាប់យកមកពិចារណាជាអាទិភាពដែរ ពោលគឺ នៅពេលមតកជនទទួលមរណភាព ឬជាពេលសន្តតិកម្មចាប់ផ្ដើម គេនឹងត្រូវពិចារណាថាតើមតកជននោះ មានបន្សល់ទុកនូវបណ្ដាំ ឬលិខិតមតកសាសន៍ឬទេ។ ប្រសិនបើមាន ជាគោលការណ៍ គេនឹងអនុវត្តទៅតាមលិខិតបណ្ដាំនោះ។ ប៉ុន្តែ ទោះជាច្បាប់ទទួលស្គាល់នូវអត្ថិភាពនៃលិខិតមតកសាសន៍ជាចម្បងយ៉ាងនេះក៏ដោយ មតកជននៅពេលនៅរស់ក្នុងការបង្ហាញឆន្ទៈចាត់ចែងបេតិកភណ្ឌរបស់ខ្លួន ក៏ត្រូវគោរពនូវលក្ខខណ្ឌតម្រូវដោយច្បាប់មួយចំនួនផងដែរ ដើម្បីឱ្យឆន្ទៈរបស់ខ្លួន អាចទទួលបានការការពារពីច្បាប់ និងយកទៅអនុវត្តបាន។ ប៉ុន្តែ នៅពេលមរណភាពរបស់មតកជន ប្រសិនបើគេមិនបានរកឃើញថាមានមតកសាសន៍នោះទេពេលនោះ ប្បញ្ញត្តិនៃសន្តតិកម្មតាមច្បាប់នឹងត្រូវយកមកអនុវត្ត។ ហើយចំពោះការអនុវត្តនូវរបបសន្តតិកម្មតាមច្បាប់ ក៏គេត្រូវសិក្សាផងដែរទៅលើថាតើ បុគ្គលណាដែលអាចមានលទ្ធភាពទទួលសន្តតិកម្មបាន ហើយដែលនៅក្នុងនោះ សន្តតិជនលំដាប់ទី ១ ដល់ទី ៣, សន្តតិជនជានិច្ច (សហព័ទ្ធរបស់មតកជន), និងប្បញ្ញត្តិស្ដីពីសន្តតិជនជំនួសត្រូវបានលើកយកមកពិភាក្សា។ ដោយឡែកចំពោះនីតិវិធីនៃការបែងចែកមត៌ក គឺមានការអនុវត្តផ្សេងៗពីគ្នារវាងសន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍ ពោលគឺនៅក្នុងនីតិវិធីចំពោះសន្តតិកម្មតាមច្បាប់ យើងបានពិភាក្សាទៅលើវិធាននៃការបែងចែក ដែលតាមរយៈនេះ យើងឃើញថាចំពោះមត៌ករបស់សន្តតិជនទៅតាមលំដាប់នីមួយៗគឺមានការបែងចែកជាក់លាក់ ដោយឡែកចំពោះនីតិវិធីនៃការបែងចែកមត៌កក្នុងករណីសន្តតិកម្មតាមមតកសាសន៍វិញ វិធាននៃការបែងចែកអាចតម្រូវឱ្យមាននូវនីតិវិធីនៃការបញ្ជាក់និងការបើកលិខិតមតកសាសន៍ ការបញ្ជាក់អំពីអត្តសញ្ញាណនៃសន្តតិជន កម្មវត្ថុនៃសន្តតិកម្ម និងការបញ្ជាក់អំពីកាតព្វកិច្ចនានាជាដើម។

ខុសពីករណីទូទៅដែលមានសន្តតិជនរង់ចាំទទួលសន្តតិកម្ម ក្នុងករណីមួយមួយចំនួនសន្តតិកម្មនោះ មិនមានសន្តតិជននោះទេ ដែលអាចកើតចេញពីការដែលមតកជនមិនមានញាតិខ្លួនឯង ឬមិនមានជនណាព្រម ទទួលសន្តតិកម្ម ឬក៏ព្រមទទួលដែរប៉ុន្តែជាអភ័ព្វបុគ្គល ឬបុគ្គលដែលត្រូវបានផ្តាច់ចេញពីមត៌កជាដើម។ នៅក្នុង ករណីនេះ មត៌កនោះនឹងក្លាយជាទ្រព្យដែលគ្មានម្ចាស់ ហើយនឹងធ្លាក់ទៅជាសិទ្ធិរបស់រដ្ឋចំពោះអចលនវត្ថុ ឬ របស់បុគ្គលផ្សេងទៀតដែលបានកាន់កាប់ចលនវត្ថុ ប្រសិនបើមិនមានការអន្តរាគមពីប្បញ្ញត្តិណាមួយទេនោះ។ ឆ្លើយតបនឹងបញ្ហានេះ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបង្កើតសញ្ញាណថ្មីមួយទាក់ទងនឹងនីតិបុគ្គលមត៌ក ដើម្បី ទទួលឋានៈបន្តពីមតកជន និងដើម្បីចាត់ចែងមត៌កនេះ ពិសេសគឺដើម្បីធានាពីសិទ្ធិលើបំណុលនៃម្ចាស់បំណុល របស់មតកជន។ ចំពោះការបង្កើត ដំណើរការ និងការបញ្ចប់នីតិបុគ្គលនេះ គឺមានលក្ខណៈពិសេសគួរឱ្យកត់ សម្គាល់។ នីតិបុគ្គលនេះ ត្រូវបានបង្កើតឡើងដោយស្វ័យប្រវត្តិក្រោយពេលដែលសន្តតិកម្មក្នុងករណីអវត្តមាន សន្តតិជនបានចាប់ផ្តើម។ ទោះជាយ៉ាងណាក៏ដោយ នីតិបុគ្គលនេះមិនអាចដំណើរការបានទេប្រសិនបើមិនមាន អ្នកដឹកនាំគ្រប់គ្រង ទើបច្បាប់នេះបានកំណត់ពីបុគ្គលមួយចំនួនដែលអាចស្នើសុំទៅតុលាការក្នុងការជ្រើសរើស អ្នកដឹកនាំ ដើម្បីឱ្យនីតិបុគ្គលនេះមានដំណើការបាន។

បន្ទាប់ពីយើងដឹងហើយថា វត្តមាននៃអ្នកគ្រប់គ្រងមត៌កមានសារៈសំខាន់ប៉ុណ្ណា យើងក៏បានដឹងរួច ហើយដែរថា អ្នកគ្រប់គ្រងដែលត្រូវបានជ្រើសតាំងដោយតុលាការនោះ នឹងទទួលនូវសិទ្ធិនិងករណីយកិច្ចមួយ ចំនួននៅក្នុងកិច្ចដំណើរការនៃការគ្រប់គ្រងនីតិបុគ្គលមត៌កនោះ។ ហើយមួយវិញទៀត ក្រៅតែអំពីភារកិច្ចដែល ច្បាប់ប្រគល់ឱ្យក្នុងការស្រាវជ្រាវស្វែងរកបេតិកភណ្ឌរបស់មតកជន និងកិច្ចការចាំបាច់មួយចំនួនទៀត អ្នក គ្រប់គ្រងមត៌កនេះ ក៏ត្រូវបានឱ្យទទួលកិច្ចការក្នុងការចាត់ចែងមត៌កផងដែរ ដែលនៅទីនេះ នីតិវិធីនៃការជូន ដំណឹងយ៉ាងហោចណាស់បីលើកត្រូវបានធ្វើឡើង ដោយអ្នកគ្រប់គ្រង ឬដោយតុលាការ។ ហើយនៅក្នុងការជូន ដំណឹងនីមួយៗគឺមានគោលបំណងរបស់វារៀងៗខ្លួន ពាក់ព័ន្ធនឹងការចាត់ចែងមត៌កនោះ។

ជាចុងក្រោយយើងឃើញថា នីតិបុគ្គលមត៌កនៅបន្ទាប់ពីបានសម្រេចនូវបេសកកម្មរបស់ខ្លួនរួចហើយ ក៏នឹងត្រូវបញ្ចប់ទៅវិញផងដែរ។ ហើយ ការបញ្ចប់ឬរលត់ទៅវិញនៃនីតិបុគ្គលមត៌ក គឺអាចកើតឡើងក្រោម រូបភាព ៣ យ៉ាងដូចជា វត្តមាននៃសន្តតិជនដែលបានរកឃើញ ហើយព្រមទទួលសន្តតិកម្ម, នៅពេលដែលគ្មាន ទ្រព្យសម្បត្តិជាកម្មវត្ថុនៃនីតិបុគ្គលមត៌កនៅសេសសល់, និង នៅពេលដែលនីតិវិធីបានបញ្ចប់ដោយស្ថាពរទៅ តាមលំដាប់លំដោយដែលច្បាប់បានកំណត់។

# អនុសាសន៍

# អនុសាសន៍

ទាញចេញពីការពិភាក្សា និងសិក្សាទៅជាចំណុចនានាដែលចោទឡើងក្នុងខ្លឹមសារនៃកិច្ចការសារណានេះ យើងអាចទាញបានជាចំណុចមួយចំនួនដែលត្រូវមានការពិចារណាកែលម្អ ដូចខាងក្រោម ៖

១) ត្រូវធ្វើការកំណត់ពីមូលហេតុនៃការចាប់ផ្ដើមសន្តតិកម្មឱ្យបានច្បាស់លាស់ ពិសេសគឺការកំណត់អត្ថិភាពនៃមរណភាពក្នុងករណីដែលមានការស្លាប់នៃខួរក្បាល ដោយហេតុថា ត្បិតបុគ្គលនេះមិនទាន់ទទួលមរណភាពនៅឡើយ ប៉ុន្តែទិដ្ឋភាពជារួមហាក់ដូចជាមនុស្សស្លាប់ដូច្នេះដែរ ដែលតម្រូវឱ្យមានការកំណត់ឱ្យបានច្បាស់លាស់។ ការកំណត់នេះត្រូវធ្វើឱ្យមានតុល្យភាពរវាងសិទ្ធិឯកជនដែលសំដៅទៅលើបុគ្គលដែលទទួលរងការស្លាប់នៃខួរក្បាល និងផលប្រយោជន៍សេដ្ឋកិច្ចដែលទាក់ទងនឹងទ្រព្យសម្បត្តិដែលត្រូវបានទុកចោលរបស់បុគ្គលនោះ។

២) ត្រូវធ្វើការកំណត់ឱ្យបានច្បាស់ពីអត្ថិភាពនៃកំណើត ត្បិតច្បាប់កម្ពុជានៅមិនទាន់ធ្វើការបញ្ជាក់ថាតើទារកមួយត្រូវកើតបានក្នុងរយៈពេលយូរប៉ុណ្ណាទើបអាចចាត់ទុកថាបានចាប់កំណើត។ បញ្ហានេះ គឺកើតឡើងដោយហេតុថា កុមារមួយចំនួនកើតមកបានក្នុងរយៈពេលខ្លី ហើយបានស្លាប់ទៅវិញដែលធ្វើឱ្យមានភាពស្មុគស្មាញក្នុងការចាត់ចែងមត៌ក។ ហេតុនេះ ការកំណត់ពីរយៈពេលច្បាស់លាស់នឹងធ្វើឱ្យការបកស្រាយច្បាប់មានសង្គតិភាព។

៣) ត្រូវធ្វើការកំណត់ឱ្យបានច្បាស់ពីទីកន្លែងដែលត្រូវចាប់ផ្ដើមសន្តតិកម្ម ក្នុងករណីមតកជនបានស្លាប់នៅបរទេសហើយមិនធ្លាប់មានទីលំនៅពិតប្រាកដនៅកម្ពុជា។ ការកំណត់នេះ គឺមានសារៈសំខាន់ចំពោះការកំណត់សមត្ថភាពតុលាការដើម្បីសម្រេចសេចក្ដីលើបញ្ហានេះ។ ត្បិតនីតិវិធីក្នុងរឿងក្ដីសន្តតិកម្ម ជារឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង នោះវាមិនស្ថិតក្នុងការកំណត់សមត្ថកិច្ចរបស់ក្រមនីតិវិធីរដ្ឋប្បវេណីឡើយ ដែលទាមទារឱ្យមានការបញ្ជាក់ពីបញ្ហានេះ។

៤) សមាសភាពនៃអ្នកគ្រប់គ្រងមត៌ក ក្នុងករណីនត្ថិភាពនៃសន្តតិជន ត្បិតច្បាប់កម្ពុជាមិនបានកំណត់ឱ្យបានច្បាស់លាស់ទៅលើថាតើ នរណាអាចនឹងសក្ដិសមត្រូវបានជ្រើសតាំងធ្វើជាអ្នកគ្រប់គ្រងមត៌ក ហើយជាពិសេសនោះបុគ្គលនោះ គួរតែជាអ្នកច្បាប់ ឬអាចជំនួយដោយអ្នកបច្ចេកទេសលើវិស័យមួយចំនួនដូចជាហិរញ្ញវត្ថុជាដើម ដើម្បីសម្រួលដល់នីតិវិធី និងកាត់បន្ថយនូវហានិភ័យនានាអំពីការចាត់ចែងជម្រះមត៌កក្នុងករណីនីតិបុគ្គលមត៌កនោះ។

៥) ករណីម្ចាស់កម្មសិទ្ធិអវិភាគ ពាក់ព័ន្ធនឹងការបោះបង់សិទ្ធិនៃចំណែកជាអាទិ៍ដូចមានចែងក្នុងមាត្រា ២១០ នៃក្រមរដ្ឋប្បវេណី តើនៅទីនេះ គួរបកស្រាយឱ្យមានការបង្កើតជានីតិបុគ្គលមត៌កឬយ៉ាងណា ដោយហេតុថា ប្រសិនបើមានការបោះបង់ចំណែកនៃកម្មសិទ្ធិអវិភាគ ដោយប្រគល់ចំណែកនោះដោយស្វ័យប្រវត្តិទៅឱ្យម្ចាស់កម្មសិទ្ធិអវិភាគផ្សេងទៀត អាចនឹងស្តែងឡើងក្រោមរូបភាពមិនសមចំពោះម្ចាស់បំណុល ឬជនមានផលប្រយោជន៍ពាក់ព័ន្ធផ្សេងទៀត។

# ឯកសារយោង

# ឯកសារយោង

## ១. បទដ្ឋានគតិយុត្ត

### ក. ធរមានប្បញ្ញត្តិ


រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣។

ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤, ១៦ កក្កដា ២០១៤។

ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខនស/រកម/០៧០៦, ០៦ កក្កដា ២០០៦។

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

អនុក្រឹត្យស្តីពីអគ្រានុកូលដ្ឋាន, លេខ ១០៣ អនក្រ.បក, ២០០០។


### ខ. អធរមានប្បញ្ញត្តិ (និរាករណ៍)


ក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០

រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៦

ច្បាប់ភូមិបាល ឆ្នាំ១៩៩២

ច្បាប់ភូមិបាល ឆ្នាំ២០០១

ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩


## ២. សៀវភៅទ្រឹស្តី និងឯកសារផ្សេងៗទៀត

### ក. ភាសាខ្មែរ


ក្រុមប្រជុំទំនៀមទម្លាប់ខ្មែរ, *ប្រជុំរឿងព្រេងខ្មែរ ភាគ ៣,* ភ្នំពេញ, វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត, ឆ្នាំ២០០១។

គណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, *សន្ទានុក្រមផ្នែករដ្ឋប្បវេណី,* ភ្នំពេញ, ទីស្តីការគណៈរដ្ឋមន្ត្រី, ឆ្នាំ២០០៧។

ដេវិឌ ឆាណ្ឌលែរ *ប្រវត្តិសាស្ត្រខ្មែរ* កម្ពុជា មជ្ឈមណ្ឌលខេមរសិក្សា បោះពុម្ពលើកទី៣ ឆ្នាំ២០០៩។

ណូមូរ៉ា តូយ៉ូហ៊ីរ៉ូ សេចក្តីផ្តើមនីតិរដ្ឋប្បវេណី ភ្នំពេញ បោះពុម្ពលើកទី៥ ដោយ JICA ឆ្នាំ ២០១១។

ត្រឹង ងារ, *អរិយធម៌ខ្មែរ,* ភ្នំពេញ, ការផ្សាយរបស់អ្នកនិពន្ធ, បោះពុម្ពលើកទី៣, ឆ្នាំ១៩៧៤។

ទេព បូផល និង អ៊ុំ ប៉ូលី, *ការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយមូលហេតុសន្តតិកម្ម* ភ្នំពេញ វិភាគទានច្បាប់ ចេញផ្សាយឆ្នាំ២០១៨។

ប៉ួយ ធីតា និង កង ស៊ីផាន់ណារ៉ា "*នីតិរដ្ឋប្បវេណី*" ភ្នំពេញ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បោះពុម្ពឆ្នាំ ២០១៨។

ព្រុំ វិទ្ធី "នីតិបេតិកភណ្ឌ និងគ្រួសារ" ភ្នំពេញ សកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច បោះពុម្ពលើកទី១ ឆ្នាំ២០១៩។

វ៉ាន់ឌី កាអុន "*ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា*" ភាគទី២ ការផ្សាយរបស់អ្នកនិពន្ធ បោះពុម្ពលើកទី២ ឆ្នាំ២០០៨។

*សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី* ភ្នំពេញ ទីស្ដីការគណៈរដ្ឋមន្ត្រី ចេញផ្សាយឆ្នាំ ២០០៧។

សមាជិកក្រុមការងារ អនាគតគ្រូបណ្ដុះបណ្ដាលនៃសាលាភូមិន្ទចៅក្រម និង នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃវិទ្យាស្ថានស្រាវជ្រាវ និង បណ្ដុះបណ្ដាលនៃក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន *ក្រមរដ្ឋប្បវេណី ភាគ ៦* ភ្នំពេញ បោះពុម្ពដោយ JICA និង ICD ឆ្នាំ២០១២។

*សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង* ភ្នំពេញ ក្រសួងយុត្តិធម៌ បោះពុម្ពឆ្នាំ ២០១១។

*សេចក្ដីកំណត់នៃមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* ភ្នំពេញ ក្រសួងយុត្តិធម៌ បោះពុម្ពឆ្នាំ២០០៩។

ហ៊ី សោភា "*នីតិវិធីរដ្ឋប្បវេណី*" ភ្នំពេញ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ហ៊ែល ចំរើន, *មគ៌កយុត្តិធម៌ខ្មែរ,* ភ្នំពេញ, រោងពុម្ពដាយអឹមិនព្រីនធីង, បោះពុម្ពឡើងវិញ, ឆ្នាំ២០១៩។

ហាប់ ផល្លី "*នីតិរដ្ឋប្បវេណី*" ភ្នំពេញ បោះពុម្ពដោយសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

អ៊ីកិដា ម៉ាសាអូ *ច្បាប់រដ្ឋប្បវេណី៖ ករណីប្រទេសជប៉ុន* បោះពុម្ពដោយ សមាគមអ្នកច្បាប់ជប៉ុនដើម្បីកម្ពុជា ឆ្នាំ២០០៨។

អ៊ុំ ប៉ូលី, *សន្តតិកម្ម (មេរៀនសង្ខេប)* ភ្នំពេញ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈមេធាវី ចេញផ្សាយឆ្នាំ ២០១១។

អេង សុត *ការសិក្សាច្បាប់គ្រប់មាត្រាទាំងអស់ក្នុងក្រមរដ្ឋប្បវេណី* ភ្នំពេញ បោះពុម្ពលើកទី១ ឆ្នាំ១៩៦៧។

## ខ. ភាសាបរទេស

*Asian* Development Bank, *Cambodia, 2019-2023: Inclusive Pathways to a Competitive Economy,* 2019.

*Commissioner* on Uniform State Laws, Revised Uniform Unclaimed Property Act, National Conference of Commissioner on Uniform State Law, 2016.

*Hindu* Succession Act, 1956.

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

## គំនូសបំព្រួញនៃលំហូរនៃនីតិវិធី ក្នុងករណីនត្ថិភាពនៃសន្តតិជន



# ក្រមរដ្ឋប្បវេណី

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

## ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# គន្ថីទី ៨

# សន្តតិកម្ម

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### ផ្នែកទី ១

### ការចាប់ផ្ដើមធ្វើសន្តតិកម្ម

**មាត្រា ១១៤៥.–** មូលហេតុនៃការចាប់ផ្ដើមធ្វើសន្តតិកម្ម

១-សន្តតិកម្ម ត្រូវចាប់ផ្ដើមដោយមរណភាពរបស់មតកជន ។

២-សន្តតិកម្ម ត្រូវធ្វើឡើងដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ឬ ដោយផ្អែកតាមឆន្ទៈរបស់មតកជន ។ សន្តតិកម្មដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ហៅថា សន្តតិកម្មតាមច្បាប់ សន្តតិកម្មដោយផ្អែកតាមឆន្ទៈរបស់មតកជន ហៅថា សន្តតិកម្មមានបណ្ដាំ ។

**មាត្រា ១១៤៦.–** ទីកន្លែងចាប់ផ្ដើមសន្តតិកម្ម

សន្តតិកម្ម ត្រូវចាប់ផ្ដើមនៅលំនៅឋានរបស់មតកជន នាពេលទទួលមរណភាព ។

### ផ្នែកទី ២

### អានុភាពនៃសន្តតិកម្ម

**មាត្រា ១១៤៧.–** ការទទួលបន្តនូវមតិក

១-សន្តតិជន ត្រូវទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ចទាំងអស់ ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន ចាប់ពីពេលដែលចាប់ផ្ដើមសន្តតិកម្ម ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសិទ្ធិ និង ករណីយកិច្ចផ្ដាច់មុខទាំងស្រុងរបស់មតកជន ។

២-ចំពោះកម្មសិទ្ធិលើវត្ថុសម្រាប់ជំនឿសាសនា និង ចេតិយ ឬ ចលនវត្ថុដែលជារតនសម្បត្តិគ្រួសារនៃបុព្វជន បើមានជនដែលត្រូវទទួលបន្តកម្មសិទ្ធិទាំងនោះ ដូចជាជន

ដែលត្រូវដឹកនាំពិធីបុណ្យនៃបុព្វជន ដោយយោងតាមការកំណត់របស់មតកជន ជននោះត្រូវទទួលបន្ត ។ បើមតកជនពុំបានកំណត់ទេ ជនដែលត្រូវដឹកនាំពិធីបុណ្យនៃបុព្វជនត្រូវទទួលបន្តនូវកម្មសិទ្ធិទាំងនោះ ដោយយោងតាមទំនៀមទម្លាប់ ។ ប្រសិនបើទំនៀមទម្លាប់មិនច្បាស់លាស់ទេ តុលាការត្រូវកំណត់ជនដែលត្រូវទទួលបន្តនោះ ។

**មាត្រា ១១៤៨.-** ការទទួលបន្តសិទ្ធិលើទ្រព្យសម្បត្តិ ក្នុងករណីដែលមានសន្តតិជនច្រើននាក់

១-ប្រសិនបើមានសន្តតិជនច្រើននាក់ សហសន្តតិជនម្នាក់ៗ ត្រូវទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ច តាមសមាមាត្រនៃចំណែកមត៌កនោះ ។ ប៉ុន្តែ សិទ្ធិ ឬ ករណីយកិច្ចដែលមិនអាចបែងចែកបាន តាមលក្ខណៈនៃសិទ្ធិ ឬ ករណីយកិច្ចនោះ ត្រូវទទួលបន្ត ដោយអវិភាគីយ៍ ។

២-មត៌កនេះ នឹងត្រូវស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់សហសន្តតិជន ។

## ផ្នែកទី ៣
## ភាពគ្រប់លក្ខណសម្បត្តិជាសន្តតិជន

**មាត្រា ១១៤៩.-** បុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ជាសន្តតិជន ជាអាទិ៍

១-មានតែជនដែលមានជីវិតរស់នៅ នាពេលចាប់ផ្តើមសន្តតិកម្ម ក្រៅពីបុគ្គលដែលបញ្ញត្តចាប់ពីមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) រហូតដល់មាត្រា ១១៥២ (ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍) ខាងក្រោមនេះទេ ទើបអាចទទួលសន្តតិកម្មបាន ។

២-ទោះមានបញ្ញត្តិដូចកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៩ (ទារកនៅក្នុងគភ៌) នៃក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះទារកដែលនៅក្នុងគភ៌ ។

**មាត្រា ១១៥០.-** អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍

បុគ្គលដែលបានកំណត់ដូចខាងក្រោមនេះ ពុំអាចក្លាយជាសន្តតិជន ឬ ពុំអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បានឡើយ :

ក-បុគ្គលដែលបានទទួលទោស ដោយមានចេតនាធ្វើឃាត ឬ ប៉ុនប៉ងធ្វើឃាតលើមតកជន ឬ លើជនដែលមានលំដាប់សន្តតិកម្មមុន ឬ លំដាប់ស្មើគ្នា ទោះដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី ។

ខ-បុគ្គលដែលដឹងអំពីការសម្លាប់មតកជន តែមិនបានរាយការណ៍ ឬ មិនបានប្តឹង ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះ មិនអាចវិនិច្ឆ័យអំពើល្អ ឬ អាក្រក់បាន ឬ ករណីដែលអ្នកសម្លាប់ជាសហព័ទ្ធ ឬ ញាតិលោហិតខ្សែផ្ទាល់របស់បុគ្គលនោះ ។

គ-បុគ្គលដែលបានរារាំងមតកជនក្នុងការធ្វើ លុបចោល ឬ កែប្រែមតក-សាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង ។

ឃ-បុគ្គលដែលបានឱ្យមតកជនធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង ។

ង-បុគ្គលដែលបានក្លែង កែបន្លំ បំផ្លាញចោល ឬ លាក់ទុកនូវលិខិតមតក-សាសន៍ស្តីពីសន្តតិកម្ម របស់មតកជន ។

**មាត្រា ១១៥១.-** ការផ្តាច់មត៌កពីសន្តតិជន

១-មតកជន កាលនៅរស់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យផ្តាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ មិនឱ្យទទួលសន្តតិកម្មបាន បើជនដែលត្រូវបានសន្មតថាជាសន្តតិជនដែលមានភាគបម្រុង បានប្រព្រឹត្តនូវសកម្មភាពដែលបានកំណត់ខាងក្រោមនេះ :

ក-បើបានធ្វើបាបចំពោះមតកជន ។

ខ-បើបានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ ។

គ-បើអាចមកមើលថែទាំមតកជននៅពេលដែលមានជម្ងឺ ប៉ុន្តែមិនមកថែទាំ ។

ឃ-បើត្រូវបានទទួលសាលក្រម ឬ សាលដីកាផ្តន្ទាទោសឱ្យជាប់ពន្ធនាគារមួយ

ជីវិត ។

ង-បើបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឱ្យកត់សំគាល់ ជាអាទិ៍ ។

មតកជន ក៏អាចបង្ហាញឆន្ទៈអំពីការផ្តាច់មត៌កនេះ តាមមតកសាសន៍បានដែរ ។

២-ជនដែលត្រូវបានសន្មតថាជាសន្តតិជនដែលបានទទួលការទាមទារផ្តាច់មត៌កនេះ អាចធ្វើវិវាទអំពីអត្ថិភាព ឬ នត្ថិភាព នៃមូលហេតុនៃការផ្តាច់មត៌កនេះ នៅក្នុងការសម្រេចសេចក្តីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

**មាត្រា ១១៥២.-** ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍

បើមតកជនបានធ្វើមតកសាសន៍ដូចបានកំណត់នៅក្នុងមាត្រា ១១៥១ (ការផ្តាច់មត៌កពីសន្តតិជន) ខាងលើនេះ អ្នកប្រតិបត្តិមតកសាសន៍ ត្រូវដាក់ពាក្យសុំទៅតុលាការឱ្យផ្តាច់មត៌កពីសន្តតិជន ដោយគ្មានការយឺតយ៉ាវ នៅក្រោយពេលដែលមតកសាសន៍នោះបានបង្កើតអានុភាព ។ ក្នុងករណីនេះ ការផ្តាច់មត៌កពីសន្តតិជននោះ មានអានុភាពប្រតិសកម្ម ចាប់ពីពេលដែលមតកជនបានទទួលមរណភាព ។

**មាត្រា ១១៥៣.-** ការកាន់កាប់មត៌ក ដោយអភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍

បើបុគ្គលដែលជាអភ័ព្វបុគ្គលនៃសន្តតិកម្ម ឬ បុគ្គលដែលមិនអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បាន តាមបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) ឬ បុគ្គលដែលត្រូវបានកាត់ផ្តាច់ពីសន្តតិកម្ម តាមបញ្ញត្តិនៃមាត្រា ១១៥១ (ការផ្តាច់មត៌កពីសន្តតិជន) និង មាត្រា ១១៥២ (ការផ្តាច់មត៌កពីសន្តតិជន ដោយមតក-សាសន៍) ខាងលើនេះ កំពុងកាន់កាប់មត៌ក បុគ្គលនោះត្រូវបានចាត់ទុកថាជាអ្នកកាន់កាប់ដោយទុច្ចរិត គិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម ។

**មាត្រា ១១៥៤.-** ការលុបចោលនូវការផ្តាច់មត៌កពីសន្តតិជន

១-មតកជន កាលនៅរស់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យលុបចោលនូវការផ្តាច់មត៌កពីជន ដែលត្រូវបានសន្មតថាជាសន្តតិជន នៅពេលណាក៏បាន ។

២-បញ្ញត្តិនៃមាត្រា ១១៥២ (ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍) ខាង

លើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការលុបចោលនូវការផ្តាច់មត៌កពីសន្តតិ-ជន ។

**មាត្រា ១១៥៥.-** ករណីដែលសន្តតិជនជាអាទិ៍ ជាជនជាតិបរទេស

១-បើសន្តតិជន ឬ បុគ្គលដែលទទួលទ្រព្យសម្បត្តិតាមមតកសាសន៍ ពុំមានសញ្ជាតិជាខ្មែរទេ ជននោះពុំអាចទទួលដីធ្លី តាមសន្តតិកម្ម ឬ តាមអច្ច័យទានបានឡើយ ។

២-បើសហសន្តតិជនម្នាក់ ឬ ច្រើននាក់ ពុំមានសញ្ជាតិជាខ្មែរទេ មត៌កត្រូវបែងចែក ដោយពិចារណាយ៉ាងហ្មត់ចត់ទៅលើបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

៣-បើសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ ពុំមានសញ្ជាតិជាខ្មែរទេ ដីធ្លីនៅក្នុងចំណោមមត៌ក ត្រូវក្លាយជានីតិបុគ្គល ហើយការគ្រប់គ្រង និង ការចាត់ចែងដីធ្លីនោះ ត្រូវធ្វើឡើងដោយសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ ។

៤-បើសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ បានលក់ដីធ្លី ក្នុងនាមជាម្ចាស់សិទ្ធិចាត់ចែងមត៌ក ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ បានយល់ព្រមទាំងស្រុង ឬ បានយល់ព្រមដោយមានកម្រិត ថ្លៃលក់ដីធ្លីនោះត្រូវក្លាយជាមត៌ក ហើយនីតិបុគ្គលមត៌កដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវរលត់ ។

៥-បើសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់ មិនបានលក់ដីធ្លី ក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលសន្តតិជនដែលមានលំដាប់សន្តតិកម្មមុនទាំងអស់នោះ បានយល់ព្រមទាំងស្រុង ឬ បានយល់ព្រមដោយមានកម្រិត ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៤ ខាងលើនេះ កម្មសិទ្ធិលើដីធ្លីនោះ ត្រូវបានធ្វើសន្តតិកម្មដោយសន្តតិជនដែលមានលំដាប់ក្រោយបន្ទាប់ ហើយដែលមានសញ្ជាតិជាខ្មែរ ។ ក្នុងករណីនេះ នីតិបុគ្គលមត៌កដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវបានចាត់ទុកថាគ្មានអត្ថិភាព ។

# ជំពូកទី ២
# សន្តតិកម្មតាមច្បាប់

## ផ្នែកទី ១
## សន្តតិជន

**មាត្រា ១១៥៦.-** សន្តតិជនដែលមានលំដាប់ទី ១

១-កូនរបស់មតកជន ត្រូវក្លាយជាសន្តតិជនដែលមានលំដាប់ទី ១ ។

២-កូនរបស់មតកជន ទោះបីជាកូនបង្កើតក្តី ឬ កូនសុំក្តី ត្រូវមានចំណែកមត៌កស្មើៗគ្នា ។

**មាត្រា ១១៥៧.-** សន្តតិកម្មជំនួស

១-បើកូនរបស់មតកជន បានទទួលមរណភាព នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិសន្តតិកម្ម ដោយត្រូវនឹងល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) ខាងលើនេះ ឬ ដោយការផ្តាច់មត៌ក កូនរបស់បុគ្គលនោះ ត្រូវក្លាយទៅជាសន្តតិជនជំនួស ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះបុគ្គលដែលមិនមែនជាបច្ឆាញាតិផ្ទាល់របស់មតកជន ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តជាបន្តបន្ទាប់ ចំពោះករណីដែលមានមូលហេតុដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនេះ ចំពោះអ្នកទទួលសន្តតិកម្មជំនួស ។

**មាត្រា ១១៥៨.-** ចំណែកមត៌ក ក្នុងករណីនៃសន្តតិកម្មជំនួស

ចំណែកមត៌ក របស់បច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន ដោយយោងតាមបញ្ញត្តិនៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) ខាងលើនេះ ត្រូវដូចគ្នានឹងចំណែកមត៌កដែលបុព្វញាតិផ្ទាល់របស់បច្ឆាញាតិផ្ទាល់នោះត្រូវទទួលបាន ។ ប្រសិនបើបច្ឆាញាតិផ្ទាល់មានចំនួនច្រើននាក់ ចំណែកមត៌កដែលបុព្វញាតិផ្ទាល់របស់បច្ឆាញាតិផ្ទាល់រៀងៗខ្លួន

នោះ ត្រូវទទួលបាន ត្រូវបែងចែកស្មើៗគ្នា រវាងបច្ឆាញាតិទាំងឡាយនោះ ។

**មាត្រា ១១៥៩.-** សន្តតិជនដែលមានលំដាប់ទី ២

១-បើមតកជនពុំមានបច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ បុព្វញាតិផ្ទាល់របស់មតកជននោះ ត្រូវក្លាយជាសន្តតិជន ។ ប៉ុន្តែ រវាងបុគ្គលដែលមានថ្នាក់ញាតិខុសគ្នា ត្រូវយកបុព្វញាតិដែលនៅជិតជាង ជាមុន ។

២-ប្រសិនបើបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន មានចំនួនច្រើននាក់ បុព្វ-ញាតិផ្ទាល់នីមួយៗត្រូវទទួលចំណែកមត៌កស្មើៗគ្នា ។

**មាត្រា ១១៦០.-** សន្តតិជនដែលមានលំដាប់ទី ៣

១-បើមតកជនពុំមានទាំងបច្ឆាញាតិផ្ទាល់ ទាំងបុព្វញាតិផ្ទាល់ ដែលត្រូវក្លាយជាសន្តតិជនទេ បងប្អូនបង្កើតរបស់មតកជននោះ ត្រូវក្លាយជាសន្តតិជន ។

២-បើបងប្អូនបង្កើតមានចំនួនច្រើននាក់ បងប្អូនបង្កើតម្នាក់ៗត្រូវបានចំណែកមត៌កភាគស្មើៗគ្នា ។ ប៉ុន្តែ ចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុក ឬ ម្តាយតែម្ខាងដូចគ្នា ត្រូវមាន ១ ភាគ ២ (មួយភាគពីរ) នៃចំណែកមត៌ករបស់បងប្អូនដែលមានឪពុក និង ម្តាយទាំងសងខាងដូចគ្នា ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) និង បញ្ញត្តិនៃមាត្រា ១១៥៨ (ចំណែកមត៌ក ក្នុងករណីនៃសន្តតិកម្មជំនួស) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបងប្អូនបង្កើតរបស់មតកជនដែលត្រូវក្លាយជាសន្តតិជន យោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ បានទទួលមរណភាពនៅមុនពេលចាប់ផ្តើមសន្តតិកម្ម ។

## ផ្នែកទី ២
## សន្តតិកម្មរបស់សហព័ទ្ធ

**មាត្រា ១១៦១.-** សន្តតិកម្មរបស់សហព័ទ្ធ

១-សហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជនជានិច្ច ។

២-នៅក្នុងករណីដែលសហព័ទ្ធរបស់មតកជន ត្រូវក្លាយជាសន្តតិជន បើមានបុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវជាសន្តតិជនដែរ ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) ខាងលើនេះ សហព័ទ្ធនោះត្រូវមានលំដាប់ស្មើគ្នានឹងបុគ្គលនោះ ។

**មាត្រា ១១៦២.-** ចំណែកមត៌ក ក្នុងករណីដែលមានសហព័ទ្ធ

ក្នុងករណីដែលសហព័ទ្ធរបស់មតកជន និង បុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធ ត្រូវក្លាយជាសន្តតិជន ចំណែកមត៌ករបស់សន្តតិជន នឹងត្រូវមានតាមកំណត់ដូចខាងក្រោមនេះ :

ក-បើសហព័ទ្ធ និង បច្ឆាញាតិផ្ទាល់របស់មតកជននោះ ជាសន្តតិជន សហព័ទ្ធ និង កូននីមួយៗ របស់មតកជននោះ នឹងត្រូវទទួលចំណែកមត៌កស្មើគ្នា ។

ខ-បើសហព័ទ្ធ និង ឪពុក ម្ដាយរបស់មតកជន ជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធ ត្រូវជា ១ ភាគ ៣ (មួយភាគបី) ឯចំណែកមត៌ករបស់ឪពុក ម្ដាយ ត្រូវជា ២ ភាគ ៣ (ពីរភាគបី) ។ ប៉ុន្តែ បើឪពុក ឬ ម្ដាយ របស់មតកជនតែម្នាក់នៅរស់ ឪពុក ម្ដាយនោះ និង សហព័ទ្ធ ត្រូវបានចំណែកមត៌កស្មើគ្នា ។

គ-បើសហព័ទ្ធ និង បុព្វញាតិផ្ទាល់ក្រៅពីឪពុក ម្ដាយរបស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសបុគ្គលទាំងនោះ ជាសន្តតិជន ចំណែកមត៌ករបស់សហព័ទ្ធ ត្រូវជា ១ ភាគ ២ (មួយភាគពីរ) ឯចំណែកមត៌ករបស់បុព្វញាតិផ្ទាល់ក្រៅពីឪពុក ម្ដាយ របស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសនោះ ត្រូវជា ១ ភាគ ២ (មួយភាគពីរ) ។

## ផ្នែកទី ៣
## ការសម្រួលចំណែកមត៌ក

**មាត្រា ១១៦៣.-** ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស

១-នៅក្នុងចំណោមសហសន្តតិជនទាំងអស់ បើមានបុគ្គលណាដែលបានទទួលប្រទានកម្ម នៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬ ហេតុការណ៍ផ្សេងទៀត ឬ ដើម្បីមូលធននៃជីវភាពរស់នៅ ឬ ដែលបានទទួលអច្ច័យទានពីមតកជននោះ តម្លៃសរុបនៃមត៌កដែលមតកជនមាននៅពេលចាប់ផ្ដើមសន្តតិកម្ម ដោយបូកបញ្ចូលនូវតម្លៃនៃប្រទានកម្ម ត្រូវបានចាត់ទុកថាជាមត៌ក ហើយចំនួនទឹកប្រាក់ដែលនៅសល់ ក្រោយពីដកតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាននោះ ចេញពីចំណែកមត៌កដែលត្រូវបានគណនាតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) និង ផ្នែកទី ២ (សន្តតិកម្មរបស់សហព័ទ្ធ) គឺជាចំណែកមត៌ករបស់បុគ្គលនោះ ។

២-បើតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាន ស្មើគ្នានឹងតម្លៃនៃចំណែកមត៌ក ឬ លើសពីតម្លៃនៃចំណែកមត៌ក សហសន្តតិជននោះពុំអាចទទួលយកចំណែកមត៌កនោះបានឡើយ ។

**មាត្រា ១១៦៤.-** តម្លៃនៃប្រទានកម្ម

បើបដិគ្គាហក បានចាត់ចែងទ្រព្យសម្បត្តិដែលខ្លួនទទួលដោយប្រទានកម្ម នៅមុនពេលចាប់ផ្ដើមសន្តតិកម្ម ឬ បើទ្រព្យសម្បត្តិនោះត្រូវបានបាត់ ឬ វិនាស នៅមុនពេលចាប់ផ្ដើមសន្តតិកម្ម តម្លៃនៃប្រទានកម្មដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) ខាងលើនេះ ត្រូវគណនា ដោយគិតតម្លៃនៅពេលដែលបានចាត់ចែង ឬ នៅពេលបាត់បង់ ឬ វិនាសនោះ ។ ប្រសិនបើតម្លៃនៃប្រទានកម្មនោះត្រូវបានផ្លាស់ប្ដូរ ដោយសារលទ្ធផលដែលបដិគ្គាហក បានផ្លាស់ប្ដូរទ្រព្យសម្បត្តិនោះមួយផ្នែក តម្លៃនៃប្រទានកម្មនោះ ត្រូវគណនាដោយចាត់ទុកថា មានស្ថានភាពដើម នៅពេលចាប់ផ្ដើមសន្តតិកម្ម ។ ការប្រាក់ និង ផលចំណេញ ដែលកើតចេញពីប្រទានកម្ម ដែលសន្តតិជននោះបានទទួល ពុំត្រូវគណនាចូលក្នុងតម្លៃនោះឡើយ ។

**មាត្រា ១១៦៥.-** ករណីដែលតម្លៃទទួលផលប្រយោជន៍ពិសេសនោះ លើសពីតម្លៃនៃចំណែកមត៌ក

១-ទោះបីជាតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាន ដែលសហសន្តតិជនបានទទួលមានចំនួនលើសពីតម្លៃនៃចំណែកមត៌កក៏ដោយ សហសន្តតិជននោះ ពុំចាំបាច់បង្វិលមកវិញ នូវទ្រព្យសម្បត្តិដែលទាក់ទងនឹងប្រទានកម្ម ដើម្បីសហសន្តតិជនផ្សេងទៀតឡើយ លើកលែងតែត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំណែកមត៌ករបស់សហសន្តតិជនផ្សេងទៀត ត្រូវមានចំនួនទឹកប្រាក់ តាមការគណនា ដោយយកមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ទៅបែងចែកតាមសមាមាត្រនៃចំណែកមត៌ករបស់សហសន្តតិជននីមួយៗ ដែលត្រូវបានកំណត់ដោយយោងតាមបញ្ញត្តិនៃកថា-ខណ្ឌទី ១ មាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) ខាងលើនេះ ។

**មាត្រា ១១៦៦.-** ភាគនៃវិភាគទាន

១-ក្នុងចំណោមសហសន្តតិជនទាំងឡាយ បើមានបុគ្គលណាបានធ្វើវិភាគទានពិសេស ដើម្បីថែរក្សា ឬ បង្កើនទ្រព្យសម្បត្តិរបស់មតកជន ដោយការផ្តល់សេវកម្មលើកិច្ចការរបស់មតកជន ឬ ដោយការផ្តល់តាវកាលិកលើទ្រព្យសម្បត្តិ ឬ ដោយការថែទាំព្យាបាលមតកជន ឬ ដោយវិធីផ្សេងទៀត តម្លៃដែលដកភាគនៃវិភាគទានរបស់បុគ្គលនោះដែលបានកំណត់តាមការពិភាក្សារបស់សហសន្តតិជន ចេញពីតម្លៃមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ត្រូវចាត់ទុកថាជាមត៌ក ហើយចំនួនទឹកប្រាក់នៃភាគនៅក្នុងសន្តតិកម្ម ដែលបានគណនាតាមបញ្ញត្តិនៃផ្នែកទី ១ (សន្តតិជន) និង ផ្នែកទី ២ (សន្តតិកម្មរបស់សហព័ទ្ធ) បូកនឹងភាគវិភាគទាន ត្រូវជាចំណែកមត៌ករបស់ជននោះ ។

២-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់ភាគនៃវិភាគទាន តាមពាក្យសុំរបស់បុគ្គលដែលបានធ្វើវិភាគទានដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នោះ ដោយ

ពិចារណាទៅលើពេល វិធី និង កម្រិតនៃវិភាគទាននោះ ចំនួនទឹកប្រាក់នៃមត៌ក និង ស្ថានភាពទាំងអស់ផ្សេងទៀត ។

៣-ភាគនៃវិភាគទាន មិនអាចឱ្យលើសពីចំនួនទឹកប្រាក់ដែលបានដកចេញនូវតម្លៃនៃអច្ច័យទាន និង តម្លៃនៃទ្រព្យសម្បត្តិ ដែលមតកជនបានកំណត់ថាជាចំណែកមត៌ករបស់សហសន្តតិជន ឬ ជាវិធីបែងចែកមត៌ក ពីចំនួនតម្លៃនៃមត៌ក ដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្មឡើយ ។

៤-ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ អាចធ្វើបានក្នុងករណីដែលមានពាក្យសុំ ដោយយោងតាមកថាខណ្ឌទី ១ នៃមាត្រា ១២៧០ (ការបែងចែកដោយតុលាការ) ឬ មានពាក្យបណ្តឹង ដោយយោងតាមមាត្រា ១២៧៤ (ការទាមទាររបស់ជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមត៌ក) ។

**មាត្រា ១១៦៧.–** ទំនាក់ទំនងជាមួយនឹងតតិយជន

ការសម្រួលចំណែកមត៌កដែលយោងតាមបញ្ញត្តិនៃផ្នែកទី ៣ (ការសម្រួលចំណែកមត៌ក) នេះ មិនអាចយកមកអះអាងនឹងតតិយជនបានឡើយ បើមិនមានល័ក្ខខ័ណ្ឌតតាំងចំពោះលទ្ធផលនៃការបែងចែកមត៌ក ដោយផ្អែកលើការសម្រួលនោះទេ ។

## ជំពូកទី ៣
## សន្តតិកម្មតាមមតកសាសន៍

### ផ្នែកទី ១
### សមត្ថភាពក្នុងការធ្វើមតកសាសន៍

**មាត្រា ១១៦៨.–** បុគ្គលដែលអាចធ្វើមតកសាសន៍បាន

១-បុគ្គលដែលជានីតិជន និង អនីតិជនដែលបានអត្តាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬ អំណាចមេបា អាចធ្វើមតកសាសន៍បាន ។

២-បញ្ញត្តិនៃមាត្រា ២៦ (សិទ្ធិលុបចោលសកម្មភាព) និង មាត្រា ៣០ (សិទ្ធិលុប

ចោលសកម្មភាព) នៃក្រមនេះ មិនត្រូវយកមកអនុវត្តចំពោះមតកសាសន៍ឡើយ ។

**មាត្រា ១១៦៩.–** សមត្ថភាពនាពេលធ្វើមតកសាសន៍

១-ម្ចាស់បណ្ដាំ ត្រូវមានសមត្ថភាព នៅពេលធ្វើមតកសាសន៍ ។

២-បុគ្គលដែលអះអាងអំពីការខ្វះសមត្ថភាពរបស់ម្ចាស់បណ្ដាំ ត្រូវបញ្ជាក់ភស្តុតាងអំពីហេតុនោះ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបានកំណត់នៅក្នុងមាត្រា ១១៧៦ (មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

## ផ្នែកទី ២
## ទម្រង់នៃមតកសាសន៍

**មាត្រា ១១៧០.–** ភាពចាំបាច់នៃទម្រង់មតកសាសន៍

១-មតកសាសន៍ ពុំអាចធ្វើបានឡើយ បើពុំផ្អែកតាមទម្រង់ដែលបានកំណត់ក្នុងក្រមនេះទេ ។

២-មតកសាសន៍ដែលធ្វើមិនត្រូវនឹងទម្រង់ណាមួយក្នុងបញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកជាមោឃៈ ។ ប៉ុន្តែ មតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ ត្រូវចាត់ទុកថាមានសុពលភាព លុះត្រាតែមតកសាសន៍នោះ មិនផ្ទុយនឹងមតកសាសន៍ផ្សេងទៀតដែលបានធ្វើដោយម្ចាស់បណ្ដាំដូចគ្នានេះ ។ នៅក្នុងករណីដែលមតកសាសន៍ដែលគ្មានការចុះថ្ងៃខែឆ្នាំ មានចំនួនច្រើន ហើយបើមតកសាសន៍ទាំងនេះ ផ្ទុយនឹងគ្នា អានុភាពនៃមតកសាសន៍ទាំងនោះត្រូវកាត់បន្ថយគ្នាទៅវិញទៅមក ។

**មាត្រា ១១៧១.–** សុពលភាពនៃទម្រង់

មតកសាសន៍ដែលត្រូវនឹងទម្រង់ណាមួយដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវចាត់ទុកថាមានសុពលភាពចំពោះទម្រង់ ។

**មាត្រា ១១៧២.–** បុគ្គលដែលមិនអាចក្លាយជាសាក្សី ជាអាទិ៍

បុគ្គលដែលកំណត់ដូចខាងក្រោមនេះ មិនអាចធ្វើជាសាក្សី ឬ ជាអ្នកសង្កេតការណ៍នៅពេលធ្វើមតកសាសន៍បានឡើយ ៖

ក-អនីតិជន ឬ ជននៅក្រោមអាណាព្យាបាលធម្មតា ។

ខ-ជនដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី ហើយនិងសហព័ទ្ធ និងញាតិលោហិតខ្សែផ្ទាល់ របស់ជនទាំងនោះ ។

គ-បើសារការីជាអ្នកពាក់ព័ន្ធក្នុងការធ្វើមតកសាសន៍ជាលិខិតយថាភូត ឬ ជាលិខិតមតកសាសន៍សម្ងាត់ សហព័ទ្ធរបស់សារការី ញាតិលោហិតខ្សែផ្ទាល់ ក្រឡាបញ្ជី និងនិយោជិត របស់សារការីនោះ ។

**មាត្រា ១១៧៣.–** មតកសាសន៍ដោយលិខិតយថាភូត

១-មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើងដោយម្ចាស់បណ្តាំ នៅចំពោះមុខសារការី តាមទម្រង់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងក្រោមនេះ ។

២-មតកសាសន៍ដោយលិខិតយថាភូត ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ ៖

ក-ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិច ២ (ពីរ) នាក់ ។

ខ-ម្ចាស់បណ្តាំត្រូវប្រាប់ផ្ទាល់មាត់ នូវខ្លឹមសារនៃមតកសាសន៍ ចំពោះសារការី ។

គ-សារការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះ ជាលាយល័ក្ខណ៍អក្សរ ហើយត្រូវសូត្រឱ្យម្ចាស់បណ្តាំ និង សាក្សីនោះស្តាប់ ។

ឃ-បន្ទាប់ពីម្ចាស់បណ្តាំ និង សាក្សី បានទទួលស្គាល់ថាកំណត់ជាលាយល័ក្ខណ៍អក្សរនោះត្រឹមត្រូវហើយ ជននីមួយៗនោះត្រូវធ្វើឱ្យមានភាពច្បាស់លាស់នៅលើឯកសារអំពីឈ្មោះ អាយុ និង លំនៅឋាន ហើយ ត្រូវចុះហត្ថលេខា រៀងៗខ្លួន ។ ប៉ុន្តែបើម្ចាស់បណ្តាំ មិនអាចសរសេរអក្សរ ឬ មិនអាចចុះហត្ថលេខាបានទេ សារការីអាចជំនួសការសរសេរ និង ហត្ថលេខាដូចកំណត់ខាងលើនេះ ដោយសរសេរឈ្មោះ អាយុ និង លំនៅឋានរបស់ជននោះ ហើយត្រូវសរសេរបន្ថែមនូវហេតុនោះផង ។

ង-សារការីត្រូវសរសេរថ្ងៃខែឆ្នាំ ហើយត្រូវចុះហត្ថលេខា ។

**មាត្រា ១១៧៤.-** មតកសាសន៍ដោយលិខិតឯកជន

១-មតកសាសន៍ដោយលិខិតឯកជន ត្រូវធ្វើឡើង ដោយម្ចាស់បណ្ដាំសរសេរពាក្យទាំងអស់ និង ចុះថ្ងៃខែឆ្នាំ ដោយខ្លួនឯង ហើយត្រូវចុះហត្ថលេខាលើលិខិតនោះ ។ មតក-សាសន៍ដោយលិខិតឯកជនដែលត្រូវបានសរសេរជំនួសដោយអ្នកដទៃ ឬ ដែលត្រូវបានសរសេរដោយប្រើម៉ាស៊ីនដូចជាអង្គុលីលេខ ជាអាទិ៍ នឹងត្រូវចាត់ទុកជាមោឃៈ ។

២-ការបន្ថែម ការលុប ឬ ការកែប្រែផ្សេងទៀត នៅក្នុងមតកសាសន៍ដោយលិខិតឯកជន ពុំមានអានុភាពឡើយ បើម្ចាស់បណ្ដាំមិនបានបង្ហាញនូវកន្លែង ហើយសរសេរបន្ថែមនូវហេតុនៃការកែប្រែនោះ ជាពិសេសបើមិនបានចុះហត្ថលេខាទេ ។

**មាត្រា ១១៧៥.-** មតកសាសន៍ដោយលិខិតសម្ងាត់

មតកសាសន៍ដោយលិខិតសម្ងាត់ ត្រូវធ្វើឡើង ដោយយោងតាមទម្រង់ដូចខាងក្រោមនេះ :

ក-ម្ចាស់បណ្ដាំត្រូវចុះហត្ថលេខាលើលិខិតនោះ ។

ខ-ម្ចាស់បណ្ដាំត្រូវដាក់លិខិតនោះក្នុងស្រោមបិទជិត ហើយត្រូវចុះហត្ថលេខា ឬ សរសេរសញ្ញាសំគាល់ ឬ មធ្យោបាយផ្សេងទៀតដែលអាចវិនិច្ឆ័យបានអំពីការបានបើក ឬ មិនបានបើកស្រោមលិខិតនោះ នៅមាត់ស្រោមលិខិតនោះ ។

គ-ម្ចាស់បណ្ដាំត្រូវដាក់លិខិតដែលបានបិទជិតនោះ នៅចំពោះមុខសារការីម្នាក់ និង សាក្សី ២ (ពីរ) នាក់ និង ធ្វើសេចក្ដីថ្លែងការណ៍ថា លិខិតនេះជាលិខិតមតកសាសន៍របស់ខ្លួន ហើយបើមានជនក្រៅពីសាមីខ្លួនបានសរសេរ ត្រូវធ្វើសេចក្ដីថ្លែងការណ៍អំពីឈ្មោះ និង លំនៅឋានរបស់ជនដែលបានសរសេរនោះ ។

ឃ-សារការីត្រូវចុះថ្ងៃខែឆ្នាំដែលសាមីខ្លួនបានដាក់លិខិតនោះ និង សរសេរសេចក្ដីថ្លែងការណ៍របស់ម្ចាស់បណ្ដាំ នៅលើលិខិតដែលបិទជិតនោះ ហើយត្រូវចុះហត្ថ-លេខាលើលិខិតនោះ ជាមួយគ្នានឹងសាក្សី និង ម្ចាស់បណ្ដាំ ។

**មាត្រា ១១៧៦.-** មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ

១-ដើម្បីធ្វើមតកសាសន៍ នៅពេលដែលជននៅក្រោមអាណាព្យាបាលទូទៅ បានសះស្បើយមួយរយៈឡើងវិញ នូវសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិត យ៉ាងតិច ២ (ពីរ) នាក់ ។

២-វេជ្ជបណ្ឌិតដែលមានវត្តមាននៅពេលធ្វើមតកសាសន៍ ត្រូវសរសេរបញ្ជាក់បន្ថែមលើលិខិតមតកសាសន៍នោះថា នៅពេលដែលម្ចាស់បណ្ដាំបានធ្វើមតកសាសន៍នោះ ម្ចាស់បណ្ដាំពុំបានស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិស្មារតីទេ ហើយត្រូវចុះហត្ថលេខាដោយបញ្ជាក់ថា ខ្លួនជាវេជ្ជបណ្ឌិតផងដែរ ។

**មាត្រា ១១៧៧.-** មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត

១-ប្រសិនបើជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត ដោយសារជម្ងឺ ឬ ហេតុផ្សេងទៀត មានបំណងចង់ធ្វើមតកសាសន៍ មតកសាសន៍នេះអាចធ្វើបានដោយតម្រូវឱ្យមានវត្តមានរបស់សាក្សីយ៉ាងតិច ៣ (បី) នាក់ ហើយដោយប្រកាសខ្លឹមសារនៃមតកសាសន៍នោះ ដោយផ្ទាល់មាត់ ចំពោះជនម្នាក់ ក្នុងចំណោមសាក្សីនោះ ។ នៅក្នុងករណីនេះ ជនដែលបានទទួលការប្រកាសដោយផ្ទាល់មាត់នោះ ត្រូវសរសេរជាលាយល័ក្ខណ៍អក្សរ ហើយអានឱ្យសាក្សីស្ដាប់ ឬ ឱ្យមើល ហើយនៅក្រោយពេលដែលសាក្សីនីមួយៗបានទទួលស្គាល់ថាការសរសេរនោះត្រឹមត្រូវហើយ សាក្សីនីមួយៗនោះ ត្រូវចុះហត្ថលេខាលើលិខិតនោះ ។

២-មតកសាសន៍ដែលបានធ្វើតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ បើសាក្សីណាម្នាក់ ឬ បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ពុំបានដាក់ពាក្យសុំទៅតុលាការ នៅក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានធ្វើមតកសាសន៍នោះ ហើយពុំបានទទួលការបញ្ជាក់ទេ ។

៣-តុលាការមិនអាចធ្វើការបញ្ជាក់មតកសាសន៍បានឡើយ ប្រសិនបើពុំមានជំនឿ

ទុកចិត្តថាមតកសាសន៍នោះ ចេញពីឆន្ទៈពិតប្រាកដរបស់ម្ចាស់បណ្តាំ ។

**មាត្រា ១១៧៨.-** មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង ជាអាទិ៍

១-បុគ្គលដែលជាប់ឃុំឃាំងនៅទីកន្លែងដាច់ដោយឡែក ដោយសាលក្រម ឬ សាលដីកា ឬ ដោយសារការចាត់ចែងផ្នែករដ្ឋបាល អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវឱ្យមានវត្តមានរបស់នគរបាល ឬ មន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ និង សាក្សី យ៉ាងតិច ២ (ពីរ) នាក់ ។

២-បុគ្គលដែលនៅក្នុងនាវា ឬ យន្តហោះ អាចធ្វើលិខិតមតកសាសន៍បាន ដោយត្រូវឱ្យមានវត្តមានមេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះម្នាក់ និង សាក្សីយ៉ាងតិច ២ (ពីរ) នាក់ ។

៣-នៅពេលធ្វើមតកសាសន៍ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះ ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍ ដោយផ្ទាល់មាត់ ចំពោះនគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះបាន ។

៤-បញ្ញត្តិពីចំណុច ខ ដល់ចំណុច ង កថាខណ្ឌទី ២ នៃមាត្រា ១១៧៣ (មតក-សាសន៍ដោយលិខិតយថាភូត) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ។ ក្នុងករណីនេះ ពាក្យ សារការីត្រូវបានបកស្រាយថាជា នគរបាល មន្ត្រីនៃមន្ទីរឃុំឃាំង មេបញ្ជាការ បរិបាលនាវា ឬ យន្តហោះ ឬ បុគ្គលិកនាវា ឬ យន្តហោះ ។

៥-មតកសាសន៍ដែលត្រូវបានធ្វើឡើង ដោយយោងតាមបញ្ញត្តិពីកថាខណ្ឌទី ១ ដល់កថាខណ្ឌទី ៤ ខាងលើនេះ ពុំមានអានុភាពឡើយ បើម្ចាស់បណ្តាំបន្តនៅរស់ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ គិតចាប់ពីពេលដែលម្ចាស់បណ្តាំនោះ បែរជាអាចធ្វើមតកសាសន៍បាន តាមទម្រង់ណាមួយដែលបានកំណត់ចាប់ពីមាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត) ដល់មាត្រា ១១៧៥ (មតកសាសន៍ដោយលិខិតសម្ងាត់) នៃក្រមនេះក្រោយពេលខ្លួនត្រូវបានដោះលែងពីមន្ទីរឃុំឃាំង ឬ ចុះពីនាវា ឬ យន្តហោះ ។

**មាត្រា ១១៧៩.-** ការធ្វើមតកសាសន៍នៃបុគ្គលដែលមិនអាចនិយាយបាន ជាអាទិ៍

១-នៅក្នុងករណីដែលបុគ្គលមិនអាចនិយាយបាន ធ្វើមតកសាសន៍តាមទម្រង់ដែលបានកំណត់នៅក្នុងមាត្រា ១១៧៣ (មតកសាសន៍ដោយលិខិតយថាភូត) មាត្រា ១១៧៥ (មតកសាសន៍ដោយលិខិតសម្ងាត់) មាត្រា ១១៧៧ (មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត) នៃក្រមនេះ ម្ចាស់បណ្តាំនោះអាចជំនួសការប្រាប់បាន ដោយធ្វើសេចក្តីថ្លែងការណ៍អំពីខ្លឹមសារនៃមតកសាសន៍ ឬ សេចក្តីថ្លែងការណ៍ថា លិខិតនោះជាលិខិតមតកសាសន៍ តាមការបកប្រែរបស់អ្នកបកប្រែ ឬ សរសេរដោយដៃខ្លួនផ្ទាល់ នៅចំពោះមុខសារការី ឬ សាក្សី ។

២-ក្នុងករណីដែលសារការី ឬ បុគ្គលផ្សេងទៀតដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវអានឱ្យម្ចាស់បណ្តាំ ឬ សាក្សី ស្តាប់នូវអត្ថន័យនៃមតកសាសន៍ ក្រោយពេលបានសរសេរជាលាយល័ក្ខណ៍អក្សរនូវខ្លឹមសារនៃមតកសាសន៍នោះ បើម្ចាស់បណ្តាំ និង សាក្សីនោះ បែរជាមនុស្សថ្លង់មិនអាចស្តាប់បានទេ សារការី ឬ បុគ្គលផ្សេងទៀតដែលត្រូវបានកំណត់នៅក្នុងក្រមនេះ អាចជំនួសការអានឱ្យស្តាប់បាន ដោយប្រាប់អំពីអត្ថន័យដែលខ្លួនបានសរសេរនោះ តាមការបកប្រែរបស់អ្នកបកប្រែ ទៅម្ចាស់បណ្តាំ ឬ សាក្សីនោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ សារការី ឬ បុគ្គលផ្សេងទៀតដែលបានកំណត់នៅក្នុងក្រមនេះ ត្រូវសរសេរអំពីហេតុនោះចូលទៅក្នុងលិខិតនោះ ។

**មាត្រា ១១៨០.-** ការសរសេរនាមត្រកូល និង នាមខ្លួន និង ការផ្តិតម្រាមដៃ ជំនួសឱ្យការចុះហត្ថលេខា

ក្នុងករណីដែលសារការី និង សាក្សី ត្រូវចុះហត្ថលេខា សារការី និង សាក្សី គ្រាន់តែសរសេរនាមត្រកូល និង នាមខ្លួន និង ផ្តិតម្រាមដៃ ជាការគ្រប់គ្រាន់ហើយ ។

**មាត្រា ១១៨១.-** បទប្បញ្ញត្តិពិសេសចំពោះមតកសាសន៍របស់ជនជាតិខ្មែរដែលរស់នៅបរទេស

បើជនជាតិខ្មែរមានបំណងចង់ធ្វើមតកសាសន៍ដោយលិខិតយថាភូត ឬ លិខិត

សម្ងាត់ នៅកន្លែងដែលមានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅ កុងស៊ុលនោះត្រូវអនុវត្តមុខនាទីរបស់សារការី ។

## ផ្នែកទី ៣
## ចំណុចនៃមតកសាសន៍

**មាត្រា ១១៨២.-** ការកំណត់ចំណែកមត៌ក

១-មតកជនអាចកំណត់ចំណែកមត៌ករបស់សហសន្តតិជនតាមមតកសាសន៍ ឬ អាចបង្គាញឆន្ទៈផ្ទុយពីបញ្ញត្តិនៃមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) នៃក្រមនេះ ស្ដីពីចំណែកមត៌ករបស់បុគ្គលដែលបានទទួលផលប្រយោជន៍ពិសេសបាន ។ ប៉ុន្តែ ការកំណត់ចំណែកមត៌កដែលបំពានភាគបម្រុង ត្រូវអនុលោមតាមបញ្ញត្តិស្ដីពីភាគបម្រុង ។

២-បើមតកជនបានកំណត់ចំណែកមត៌ក ចំពោះសន្តតិជនតែម្នាក់ ឬ ច្រើននាក់ក្នុងចំណោមសហសន្តតិជនទាំងអស់ ចំណែកមត៌ករបស់សហសន្តតិជនផ្សេងទៀត ត្រូវកំណត់ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ៣ (ការសម្រួលចំណែកមត៌ក) ជំពូកទី ២ ។

**មាត្រា ១១៨៣.-** ការកំណត់នូវវិធីបែងចែកដោយមតកសាសន៍ ជាអាទិ៍

មតកជន អាចកំណត់នូវវិធីបែងចែកតាមមតកសាសន៍ ឬ អាចប្រគល់អាណត្តិឱ្យតតិយជនកំណត់វិធីនោះ ឬ អាចហាមឃាត់មិនឱ្យបែងចែកនៅក្នុងអំឡុងពេលដែលមិនលើសពី ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្ដើមសន្តតិកម្មនោះ បាន ។

**មាត្រា ១១៨៤.-** អនុប្បទានទ្រព្យសម្បត្តិ

ម្ចាស់បណ្ដាំអាចធ្វើប្រទានកម្មនូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែក ឬ អាចធ្វើប្រទានកម្មដោយមតកសាសន៍ តាមវិធីដែលបានកំណត់នៅក្នុងមាត្រា ១១៩៩ (និយមន័យនៃអច្ច័យទាន) នៃក្រមនេះបាន នៅក្នុងល័ក្ខខ័ណ្ឌដែលអនុលោមតាមបញ្ញត្តិស្ដីពីភាគបម្រុង ។

**មាត្រា ១១៨៥.-** អនុប្បទានទ្រព្យសម្បត្តិចំពោះសន្តតិជន

១-បើមតកជនបានធ្វើមតកសាសន៍ដែលមានអត្ថន័យជាការធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬ ច្រើន ឱ្យទៅសហសន្តតិជនតែម្នាក់ ឬ ច្រើននាក់ មតក-សាសន៍នោះត្រូវបានសន្មតថាបានកំណត់នូវវិធីបែងចែកមតិក លើកលែងតែនៅក្នុងករណីដែលមតកសាសន៍នោះមានអត្ថន័យជាអច្ច័យទានយ៉ាងច្បាស់លាស់ ដូចជាអច្ច័យទានដែលភ្ជាប់ជាមួយនឹងបន្ទុក ជាអាទិ៍ ហើយបើតម្លៃនៃទ្រព្យសម្បត្តិដែលបានកំណត់នោះ មានចំនួនលើសពីចំណែកមតិករបស់សន្តតិជន នោះត្រូវសន្មតថាបានកំណត់ចំណែកមតិកផងដែរ ។

២-ក្នុងករណីដែលមតកជនបានធ្វើមតកសាសន៍ ចំពោះទ្រព្យសម្បត្តិតែមួយភាគនៅក្នុងចំណោមមតិក បើតម្លៃនៃទ្រព្យសម្បត្តិនោះ មានចំនួនតិចជាងចំណែកមតិក ដែលសន្តតិជននោះត្រូវទទួល លុះត្រាតែពុំមានការបង្ហាញឆន្ទៈផ្សេងទៀតនៅក្នុងមតកសាសន៍នោះ ត្រូវសន្មតថាបានកំណត់ត្រឹមតែវិធីបែងចែកមតិកដែលត្រូវធ្លាក់ទៅលើសន្តតិជននោះតែប៉ុណ្ណោះ ។

**មាត្រា ១១៨៦.-** ការកំណត់នូវអ្នកប្រតិបត្តិមតកសាសន៍

ម្ចាស់បណ្តាំអាចកំណត់អ្នកប្រតិបត្តិមតកសាសន៍ម្នាក់ ឬ ច្រើននាក់ ឬ អាចប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិនោះ តាមមតកសាសន៍បាន ។

**មាត្រា ១១៨៧.-** ចំណុចផ្សេងៗ

ក្រៅពីធ្វើមតកសាសន៍តាមចំណុចដែលបានកំណត់នៅក្នុងក្រមនេះ ម្ចាស់បណ្តាំអាចធ្វើមតកសាសន៍ដោយផ្តល់ដំបូន្មាន ឬ យោបល់ ដើម្បីឱ្យមានភាពសុខដុមរមនាដល់ក្រុមគ្រួសារ និង ចំណុចផ្សេងៗទៀតបាន ។ នៅក្នុងករណីនេះ សន្តតិជន ជាអាទិ៍ ត្រូវគោរពទៅតាមមតកសាសន៍នោះ ។

## ផ្នែកទី ៤
## ការលុបចោលនូវមតកសាសន៍

**មាត្រា ១១៨៨.-** ពេល និង ទម្រង់នៃការលុបចោលនូវមតកសាសន៍

ម្ចាស់បណ្តាំអាចលុបចោលនូវមតកសាសន៍ មួយភាគ ឬ ទាំងមូល នៅពេលណាក៏បាន ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ៤ (ការលុបចោលនូវមតកសាសន៍) នេះ ។

**មាត្រា ១១៨៩.-** ការលុបចោលដោយទម្រង់នៃមតកសាសន៍

១-ម្ចាស់បណ្តាំអាចលុបចោលនូវមតកសាសន៍ មួយភាគ ឬ ទាំងមូលបាន តាមទម្រង់នៃមតកសាសន៍ ។

២-បើមតកសាសន៍ដែលបានធ្វើក្រោយនេះ មានភាពផ្ទុយនឹងមតកសាសន៍ដែលបានធ្វើមុន ត្រូវចាត់ទុកថា មតកសាសន៍ដែលបានធ្វើក្រោយនោះ បានលុបចោលមតក-សាសន៍ដែលបានធ្វើមុន ចំពោះផ្នែកដែលផ្ទុយគ្នានោះ ។

**មាត្រា ១១៩០.-** ការលុបចោលមតកសាសន៍ ដោយការចាត់ចែងនាពេលនៅរស់

បើម្ចាស់បណ្តាំបានធ្វើអនុប្បទាន ឬ បានធ្វើសកម្មភាពផ្សេងទៀត ចំពោះវត្ថុដែលជាកម្មវត្ថុនៃមតកសាសន៍ នាពេលនៅរស់ ត្រូវចាត់ទុកថា ម្ចាស់បណ្តាំបានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលផ្ទុយនឹងអនុប្បទាន ឬ សកម្មភាពផ្សេងនោះ ។

**មាត្រា ១១៩១.-** ការលុបចោលដោយការបដិសេធលិខិតមតកសាសន៍ ជាអាទិ៍

បើម្ចាស់បណ្តាំបានបំផ្លាញច្បាប់ដើមនៃមតកសាសន៍ ដោយចេតនា ត្រូវចាត់ទុកថាបានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលត្រូវបានបំផ្លាញនោះ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បណ្តាំបានបំផ្លាញវត្ថុ ដែលជាកម្មវត្ថុនៃមតកសាសន៍ ដោយចេតនា ។

**មាត្រា ១១៩២.-** ការបោះបង់សិទ្ធិលុបចោលមតកសាសន៍

ម្ចាស់បណ្តាំមិនអាចបោះបង់សិទ្ធិលុបចោលមតកសាសន៍ បានឡើយ ។

**មាត្រា ១១៩៣.-** ការលុបចោលអច្ច័យទានដែលភ្ជាប់បន្ទុក

បើអច្ច័យលាភីពុំបានអនុវត្តករណីយកិច្ចដែលម្ចាស់បណ្តាំបានតម្រូវឱ្យអច្ច័យលាភី នោះទទួលបន្ទុកជាថ្នូរនឹងអច្ច័យទានទេ អ្នកប្រតិបត្តិមតកសាសន៍ ឬ បើគ្មានអ្នកប្រតិបត្តិមតកសាសន៍នោះទេ សន្តតិជនអាចដាស់តឿនឱ្យអច្ច័យលាភីនោះ អនុវត្តករណីយកិច្ចនោះ ដោយកំណត់អំឡុងពេលសមរម្យ ហើយប្រសិនបើអច្ច័យលាភីនោះ មិនបានអនុវត្តករណីយកិច្ច នៅក្នុងអំឡុងពេលនោះទេ អ្នកប្រតិបត្តិមតកសាសន៍ ឬ សន្តតិជននោះ អាចទាមទារទៅតុលាការ ឱ្យលុបចោលអច្ច័យទាននោះបាន ។

## ផ្នែកទី ៥
## អានុភាពនៃមតកសាសន៍

**មាត្រា ១១៩៤.-** ពេលដែលមតកសាសន៍បង្កើតអានុភាព

១-មតកសាសន៍ ត្រូវបង្កើតអានុភាព ចាប់ពីពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ។

២-នៅក្នុងករណីដែលមតកសាសន៍ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ បើល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញនៅក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព មតកសាសន៍នោះ ត្រូវមានអានុភាព ចាប់ពីពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ។

**មាត្រា ១១៩៥.-** អានុភាពនៃការកំណត់ចំណែកមត៌ក ជាអាទិ៍

១-បើមតកជនបានកំណត់ចំណែកមត៌ក ឬ វិធីបែងចែកមត៌ក ដោយធ្វើអនុប្បទានទ្រព្យសម្បត្តិជាក់លាក់តែមួយ ឬ ច្រើន ឱ្យចំពោះសន្តតិជនតែម្នាក់ ឬ ច្រើននាក់ ដោយមតកសាសន៍ ទ្រព្យសម្បត្តិជាក់លាក់នោះ ត្រូវធ្លាក់ទៅសន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះ ដោយស្វ័យប្រវត្តិ ព្រមគ្នានឹងពេលមតកសាសន៍នោះបង្កើតអានុភាព ។

២-នៅក្នុងករណីដែលមតកសាសន៍ ភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ បើល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញនៅក្រោយពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចាត់ទុកថា ត្រូវបានធ្លាក់ទៅ

សន្តតិជនដែលនឹងត្រូវទទួលទ្រព្យសម្បត្តិនោះ ដោយប្រតិសកម្ម គិតចាប់តាំងពីពេលដែលមតកជននោះ បានទទួលមរណភាព ។

**មាត្រា ១១៩៦.–** មរណភាពនៃជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអាទិ៍

១-នៅក្នុងករណីដែលមតកជនបានកំណត់ចំណែកមត៌ករបស់សន្តតិជន ឬ វិធីនៃការបែងចែកមត៌ក ដោយមតកសាសន៍ បើជនដែលត្រូវបានសន្មតថាជាសន្តតិជន បានទទួលមរណភាព នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិសន្តតិកម្ម ដោយត្រូវនឹងបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) នៃក្រមនេះ ឬ ដោយការកាត់កាល់សន្តតិជន ការកំណត់នោះត្រូវបានចាត់ទុកថា បានធ្វើចំពោះអ្នកទទួលសន្តតិកម្មជំនួសរបស់ជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើគ្មានអ្នកទទួលសន្តតិកម្មជំនួសជនដែលត្រូវបានសន្មតថាជាសន្តតិជននោះទេ ការកំណត់ចំពោះជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ ពុំត្រូវបង្កើតអានុភាពឡើយ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសន្តតិជនបានបោះបង់សន្តតិកម្ម ។

៣-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ ទី ២ ខាងលើនេះក៏ដោយ បើមតកជនបានបង្ហាញឆន្ទៈផ្សេង ក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១១៩៧.–** ការកម្រិតនូវមតកសាសន៍ ចំពោះអ្នកអាណាព្យាបាល ជាអាទិ៍

១-បើជនដែលនៅក្រោមអាណាព្យាបាលទូទៅ បានធ្វើមតកសាសន៍ ដែលជាផលប្រយោជន៍ដល់អ្នកអាណាព្យាបាល ឬ សហព័ទ្ធ ឬ បច្ឆាញាតិផ្ទាល់របស់អ្នកអាណាព្យាបាលនោះ នៅមុនពេលបញ្ចប់ការគណនានូវចំណូលចំណាយក្នុងកិច្ចការអាណាព្យាបាល មតក-សាសន៍នោះត្រូវចាត់ទុកជាមោឃៈ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលញាតិលោហិតផ្ទាល់ សហព័ទ្ធ ឬ បងប្អូនបង្កើត ជាអ្នកអាណាព្យាបាលទូទៅ ។

**មាត្រា ១១៩៨.-** សិទ្ធិទទួលទ្រព្យសម្បត្តិ ក្នុងករណីដែលអច្ច័យទានមោឃៈ ជាអាទិ៍

បើអច្ច័យទានពុំបានបង្កើតអានុភាព ដោយសារអច្ច័យលាភីជាអភ័ព្វបុគ្គល ឬ ទទួលមរណភាព ឬ ដោយសារហេតុផ្សេងទៀត ឬ បើពុំបានបង្កើតអានុភាពដោយសារការបោះបង់ ទ្រព្យដែលអច្ច័យលាភីត្រូវទទួលនោះ ត្រូវធ្លាក់ទៅសន្តតិជនរបស់មតកជន ។ ប៉ុន្តែ បើម្ចាស់បណ្ដាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

## ផ្នែកទី ៦
## អច្ច័យទាន

**មាត្រា ១១៩៩.-** និយមន័យនៃអច្ច័យទាន

អច្ច័យទានសកល គឺជាប្រទានកម្មដែលម្ចាស់បណ្ដាំធ្វើទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់ នូវទ្រព្យសម្បត្តិទាំងអស់ ឬ មួយផ្នែកដែលកំណត់ទៅតាមភាគ រីឯអច្ច័យទានមានកំណត់ គឺជាប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ ទៅឱ្យមនុស្សម្នាក់ ឬ ច្រើននាក់ ដោយមតកសាសន៍ ។

**មាត្រា ១២០០.-** មរណភាពរបស់អច្ច័យលាភី

១-អច្ច័យទាន ពុំបង្កើតអានុភាពឡើយ បើអច្ច័យលាភីបានទទួលមរណភាព នៅមុន ឬ ក្នុងពេលដែលម្ចាស់បណ្ដាំទទួលមរណភាព ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអច្ច័យទានភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌបង្អង់ ហើយអច្ច័យលាភីបានទទួលមរណភាព នៅមុនពេលដែលល័ក្ខខ័ណ្ឌនោះត្រូវបានបំពេញ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បើម្ចាស់បណ្ដាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

៣-ក្នុងករណីដែលសន្តតិជនដែលត្រូវបានសន្មត ជាអច្ច័យលាភី បញ្ញត្តិនៃកថា-ខណ្ឌទី ១ ខាងលើនេះ មិនរារាំងចំពោះការយកបញ្ញត្តិនៃកថាខណ្ឌទី ១ មាត្រា ១១៩៦ (មរណភាពនៃជនដែលត្រូវបានសន្មតថាជាសន្តតិជន ជាអាទិ៍) នៃក្រមនេះ មកអនុវត្តឡើយ ។

**មាត្រា ១២០១.–** ការបោះបង់អច្ច័យទាន

១-នៅក្រោយពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព អច្ច័យលាភីអាចបោះបង់អច្ច័យទាន នៅពេលណាក៏បាន ។ ប៉ុន្តែ ចំពោះការបោះបង់អច្ច័យទានសកល ត្រូវអនុលោមតាមបញ្ញត្តិស្ដីពីការបោះបង់សន្តតិកម្ម ។

២-ការបោះបង់អច្ច័យទាន ត្រូវមានអានុភាពប្រតិសកម្ម ចាប់ពីពេលដែលម្ចាស់បណ្ដាំបានទទួលមរណភាព ។

**មាត្រា ១២០២.–** ការដាស់តឿនរបស់ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍

បុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធទៅនឹងអច្ច័យទាន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អាចដាស់តឿនឱ្យអច្ច័យលាភីទទួលស្គាល់ ឬ បោះបង់អច្ច័យទានបានដោយកំណត់អំឡុងពេលសមរម្យ ។ បើអច្ច័យលាភីមិនបានបង្ហាញឆន្ទៈ ចំពោះបុគ្គលដែលមានករណីយកិច្ចពាក់ព័ន្ធទៅនឹងអច្ច័យទាន នៅក្នុងអំឡុងពេលដែលបានកំណត់នោះទេ ត្រូវចាត់ទុកថា អច្ច័យលាភីបានទទួលស្គាល់អច្ច័យទាននោះ ។

**មាត្រា ១២០៣.–** ការបោះបង់ ឬ ការទទួលស្គាល់ ដោយសន្តតិជនរបស់អច្ច័យលាភី

បើអច្ច័យលាភីបានទទួលមរណភាព ដោយមិនបានទទួលស្គាល់ ឬ បោះបង់អច្ច័យទានទេ សន្តតិជនរបស់អច្ច័យលាភីនោះ អាចទទួលស្គាល់ ឬ បោះបង់អច្ច័យទានបាន ត្រឹមទំហំនៃសិទ្ធិលើសន្តតិកម្មរបស់ខ្លួន ។ ប៉ុន្តែ បើម្ចាស់បណ្ដាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១២០៤.–** ការលុបចោលនូវការទទួលស្គាល់ ឬ ការបោះបង់

១-ការទទួលស្គាល់ ឬ ការបោះបង់អច្ច័យទាន ពុំអាចលុបចោលវិញបានទេ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៥២ (ការលុបចោលការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការទទួលស្គាល់ និង ការបោះបង់អច្ច័យទាននេះ ។

**មាត្រា ១២០៥.–** ការទទួលស្គាល់ ឬ បោះបង់ ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន

១-ក្នុងករណីដែលអច្ច័យលាភីជាសន្តតិជន បើបានបោះបង់សន្តតិកម្ម បុគ្គលនោះត្រូវបានចាត់ទុកថាបានបោះបង់អច្ច័យទានផងដែរ ។ អច្ច័យលាភីនោះ មិនអាចទទួលស្គាល់អច្ច័យទាន ដោយបោះបង់សន្តតិកម្មបានឡើយ ។

២-ទោះបីបានទទួលស្គាល់សន្តតិកម្មហើយក៏ដោយ ក៏អច្ច័យលាភីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចបោះបង់អច្ច័យទានមានកំណត់ បានដែរ ។

**មាត្រា ១២០៦.–** សិទ្ធិទទួលផលរបស់អច្ច័យលាភី

អច្ច័យលាភីអាចទទួលផល ចាប់តាំងពីពេលដែលខ្លួនអាចទាមទារឱ្យអនុវត្តអច្ច័យ-ទានបាន ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១២០៧.–** អច្ច័យទាននៃសិទ្ធិដែលមិនស្ថិតនៅក្នុងមត៌ក

អច្ច័យទាន ពុំមានអានុភាពឡើយ បើសិទ្ធិដែលជាកម្មវត្ថុនៃអច្ច័យទាននោះ ពុំស្ថិតនៅក្នុងមត៌ក នៅពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ។

**មាត្រា ១២០៨.–** អច្ច័យទាននៃវត្ថុ ឬ សិទ្ធិដែលភ្ជាប់ជាមួយនឹងសិទ្ធិរបស់តតិយជន

បើវត្ថុ ឬ សិទ្ធិ ដែលជាកម្មវត្ថុនៃអច្ច័យទាន ជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជន នៅពេលដែលម្ចាស់បណ្តាំទទួលមរណភាព អច្ច័យលាភីមិនអាចទាមទារឱ្យរំលត់សិទ្ធិនោះចំពោះជនដែលមានករណីយកិច្ចពាក់ព័ន្ធនឹងអច្ច័យទានបានឡើយ ។

**មាត្រា ១២០៩.–** ឧបាទេសកម្មលើវត្ថុ

១-បើម្ចាស់បណ្តាំមានសិទ្ធិទាមទារប្រាក់សំណង ចំពោះតតិយជន ដោយការបាត់បង់ ឬ កែបន្លំវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទាន ឬ បាត់បង់ការកាន់កាប់វត្ថុនោះ ត្រូវសន្មតថាបានយកសិទ្ធិនោះ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

២-ក្នុងករណីដែលវត្ថុដែលជាកម្មវត្ថុនៃអច្ច័យទាន មានភាពជាប់គ្នា លាយគ្នា ឬ

ច្របល់គ្នានឹងវត្ថុផ្សេងទៀត បើម្ចាស់បណ្តាំបានក្លាយជាកម្មសិទ្ធិករតែឯង ឬ ជាម្ចាស់កម្មសិទ្ធិអវិភាគនៃវត្ថុដែលបានផ្សំ ដោយយោងតាមបញ្ញត្តិនៃមាត្រា ១៨៦ (ការជាប់គ្នារវាងចលនវត្ថុ និង អចលនវត្ថុ) ឬ មាត្រា ១៩៨ (ការជាប់គ្នា ការលាយច្របល់គ្នានៃចលនវត្ថុ) នៃក្រមនេះ ត្រូវសន្មតថា ម្ចាស់បណ្តាំបានយកកម្មសិទ្ធិទាំងអស់ ឬ កម្មសិទ្ធិអវិភាគនោះ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

**មាត្រា ១២១០.-** ឧបាទេសកម្មលើវត្ថុនៃអច្ច័យទាននៃសិទ្ធិលើបំណុល

១-ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវបានយកមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន បើម្ចាស់បណ្តាំបានទទួលសំណង ហើយបើវត្ថុដែលបានទទួលនោះ នៅតែមានក្នុងមត៌ក ត្រូវសន្មតថាបានយកវត្ថុនោះមកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ។

២-ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ត្រូវសន្មតថាបានយកប្រាក់ និង ប្រាក់បញ្ញើ មកធ្វើជាកម្មវត្ថុនៃអច្ច័យទាន ត្រឹមកម្រិតនៃប្រាក់ដែលមាននៅក្នុងមត៌ក និង ប្រាក់ដែលបានបញ្ចូលក្នុងប្រាក់បញ្ញើ ក្រោយពីបានសង ។

**មាត្រា ១២១១.-** ការទទួលខុសត្រូវរបស់អច្ច័យលាភី នៅក្នុងអច្ច័យទានភ្ជាប់បន្ទុក

១-ជនដែលបានទទួលអច្ច័យទានភ្ជាប់បន្ទុក ត្រូវទទួលខុសត្រូវក្នុងការអនុវត្តករណីយកិច្ចដែលខ្លួនទទួលបន្ទុក ត្រឹមតែកម្រិតដែលមិនលើសពីតម្លៃនៃកម្មវត្ថុនៃអច្ច័យទាននោះប៉ុណ្ណោះ ។

២-បើតម្លៃនៃកម្មវត្ថុនៃអច្ច័យទានភ្ជាប់បន្ទុក បានចុះថយ ដោយសារការទទួលស្គាល់សន្តតិកម្មដោយមានកម្រិត ឬ ដោយសារការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង អច្ច័យលាភីត្រូវរួចផុតពីករណីយកិច្ចដែលខ្លួនត្រូវទទួលបន្ទុក តាមសមាមាត្រនៃភាគដែលចុះថយនោះ ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

**មាត្រា ១២១២.-** សិទ្ធិ និង ករណីយកិច្ចរបស់អច្ច័យលាភីសកល

១-អច្ច័យលាភីសកល មានសិទ្ធិ និង ករណីយកិច្ច ដូចគ្នានឹងសន្តតិជន ។

២-បើមត៌កទាំងអស់ត្រូវបានធ្វើអច្ច័យទានសកលឱ្យទៅបុគ្គលផ្សេងដែលមិនមែនជាសន្តតិជន សន្តតិជនត្រូវបានចាត់ទុកថា មិនបានទទួលសន្តតិកម្ម លើកលែងតែសិទ្ធិលើភាគបម្រុង ។

## ផ្នែកទី ៧
## ការប្រតិបត្តិមតកសាសន៍

**មាត្រា ១២១៣.–** ការពិនិត្យបញ្ជាក់ និង ការបើកលិខិតមតកសាសន៍

១-អ្នកថែរក្សាគ្រប់គ្រងលិខិតមតកសាសន៍ ត្រូវដាក់ពាក្យសុំការបញ្ជាក់លិខិតនោះ ដោយភ្ជាប់លិខិតមតកសាសន៍នោះ ជូនទៅតុលាការ ដោយគ្មានការយឺតយ៉ាវ ក្រោយពីខ្លួនបានដឹងអំពីការចាប់ផ្ដើមសន្តតិកម្ម ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលគ្មានអ្នកថែរក្សាគ្រប់គ្រង ក្រោយពេលដែលសន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ផ្សេងទៀត បានរកឃើញលិខិតមតកសាសន៍នោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះមតកសាសន៍ដែលបានធ្វើដោយលិខិតយថាភូត ។

៣-លិខិតមតកសាសន៍ដែលបិទដោយប្រថាប់ត្រា អាចបើកបានតែនៅតុលាការ ដោយមានវត្តមានរបស់អ្នកសង្កេតការណ៍ជាសន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ឬ អ្នកតំណាងរបស់ជននោះ ។

៤-បុគ្គលដែលបានបើកលិខិតមតកសាសន៍ នៅក្រៅតុលាការ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ នឹងត្រូវពិន័យស៊ីវិលជាប្រាក់ មិនលើសពី ១.០០០.០០០ (មួយលាន) រៀល ។

៥-ចំពោះលិខិតមតកសាសន៍ ទោះបីជាបានបើកនៅក្រៅតុលាការ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ក៏ដោយ មិនត្រូវបាត់បង់អានុភាព ដោយសារតែមូលហេតុនោះឡើយ ។

**មាត្រា ១២១៤.-** ការកំណត់អ្នកប្រតិបត្តិមតកសាសន៍

១-បើម្ចាស់បណ្តាំបានប្រគល់អាណត្តិឱ្យតតិយជនកំណត់អ្នកប្រតិបត្តិមតកសាសន៍តាមមតកសាសន៍ ជនដែលបានទទួលអាណត្តិ ត្រូវកំណត់អ្នកប្រតិបត្តិមតកសាសន៍ ហើយត្រូវជូនដំណឹងនោះទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

២-បើជនដែលបានទទួលអាណត្តិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មានបំណងលាឈប់ពីអាណត្តិនោះ ជននោះត្រូវជូនដំណឹងអំពីហេតុនោះ ទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

**មាត្រា ១២១៥.-** ការកាន់មុខងាររបស់អ្នកប្រតិបត្តិមតកសាសន៍

បើអ្នកប្រតិបត្តិមតកសាសន៍ បានយល់ព្រមកាន់មុខងារហើយ អ្នកប្រតិបត្តិមតក-សាសន៍នោះ ត្រូវអនុវត្តភារកិច្ចនោះ ភ្លាមៗ ។

**មាត្រា ១២១៦.-** ការដាស់តឿនឱ្យអ្នកប្រតិបត្តិមតកសាសន៍កាន់មុខងារ

១-សន្តតិជន ឬ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ផ្សេងទៀត អាចកំណត់អំឡុងពេលសមរម្យ ហើយដាស់តឿន ចំពោះជនដែលត្រូវបានកំណត់ជាអ្នកប្រតិបត្តិមតក-សាសន៍ ឱ្យឆ្លើយបញ្ជាក់ច្បាស់ក្នុងអំឡុងពេលនោះ អំពីការយល់ព្រម ឬ មិនយល់ព្រមកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍បាន ។ បើអ្នកប្រតិបត្តិមតកសាសន៍ មិនបានឆ្លើយបញ្ជាក់ច្បាស់ ក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា បានលាឈប់ពីការងារនោះ ។

២-បញ្ញត្តិនៃវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលតតិយជន ដែលត្រូវបានប្រគល់អាណត្តិឱ្យកំណត់អ្នកប្រតិបត្តិមតកសាសន៍ ពុំបានកំណត់អ្នកប្រតិបត្តិមតកសាសន៍ ឱ្យបានឆាប់រហ័ស ។ ក្នុងករណីនេះ បើតតិយជននោះមិនបានកំណត់អ្នកប្រតិបត្តិមតកសាសន៍ នៅក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា បានលាឈប់ពីអាណត្តិនោះ ។

**មាត្រា ១២១៧.-** បុគ្គលដែលមិនអាចក្លាយជាអ្នកប្រតិបត្តិមតកសាសន៍

ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិត្ថូបត្ថម្ភ អនីតិជន និង ជន

ធនក្ស័យ ពុំអាចធ្វើជាអ្នកប្រតិបត្តិមតកសាសន៍បានឡើយ ។

**មាត្រា ១២១៨.-** ការជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍

បើគ្មានអ្នកប្រតិបត្តិមតកសាសន៍ទេ ឬ បើបាត់បង់អ្នកប្រតិបត្តិមតកសាសន៍ តុលាការអាចជ្រើសតាំងអ្នកប្រតិបត្តិមតកសាសន៍បាន តាមការទាមទាររបស់សន្តតិជន ឬ អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ ។

**មាត្រា ១២១៩.-** ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ

១-អ្នកប្រតិបត្តិមតកសាសន៍ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ ហើយប្រគល់បញ្ជីសារពើភ័ណ្ឌនោះទៅឱ្យសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

២-សន្តតិជន អាចមានវត្តមាន នៅពេលដែលអ្នកប្រតិបត្តិមតកសាសន៍ ធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិបាន ។

**មាត្រា ១២២០.-** សិទ្ធិអំណាច មុខនាទី នៃអ្នកប្រតិបត្តិមតកសាសន៍

អ្នកប្រតិបត្តិមតកសាសន៍ មានសិទ្ធិ និង ករណីយកិច្ចក្នុងការគ្រប់គ្រងមត៌ក និង ធ្វើនូវរាល់សកម្មភាពផ្សេងទៀតដែលចាំបាច់ ដើម្បីប្រតិបត្តិមតកសាសន៍ ។

**មាត្រា ១២២១.-** ការបាត់បង់នូវសិទ្ធិចាត់ចែងរបស់សន្តតិជន

១-បើមានអ្នកប្រតិបត្តិមតកសាសន៍ សន្តតិជនពុំអាចចាត់ចែងមត៌ក ឬ ធ្វើសកម្មភាពផ្សេងទៀតដែលនាំឱ្យរារាំងដល់ការប្រតិបត្តិមតកសាសន៍បានឡើយ ។

២-ការចាត់ចែងដែលបានធ្វើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានអានុភាពឡើយ ។

**មាត្រា ១២២២.-** ការប្រតិបត្តិមតកសាសន៍ ចំពោះទ្រព្យសម្បត្តិដែលបានកំណត់ជាក់លាក់

ក្នុងករណីមតកសាសន៍ ទាក់ទងនឹងទ្រព្យសម្បត្តិដែលបានកំណត់ជាក់លាក់ បញ្ញត្តិចាប់ពីមាត្រា ១២១៩ (ការធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិ) រហូតដល់មាត្រា ១២២១

(ការបាត់បង់នូវសិទ្ធិចាត់ចែងរបស់សន្តតិជន) នៃក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះតែទៅលើទ្រព្យសម្បត្តិនោះប៉ុណ្ណោះ ។

**មាត្រា ១២២៣.–** ឋានៈនៃអ្នកប្រតិបត្តិមតកសាសន៍

១-អ្នកប្រតិបត្តិមតកសាសន៍ ត្រូវធ្វើសកម្មភាព នៅក្នុងនាមជាអ្នកប្រតិបត្តិមតក-សាសន៍ ចំពោះមតិកដែលខ្លួនត្រូវប្រតិបត្តិ ។

២-សកម្មភាពដែលអ្នកប្រតិបត្តិមតកសាសន៍បានធ្វើជាមុខនាទី ត្រូវមានអានុភាពផ្ទាល់ ចំពោះសន្តតិជន ។

**មាត្រា ១២២៤.–** សិទ្ធិជ្រើសតាំងបន្ត របស់អ្នកប្រតិបត្តិមតកសាសន៍

១-បើគ្មានមូលហេតុដែលពុំអាចជៀសវាងបានទេ អ្នកប្រតិបត្តិមតកសាសន៍ ពុំអាចឱ្យតតិយជនអនុវត្តភារកិច្ចរបស់ខ្លួនបានឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេង នៅក្នុងមតកសាសន៍ ។

២-ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍ បានឱ្យតតិយជនអនុវត្តភារកិច្ចរបស់ខ្លួន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកប្រតិបត្តិមតកសាសន៍នោះត្រូវទទួលខុសត្រូវក្នុងការជ្រើសតាំង និង ការត្រួតពិនិត្យជននោះ ចំពោះអច្ច័យលាភី និង សន្តតិជន ។ បើអ្នកប្រតិបត្តិមតកសាសន៍ បានឱ្យតតិយជនអនុវត្តភារកិច្ចនោះ ដោយផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសងសំណងនៃការខូចខាត ដែលកើតឡើងដោយសារហេតុនោះ ចំពោះអច្ច័យលាភី និង សន្តតិជន ។

**មាត្រា ១២២៥.–** សហអ្នកប្រតិបត្តិមតកសាសន៍

១-ក្នុងករណីដែលអ្នកប្រតិបត្តិមតកសាសន៍មានច្រើននាក់ ការអនុវត្តភារកិច្ចនោះត្រូវសម្រេចដោយសម្លេងលើសពីពាក់កណ្តាល ។ ប៉ុន្តែ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈផ្សេងក្នុងមតកសាសន៍ ត្រូវអនុលោមតាមឆន្ទៈនោះ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ អ្នកប្រតិបត្តិមតក-សាសន៍នីមួយៗ អាចធ្វើសកម្មភាពរក្សាទុកបាន ។

**មាត្រា ១២២៦.–** កម្រៃរបស់អ្នកប្រតិបត្តិមតកសាសន៍

១-អ្នកប្រតិបត្តិមតកសាសន៍ អាចទទួលកម្រៃដែលបានកំណត់នៅក្នុងមតកសាសន៍បាន ។

២-ក្នុងករណីដែលមតកសាសន៍ពុំបានកំណត់កម្រៃទេ តុលាការត្រូវកំណត់ចំនួនទឹកប្រាក់នៃកម្រៃនោះ តាមពាក្យសុំរបស់អ្នកប្រតិបត្តិមតកសាសន៍ បើយល់ឃើញថាសមរម្យក្នុងការបង់កម្រៃ ដោយពិចារណាទៅលើស្ថានភាពនៃមតិក ទំនាក់ទំនងរវាងម្ចាស់បណ្ដាំ និង អ្នកប្រតិបត្តិមតកសាសន៍ និង ស្ថានភាពផ្សេងទៀត ។

**មាត្រា ១២២៧.–** ការលាឈប់ និង ការបញ្ឈប់អ្នកប្រតិបត្តិមតកសាសន៍

១-បើមានមូលហេតុត្រឹមត្រូវ អ្នកប្រតិបត្តិមតកសាសន៍ អាចលាឈប់ពីភារកិច្ចបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

២-បើអ្នកប្រតិបត្តិមតកសាសន៍ បានធ្វេសប្រហែសក្នុងភារកិច្ច ឬ បើមានមូលហេតុត្រឹមត្រូវផ្សេងទៀត អ្នកពាក់ព័ន្ធនឹងផលប្រយោជន៍ អាចដាក់ពាក្យសុំទៅតុលាការឱ្យបញ្ឈប់ជននោះបាន ។

**មាត្រា ១២២៨.–** សោហ៊ុយនៃការប្រតិបត្តិមតកសាសន៍

សោហ៊ុយដែលទាក់ទងទៅនឹងការប្រតិបត្តិមតកសាសន៍ ត្រូវជាបន្ទុកនៃមតិក ។ ប៉ុន្តែ មិនអាចបន្ថយភាគបម្រុង ដោយសារបន្ទុកនេះឡើយ ។

**មាត្រា ១២២៩.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្ដីពីអាណត្តិ

បញ្ញត្តិស្ដីពីអាណត្តិ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះមុខនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍ លើកលែងតែមានភាពផ្ទុយនឹងលក្ខណៈនៃតួនាទីរបស់អ្នកប្រតិបត្តិមតកសាសន៍នោះ ។

# ជំពូកទី ៤
# ភាគបម្រុង

## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១២៣០.–** អ្នកមានសិទ្ធិលើភាគបម្រុង

១-បច្ឆាញាតិផ្ទាល់ ឬ ឪពុកម្តាយ ឬ ជីដូនជីតា និង សហព័ទ្ធរបស់មតកជន អាចធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិ ដូចខាងក្រោមនេះ :

ក-១ ភាគ ៣ (មួយភាគបី) នៃទ្រព្យសម្បត្តិរបស់មតកជន ក្នុងករណីដែលមានតែសន្តតិជនជាឪពុកម្តាយ ឬ ជីដូន ជីតាប៉ុណ្ណោះ ។

ខ-១ ភាគ ២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរបស់មតកជន ក្នុងករណីផ្សេង ។

២-ក្នុងករណីដែលមានសន្តតិជនច្រើននាក់ អ្នកមានសិទ្ធិលើភាគបម្រុងនីមួយៗ អាចទទួលភាគបម្រុង តាមសមាមាត្រនៃចំណែកមត៌កបាន ។

៣-បញ្ញត្តិនៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) និង មាត្រា ១១៥៨ (ចំណែកមត៌កក្នុងករណីនៃសន្តតិកម្មជំនួស) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះភាគបម្រុង ។

**មាត្រា ១២៣១.–** ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

១-ភាគបម្រុង ត្រូវគណនាដោយយកទ្រព្យសម្បត្តិដែលមតកជនមាននៅពេលចាប់ផ្តើមធ្វើសន្តតិកម្ម បូកតម្លៃនៃផលប្រយោជន៍ពិសេស ដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) និង តម្លៃនៃទ្រព្យសម្បត្តិប្រទានកម្មដែលបានកំណត់ក្នុងមាត្រា ១២៣២ (ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង) នៃក្រមនេះ ហើយដកនូវចំនួនប្រាក់សរុបនៃកាតព្វកិច្ចចេញ ។

២-សិទ្ធិដែលភ្ជាប់ជាមួយនឹងល័ក្ខខ័ណ្ឌ ឬ សិទ្ធិដែលអំឡុងពេលមានអត្ថិភាពមិនច្បាស់លាស់ ត្រូវកំណត់តម្លៃនោះ ដោយផ្អែកតាមការវាយតម្លៃរបស់អ្នកវាយតម្លៃ ដែល

ត្រូវបានជ្រើសតាំងដោយតុលាការ ។

៣-កាតព្វកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវរាប់បញ្ចូលផងដែរ នូវសោហ៊ុយបុណ្យសពតាមឋានៈរបស់មតកជន ។

**មាត្រា ១២៣២.‒** ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

១-ប្រទានកម្មដែលបានកំណត់ដូចខាងក្រោមនេះ ត្រូវក្លាយជាមូលដ្ឋានក្នុងការគណនាភាគបម្រុង លើកលែងតែផលប្រយោជន៍ពិសេសដែលបានកំណត់នៅក្នុងមាត្រា ១១៦៣ (ចំណែកមត៌ករបស់អ្នកទទួលផលប្រយោជន៍ពិសេស) នៃក្រមនេះ ៖

ក- ប្រទានកម្មដែលបានធ្វើក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ។

ខ- ក្រៅពីប្រទានកម្មដែលបានកំណត់ក្នុងចំណុច ក ខាងលើនេះ ប្រទានកម្មដែលត្រូវបានធ្វើឡើង ដោយភាគីសងខាងបានដឹងថា នឹងបណ្តាលឱ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង ។

២-នៅក្នុងជំពូកទី ៤ (ភាគបម្រុង) នេះ ការលើកលែងកាតព្វកិច្ចដោយមិនយកតម្លៃថ្នូរ ត្រូវចាត់ទុកថាជាប្រទានកម្ម ។

**មាត្រា ១២៣៣.‒** ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

អច្ច័យទាន ការកំណត់ចំណែកមត៌កតាមមតកសាសន៍ ការទទួលផលប្រយោជន៍ពិសេស និង ប្រទានកម្មដែលបានកំណត់នៅក្នុងមាត្រា ១២៣២ (ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង) ខាងលើនេះ គឺជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។ ប៉ុន្តែ ក្នុងករណីដែលអច្ច័យទានចំពោះសន្តតិជន ការកំណត់ចំណែកមត៌ក និង ការទទួលផលប្រយោជន៍ពិសេស ត្រូវក្លាយជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង កម្មវត្ថុនៃការកាត់បន្ថយនោះ មានត្រឹមតែផ្នែកដែលលើសពីចំនួនទឹកប្រាក់នៃភាគបម្រុងរបស់សន្តតិជននោះប៉ុណ្ណោះ ។

**មាត្រា ១២៣៤.–** ចំនួនទឹកប្រាក់នៃការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

ចំនួនទឹកប្រាក់ដែលអ្នកមានសិទ្ធិលើភាគបម្រុងអាចទាមទារបានដោយការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺជាចំនួនទឹកប្រាក់ដែលត្រូវបានគណនា ដោយយកចំនួនទឹកប្រាក់នៃភាគបម្រុង ដកចំនួនសរុបនៃទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលដោយសន្តតិកម្ម និង ចំនួននៃផលប្រយោជន៍ពិសេស ហើយបូកបញ្ចូលនូវចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលបុគ្គលនោះត្រូវទទួលបន្ទុកដោយសន្តតិកម្ម ។

## ផ្នែកទី ២
## វិធីកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

**មាត្រា ១២៣៥.–** ការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

អ្នកមានសិទ្ធិលើភាគបម្រុង និង អ្នកទទួលបន្តនោះ អាចទាមទារឱ្យធ្វើការកាត់បន្ថយអច្ច័យទាន ជាអាទិ៍ ចំពោះជនដែលបានទទួលទ្រព្យសម្បត្តិ ឬ ផលប្រយោជន៍ដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន ត្រឹមកម្រិតដែលចាំបាច់ដើម្បីរក្សាភាគបម្រុងនោះ ។

**មាត្រា ១២៣៦.–** លំដាប់នៃការកាត់បន្ថយ

ប្រទានកម្ម និង ការទទួលផលប្រយោជន៍ពិសេស ពុំអាចកាត់បន្ថយបានឡើយ បើមិនបានកាត់បន្ថយពីអច្ច័យទាន និង ចំណែកមត៌កដែលបានកំណត់តាមមតកសាសន៍ជាមុនទេ ។

**មាត្រា ១២៣៧.–** ការកាត់បន្ថយអច្ច័យទាន ជាអាទិ៍

១-ដំបូង ត្រូវធ្វើការកាត់បន្ថយពីអច្ច័យទាន និង ចំណែកមត៌កដែលបានកំណត់ចំពោះសន្តតិជន នៅក្នុងពេលជាមួយគ្នា ហើយប្រសិនបើនៅតែខ្វះ ត្រូវធ្វើការកាត់បន្ថយពីអច្ច័យទានដែលបានធ្វើចំពោះបុគ្គលផ្សេងក្រៅពីសន្តតិជន ។

២-អច្ច័យទាន ត្រូវធ្វើការកាត់បន្ថយទៅតាមសមាមាត្រនៃតម្លៃរបស់កម្មវត្ថុនោះ ។

បញ្ញត្តិនេះ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះចំណែកមត៌កដែលបានកំណត់តាមវិធីធ្វើអនុប្បទានទ្រព្យសម្បត្តិដែលមានកំណត់ តែមួយចំណុច ឬ ច្រើនចំណុច ។ ប៉ុន្តែ ក្នុងករណីដែលអច្ច័យទានដែលធ្វើចំពោះសន្តតិជន និង ចំណែកមត៌កដែលបានកំណត់នោះ ជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ផ្នែកដែលលើសពីចំនួនប្រាក់នៃភាគបម្រុងរបស់សន្តតិជននោះ ត្រូវចាត់ទុកថាជាតម្លៃនៃកម្មវត្ថុ ។

៣-ចំណែកមត៌កតាមមតកសាសន៍ ដែលបានកំណត់ជាភាគនៃមត៌ក ត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ដោយធ្វើការផ្លាស់ប្តូរភាគនោះ ។

៤-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ទី ២ និង ទី ៣ ខាងលើនេះក៏ដោយ បើម្ចាស់បណ្តាំបានបង្ហាញឆន្ទៈពិសេសផ្សេង ក្នុងមតកសាសន៍ ត្រូវអនុលោមទៅតាមឆន្ទៈនោះ ។

**មាត្រា ១២៣៨.-** លំដាប់នៃការកាត់បន្ថយប្រទានកម្ម ជាអាទិ៍

១-ការកាត់បន្ថយប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេស ត្រូវចាប់ផ្តើមពីប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើក្រោយគេ បន្ទាប់មក ត្រូវធ្វើចំពោះប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើពីមុនមកជាបន្តបន្ទាប់ ។

២-បើបានធ្វើប្រទានកម្ម ឬ ទទួលផលប្រយោជន៍ពិសេស លើសពី ២០ (ម្ភៃ) ឆ្នាំនៅមុនពេលចាប់ផ្តើមសន្តតិកម្ម បដិគ្គាហក ឬ សន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេសនោះអាចបដិសេធនូវការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន ។

**មាត្រា ១២៣៩.-** ការសងផលមកវិញ

សហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក ក្រៅពីទ្រព្យសម្បត្តិ ឬ ប្រាក់សំណងដែលត្រូវសងមកវិញនោះ ត្រូវសងមកវិញផងដែរនូវផលដែលកើតឡើងក្រោយពីថ្ងៃដែលបានទាមទារឱ្យធ្វើការកាត់បន្ថយ ។

**មាត្រា ១២៤០.-** បន្ទុកនៃការខាតបង់ ដោយអសាធនភាព

ការខាតបង់ដែលកើតឡើងដោយសារអសាធនភាព របស់សហសន្តតិជន អច្ច័យ-

លាភី ឬ បដិគ្គាហក ដែលត្រូវទទួលការកាត់បន្ថយ ត្រូវធ្លាក់ជាបន្ទុករបស់អ្នកមានសិទ្ធិលើភាគបម្រុង ។

**មាត្រា ១២៤១.–** ការកាត់បន្ថយប្រទានកម្មដែលមានភ្ជាប់បន្ទុក

ចំពោះប្រទានកម្មដែលមានភ្ជាប់បន្ទុក ដែលបានដកតម្លៃនៃបន្ទុកចេញពីក្នុងតម្លៃនៃកម្មវត្ថុនោះ អាចទាមទារឱ្យធ្វើការកាត់បន្ថយបាន ។

**មាត្រា ១២៤២.–** ការកាត់បន្ថយចំពោះកិច្ចសន្យា ជាអាទិ៍ ដែលត្រូវចាត់ទុកថាជាប្រទានកម្ម

១-កិច្ចសន្យាដែលបានធ្វើដោយយកតម្លៃថ្នូរមិនត្រឹមត្រូវ ត្រូវចាត់ទុកថាជាប្រទាន-កម្ម តែក្នុងករណីដែលត្រូវបានធ្វើឡើង ដោយភាគីទាំងសងខាងបានដឹងថា នឹងបណ្តាលឱ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុងប៉ុណ្ណោះ ។ ក្នុងករណីនេះ បើអ្នកមានសិទ្ធិលើភាគបម្រុង ទាមទារឱ្យធ្វើការកាត់បន្ថយនោះ អ្នកនោះត្រូវសងតម្លៃថ្នូរនោះមកវិញ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការលើកលែងកាតព្វកិច្ច ដោយយកតម្លៃថ្នូរមិនត្រឹមត្រូវ ។

**មាត្រា ១២៤៣.–** ការកាត់បន្ថយក្នុងករណីដែលបានចាត់ចែងកម្មវត្ថុនៃប្រទានកម្ម

១-បើសហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក ដែលត្រូវទទួលការកាត់បន្ថយបានធ្វើអនុប្បទាននូវកម្មវត្ថុនៃប្រទានកម្ម ទៅឱ្យអ្នកដទៃ ជននោះត្រូវសងចំនួនទឹកប្រាក់ក្នុងកម្រិតនៃតម្លៃនៅពេលដែលបានចាត់ចែងនោះ ទៅឱ្យអ្នកមានសិទ្ធិលើភាគបម្រុង ។ ប៉ុន្តែ ប្រសិនបើអនុប្បទានិកនោះបានដឹងថា នឹងបណ្តាលឱ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង នៅពេលធ្វើអនុប្បទាន អ្នកមានសិទ្ធិលើភាគបម្រុងក៏អាចទាមទារឱ្យកាត់បន្ថយចំពោះអនុប្បទានិកនោះ បានដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក បានបង្កើតសិទ្ធិលើកម្មវត្ថុនៃប្រទានកម្មនោះ ។

**មាត្រា ១២៤៤.-** សំណងដោយបង់តម្លៃ

១-សហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក អាចរួចផុតពីកាតព្វកិច្ចនៃការសង បាន ដោយបង់តម្លៃនៃចំណែកមត៌កដែលបានកំណត់ តម្លៃនៃកម្មវត្ថុនៃអច្ច័យទាន ឬ តម្លៃនៃកម្មវត្ថុនៃប្រទានកម្ម ទៅឱ្យអ្នកដែលមានសិទ្ធិលើភាគបម្រុង ត្រឹមកម្រិតដែលត្រូវទទួលការកាត់បន្ថយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រា ១២៤៣ (ការកាត់បន្ថយក្នុងករណីដែលបានចាត់ចែងកម្មវត្ថុនៃប្រទានកម្ម) ខាងលើនេះ ។

## ផ្នែកទី ៣
## ការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយ

**មាត្រា ១២៤៥.-** អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យកាត់បន្ថយ

សិទ្ធិទាមទារឱ្យកាត់បន្ថយ ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ១ (មួយ) ឆ្នាំ បានកន្លងហួស គិតចាប់ពីពេលដែលអ្នកមានសិទ្ធិលើភាគបម្រុងបានដឹងអំពីការចាប់ផ្តើមសន្តតិកម្ម និង ការកំណត់ចំណែកមត៌ក អច្ច័យទាន ប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលត្រូវកាត់បន្ថយ ។ សិទ្ធិទាមទារឱ្យកាត់បន្ថយ ក៏ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ៥ (ប្រាំ) ឆ្នាំ បានកន្លងហួស គិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម ។

**មាត្រា ១២៤៦.-** ការបោះបង់ភាគបម្រុង

ភាគបម្រុង អាចបោះបង់ចោលទាំងអស់ ឬ មួយផ្នែកបាន ។ ប៉ុន្តែ ការបោះបង់ភាគបម្រុងនៅមុនពេលចាប់ផ្តើមសន្តតិកម្ម មានអានុភាព លុះត្រាតែបានទទួលការអនុញ្ញាតពីតុលាការ ។

**មាត្រា ១២៤៧.–** ករណីជាសហសន្តតិជន

ការរលត់ដោយអាជ្ញាយុកាល នៃសិទ្ធិទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងរបស់សន្តតិជនណាម្នាក់ ឬ ការបោះបង់ភាគបម្រុងដោយសហសន្តតិជនណាម្នាក់ ពុំមានឥទ្ធិពលទៅលើភាគបម្រុងរបស់សហសន្តតិជនផ្សេងទៀតទេ ។

# ជំពូកទី ៥
# ការយល់ព្រម និង ការបោះបង់សន្តតិកម្ម

## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១២៤៨.–** អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់

១-សន្តតិជន ត្រូវធ្វើការយល់ព្រម ឬ ការបោះបង់សន្តតិកម្ម ទាំងស្រុង ឬ ដោយកម្រិត នៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួន បានចាប់ផ្តើម ។ ប៉ុន្តែ អំឡុងពេលនេះ អាចពន្យារទៀតបាន តាមពាក្យសុំរបស់សន្តតិ-ជនទៅតុលាការ ។

២-សន្តតិជន អាចធ្វើការស្រាវជ្រាវមតិកបាន នៅមុនពេលធ្វើការយល់ព្រម ឬ ការបោះបង់ ។

**មាត្រា ១២៤៩.–** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនទទួលមរណភាព

បើសន្តតិជនបានទទួលមរណភាព នៅមុនពេលធ្វើការយល់ព្រម ឬ ការបោះបង់ អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជនរបស់ជននោះ បានដឹងថា សន្តតិកម្មចំពោះខ្លួន បានចាប់ផ្តើម ។

**មាត្រា ១២៥០.–** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនជាអនីតិជន ជាអាទិ៍

បើសន្តតិជន ជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ អំឡុងពេល

ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់នោះ បានដឹងថា សន្តតិកម្មចំពោះជនដែលជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅនោះ បានចាប់ផ្តើម ។

**មាត្រា ១២៥១.–** ករណីពិសេសនៃអំឡុងពេល បើសន្តតិជនមិនដឹងអំពីអត្ថិភាពនៃកាតព្វកិច្ច

១-ក្នុងករណីដែលមតកជនមានកាតព្វកិច្ចដែលមានចំនួនទឹកប្រាក់ច្រើន ហើយមិនអាចយកមត៌កទៅសងឱ្យគ្រប់ចំនួនបានទេ បើសន្តតិជនមិនអាចដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ តាមស្ថានភាពនៃជីវភាពរបស់មតកជន ស្ថានភាពនៃទ្រព្យសម្បត្តិរបស់មតកជន ឬ ស្ថានភាពផ្សេងៗទៀត អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) ខាងលើនេះ ត្រូវគណនាដោយគិតចាប់ពីពេលដែលសន្តតិជនបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសន្តតិជនបានចាត់ចែងមត៌កដើម្បីសងកាតព្វកិច្ចផ្សេង ដែលត្រូវបានទទួលតាមរយៈសន្តតិកម្ម នៅមុនពេលបានដឹងអំពីអត្ថិភាពនៃកាតព្វកិច្ចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនេះ បញ្ញត្តិនៃចំណុច ក មាត្រា ១២៥៥ (ការយល់ព្រមទាំងស្រុងតាមច្បាប់) នៃក្រមនេះ មិនត្រូវយកមកអនុវត្តឡើយ ។

**មាត្រា ១២៥២.–** ការលុបចោលការយល់ព្រម ឬ ការបោះបង់

១-ការយល់ព្រម និង ការបោះបង់សន្តតិកម្ម មិនអាចលុបចោលបានឡើយ ទោះជានៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ក៏ដោយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងចំពោះការលុបចោលនូវការយល់ព្រម ឬ បោះបង់សន្តតិកម្ម ដោយយកមូលហេតុមានវិការៈក្នុងការបង្ហាញឆន្ទៈឡើយ ។ ប៉ុន្តែ សិទ្ធិលុបចោលនេះ ត្រូវរលត់ បើពុំបានអនុវត្ត នៅក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ

គិតចាប់ពីពេលដែលអាចផ្តល់សច្ចានុមតិបាន ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលពុំបានអនុវត្តសិទ្ធិលុបចោលនៅក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលចាប់ផ្តើមធ្វើសន្តតិកម្ម ។

៣-បុគ្គលដែលមានបំណងចង់លុបចោល ការយល់ព្រមដោយកម្រិត ឬ ការបោះបង់ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ត្រូវដាក់ពាក្យសុំលុបចោលនោះ ទៅតុលាការ ។

**មាត្រា ១២៥៣.–** ការហាមឃាត់មិនឱ្យធ្វើបណ្តឹងចំពោះសន្តតិជន នៅមុនការយល់ព្រម

សិទ្ធិទាមទារចំពោះបេតិកភ័ណ្ឌ ពុំអាចយកមកអះអាងក្នុងបណ្តឹងចំពោះសន្តតិជន នៅមុនពេលយល់ព្រមលើសន្តតិកម្មបានឡើយ ។

## ផ្នែកទី ២
## ការយល់ព្រម

**មាត្រា ១២៥៤.–** ការយល់ព្រមទាំងស្រុង

បើសន្តតិជនបានយល់ព្រមទាំងស្រុង ត្រូវទទួលបន្តដោយគ្មានកម្រិត នូវសិទ្ធិ និង កាតព្វកិច្ចរបស់មតកជននោះ ។

**មាត្រា ១២៥៥.–** ការយល់ព្រមទាំងស្រុងតាមច្បាប់

ក្នុងករណីដែលកំណត់ដូចខាងក្រោមនេះ ត្រូវចាត់ទុកថា សន្តតិជនបានយល់ព្រមទាំងស្រុងតាមច្បាប់ :

ក-បើសន្តតិជនបានចាត់ចែងមតិកនោះ ទាំងអស់ ឬ មួយភាគ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះសកម្មភាពរក្សា និង សកម្មភាពត្រឹមតែជាការគ្រប់គ្រង ។

ខ-បើសន្តតិជនមិនបានយល់ព្រមដោយកម្រិត ឬ បោះបង់ នៅក្នុងអំឡុងពេល

ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ។

គ-ទោះបីជាសន្តតិជនបានយល់ព្រមដោយកម្រិត ឬ បោះបង់ ក៏ដោយ បើសន្តតិជនបានលាក់មតិកទាំងអស់ ឬ មួយភាគ ឬ បានប្រើប្រាស់មតិកនោះដើម្បីខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ នៅក្រោយពេលដែលជនដែលបានក្លាយជាសន្តតិជនដោយសារការបោះបង់របស់សន្តតិជនលំដាប់មុនបានយល់ព្រម ។

**មាត្រា ១២៥៦.–** ការយល់ព្រមដោយមានកម្រិត

១-សន្តតិជនអាចយល់ព្រម ដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និង អច្ច័យទានរបស់មតកជនបាន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្ម តែប៉ុណ្ណោះ ។

២-បើសន្តតិជនមានច្រើននាក់ ការយល់ព្រមដោយកម្រិតនេះ អាចធ្វើបាន លុះត្រាតែសហសន្តតិជននោះបានធ្វើដោយរួមគ្នាទាំងអស់ ។

**មាត្រា ១២៥៧.–** វិធីនៃការយល់ព្រមដោយកម្រិត

សន្តតិជនដែលមានបំណងចង់យល់ព្រមដោយកម្រិត ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌ ហើយត្រូវដាក់ពាក្យសុំអំពីការយល់ព្រមដោយកម្រិតនោះ ទៅតុលាការ នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ ។

**មាត្រា ១២៥៨.–** អានុភាពនៃការយល់ព្រមដោយកម្រិត

១-ក្នុងករណីដែលសន្តតិជនបានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជន ពុំអាចតាមទាមទារឱ្យសន្តតិជនទទួលខុសត្រូវ ចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជននោះបានឡើយ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ សិទ្ធិ និង កាតព្វកិច្ចរបស់សន្តតិជនដែលមានចំពោះមតកជននោះ ត្រូវចាត់ទុកថាមិនបានរលត់ដោយល្បាកុល-

ភាពឡើយ ។

**មាត្រា ១២៥៩.-** ករណីដែលហេតុនៃការយល់ព្រមតាមច្បាប់ កើតឡើង ក្រោយការយល់ព្រមដោយកម្រិត

១-ក្នុងករណីដែលជនដែលបានធ្វើសន្តតិកម្មតែម្នាក់ឯង បានយល់ព្រមដោយកម្រិត បើសន្តតិជននោះមិនបានសរសេរទ្រព្យសម្បត្តិទាំងអស់ ឬ មួយភាគ នៅក្នុងបញ្ជីសារពើភ័ណ្ឌ ដោយទុច្ចរិត ឬ បើមានហេតុដែលបានកំណត់នៅក្នុងចំណុច ក ឬ គ នៃមាត្រា ១២៥៥ (ការយល់ព្រមទាំងស្រុងតាមច្បាប់) នៃក្រមនេះ កើតឡើងចំពោះសន្តតិ-ជននោះ ត្រូវចាត់ទុកថា សន្តតិជននោះបានយល់ព្រមទាំងស្រុង ហើយសេចក្តីថ្លែងការណ៍នៃការយល់ព្រមដោយកម្រិត មិនបង្កើតអានុភាព តាំងពីដំបូងមក ។

២-បើមានមូលហេតុដូចកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះសហ-សន្តតិជនម្នាក់ ឬ ច្រើននាក់ ដែលបានយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជនអាចអនុវត្តសិទ្ធិរបស់ខ្លួនទៅលើសហសន្តតិជនម្នាក់ ឬ ច្រើននាក់នោះ ចំពោះចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល ដែលពុំអាចទទួលការសងដោយមតិក តាមចំណែកមតិកនីមួយៗនោះបាន ។

## ផ្នែកទី ៣
## ការបោះបង់

**មាត្រា ១២៦០.-** ការបោះបង់សន្តតិកម្ម

បុគ្គលដែលមានបំណងបោះបង់សន្តតិកម្ម ត្រូវដាក់ពាក្យសុំការបោះបង់សន្តតិកម្មនោះ ទៅតុលាការ ។

**មាត្រា ១២៦១.-** អានុភាពនៃការបោះបង់

បុគ្គលដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា បុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដំបូងមក ។

# ជំពូកទី ៦
# ការគ្រប់គ្រង និង ការបែងចែកមត៌ក

## ផ្នែកទី ១
## ការគ្រប់គ្រងមត៌ក

**មាត្រា ១២៦២.–** ការរក្សាទុក និង ការគ្រប់គ្រងមត៌ក

១-សន្តតិជនដែលកាន់កាប់មត៌ក នៅពេលមតកជនបានទទួលមរណភាព ត្រូវរក្សាទុក និង គ្រប់គ្រងមត៌កនោះ រហូតដល់ពេលធ្វើការបែងចែកមត៌ក ។ ប៉ុន្តែ ការរក្សាទុក និង ការគ្រប់គ្រងនេះ ត្រូវអនុលោមតាមបញ្ញត្តិនៃមាត្រា ១២៦៣ (ការរក្សាទុកដោយអ្នកប្រតិបត្តិមតកសាសន៍) ខាងក្រោមនេះ ។

២-ទោះបីជានៅមុនពេលយល់ព្រម ឬ បោះបង់សន្តតិកម្មក៏ដោយ សន្តតិជនត្រូវគ្រប់គ្រងមត៌កនោះ ដោយប្រុងប្រយ័ត្ន ដូចគ្នានឹងទ្រព្យសម្បត្តិផ្ទាល់ខ្លួនផងដែរ ។ ទោះបីជានៅក្រោយពេលបោះបង់សន្តតិកម្មក៏ដោយ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ រហូតដល់ពេលបុគ្គលដែលបានក្លាយជាសន្តតិជន ដោយសារការបោះបង់នោះ អាចចាប់ផ្តើមធ្វើការគ្រប់គ្រងមត៌កនោះបាន ។

**មាត្រា ១២៦៣.–** ការរក្សាទុកដោយអ្នកប្រតិបត្តិមតកសាសន៍

បើបានកាន់មុខងារជាអ្នកប្រតិបត្តិមតកសាសន៍ហើយ អ្នកប្រតិបត្តិមតកសាសន៍នោះ ត្រូវធ្វើការគ្រប់គ្រងមត៌ក ។ ប៉ុន្តែ ប្រសិនបើមតកសាសន៍ទាក់ទងនឹងទ្រព្យសម្បត្តិដែលមានកំណត់ ត្រូវគ្រប់គ្រងតែទ្រព្យសម្បត្តិនោះប៉ុណ្ណោះ ។

**មាត្រា ១២៦៤.–** អ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្ន

១-បើគ្មានអ្នកប្រតិបត្តិមតកសាសន៍ គ្រប់គ្រងមត៌កទាំងមូលទេ សន្តតិជន អច្ច័យលាភី ឬ ម្ចាស់បំណុលរបស់មតកជន អាចដាក់ពាក្យសុំទៅតុលាការ ឱ្យធ្វើការជ្រើសតាំងអ្នកគ្រប់គ្រងមត៌កជាបណ្តោះអាសន្នបាន រហូតដល់ពេលធ្វើការបែងចែកមត៌ក ។

២-ទោះបីជាមានបញ្ញត្តិនៃមាត្រា ១២៥៣ (ការហាមឃាត់មិនឱ្យធ្វើបណ្តឹងចំពោះសន្តតិជន នៅមុនការយល់ព្រម) នៃក្រមនេះ ក៏ដោយ អ្នកគ្រប់គ្រងជាបណ្តោះអាសន្ន ដែលត្រូវបានជ្រើសតាំងដោយបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ គឺជាអ្នកទទួលបន្ទុកក្នុងបណ្តឹងនោះ ចំពោះសិទ្ធិទាមទារដែលទាក់ទងនឹងមត៌ក នៅក្នុងនាមជាអ្នកទទួលបន្ទុកក្នុងបណ្តឹងរបស់សន្តតិជននៃមតកជន ដោយបញ្ជាក់ឈ្មោះមតកជននោះផង រហូតដល់ពេលដែលសន្តតិជនយល់ព្រមទទួលសន្តតិកម្មនោះ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ៣ នៃមាត្រា ៤០ (សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអាទិ៍) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកគ្រប់គ្រងជាបណ្តោះអាសន្ន ។

**មាត្រា ១២៦៥.-** សោហ៊ុយដែលទាក់ទងទៅនឹងមត៌ក

សោហ៊ុយដែលទាក់ទងទៅនឹងមត៌ក ត្រូវចំណាយចេញពីក្នុងទ្រព្យសម្បត្តិនោះ ។ ប៉ុន្តែ សោហ៊ុយដែលកើតចេញពីកំហុសរបស់សន្តតិជន គឺជាបន្ទុករបស់សន្តតិជននោះ ។

## ផ្នែកទី ២
## ការបែងចែកមត៌ក

**មាត្រា ១២៦៦.-** ការពិភាក្សាបែងចែកមត៌ក

១-សហសន្តតិជនអាចចាប់ផ្តើមពិភាក្សាបែងចែកមត៌ក នៅពេលណាក៏បាន បើអំឡុងពេល ១ (មួយ) ខែ បានកន្លងផុត ក្រោយពីការចាប់ផ្តើមសន្តតិកម្ម ។ ប៉ុន្តែ ចំពោះការផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិលើមត៌ក ដោយសារលទ្ធផលនៃការបែងចែកមត៌ក ត្រូវអនុលោមតាមបញ្ញត្តិនៃមាត្រា ១២៧៧ (ការហាមឃាត់មិនឱ្យផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិ) នៃក្រមនេះ ឬ ចំពោះករណីដែលមតកជនហាមឃាត់ការបែងចែកមត៌កតាមមតកសាសន៍ ការបែងចែកមត៌កពុំអាចធ្វើបានឡើយ នៅក្នុងអំឡុងពេលដែលហាមឃាត់នោះ ។

២-ដើម្បីផ្ទេរសិទ្ធិចំពោះវត្ថុតាមការបែងចែកមត៌ក ការបែងចែកត្រូវធ្វើជាលាយល័ក្ខណ៍អក្សរទៅតាមទម្រង់នីមួយៗ ដែលចាំបាច់នៅក្នុងការផ្ទេរសិទ្ធិនោះ ។

**មាត្រា ១២៦៧.-** មូលដ្ឋាននៃការបែងចែក

១-បើពុំបានកំណត់វិធីបែងចែកនៅក្នុងមតកសាសន៍ទេ ការបែងចែកមត៌កនេះ ត្រូវធ្វើដោយពិចារណាទៅលើប្រភេទ និង លក្ខណៈនៃវត្ថុ ឬ សិទ្ធិដែលមាននៅក្នុងមត៌ក ឬ អាយុ មុខរបរ ស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត ស្ថានភាពជីវភាព របស់សហសន្តតិជននីមួយៗ និង ស្ថានភាពផ្សេងទៀត ។

២-ក្នុងករណីដែលការបែងចែកបណ្ដាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់តម្លៃ បើយល់ឃើញថាសមរម្យ សហសន្តតិជនអាចឱ្យសហសន្តតិជនណាម្នាក់ ធ្វើលទ្ធកម្មទ្រព្យសម្បត្តិនោះបាន ដោយដាក់ល័ក្ខខ័ណ្ឌឱ្យបង់ប្រាក់សម្រួល ចំពោះសហសន្តតិជនផ្សេងទៀត តាមការពិភាក្សា ។

**មាត្រា ១២៦៨.-** សិទ្ធិអាទិភាពរបស់សហព័ទ្ធ

ក្នុងករណីដែលសហព័ទ្ធក្លាយជាសន្តតិជន បើមានទ្រព្យសម្បត្តិដែលទទួលបានជាកម្មសិទ្ធិអវិភាគជាមួយនឹងមតកជន ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ នៅក្នុងការបែងចែកមត៌ក សហព័ទ្ធនេះមានអាទិភាពជាងសហសន្តតិជនផ្សេងទៀត ក្នុងការទទួលយកចំណែកកម្មសិទ្ធិអវិភាគដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិនោះ រហូតដល់គ្រប់ចំនួននៃចំណែកមត៌កនោះ ។

**មាត្រា ១២៦៩.-** សំណងនៃកាតព្វកិច្ចរបស់មតកជន ជាអាទិ៍

បើមតកជនមានកាតព្វកិច្ច សហសន្តតិជនត្រូវបែងចែកមត៌ក ដោយពិចារណាពីការណ៍ថា ខ្លួនត្រូវសងកាតព្វកិច្ចនោះ និង មិនអាចប្ដូរភាគបន្ទុកនៃកាតព្វកិច្ចនោះ ដោយគ្មានការយល់ព្រមពីសំណាក់ម្ចាស់បំណុលឡើយ ។

**មាត្រា ១២៧០.-** ការបែងចែកដោយតុលាការ

១-បើការពិភាក្សារវាងសហសន្តតិជន ចំពោះការបែងចែកមត៌ក ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ សហសន្តតិជនណាម្នាក់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យធ្វើការបែងចែកមត៌កនោះបាន ។

២-ក្នុងការបែងចែកមត៌ក ក្រៅពីបញ្ញត្តិចាប់ពីមាត្រា ១២៦៧ (មូលដ្ឋាននៃការបែងចែក) រហូតដល់មាត្រា ១២៦៩ (សំណងនៃកាតព្វកិច្ចរបស់មតកជន ជាអាទិ៍) ខាងលើនេះ តុលាការត្រូវធ្វើការពិចារណានូវទំនៀមទម្លាប់នៅក្នុងតំបន់នោះ និង មតិលើសពីពាក់កណ្តាលរបស់សហសន្តតិជន ។

**មាត្រា ១២៧១.–** ការប្តូរជាប្រាក់ដោយការលក់

ចំពោះទ្រព្យសម្បត្តិដែលមិនអាចទទួលការព្រមព្រៀងអំពីការបែងចែក ឬ អំពីបុគ្គលដែលត្រូវទទួល រវាងសហសន្តតិជនទេ តុលាការអាចលក់ ហើយធ្វើការបែងចែកប្រាក់ដែលបានមកពីការលក់នោះបាន ។

**មាត្រា ១២៧២.–** ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្ម ដោយផ្អែកលើការចាត់ចែងទ្រព្យសម្បត្តិ នៅមុនពេលបែងចែក ជាអាទិ៍

ទ្រព្យដែលត្រូវបានធ្វើលទ្ធកម្ម ដោយការសងជំនួសការបាត់បង់ ការខូចខាត ឬការបំពានយកកម្មវត្ថុមត៌ក ឬ តាមកិច្ចសន្យាដែលយកមត៌កជាកម្មវត្ថុ ដោយផ្អែកលើសិទ្ធិដែលស្ថិតនៅក្នុងមត៌កនោះ ត្រូវស្ថិតនៅក្នុងមត៌ក ។

**មាត្រា ១២៧៣.–** អានុភាពនៃការបែងចែក

១-ការបែងចែកមត៌ក មានអានុភាពប្រតិសកម្ម គិតចាប់ពីពេលដែលបានចាប់ផ្តើមសន្តតិកម្ម ។ ប៉ុន្តែ ការបែងចែកនេះ ពុំអាចបំពានសិទ្ធិរបស់តតិយជនដែលបានចុះបញ្ជី ឬបានទទួលល័ក្ខខ័ណ្ឌតតាំងបានឡើយ ។

២-សហសន្តតិជននីមួយៗ ត្រូវទទួលយកលិខិតបញ្ជាក់សិទ្ធិដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិដែលខ្លួនបានធ្វើលទ្ធកម្ម ។

**មាត្រា ១២៧៤.–** ការទាមទាររបស់ជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមត៌ក

ក្នុងករណីដែលជនដែលបានក្លាយជាសន្តតិជន ដោយសារជននោះត្រូវបានទទួលស្គាល់ ក្រោយពេលមតកជនបានទទួលមរណភាព មានបំណងទាមទារឱ្យបែងចែកមត៌ក

បើសហសន្តតិជនផ្សេងទៀតបានបែងចែកមត៌ក ឬ បានធ្វើការចាត់ចែងផ្សេងទៀតចំពោះមត៌ក ជននោះមានសិទ្ធិទាមទារឱ្យសងដោយតម្លៃតែប៉ុណ្ណោះ ។

**មាត្រា ១២៧៥.–** ល័ក្ខខ័ណ្ឌតតាំង ជាអាទិ៍ នៃការបែងចែកសិទ្ធិលើបំណុល

១-នៅក្នុងការបែងចែកមត៌ក ក្នុងករណីដែលបានបែងចែកសិទ្ធិលើបំណុលដែលមតកជនមាន ទៅតាមភាគក្រៅពីចំណែកមត៌កដែលកំណត់ដោយច្បាប់ បើសហសន្តតិ-ជនទាំងអស់មិនបានជូនដំណឹងពីការបែងចែកនោះ ឬ បើការបែងចែកមត៌កនោះ ត្រូវបានធ្វើដោយលិខិតយថាភូត តែមិនបានបង្ហាញលិខិតនោះ ឬ ប្រគល់លិខិតចម្លងនោះទៅឱ្យកូនបំណុលទេ ពុំអាចតតាំងជាមួយកូនបំណុលបានឡើយ ។

២-កូនបំណុលនៃមតកជន ដែលបានសងសំណងតាមចំណែកមត៌កដែលកំណត់ដោយច្បាប់ ចំពោះសហសន្តតិជន នៅមុនពេលបានទទួលដំណឹង ដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចតតាំងចំពោះសហសន្តតិជនដែលបានធ្វើលទ្ធកម្មសិទ្ធិលើបំណុល តាមការបែងចែកមត៌កនោះបាន ។

**មាត្រា ១២៧៦.–** ការទទួលខុសត្រូវក្នុងការធានា របស់សហសន្តតិជន

សហសន្តតិជនម្នាក់ៗ ត្រូវមានបន្ទុកទទួលខុសត្រូវក្នុងការធានា ទៅតាមសមាមាត្រនៃចំណែកមត៌កនោះ ដូចជាអ្នកលក់ដែរ ចំពោះសហសន្តតិជនដទៃទៀត ។

## ផ្នែកទី ៣
## ការសម្រួលរវាងម្ចាស់បំណុល

**មាត្រា ១២៧៧.–** ការហាមឃាត់មិនឱ្យផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិ

សន្តតិជន និង អ្នកគ្រប់គ្រងមត៌ក មិនអាចផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិលើមត៌កទៅឱ្យសន្តតិជន ឬ អច្ច័យលាភី បានឡើយ រហូតដល់ពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ បានកន្លងហួស ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ

ចំពោះករណីដែលផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិលើមត៌ក តាមភាពចាំបាច់ដើម្បីសងកាតព្វកិច្ច របស់មតកជន ។

**មាត្រា ១២៧៨.–** ម្ចាស់បំណុលរបស់មតកជន

ម្ចាស់បំណុលនៃមតកជនពុំអាចអនុវត្តសិទ្ធិរបស់ខ្លួន ចំពោះទ្រព្យសម្បត្តិផ្ទាល់របស់សន្តតិជនបានឡើយ រហូតដល់ពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ បានកន្លងហួស ។

**មាត្រា ១២៧៩.–** ម្ចាស់បំណុលរបស់សន្តតិជន

ម្ចាស់បំណុលរបស់សន្តតិជន មិនអាចអនុវត្តសិទ្ធិរបស់ខ្លួន ចំពោះមត៌កបានឡើយ រហូតដល់ពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៤៨ (អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់) នៃក្រមនេះ បានកន្លងហួស ។

## ផ្នែកទី ៤
## ការជម្រះ ជាអាទិ៍ នៅក្នុងករណីដែលមានការយល់ព្រមដោយកម្រិត

**មាត្រា ១២៨០.–** ការគ្រប់គ្រងមត៌កនៅក្រោយពេលយល់ព្រមដោយកម្រិត

អ្នកយល់ព្រមដោយកម្រិត ត្រូវបន្តការគ្រប់គ្រងមត៌ក ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ។

**មាត្រា ១២៨១.–** ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន

១-អ្នកយល់ព្រមដោយកម្រិត ត្រូវជូនដំណឹងជាសាធាណៈ នៅក្នុងអំឡុងពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានយល់ព្រមដោយកម្រិតហើយ ចំពោះម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភីទាំងអស់ អំពីការណ៍ដែលខ្លួនបានយល់ព្រមដោយកម្រិត និង ការណ៍ដែលម្ចាស់បំណុល និង អច្ច័យលាភីទាំងនោះ ត្រូវស្នើសុំអំពីការទាមទារនៅក្នុងអំឡុងពេលដែលកំណត់ ។ ប៉ុន្តែ អំឡុងពេលនេះ មិនត្រូវឱ្យតិចជាង ២ (ពីរ) ខែ ឡើយ ។

២-នៅក្នុងការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកយល់ព្រមដោយកម្រិត ត្រូវសរសេរបន្ថែមថា បើម្ចាស់បំណុលមិនបានស្នើសុំនៅក្នុងអំឡុងពេលកំណត់នោះទេ សិទ្ធិលើបំណុលនោះនឹងត្រូវដកចេញពីការជម្រះ ។ ប៉ុន្តែ អ្នកយល់ព្រមដោយកម្រិតនេះ មិនអាចដកម្ចាស់បំណុលដែលខ្លួនបានដឹងចេញបានឡើយ ។

៣-អ្នកយល់ព្រមដោយកម្រិត ត្រូវដាស់តឿនដោយឡែកៗ ចំពោះម្ចាស់បំណុលដែលខ្លួនបានដឹងឱ្យធ្វើការស្នើសុំ ។

**មាត្រា ១២៨២.-** សិទ្ធិបដិសេធការសងនៅក្នុងអំឡុងពេលដាស់តឿន

នៅមុនពេលផុតអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) ខាងលើនេះ អ្នកយល់ព្រមដោយកម្រិត អាចបដិសេធការសង ចំពោះម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភីបាន ។

**មាត្រា ១២៨៣.-** ការសងតាមការចែកចំណែក

ក្រោយពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) ខាងលើនេះ បានកន្លងហួស អ្នកយល់ព្រមដោយកម្រិត ត្រូវយកមត៌កនោះមកសងឱ្យម្ចាស់បំណុលដែលបានស្នើសុំនៅក្នុងអំឡុងពេលនោះ និង ម្ចាស់បំណុលផ្សេងទៀតដែលខ្លួនបានដឹង ទៅតាមសមាមាត្រនៃចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលនីមួយៗនោះ ។ ប៉ុន្តែ ការសងនេះ ពុំអាចបំពានសិទ្ធិរបស់ម្ចាស់បំណុលដែលមានសិទ្ធិអាទិភាពបានឡើយ ។

**មាត្រា ១២៨៤.-** ការសងកាតព្វកិច្ច ជាអាទិ៍ នៅមុនពេលកំណត់

១-ទោះបីជាសិទ្ធិលើបំណុលមិនទាន់ដល់ពេលកំណត់សងក៏ដោយ អ្នកយល់ព្រមដោយកម្រិត ត្រូវសងដោយយោងតាមបញ្ញត្តិនៃមាត្រា ១២៨៣ (ការសងតាមការចែក

ចំណែក) ខាងលើនេះ ។

២-ចំពោះសិទ្ធិលើបំណុលដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌ ឬ សិទ្ធិលើបំណុលដែលអំឡុងពេលបន្តអត្ថិភាពមិនពិតប្រាកដ អ្នកយល់ព្រមដោយកម្រិតត្រូវសងសិទ្ធិលើបំណុលនោះ ដោយយោងតាមការវាយតម្លៃរបស់អ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការ ។

**មាត្រា ១២៨៥.-** ការសងចំពោះអច្ច័យលាភី

អ្នកយល់ព្រមដោយកម្រិត មិនអាចសងទៅឱ្យអច្ច័យលាភីបានឡើយ បើមិនទាន់បានសងចំពោះម្ចាស់បំណុលនីមួយៗ តាមបញ្ញត្តិនៃមាត្រា ១២៨៣ (ការសងតាមការចែកចំណែក) និង មាត្រា ១២៨៤ (ការសងកាតព្វកិច្ច ជាអាទិ៍ នៅមុនពេលកំណត់) ខាងលើនេះ ។

**មាត្រា ១២៨៦.-** ការប្តូរមត៌កជាប្រាក់

១-ប្រសិនបើចាំបាច់ត្រូវលក់មត៌កដើម្បីសង ដោយយោងតាមបញ្ញត្តិចាប់ពីមាត្រា ១២៨៣ (ការសងតាមការចែកចំណែក) រហូតដល់មាត្រា ១២៨៥ (ការសងចំពោះអច្ច័យលាភី) ខាងលើនេះ អ្នកយល់ព្រមដោយកម្រិត ត្រូវលក់មត៌កនោះ តាមវិធីលក់ដោយបង្ខំ ឬ លក់ក្នុងតម្លៃខ្ពស់ជាងការវាយតម្លៃរបស់អ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការ ។

២-អ្នកយល់ព្រមដោយកម្រិត ម្ចាស់បំណុលរបស់មតកជន ឬ អច្ច័យលាភី អាចក្លាយជាអ្នកទិញដោយផ្ទាល់ខ្លួន នៅក្នុងការលក់ដោយបង្ខំ ឬ ការលក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

**មាត្រា ១២៨៧.-** ការទទួលខុសត្រូវក្នុងការសងមិនត្រឹមត្រូវ

១-ប្រសិនបើអ្នកយល់ព្រមដោយកម្រិតមានការធ្វេសប្រហែស ក្នុងការជូនដំណឹងជាសាធារណៈ ឬ ការដាស់តឿនដែលបានកំណត់នៅក្នុងមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) នៃក្រមនេះ ឬ បើពុំអាចសងទៅឱ្យម្ចាស់បំណុល ឬ អច្ច័យលាភីដទៃទៀត ដោយសារបានសងទៅឱ្យម្ចាស់បំណុល ឬ អច្ច័យលាភីណាផ្សេង

នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងការជូនដំណឹងជាសាធារណៈដែលបានកំណត់ នៅក្នុងកថាខណ្ឌទី ១ នៃមាត្រានេះទេ អ្នកយល់ព្រមដោយកម្រិតនោះ ត្រូវសង សំណងការខូចខាតដែលកើតឡើងដោយសារហេតុនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំរារាំងការទាមទារសំណងការខូចខាត របស់ម្ចាស់បំណុល ឬ អច្ច័យលាភីដទៃ ចំពោះម្ចាស់បំណុល ឬ អច្ច័យលាភីដែលបាន ទទួលការសង ដោយដឹងអំពីភាពមិនត្រឹមត្រូវនៃការសងនោះ ។

**មាត្រា ១២៨៨.–** ករណីដែលពុំបានស្នើសុំ

ម្ចាស់បំណុល និង អច្ច័យលាភី ដែលពុំបានស្នើសុំនៅក្នុងអំឡុងពេលដែលបាន កំណត់នៅក្នុងការជូនដំណឹងជាសាធារណៈ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃ មាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) នៃក្រមនេះ ហើយដែល អ្នកយល់ព្រមដោយកម្រិតពុំអាចដឹងបាន អាចអនុវត្តសិទ្ធិរបស់ខ្លួនបាន ត្រឹមតែចំពោះ ទ្រព្យសម្បត្តិដែលនៅសេសសល់ប៉ុណ្ណោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះជនដែលមានសិទ្ធិប្រាតិភោគលើវត្ថុ ឬ សិទ្ធិដែលបានកំណត់ជាក់លាក់ក្នុងចំណោម មត៌ក ។

**មាត្រា ១២៨៩.–** ករណីដែលមានសន្តតិជនច្រើននាក់

១-នៅក្នុងករណីដែលមានសន្តតិជនច្រើននាក់ បើមានការយល់ព្រមដោយកម្រិត តុលាការត្រូវជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក ពីក្នុងចំណោមសន្តតិជនទាំងនោះ ។

២-អ្នកគ្រប់គ្រង ត្រូវបំពេញរាល់សកម្មភាពចាំបាច់ក្នុងការគ្រប់គ្រងមត៌ក និង សង កាតព្វកិច្ច ដើម្បីខ្លួនឯងផ្ទាល់ និង ជំនួសសហសន្តតិជនដទៃទៀត ។

៣-បញ្ញត្តិចាប់ពីមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) រហូតដល់មាត្រា ១២៨៨ (ករណីដែលពុំបានស្នើសុំ) ខាងលើនេះ ត្រូវយកមកអនុវត្តដូច គ្នាផងដែរ ចំពោះអ្នកគ្រប់គ្រង ។ ប៉ុន្តែ អំឡុងពេលដែលត្រូវជូនដំណឹងជាសាធារណៈ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) នៃក្រមនេះ មានចំនួន ១០ (ដប់) ថ្ងៃ បន្ទាប់ពីបានជ្រើសតាំងអ្នក

គ្រប់គ្រង ។

## ជំពូកទី ៧
## នត្ថិភាពនៃសន្តតិជន

**មាត្រា ១២៩០.-** នីតិបុគ្គលមត៌ក

ប្រសិនបើពុំច្បាស់ថាមានសន្តតិជនទេ មត៌កនោះត្រូវក្លាយជានីតិបុគ្គល ។

**មាត្រា ១២៩១.-** ការជ្រើសតាំងអ្នកគ្រប់គ្រង

១-ក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ១២៩០ (នីតិបុគ្គលមត៌ក) ខាងលើនេះ តុលាការត្រូវជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក តាមពាក្យសុំរបស់បុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋាន ចុងក្រោយរបស់មតកជន ឬ តំណាងអយ្យការ ។

២-បើបានជ្រើសតាំងអ្នកគ្រប់គ្រងមត៌កហើយ តុលាការត្រូវធ្វើការជូនដំណឹងជាសាធារណៈអំពីការណ៍នោះ ដោយគ្មានការយឺតយ៉ាវ ។

**មាត្រា ១២៩២.-** សិទ្ធិ និង កាតព្វកិច្ចរបស់អ្នកគ្រប់គ្រង

១-អ្នកគ្រប់គ្រង ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌដែលទាក់ទងទៅនឹងមត៌ក ដោយគ្មានការយឺតយ៉ាវ ។

២-អ្នកគ្រប់គ្រង ត្រូវថែរក្សា និង គ្រប់គ្រងមត៌ក ។ បើមានការចាំបាច់ដើម្បីថែរក្សា និង គ្រប់គ្រងមត៌កនោះ អ្នកគ្រប់គ្រងអាចប្តូរមត៌កជាប្រាក់ ឬ អាចចាត់ចែងមត៌កនោះបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

៣-បើមានការទាមទារពីម្ចាស់បំណុលរបស់មតកជន ឬ អច្ច័យលាភី អ្នកគ្រប់គ្រងត្រូវរាយការណ៍អំពីស្ថានភាពនៃមត៌កទៅឱ្យជននោះ ។

៤-អ្នកគ្រប់គ្រងត្រូវអនុវត្តតាមចំណុចនីមួយៗ ដែលបានកំណត់ក្នុងបញ្ញត្តិចាប់ពីមាត្រា ១២៨២ (សិទ្ធិបដិសេធការសងនៅក្នុងអំឡុងពេលដាស់តឿន) រហូតដល់មាត្រា

១២៨៨ (ករណីដែលពុំបានស្នើសុំ) នៃក្រមនេះ ដែលត្រូវយកមកអនុវត្តដូចគ្នា ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៩៦ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុល ជាអាទិ៍) ខាងក្រោមនេះ ។

៥-តាមការបង្គាប់របស់តុលាការ អ្នកគ្រប់គ្រង ត្រូវស្រាវជ្រាវអង្គហេតុ ហើយត្រូវធ្វើសេចក្ដីរាយការណ៍អំពីលទ្ធផលនោះទៅតុលាការ ។

**មាត្រា ១២៩៣.-** កម្រៃសម្រាប់ អ្នកគ្រប់គ្រង

តុលាការអាចផ្ដល់កម្រៃសមរម្យ ចេញពីក្នុងចំណោមមត៌ក ឱ្យទៅអ្នកគ្រប់គ្រងបាន ដោយគិតពិចារណាទៅលើស្ថានភាពនៃមត៌ក និង ស្ថានភាពផ្សេងទៀត ។

**មាត្រា ១២៩៤.-** ករណីដែលដឹងច្បាស់អំពីសន្តតិជន

ប្រសិនបើដឹងច្បាស់ថាមានសន្តតិជន នីតិបុគ្គលមត៌កត្រូវចាត់ទុកថាពុំមានអត្ថិភាពតាំងពីដំបូង ។ ប៉ុន្តែ បញ្ញត្តិនេះពុំរារាំងអានុភាពនៃសកម្មភាពដែលអ្នកគ្រប់គ្រងបានធ្វើហើយ នៅក្នុងទំហំនៃសិទ្ធិអំណាចរបស់ខ្លួនឡើយ ។

**មាត្រា ១២៩៥.-** ពេលរលត់សិទ្ធិអំណាចរបស់អ្នកគ្រប់គ្រង

១-សិទ្ធិអំណាចរបស់អ្នកគ្រប់គ្រង ត្រូវរលត់ នៅពេលដែលសន្តតិជនបានយល់ព្រមទទួលសន្តតិកម្ម ។

២-បើសន្តតិជនបានយល់ព្រមទទួលសន្តតិកម្មហើយ អ្នកគ្រប់គ្រងត្រូវគណនាអំពីការគ្រប់គ្រងនោះ ចំពោះសន្តតិជន ដោយគ្មានការយឺតយ៉ាវ ។

**មាត្រា ១២៩៦.-** ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុល ជាអាទិ៍

១-បើពុំបានដឹងច្បាស់អំពីអត្ថិភាពនៃសន្តតិជន នៅក្នុងអំឡុងពេល ២ (ពីរ) ខែ បន្ទាប់ពីបានធ្វើការជូនដំណឹងជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ១២៩១ (ការជ្រើសតាំងអ្នកគ្រប់គ្រង) នៃក្រមនេះទេ អ្នកគ្រប់គ្រង ត្រូវជូនដំណឹងជាសាធារណៈ ដោយគ្មានការយឺតយ៉ាវ ចំពោះម្ចាស់បំណុលរបស់មតកជន និង អច្ច័យ-

លាភីទាំងអស់ អំពីការណ៍ដែលម្ចាស់បំណុល និង អច្ច័យលាភីទាំងនោះ ត្រូវស្នើសុំអំពីការទាមទារក្នុងអំឡុងពេលដែលកំណត់ ។ ប៉ុន្តែ អំឡុងពេលនេះ មិនត្រូវឱ្យតិចជាង ២ (ពីរ) ខែ ឡើយ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១២៨១ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿន) និង បញ្ញត្តិចាប់ពីមាត្រា ១២៨២ (សិទ្ធិបដិសេធការសងនៅក្នុងអំឡុងពេលដាស់តឿន) រហូតដល់មាត្រា ១២៨៨ (ករណីដែលពុំបានស្នើសុំ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។ ប៉ុន្តែ អ្នកគ្រប់គ្រង ពុំអាចក្លាយជាអ្នកទិញនៅក្នុងការលក់ដោយបង្ខំ ឬ ការលក់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៨៦ (ការប្តូរមតិកជាប្រាក់) នៃក្រមនេះ ដែលត្រូវបានយកមកអនុវត្តដូចគ្នា បានឡើយ ។

**មាត្រា ១២៩៧.-** ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន

១-ក្រោយពីអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៩៦ (ការជូនដំណឹងជាសាធារណៈ និង ការដាស់តឿនចំពោះម្ចាស់បំណុល ជាអាទិ៍) ខាងលើនេះ បានកន្លងហួស ប្រសិនបើនៅតែមិនទាន់ដឹងច្បាស់ថាមានសន្តតិជននៅឡើយ តាមពាក្យសុំរបស់អ្នកគ្រប់គ្រង ឬ តំណាងអយ្យការ តុលាការត្រូវធ្វើការជូនដំណឹងជាសាធារណៈថា ប្រសិនបើមានសន្តតិជន សន្តតិជននោះត្រូវធ្វើការស្នើសុំអំពីការណ៍នោះ នៅក្នុងអំឡុងពេលដែលកំណត់ ។ ប៉ុន្តែ អំឡុងពេលនេះ មិនត្រូវឱ្យតិចជាង ៦ (ប្រាំមួយ) ខែ ឡើយ ។

២-បើប៉ាន់ប្រមាណឃើញថាគ្មានសេសសល់មតិកទេ អ្នកគ្រប់គ្រង ឬ តំណាងអយ្យការ មិនអាចធ្វើការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះឡើយ ។

**មាត្រា ១២៩៨.-** ការដកហូតសិទ្ធិតាមការជូនដំណឹងជាសាធារណៈ

បើគ្មានការស្នើសុំថា ខ្លួនជាសន្តតិជន នៅក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងបញ្ញត្តិនៃមាត្រា ១២៩៧ (ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន) ខាងលើនេះទេ សន្តតិជន ព្រមទាំងម្ចាស់បំណុលរបស់មតកជន និង អច្ច័យលាភី ដែលអ្នកគ្រប់គ្រងមិន

អាចដឹងបាន ពុំអាចអនុវត្តសិទ្ធិបានឡើយ ។

**មាត្រា ១២៩៩.-** ការចែកមត៌កឱ្យទៅជនដែលមាននិស្ស័យពិសេស

១-នៅក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ១២៩៨ (ការដកហូតសិទ្ធិតាមការជូនដំណឹងជាសាធារណៈ) ខាងលើនេះ បើយល់ឃើញថាសមរម្យ តុលាការអាចចែកមួយផ្នែកនៃមត៌កដែលនៅសេសសល់ក្រោយការជម្រះ ទៅឱ្យជនដែលមានជីវភាពជាមួយគ្នានឹងមតកជន ជនដែលបានខិតខំមើលថែទាំព្យាបាលមតកជន និង ជនដែលមាននិស្ស័យពិសេសផ្សេងទៀត តាមពាក្យសុំរបស់ជននោះ ។ ប៉ុន្តែ ចំនួនសរុបនៃតម្លៃទ្រព្យដែលត្រូវចែកទៅឱ្យនោះ មិនត្រូវលើសពីចំនួនពាក់កណ្ដាលនៃមត៌កដែលនៅសេសសល់នោះទេ ។

២-ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើនៅក្នុងអំឡុងពេល ៣ (បី) ខែ ក្រោយពីអំឡុងពេលដែលបានកំណត់នៅក្នុងមាត្រា ១២៩៧ (ការជូនដំណឹងជាសាធារណៈស្វែងរកសន្តតិជន) ខាងលើនេះ បានកន្លងហួស ដោយបញ្ជាក់អំពីហេតុនៃនិស្ស័យពិសេសនោះឱ្យបានច្បាស់លាស់ ។

៣-ក្នុងការចែកទ្រព្យដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការអាចស្រាវជ្រាវអំពីអង្គហេតុបាន ។ បើនៅក្នុងការស្រាវជ្រាវនេះ តុលាការអាចសួរយោបល់របស់មេឃុំ ឬ ចៅសង្កាត់បាន ។

**មាត្រា ១៣០០.-** មត៌កដែលធ្លាក់ទៅជាទ្រព្យរដ្ឋ

មត៌កដែលមិនត្រូវបានចាត់ចែង តាមបញ្ញត្តិនៃមាត្រា ១២៩៩ (ការចែកមត៌កឱ្យទៅជនដែលមាននិស្ស័យពិសេស) ខាងលើនេះ ត្រូវធ្លាក់ទៅជាទ្រព្យរដ្ឋ ។ ក្នុងករណីនេះ អ្នកគ្រប់គ្រងត្រូវគណនាអំពីការគ្រប់គ្រងនោះ ហើយដាក់ជូនទៅតុលាការ ដោយគ្មានការយឺតយ៉ាវ ។

## ជំពូកទី ៨
## ការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម

**មាត្រា ១៣០១.-** គោលបំណងនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម

សន្តតិជនដែលត្រូវបានដកហូតសិទ្ធិសន្តតិកម្ម អាចទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ដើម្បីទទួលបដិទាននៃមត៌កទាំងអស់ ឬ មួយភាគ បាន ។

**មាត្រា ១៣០២.-** អត្ថន័យនៃការទាមទារឱ្យធ្វើបដិទាននូវសន្តតិកម្ម

១-សន្តតិជនអាចទាមទារចំពោះជនដែលបានទទួលមត៌ក តាមសិទ្ធិសន្តតិកម្មដែលពុំត្រូវបានទៅជននោះ ឱ្យប្រគល់មកវិញ នូវទ្រព្យដែលបានទទួលនោះ ។

២-ទ្រព្យដែលភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម បានទទួល តាមកិច្ចសន្យាដែលយកមត៌កធ្វើជាកម្មវត្ថុ ក៏ត្រូវក្លាយជាកម្មវត្ថុនៃការទាមទារឱ្យធ្វើបដិទាននូវសន្តតិកម្មផងដែរ ។

**មាត្រា ១៣០៣.-** ខ្លឹមសារនៃករណីយកិច្ចប្រគល់វិញ

១-ភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម ត្រូវប្រគល់មត៌កមកឱ្យសន្តតិជនដែលបានទាមទារវិញ ។ បើភាគីម្ខាងទៀតសុចរិត ជននោះមានសិទ្ធិរក្សាទុកនូវផល និង ការប្រាក់ដែលបានទទួល សិទ្ធិទាមទារឱ្យសងវិញនូវសោហ៊ុយដែលបានបង្កើនតម្លៃចំពោះទ្រព្យនោះ ហើយមានសិទ្ធិទាមទារសំណងចំពោះកាតព្វកិច្ចដែលត្រូវបានទទួលតាមរយៈសន្តតិកម្ម ដែលបានសងរួចហើយនោះ ។

២-បើភាគីម្ខាងទៀតទុច្ចរិត ជននោះមានកាតព្វកិច្ចត្រូវប្រគល់វិញនូវផល និង ការប្រាក់ដែលបានទទួល ហើយមិនត្រឹមតែគ្មានសិទ្ធិទាមទារសំណងចំពោះកាតព្វកិច្ចដែលត្រូវបានទទួលតាមរយៈសន្តតិកម្មដែលបានសងនោះទេ ថែមទាំងគ្មានសិទ្ធិទាមទារឱ្យសងវិញនូវសោហ៊ុយដែលបានបង្កើនតម្លៃចំពោះទ្រព្យនោះផង ។

**មាត្រា ១៣០៤.–** អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យធ្វើបដិទានសន្តតិកម្ម

អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យធ្វើបដិទានសន្តតិកម្ម នៅក្នុងករណីដែលមត៌កត្រូវបានផ្ទេរទៅភាគីម្ខាងទៀតនៃការទាមទារឱ្យធ្វើបដិទានសន្តតិកម្ម តាមមតកសាសន៍ ឬ ការបែងចែកមត៌ក មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលនោះ រីឯក្នុងករណីដែលជនតែម្នាក់បានទទួលសន្តតិកម្មក្នុងនាមជាសន្តតិជន មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីថ្ងៃដែលមតកជនបានទទួលមរណភាព ។